## កម្មវិធីគាំទ្រវិស័យអប់រំកុមារដែលរស់នៅតំបន់ដាច់ស្រយាល

(អេស្កាប់)

Educational Quality Improvement Program
Classrooms • Schools • Communities

# សាលាកុមារមេត្រី



# វគ្គបណ្តុះបណ្តាលសម្រាប់គ្រូបឋមសិក្សា

កក្កដា ២០០៦

កម្មវិធីគាំទ្រសេវាអប់រំកុមារនៅតំបន់ដាច់ស្រយាល(អេស្កាប់)

Educational Quality Improvement Program
Classrooms • Schools • Communities

## ឯកសារបណ្តុះបណ្តាលគ្រូថ្នាក់កុមារមេត្រី
## សម្រាប់បឋមសិក្សា

# ការយល់ដឹងពីសិទ្ធិកុមារ

# Child Rights




ខេត្តកំពង់ចាម ប្រទេសកម្ពុជា
ខែ សីហា ឆ្នាំ ២០០៦
ឯកសារដើមពីអង្គការខេប

កម្មវិធីគាំទ្រសេវាអប់រំកុមារនៅតំបន់ដាច់ស្រយាល ( អេស្កាប់ )

EQUIP1
Educational Quality Improvement Program
Classrooms • Schools • Communities

## ឯកសារបណ្តុះបណ្តាលគ្រូថ្នាក់កុមារមេត្រី
## សម្រាប់បឋមសិក្សា

# វិធីគ្រប់គ្រងថ្នាក់រៀនសាលាកុមារមេត្រី
# Managing Child-friendly Classrooms



ខេត្តកំពង់ចាម ប្រទេសកម្ពុជា
ខែ សីហា ឆ្នាំ ២០០៦
ឯកសារដើមពីអង្គការខេប

## ឯកសារទី១៖ គោលបំណង និង វត្ថុបំណង

### គោលបំណង

- ឯកសារនេះមានគោលបំណងជួយឱ្យអ្នកអប់រំនៅកម្ពុជារៀបចំបរិស្ថានរៀនសូត្រ ដោយមានលក្ខណៈកុមារមេត្រី។ បន្ទប់រៀនដែលមានបរិស្ថានកុមារមេត្រី គឺជាបន្ទប់ដែលធ្វើឱ្យសិស្សចាប់អារម្មណ៍ក្នុង ការរៀនសូត្រ ។ ម្យ៉ាងទៀតវាផ្តល់ឱកាសឱ្យសិស្សរៀនដោយសហការជាមួយគ្នាដើម្បីទទួលបានហើយ និង ស្វែងយល់ចំណេះដឹង បំណិន និង ឥរិយាបថមួយវិញទៀតបរិស្ថានក្នុងបន្ទប់រៀន ជួយគាំទ្រវិធី និង ល្បិច បង្រៀនដែលលើកស្ទួយការគិតដោយវិភាគ និង បំណិនគិតដោយច្នៃប្រឌិត របស់សិស្ស

- ឯកសារនេះត្រូវបានប្រើប្រាស់ដោយអ្នកសម្របសម្រួល*កម្មវិធីសាលាកុមារមេត្រី* អ្នកសម្របសម្រួលកម្មវិធីសាលាកុមារមេត្រីអាចប្រើឯកសារនេះ ដើម្បីរៀបចំសិក្ខាសាលាសម្រាប់គ្រូដែលស្ម័គ្រចិត្តសាកល្បងថ្នាក់កុមារមេត្រី អ្នកសម្របសម្រួលកម្មវិធីសាលាកុមារមេត្រីអាចប្រើឯកសារនេះជាឯកសារយោងពេលដែលគេចុះទៅសង្កេតគ្រូដើម្បីជួយរំលឹកគ្រូឡើងវិញអំពីសកម្មភាពផ្សេងៗដែលគេអាចសាកល្បង ។
- ឯកសារនេះប្រើប្រាស់ជាឯកសារយោង ដើម្បីណែនាំគេរៀបចំបរិស្ថានចិត្ត-សង្គម ក្នុងថ្នាក់កុមារ មេត្រី ។

### វត្ថុបំណង

- មានការយល់ដឹងអំពីការរៀបចំបន្ទប់រៀន មុននឹងចាប់ផ្តើមសកម្មភាពបង្រៀន និង រៀន
- ប្រាប់បានអំពីផែនការថ្នាក់កុមារមេត្រី
- មានការយល់ដឹងអំពីសកម្មភាពផ្សេងៗ ដែលបានជូនឧទាហរណ៍ក្នុងផែនការថ្នាក់កុមារមេត្រី
- មានសមត្ថភាពរៀបចំផែនការថ្នាក់កុមារមេត្រី
- ប្រាប់បានអំពីភាពខុសគ្នារវាងកិច្ចតែងការបង្រៀន និង ផែនការថ្នាក់កុមារមេត្រី ។

## ឯកសារទី២: ការរៀបចំបរិស្ថានរៀនសូត្រក្នុងបន្ទប់រៀនកុមារមេត្រី

### *១- ការរៀបចំកៀន និង ការប្រើប្រាស់ជញ្ជាំងក្នុងថ្នាក់កុមារមេត្រី*

- ផ្នែកនេះបង្ហាញពីប្លង់បន្ទប់កុមារមេត្រី ។ ប្លង់នេះចង់ឱ្យគ្រូប្រើប្រាស់កន្លែងទាំងអស់ក្នុងបន្ទប់ប្រកបដោយប្រសិទ្ធភាព ។ មានប្លង់ ២ប្រភេទ ដូចដែលមានក្នុង **ឧបសម្ព័ន្ធ ក** ។ ប្លង់ប្រភេទទី១ បង្ហាញអំពីការរៀបចំតុសិស្ស និង កៀនដាក់សម្ភារផ្សេងៗ សម្រាប់ការបង្រៀន និង រៀនដូចជា ÷ កៀនគណិតវិទ្យា កៀនបណ្ណាល័យ កៀនគំនូរ កៀនវិទ្យាសាស្ត្រអនុវត្ត និង កៀនភាសាខ្មែរ . . .។ កៀនមួយដែលមានសារសំខាន់ គឺកៀនទុកកម្រងស្នាដៃសិស្ស។ ការប្រមូលកម្រងស្នាដៃសិស្ស ជួយឱ្យសិស្សចូលរួមស្វ័យវាយតម្លៃ និង ទទួលខុសត្រូវសម្រាប់ការរៀនសូត្ររបស់ខ្លួន ។ ម៉្យាង ទៀតគ្រូអាចទុកវាជាភស្តុតាងសម្រាប់អំពីការរីកចំរើនរបស់សិស្ស ។ ឯប្លង់ប្រភេទ២បង្ហាញពីការប្រើប្រាស់ជញ្ជាំងទាំង ៤ ។ ការប្រើប្រាស់ជញ្ជាំងអាចរួមបញ្ចូលទាំងការបិទ ឬ ព្យួររូបភាពសិក្សា ស្នាដៃសិស្ស ក្តារខៀនជូនព័ត៌មាន ក្តារខៀនបង្ហាញលទ្ធផលនៃការស្រាវជ្រាវ ឬ ក្តារខៀនតូចឱ្យសិស្សសរសេរ។ វាជាការចាំបាច់ណាស់ថា គ្រូគួរតែផ្លាស់ប្តូររូបភាព និង ខ្លឹមសារផ្សេងៗលើជញ្ជាំង ជាញឹកញាប់ដើម្បីទាក់ទាញអារម្មណ៍របស់សិស្សជាបន្តបន្ទាប់ ។

<u>ចំណាំ</u>: ប្លង់ទាំងអស់ក្នុងឯកសារនេះគ្រាន់តែជាឧទាហរណ៍មួយគ្រូមិនចាំបាច់យកតាមគំរូនេះទាំងស្រុងទេ ប៉ុន្តែអាចរៀបចំបន្ទប់តាមសេចក្តីត្រូវការជាក់ស្តែង ។ អ្វីដែលសំខាន់គឺគ្រូយល់ថា ពេលដែលគេរៀបចំ បរិស្ថានចិត្ត-សង្គមដែលល្អគេអាចបង្កើនប្រសិទ្ធភាព និងគុណភាពនៃការរៀនសូត្រប្រចាំថ្ងៃសម្រាប់សិស្ស ។យើងជូនជាយោបល់ថាក្នុងសិក្ខាសាលា អ្នកសម្របសម្រួលអាចចំណាយពេលវេលាពី ៣០ ទៅ ៤៥ នាទី សម្រាប់ពិគ្រោះយោបល់ជាមួយសិក្ខាកាមអំពីប្លង់នេះ ។ វាជាការល្អមួយ ប្រសិនជាលោក លោកស្រីអាចរៀបចំសិក្ខាសាលានេះនៅក្នុងបន្ទប់កុមារមេត្រីដែលត្រូវបានរៀបចំជាស្រេច ។ អ្នកសម្របសម្រួល គួរតែផ្តល់ឱកាសឱ្យសិក្ខាកាមជូនយោបល់ និងកែសម្រួលប្លង់នេះដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការជាក់ស្តែង .

### *២- លក្ខណៈពិសេសនៃថ្នាក់កុមារមេត្រី :*

- ផ្នែកនេះចង់ផ្តល់ការពិពណ៌នាកាន់តែលំអិត ស្តីអំពីលក្ខណៈពិសេសមួយចំនួននៃថ្នាក់កុមារមេត្រីដែលត្រូវបានបង្ហាញក្នុងប្លង់ ។ គ្រូជ្រើសរើសយកសកម្មភាពណាមួយបញ្ចូលក្នុងសកម្មភាពសិក្សាប្រចាំថ្ងៃដូចខាងក្រោម :

**២.១-***<u>ធនាគារពាក្យ</u>* ***<u>( Word Bank )</u>***

- *ធនាគារពាក្យ* គឺជាប្រអប់សន្ទុំពាក្យ ព្យញ្ជនៈ កម្រងសំណួររូបមន្តសម្រាប់ការពង្រឹងចំណេះដឹងបន្ថែម។ គ្រូអាចសរសេរពាក្យថ្មី ឬ ព្យញ្ជនៈដែលសិស្សមិនទាន់ស្គាល់លើប័ណ្ណពាក្យតូចៗ ដាក់ក្នុងប្រអប់ ។ ពាក្យ និង ព្យញ្ជនៈ

នេះ អាចដកស្រង់ចេញពីសៀវភៅសិក្សា ។ វាជាការសំខាន់ណាស់ថាគ្រូមិនគួរដាក់ពាក្យច្រើនពេក យ៉ាងច្រើនបំផុត 5 ពាក្យសម្រាប់ថ្នាក់ទី ១។ ក្នុងការងារប្រចាំសប្តាហ៍សិស្សអាចជួយគ្នាទៅវិញទៅមក ចេះអានពាក្យក្នុង *ធនាគារពាក្យ* ជាពិសេសពេលដែលគេទំនេរ ឬពេលបញ្ចប់កិច្ចការផ្សេងៗ ។ នៅចុងបញ្ចប់សប្តាហ៍គ្រូពិនិត្យមើលតើសិស្សទាំងអស់ក្នុងក្រុមចេះអានពាក្យឬទេ ? ពាក្យណាដែលសិស្ស ងាយស្រួលអានគួរដកចេញដាក់ក្នុង *ប្រអប់សន្សំពាក្យ* សម្រាប់ពាក្យដែលសិស្សស្គាល់រួចហើយ ។ *ប្រអប់ សន្សំពាក្យ* នេះអាចថែរក្សាទុកនៅកៀនបណ្ណាល័យ ឬ កៀនភាសាខ្មែរ ។ នៅចុងខែគ្រូគួរតែរំលឹកឡើង វិញពាក្យមួយចំនួន ដែលមានក្នុង *ប្រអប់សន្សំពាក្យ* នេះ ។ បើសិស្សជួបការលំបាកក្នុងការអានពាក្យនេះ គ្រូអាចដាក់ក្នុង *ធនាគារពាក្យ* ម្តងទៀត ។

- សម្រាប់ថ្នាក់ទី ៤ ទី ៥ និង ទី ៦ មិនចាំបាច់ប្រើប្រអប់ *ធនាគារពាក្យ* ទេ ត្រូវជំនួសដោយសៀវភៅសរសេរ ។ សៀវភៅនេះគេហៅថា *សៀវភៅធនាគារពាក្យ* ទុកលើតុតាមក្រុមនីមួយៗ ។ សិស្សអាចសហការជាមួយគ្នាសរសេរពាក្យថ្មីៗ ក្នុង *សៀវភៅធនាគារពាក្យ* ។ ដើម្បីបង្ហាញថាសិស្សយល់ពាក្យ ដែលគេបានសរសេរក្នុងសៀវភៅ ហើយសិស្សក្នុងក្រុមគួរតែងឃ្លា និង ពាក្យថ្មីៗនេះ។ *សៀវភៅ ធនាគារពាក្យ* ត្រូវប្រើតាម អក្ខរក្រម។

**២.២-** ***<u>កៀនបណ្ណាល័យ</u>*** : ដើម្បីយល់ពាក្យកៀនបណ្ណាល័យគួរយល់ពាក្យ

- **កៀន** : ជាកន្លែងដែលនៅសល់ពីតុសិស្ស និង តុគ្រូ វាជាទូ តុ ឬ ធ្វើជាថ្នាក់ៗសម្រាប់ដាក់ឯកសារផ្សេងៗ
- **កៀនបណ្ណាល័យ** : ជាកន្លែងសម្រាប់សៀវភៅ ឬ ឯកសារទាក់ទងនឹងការរៀនសូត្ររបស់សិស្សសម្រាប់ធ្វើសកម្មភាពស្រាវជ្រាវ ។
- ការប្រើប្រាស់ *កៀនបណ្ណាល័យ* នៅក្នុងថ្នាក់រៀន អាចបង្កើនការអាន សរសេររបស់កុមារកាន់តែប្រសើរឡើង គ្រូគួរតែពិចារណាលើសកម្មភាពដូចខាងក្រោមក្នុងការរៀបចំកៀនបណ្ណាល័យ :

១ នៅក្នុងកៀនបណ្ណាល័យមានសៀវភៅរឿងនិទានសម្រាប់កុមារ ។

២ គ្រូត្រូវតែផ្លាស់ប្តូរសៀវភៅផ្សេងៗ គ្នាឱ្យបានញឹកញាប់ និង ទៀងទាត់ ។

៣ គ្រូគួរតែយល់ដឹងអំពីការជ្រើសរើសសៀវភៅទៅតាមកម្រិតនៃការយល់ដឹងរបស់កុមារ ។ ឧទាហរណ៍ : មិនគួរដាក់សៀវភៅគ្មានរូបភាពក្នុងកៀនបណ្ណាល័យនៅថ្នាក់ទី១ ឬ ទី២។ ក្នុងករណីគ្រូមិនសូវយល់ថា សៀវភៅណាមួយមានលក្ខណៈសមស្របសម្រាប់កុមារ គ្រូគួរតែឱ្យសិស្ស ២ ឬ ៣ នាក់សាកល្បងអានទំព័រណាមួយក្នុងសៀវភៅ មុននិងដាក់សៀវភៅក្នុងកៀនបណ្ណាល័យ ។ ប្រសិនជាសិស្សជួបការ លំបាកក្នុងការអានសៀវភៅនេះ គ្រូគួរតែជ្រើសរើសសៀវភៅណាដែលស្រួលអានជាងចំពោះសិស្សណារៀន យឺត ឬ រៀនលឿនយើងគួរតែជ្រើសរើសសៀវភៅណាដែលពួកគេចាប់អារម្មណ៍ ។

៤ វាជារឿងមួយដ៏សំខាន់ដែលកុមារអាចយល់នូវអ្វីដែលពួកគេបានអាន ។ ហេតុដូច្នេះហើយ *ទម្រង់សម្រាប់អានសៀវភៅ* ត្រូវបានដាក់នៅកៀនបណ្ណាល័យ (មើល **ឧបសម្ព័ន្ធខ**)។ គ្រូត្រូវតែធ្វើការពន្យល់ដល់កុមារនូវរបៀបបំពេញទម្រង់នោះ ។

៥ បន្ទាប់ពីអានសៀវភៅរួចកុមារត្រូវតែបំពេញ *ទម្រង់សម្រាប់អានសៀវភៅ* ។ នៅពេលដែលបញ្ចប់ការបំពេញទម្រង់រួច កុមារត្រូវតែយកវាទៅទុកនៅ *កៀនបណ្ណាល័យ* កុមារអាចអានទម្រង់ទាំងនោះ និង ជ្រើសរើសសៀវភៅផ្អែកទៅលើអ្វីដែលសិស្សផ្សេងទៀតបានសរសេរ ។

៦ គ្រូប្រចាំថ្នាក់ ឬ បណ្ណារក្សដាក់សំណួរឱ្យសិស្សស្រាវជ្រាវ ដែលគេហៅថា " *សំណួរប្រចាំសប្ដាហ៍* " ឬ " *សំណួរប្រចាំថ្ងៃ* " ។ គ្រូចបិទសំណួរនេះលើជញ្ជាំង ហើយសិស្សធ្វើការស្រាវជ្រាវរយៈពេលមួយ សប្ដាហ៍ ឬមួយថ្ងៃដើម្បីរកចម្លើយ ។ សិស្សធ្វើការស្រាវជ្រាវនេះដោយពិនិត្យមើលសៀវភៅក្នុងកៀន បណ្ណាល័យក្នុងថ្នាក់របស់គេ ឬក្នុងបណ្ណាល័យសាលារៀន ។ ម៉្យាងទៀតសិស្សអាចស្រាវជ្រាវដោយពិនិត្យ មើលរូបភាពសម្ភារសិក្សា ឬ ផែនទីផ្សេងៗ ដែលបិទលើជញ្ជាំងក្នុងបណ្ណាល័យ ។

៧ ការជ្រើសរើសមិត្តភក្ដិតាមរយៈលិខិតៈបណ្ណារក្សប្រមូលសំបុត្រ ដែលផ្ញើពីសិស្សតាមកម្រង ផ្សេងទៀតថែរក្សាទុកក្នុងបណ្ណាល័យ ។ ដើម្បីជួយសិស្សសរសេរសំបុត្រគួរតែមានសេចក្ដីណែនាំអំពីខ្លឹមសារនៃការសរសេរសំបុត្រក្នុងកៀនបណ្ណាល័យដូចមានក្នុង **ឧបសម្ព័ន្ធ គ** ។

**២.៣-** ***<u>កៀនភាសាខ្មែរ</u>*** ជាកន្លែងតំកល់ឯកសារទាក់ទងនឹងការរៀនភាសាខ្មែរដើម្បីពង្រឹងសមត្ថភាពទាំងបួនរបស់ភាសា

- ការរៀបចំកៀនភាសាខ្មែរ ក្នុងថ្នាក់រៀនអាចពង្រឹងសមត្ថភាព សរសេរ ស្ដាប់ និយាយ អាន
- ក្នុងកៀនរៀនភាសាខ្មែរអាចមានសម្ភារដូចជា អក្សរចល័ត ប័ណ្ណរូបភាព ល្បែងភាសា
- នេះជាឧទាហរណ៍ស្ដីអំពីវិធីប្រើប្រាស់កៀនភាសាខ្មែរសម្រាប់ថ្នាក់ទី 1 និង ទី 2 :

ក . ពាក្យខ្លះដែលសិស្សស្គាល់ក្នុង *ធនាគារពាក្យ* របស់គេអាចដាក់ក្នុងកៀនភាសាសម្រាប់ការពង្រឹងចំណេះដឹងបន្ថែមទៀត ។

ខ. គ្រូបិទព្យញ្ជនៈបីតួ ដែលសិស្សរៀនហើយ ក្នុងកៀនភាសារៀងរាល់សប្ដាហ៍។ សិស្សអាចប្រមូលសម្ភារពីផ្ទះ ឬ ពីបរិស្ថានរបស់គេ ។ សម្ភារនេះផ្ដើមដោយ ព្យញ្ជនៈដែលគ្រូបិទនៅកៀនភាសាខ្មែរ។ នៅចុងសប្ដាហ៍សិស្សគួរតែមានឱកាសពិភាក្សាអំពីសម្ភារដែលគេបានប្រមូល។ សិស្សអាចបង្ហាញវត្ថុនីមួយៗ នៅកៀនភាសាខ្មែរដោយតែងឃ្លាទាក់ទងនឹងឈ្មោះវត្ថុនេះ ។

- ខាងក្រោមនេះមានឧទាហរណ៍ខ្លះ ស្ដីអំពីវិធីប្រើប្រាស់កៀនភាសាខ្មែរសម្រាប់ថ្នាក់ទី៣ និង ទី៦ ÷

ក. គ្រូគួរតែយល់ថាក្នុងមេរៀនគ្រប់មុខវិជ្ជាទាំងអស់មានឱកាសច្រើនដើម្បីពង្រឹងភាសារបស់សិស្សមិនមែនត្រឹមតែមេរៀនភាសាខ្មែរប៉ុណ្ណោះទេ ។ ឧទាហរណ៍ ៖ ពេលដែលគ្រូថ្នាក់ទី ៥ ទី ៦ កំពុងបង្រៀន ភូមិវិទ្យាគ្រូអាចរៀបចំបណ្ណពាក្យដែលបង្ហាញពីពាក្យថ្មីៗជាមួយបញ្ញត្តិ និង និយមន័យដោយបិទនៅកៀនភាសាខ្មែរសម្រាប់ពាក្យដូចជា ៖ *អេក្វាទ័រ ខ្សែស្រប ខ្សែបណ្តោយ* . . . ។

ខ. សកម្មភាពមួយទៀតដែលគ្រូអាចសាកល្បង គឺការរៀបចំល្បែងប្រលងប្រណាំងនឹងពាក្យប្រៀបធៀប ។ រាល់សប្តាហ៍គ្រូសរសេរឈ្មោះមិនទាន់ពេញលេញដូចជា លឿនដូច . . .បៃតងដូច . . .ទន់ដូច . . . ។សិស្សត្រូវស្រាវជ្រាវដោយអង្កេតបរិស្ថានរបស់គេដើម្បីរកឱ្យឃើញចំលើយសមស្រប ។ ក្រុមសិស្សណាដែលរក បានចម្លើយច្រើនជាងគេជាអ្នកឈ្នះអាចបិទចម្លើយរបស់គេនៅកៀនភាសាខ្មែរ អាចសាកល្បងសកម្មភាពប្រហាក់ ប្រហែលគ្នា ដូចជារកសទិសន័យ ឬ សទិសសូរ ពាក្យផ្ទុយ . . .។

គ. ម្យ៉ាងទៀតគ្រូអាចបិទ *ពាក្យប្រចាំថ្ងៃ* ឬ *ឃ្លាប្រចាំសប្តាហ៍* ក្នុង *កៀនភាសាខ្មែរ* ដែលគ្រូ ឬ សិស្សអាចជ្រើសរើស ។ គោលបំណងនៃសកម្មភាពនេះចង់ពង្រឹងសមត្ថភាពស្តាប់ និង ការយកចិត្តទុកដាក់របស់ សិស្ស ។ ពេលដែលសិស្សឮពាក្យ ឬ ឃ្លាថ្មី សិស្សអាចសួរគ្រូ ។ គ្រូបិទពាក្យថ្មីនេះក្នុងកៀនភាសាខ្មែរហើយ ពិគ្រោះយោបល់ និង សិស្សផ្សេងទៀតអំពីន័យរបស់ពាក្យនោះ ។ ពាក្យនេះអាចទាក់ទងនឹងរឿង ឬ បញ្ហា ក្នុងព័ត៌មានជាប្រចាំដូចជា "ក្រុមប្រឹក្សាឃុំ " " ថវិកាជាតិ " " វិមជ្ឈការ " ។ ល ។ មិនចាំបាច់ឱ្យសិស្សមានការយល់ដឹងច្បាស់លាស់លើពាក្យលំបាកៗ ដូចជា " វិមជ្ឈការ " ក៏ប៉ុន្តែអ្វីដែលសំខាន់គឺគ្រូជំរុញឱ្យសិស្សចាប់អារម្មណ៍ និង ចាប់ផ្តើមពិភាក្សាអំពីបញ្ហាដែលកើតមានឡើងក្នុងបរិស្ថានជុំវិញខ្លួន ។

***២.៤- <u>ផ្ទាំងក្រដាសវាក្យស័ព្ទ</u>*** ជាបញ្ជីពាក្យដែលអាចប្រើប្រាស់បានក្នុងមេរៀនជាច្រើនគ្រូរៀបចំ *ផ្ទាំងក្រដាសវាក្យស័ព្ទ* ដើម្បីជួយឱ្យសិស្សកែលំអសមត្ថភាពសរសេរ និង សមត្ថភាពនិយាយរបស់គេ ។ ដូច្នេះ បិទផ្ទាំងក្រដាសវាក្យសព្ទលើជញ្ជាំងរយៈពេលយូរ ដែលខុសពីផ្ទាំងក្រដាសពាក្យនៅកៀនភាសាខ្មែរគ្រាន់តែបង្ហាញអំពីពាក្យថ្មីសម្រាប់ប្រធានបទមួយទេ ) ។

សម្រាប់ថ្នាក់ទី១ និង ទី២ គ្រូគួរតែរៀបចំ *ផ្ទាំងក្រដាសវាក្យស័ព្ទ* ដែលជួយឱ្យសិស្សស្រួលសរសេរឃ្លា ងាយៗ ។ សិស្សនៅថ្នាក់ទី១ និងទី ២ ចាប់អារម្មណ៍ក្នុងការសរសេរពាក្យពេលដែលគេចង់បញ្ចេញគំនិត ។ ការរៀបចំ *ផ្ទាំងក្រដាសវាក្យស័ព្ទ* គ្រូត្រូវតែពិចារណាលើលក្ខណៈនៃភាសាដែលសិស្សថ្នាក់ទី១ និងទី២ ចូលចិត្តប្រើពេលដែលគេនិយាយរាល់ថ្ងៃ ។ ពេលគ្រូរៀបចំបរិស្ថានក្នុងបន្ទប់ដែលជួយឱ្យសិស្សដោះស្រាយ បញ្ហាព្យញ្ជនៈប្រកប និង ជំរុញឱ្យសិស្សសរសេរ ។ *ផ្ទាំងក្រដាសវាក្យស័ព្ទ* មានភាពសមស្របសម្រាប់ ថ្នាក់ទី១ និង ទី ២ អាចមានដូចខាងក្រោម ៖

- ថ្ងៃក្នុងសប្តាហ៍
- ចំនួនពីមួយ ដល់ ដប់
- ពាក្យទាក់ទងនឹងក្រុមគ្រួសារ
- ពាក្យទាក់ទងនឹងធាតុអាកាស
- ពាក្យទាក់ទងនឹងទីកន្លែងក្នុងមូលដ្ឋាន
- ពណ៌ផ្សេងៗ
- គុណនាមងាយៗ
- កិរិយាស័ព្ទដែលប្រើប្រាស់ច្រើនក្នុងការនិយាយ
- មុខម្ហូបផ្សេងៗដែលគេស្គាល់

សម្រាប់ថ្នាក់ទី៥ និង ទី៦ សិស្សមិនសូវមានការលំបាកក្នុងការប្រកបពាក្យ ក៏ប៉ុន្តែគ្រូអាចរៀបចំផ្ទាំងក្រដាសវាក្យសព្ទក្នុងគោលបំណងចង់ឱ្យសិស្សកែលំអ និង ពង្រីកបន្ថែមក្នុងការប្រើប្រាស់ភាសាឱ្យកាន់តែប្រសើរឡើងជាពិសេសគួរតែជំរុញឱ្យសិស្សចៀសវាងការប្រើប្រាស់ពាក្យដដែលៗ ។ ការគិតដោយវិភាគ គ្រូត្រូវតែពង្រឹង និងជំរុញឱ្យសិស្សជ្រើសរើសកិរិយាស័ព្ទសម្បូរបែប និង ចៀសវាងការប្រើកិរិយាស័ព្ទដែល មានន័យទូទៅ ។ ដូច្នេះ *ផ្ទាំងក្រដាសវាក្យសព្ទ* ត្រូវមានភាពសមស្របសម្រាប់ថ្នាក់ទី ៣ និង ទី ៦ មាន ដូចតទៅ ÷

- កិរិយាស័ព្ទផ្សេងៗ ដែលជំនួសពាក្យ " ទៅ " " មើល " " និយាយ " ...។ ម្យ៉ាងទៀតគ្រូគួរតែរៀបចំផ្ទាំងក្រដាសដែលបង្ហាញអំពីពាក្យផ្សេងៗក្នុងការសួរសំណួរដូចជា + អ្វី ? ហេតុអ្វី ? យ៉ាង ដូចម្តេច ? ... ។

សកម្មភាពសំខាន់មួយក្នុងថ្នាក់សាកល្បង គឺការផ្តល់ឱកាសឱ្យសិស្សសួរសំណួរទៅគ្រូ និង សួរគ្នាទៅវិញទៅមក ។ នៅចុងបញ្ចប់មេរៀននីមួយៗ គ្រូផ្តល់ឱកាសឱ្យសិស្ស ( ជាបុគ្គល ឬ ជាក្រុម ) តែងសំណួរ ។ បើគ្រូសង្កេតឃើញថាមានសំណួររបស់សិស្សផ្តើមដោយពាក្យដដែលៗ ដូចជា " អ្វី " គ្រូគួរ តែជំរុញឱ្យសិស្សមើល *បញ្ជីពាក្យផ្តើមសំណួរ* ដើម្បីជ្រើសរើសពាក្យផ្តើមសំណួរផ្សេងទៀតដូចជាពាក្យ "ហេតុអ្វី " មកប្រើវិញម្តង ។

### *២.៥- <u>សៀវភៅសំណួរ</u>*

ជាសៀវភៅដែលក្រុមនីមួយ ត្រូវតែមានសម្រាប់កត់ត្រាសំណួរទាក់ទងនឹងប្រធានបទដែលគេកំពុងរៀនទុកលើតុសម្រាប់សួរគ្រូ ឬក្រុមដទៃ ។ នៅចុងបញ្ចប់មេរៀននីមួយៗ គ្រូគួរតែកំណត់ពេលវេលា ប្រហែល ៥ នាទី ឱ្យសិស្សសហការគ្នាក្នុងក្រុម រកសំណួរសម្រាប់សួរគ្រូ ឬ សួរគ្នាពីក្រុមមួយទៅក្រុមមួយ ទៀត ។ ការទុកឱកាសឱ្យសិស្សសួរសំណួរ វាជាការសំខាន់ណាស់សម្រាប់ការសិក្សាមេរៀននីមួយៗ ព្រោះគ្រូអាចវាស់ស្ទង់ការយល់ដឹងរបស់សិស្ស មេរៀនដែលបានបង្រៀនរួចនឹងអាចដឹងថាសិស្សយល់មេរៀនបាន ប៉ុន្មានភាគរយចំពោះការឆ្លើយនឹងសំណួប្រសិនជាសិស្សឆ្លើយសំណួរមិនបានគ្រូជួយឆ្លើយក៏ប៉ុន្តែមុននឹងឆ្លើយ

ភ្លាមៗគ្រូអាចឱ្យសិស្សស្រាវជ្រាវសំណួរនេះនៅផ្ទះដោយសួរឪពុក ម្ដាយ ឬ បងប្អូនរបស់គេសិន ។ សិស្សដែលបាន រកចម្លើយត្រូវរាយការណ៍នៅថ្ងៃបន្ទាប់ ។

## ***២.៦- ក្ដារខៀនព័ត៌មាន***

សម្រាប់ថ្នាក់ទី ១ ទី ២ និង ទី ៣ រៀបចំក្ដារខៀនតូចក្នុងបន្ទប់រៀនដែលគេហៅថា *ក្ដារខៀនព័ត៌មាន* ។ រាល់ថ្ងៃ គ្រូបំផុសការពិភាក្សាជាមួយសិស្ស ហើយនឹងសរសេរឃ្លាងាយៗ ទាក់ទងនឹងព័ត៌មានរបស់សិស្សដូច ជា ÷ " *ម្សិលមិញសុខបានទៅផ្សារ* " ។ គ្រូមិនគួរព្រួយបារម្ភប្រសិនបើសិស្សមិនទាន់ចេះអានឃ្លាទាំងអស់នោះ ប៉ុន្តែធ្វើ ដូចនេះ ជួយឱ្យសិស្សយល់ពីទំនាក់ទំនងរវាងភាសានិយាយ និង ភាសាសរសេរ ។ ម៉្យាងទៀតសិស្សមានអារម្មណ៍ថា គំនិតរបស់គេមានសារសំខាន់ពេលដែលគេឃើញគ្រូសរសេរឃ្លាលើក្ដារខៀនដែលមានឈ្មោះ គេក្នុងនោះ ។ គ្រូត្រូវផ្ដល់ ឱកាសឱ្យសិស្សច្រើននាក់ផ្ដល់ព័ត៌មានរៀងរាល់ថ្ងៃ ប៉ុន្តែមិនចាំបាច់សរសេរព័ត៌មាន ទាំងអស់នោះទេ ។ ជាដំបូងគ្រូ ជ្រើសរើសព័ត៌មានរបស់សិស្សម្នាក់ ហើយជ្រើសរើសសិស្សផ្សេងៗទៀតជា រៀងរាល់ថ្ងៃ ។ ពេលដែលសិស្សចាប់ ផ្ដើមអភិវឌ្ឍន៍សមត្ថភាពអាន គេចាប់ផ្ដើមស្គាល់ព្យញ្ជនៈ ស្រះ និង ពាក្យក្នុងឃ្លា ។

- សម្រាប់ថ្នាក់ទី ៤ ទី ៥ និង ទី ៦ អាចប្រមូលព័ត៌មានទាក់ទងនឹងជាតិ អន្តរជាតិ និង ផ្ទាល់ខ្លួន ។ គួរតែ ជំរុញឱ្យសិស្សសួរឪពុកម្ដាយ និង បងរបស់គេអំពីឧប្បត្តិហេតុសំខាន់ៗកំពុងកើតមានឡើងដែលគេបានឮបានឃើញ តាមរយៈវិទ្យុ ទូរទស្សន៍ ឬ គេបានសន្ទនាទូទៅដោយមិនបាច់សរសេរលំអិតទេ គ្រាន់តែសរសេរសង្ខេបដូចជា " *រាជរដ្ឋាភិបាលនឹងរៀបចំការបោះឆ្នោតសកលនៅខែកក្កដាឆ្នាំ 2003* " *ឬ* " *មានភាពរាំងស្ងួត នៅខេត្តតាកែវ* " "*ព្រះមហាក្សត្រយាងចូលមន្ទីរពេទ្យនៅប្រទេសចិន* " " *នាយករដ្ឋមន្ត្រីចូលរួមប្រជុំ ជាមួយប្រទេសផ្សេងៗនៅទ្វីបអាស៊ី* " " *ប្រទេសប្រេស៊ីលបានឈ្នះពានរង្វាន់បាល់ទាត់ពិភពលោក* " ។ ពេលដែលសិស្សសរសេរអំពីព័ត៌មានជាតិ ឬ អន្តរជាតិ ប្រាកដជាគេនិយាយអំពីតំបន់ផ្សេងៗ ក្នុងប្រទេស ឬ ពិភពលោក ។ នៅពេលនោះគ្រូគួរតែឆ្លៀត ឱកាសឱ្យសិស្សចង្អុលបង្ហាញតំបន់ដូចជាប្រទេសប្រេស៊ីល ឬ ប្រទេសចិនលើផែនទីពិភពលោក ឬ ខេត្តតាកែវលើ ផែនទីប្រទេសកម្ពុជា ។ គ្រូបំផុសការពិភាក្សាបន្ថែមទៀតពេលដែលសិស្សកំពុងស្រាវជ្រាវផែនទីដោយសួរសំណួរ ដូចជា " *តើប្រទេសណាខ្លះមានព្រំដែនជាប់ប្រទេសចិន ?* " " តើខេត្តណាខ្លះមានព្រំដែនជាប់ខេត្តតាកែវ ? " តើខេត្ត តាកែវស្ថិតក្នុងតំបន់ខាងត្បូង ឬ ខាងជើងនៃប្រទេសកម្ពុជា ? "

## ៣- *ការណែនាំសម្រាប់កុមារស្ដីអំពីក្បៀន និង លក្ខណៈផ្សេងៗទៀតនៅថ្នាក់កុមារមេត្រី*

ដើម្បីឱ្យក្បៀន និង លក្ខណៈផ្សេងៗទៀតក្នុងថ្នាក់កុមារមេត្រីប្រកបដោយប្រសិទ្ធភាព សិស្សត្រូវតែមាន ការយល់ដឹងច្បាស់លាស់អំពីចំណុច បី យ៉ាង :

- តើមានសម្ភារអ្វីខ្លះក្នុងក្បៀន ?
- តើគេប្រើប្រាស់សម្ភារនេះយ៉ាងដូចម្ដេច ?

- តើសិស្សធ្វើសកម្មភាពក្នុងកៀនទៅពេលណា ?

នៅចុងបញ្ចប់មេរៀន ជាធម្មតាគ្រូដាក់លំហាត់ឱ្យសិស្សធ្វើ ។ សិស្សមួយចំនួនធ្វើលំហាត់នេះយ៉ាងរហ័យ ។ ដូច្នេះគ្រូឱ្យសិស្សនេះធ្វើសកម្មភាពជាមួយសម្ភារក្នុងកៀនបណ្ណាល័យ ឬ កៀនភាសាខ្មែរ ។

<u>ចំណាំ</u> : យុទ្ធវិធីនេះគ្រាន់តែមានផលប្រយោជន៍សម្រាប់សិស្សពូកែតែប៉ុណ្ណោះ ។ ដូច្នេះគ្រូពិចារណាអំពីយុទ្ធវិធីផ្សេងទៀត ដើម្បីផ្តល់ឱកាសឱ្យសិស្សរៀនយឺតទទួលផលប្រយោជន៍ផងដែរ ។

គ្រូកំណត់ពេលវេលាជាក់ស្តែងក្នុងកាលវិភាគប្រចាំសប្តាហ៍ឱ្យសិស្សទាំងអស់ធ្វើការក្នុងកៀនផ្សេងៗក្នុង បន្ទប់។ ពេលដែលគ្រូចាប់ផ្តើមអនុវត្តសកម្មភាពនេះគ្រូអាចឱ្យសិស្សមួយក្រុមតូចធ្វើការក្នុងកៀនបណ្ណាល័យ ឬ កៀនភាសាខ្មែររាល់ពេលសម្រាក ១៥ នាទី មួយសប្តាហ៍ម្តង ។ គ្រូរៀបចំកាលវិភាគដើម្បីធានាថាក្រុម សិស្សទាំងអស់មានឱកាសធ្វើការជាមួយសម្ភារនៅក្នុងកៀនផ្សេងៗ ។ ប្រសិនជាកន្លែងចង្អៀតក្នុងថ្នាក់សិស្ស អាចយកសម្ភារពីកៀនផ្សេងៗយកទៅប្រើនៅលើតុរបស់គេ ។

ពេលដែលសិស្ស និង គ្រូមានការយល់ដឹងកាន់តែច្បាស់អំពីវិធីប្រើកៀនផ្សេងៗ អ្នកសម្របសម្រួល កម្មវិធីសាលាកុមារមេត្រីជួយគ្រូបញ្ចូលសកម្មភាពនេះក្នុងម៉ោងសិក្សា ។ ដោយសារធ្វើការងារក្នុងកៀនមានលក្ខណៈសប្បាយគ្រូប្រើយុទ្ធវិធីនេះដើម្បីលើកទឹកចិត្តសិស្ស ។ គ្រូឱ្យសិស្សណាខ្លះដែលខិតខំប្រឹងប្រែងទៅធ្វើលំហាត់ប្លែកៗក្នុងកៀនផ្សេងៗ ។

**ឧបសម្ព័ន្ធ ក: ប្លង់បន្ទប់កុមារមេត្រី**




- **ប្លង់សម្រាប់បន្ទប់កុមារមេត្រី សម្រាប់សិស្ស ៤៨ នាក់**

# ជញ្ជាំងចំហៀងខាងមុខទ្វារ



# ជញ្ជាំងខាងក្រោយបន្ទប់រៀន



# ជញ្ជាំងចំហៀងខាងទ្វារចូល



# ជញ្ជាំងមានក្តារខៀន ( ផ្នែកខាងមុខ )




តារាងព័ត៌មានស្តីពីអាកាសធាតុ :

- សីតុណ្ហភាព
- កម្រិតទឹកភ្លៀង និង ភ្លៀងប៉ុន្មានដងក្នុង ១ សប្តាហ៍
- ទិសរបស់ខ្យល់បក់

**ឧបសម្ព័ន្ធ ខ:**

# ទម្រង់អានសៀវភៅ

- សៀវភៅនេះអានដោយ : ____________________
- ចំណងជើងសៀវភៅ : ____________________
- ឈ្មោះអ្នកនិពន្ធ : ____________________
- សូមប្រាប់ប្រភេទរឿងនិងផាត់ពណ៌នៅលើរូបមនុស្សដែលប្អូនជ្រើសរើស : ______________________________

ប្រភេទរឿង គឺ



រឿងកំប្លែង រឿងកំសត់ រឿងរំភើប រឿងធុញទ្រាន់ រឿងរន្ធត់

តើរឿងនេះនិយាយអំពីអ្វី ?________________________________________

តើរឿងនេះកើតឡើងនៅឯណា ? ________________________________________

តើមានអ្វីកើតឡើងនៅក្នុងរឿងនេះ ? ________________________________________

________________________________________

________________________________________

________________________________________

តើរឿងនេះបានបញ្ចប់យ៉ាងដូចម្តេច ?________________________________________

________________________________________

________________________________________

________________________________________

ពាក្យថ្មីដែលខ្ញុំបានអានក្នុងសៀវភៅនេះ : ________________________________________

________________________________________

________________________________________

សូមធ្វើការវាយតម្លៃទៅលើសៀវភៅដែលប្អូនបានអានដោយផាត់ពណ៌ចំណាំ ។

1 2 3 4 5 6 7 8 9 10

**មិនល្អ មធ្យម ល្អបង្គួរ ល្អណាស់**

ខ្ញុំបានប្រាប់មិត្តខ្ញុំឈ្មោះ ______________________________ អំពីសៀវភៅនេះ ។

សូមគូររូប និង ផាត់ពណ៌តាមដំណើររឿងដែលប្អូនបានអានរួច ។

( **សូមកុំផ្តាមរូបភាពណាមួយចេញពីសៀវភៅ** ) ។

**ឧបសម្ព័ន្ធ គៈ**

## ប្រធានបទក្នុងការសរសេរសំបុត្រទៅមិត្តរបស់យើងនៅកម្រងដទៃទៀត

" តើនៅពេលនេះយើងសរសេរអំពីអ្វី ? "

- ជាបឋមយើងគួរតែសួរសុខទុក្ខរបស់មិត្ត និង ប្រាប់គេអំពីសុខទុក្ខរបស់យើងវិញ ។
- រួចហើយឱ្យយើងជ្រើសរើសខ្លឹមសារប្រាប់មិត្តរបស់យើងដូចជា :
    - ឈ្មោះយើង
    - ទីកន្លែង
    - ស្គាល់គ្នាប៉ុន្មានឆ្នាំហើយ
    - យើងកំពុងសរសេរសំបុត្រនេះនៅទីណា
    - ឪពុកម្តាយរបស់យើងមានមុខរបរអ្វី
    - ឈ្មោះសាលារៀនរបស់យើង
    - ចំនួនសិស្ស និង គ្រូនៅសាលាយើង
    - ទីតាំងសាលារៀនយើង
    - កន្លែងពិសេសក្នុងសាលារបស់យើងដូចជាបណ្ណាល័យ សួនកុមារ ទីធ្លាកីឡា
    - សកម្មភាពដែលយើងធ្វើក្រៅម៉ោងសិក្សា ( ស្រែពិសោធន៍ គេហកិច្ច ការអានសៀវភៅក្នុងបណ្ណាល័យ លេងបាល់ទះ កិច្ចការនៅផ្ទះ )
    - រឿងកំប្លែង
    - កន្លែងគួរឱ្យចាប់អារម្មណ៍ដែលយើងធ្លាប់ធ្វើទស្សនកិច្ច
- យើងគួរតែឆ្លើយសំណួរដែលមិត្តយើងបានសួរកន្លងមកត្រូវអានសំបុត្រគេឡើងវិញ ។
- តើយើងអាចសួរសំណួរអ្វីខ្លះពីមិត្តរបស់យើង ?
    - តើសាលារបស់មិត្តស្ថិតនៅជនបទ ឬ ទីប្រជុំជន ?
    - តើមិត្តធ្វើដំណើរទៅសាលារៀនដោយសារអ្វី ?
    - តើមានគេជួយសរសេរសំបុត្រឬទេ ?
    - តើមានមិត្តម្នាក់ក្នុងក្រុមធ្លាប់ទៅធ្វើទស្សនកិច្ចនៅភ្នំពេញឬទេ ?
- តើយើងបញ្ចប់សំបុត្រយើងយ៉ាងដូចម្តេច ? យើងគួរតែជំរាបលា ជូនពរនឹងឱ្យគេឆ្លើយតបមកវិញយ៉ាងឆាប់រហ័សប្រហែលយើងអាចដាក់រូបថត ឬ រូបភាពក្នុងស្រោមសំបុត្រយើងគួរតែចុះហត្ថលេខាក្នុង សំបុត្រ ។

## ឯកសារទី៣: ទម្រង់ផែនការថ្នាក់កុមារមេត្រី

| **<u>ផែនការថ្នាក់កុមារមេត្រី</u>** | |
|---|---|
| ១. ការរៀបចំបរិស្ថានក្នុងបន្ទប់រៀន | |
| ២. សកម្មភាពពង្រីកបន្ថែមក្នុងសៀវភៅសិក្សា | |
| ៣. សកម្មភាពបញ្ច្រាបជាមួយមុខវិជ្ជាផ្សេងទៀត | |
| ៤. សកម្មភាពគិតដោយវិភាគ | |
| ៥. សកម្មភាពគិតដោយច្នៃប្រឌិត | |
| ៦. ការវាយតម្លៃជាដំណាក់ៗ និង កម្រងស្នាដៃសិស្ស | |
| ៧. លំហាត់នៅផ្ទះ និង ការស្រាវជ្រាវក្រៅសាលា | |

ឯកសារទី៤: ប័ណ្ណល្បះ-លំហាត់ស្គាល់ទម្រង់ផែនការថ្នាក់កុមារមេត្រី

## លក្ខណៈពិសេសបរិស្ថានបន្ទប់រៀនសាលាកុមារមេត្រី

### ការរៀបចំបរិស្ថានក្នុងបន្ទប់

- ក្បៀនវិទ្យាសាស្រ្តអនុវត្តដែលមានសម្ភារ ដូចជា ÷ មេដែក កែវពង្រីក រុក្ខជាតិ គ្រាប់រុក្ខជាតិផ្សេងៗ មីក្រូស្កូប ត្រីវិស័យ ។ល ។
- រៀបចំសិស្សជាក្រុមតូចៗ ដែលមានសមត្ថភាពចម្រុះ និង មិនរើសអើង ។
- តុបតែងជញ្ជាំងក្នុងបន្ទប់រៀន ដោយប្រើសម្ភារសិក្សា ផ្ទាំងក្រដាស ប័ណ្ណពាក្យ ។ គួរតែផ្លាស់ប្តូរសម្ភារលើជញ្ជាំង យ៉ាងទៀងទាត់ ដែលសមស្របទៅនឹងខ្លឹមសារ ក្នុងកម្មវិធីសិក្សា ដើម្បីធានាការទាក់ទាញអារម្មណ៍របស់សិស្ស ។
- កន្លែងពិសេសដែលមានតារាងកត់ត្រាកម្ពស់ ទម្ងន់ របស់សិស្សយ៉ាងទៀងទាត់ ។
- ផ្ទាំងក្រដាសដើម្បីពង្រឹងការប្រើប្រាស់ពាក្យ ល្បះ ដូចជា ពណ៌ ចំនួន គុណនាម គុណកិរិយាហើយ និង កិរិយាស័ព្ទ ជំនួស ។( ឧ-សម្រាប់ជំនួសពាក្យដែលប្រើញឹកញាប់ ដូចជា និយាយ ទៅ មើល . . . ) ។
- ដាក់ប្រអប់តូចអោយក្រុមសិស្សនីមួយៗ ប្រើជាធនាគារពាក្យ ។ គ្រូគួរតែរៀបចំប័ណ្ណពាក្យមួយចំនួនតូច រៀងរាល់ថ្ងៃ (ពីរ ឬ បី ប័ណ្ណពាក្យ ) ។
- ជាការងាយស្រួលដកតុទាបដាក់នៅក្បៀនជញ្ជាំងជាបណ្តោះអាសន្នសម្រាប់ មេរៀនមួយចំនួន ។
- មានកន្លែងពិសេស សម្រាប់ទុកកម្រងស្នាដៃសិស្ស និង បង្ហាញស្នាដៃសិស្ស ។
- មានកន្លែងពិសេសរៀបចំជាក្បៀនបណ្ណាល័យតូច ។
- ក្តារខៀនជូនព័ត៌មាន : ព័ត៌មានងាយស្រួលរបស់សិស្សថ្នាក់ទី១ ដូចជា " ថ្ងៃនេះសុខដើរទៅលេងផ្ទះរបស់យាយគាត់ " ព័ត៌មានផ្ទាល់ខ្លួន ជាតិ និង អន្តរជាតិ សម្រាប់សិស្សថ្នាក់ទី ៥ និង ទី ៦ ។

### សកម្មភាពពង្រីកបន្ថែមក្នុងសៀវភៅសិក្សា

- គ្រូដឹកនាំសិស្សធ្វើសកម្មភាពក្រៅថ្នាក់ដើម្បីសង្កេតក្នុងបរិវេណសាលាឬក្រៅសាលា ។
- សិស្សធ្វើសកម្មភាពបំផុសគំនិតជាក្រុមតូច ។ ឧទាហរណ៍ ÷ មុននឹងអាន អត្ថបទស្តីអំពីទឹកជំនន់ ( ភាសាខ្មែរ ថ្នាក់ទី៥ ) សិស្សពិភាក្សាជាមួយគ្នា ហើយ និង សរសេរពាក្យដែលគេស្គាល់រួចមកហើយទាក់ទងនឹងទឹកជំនន់ ។
- អោយសិស្សម្នាក់បង្ហាញសកម្មភាពមួយក្នុងរឿងនិទាន តាមរយៈវិធីល្ខោនគ ។ សិស្សផ្សេងទៀតមើលអត្ថបទ ឡើងវិញ ដើម្បីរកក្នុងកថាខណ្ឌដែលរៀបរាប់ពី សកម្មភាពនេះ ។ សិស្សណាដែលរកឃើញមុនគេឱ្យអានផ្នែកផ្សេងៗ ទៀត ។

- ក្នុងបន្ទប់ជាសរុបមាន ៦ ក្រុមសិស្ស ។ ក្នុង ២ ក្រុម សិស្សសហការជាមួយគ្នា ដើម្បីធ្វើលំហាត់គណិតវិទ្យាកំណត់ដោយគ្រូ ។ គ្រូអង្គុយជាមួយនឹងក្រុមមួយទៀត ដែលកំពុងជួបការលំបាកក្នុងលំហាត់គណិតវិទ្យានេះ ។ បីក្រុមផ្សេងទៀតបានធ្វើ លំហាត់គណិតវិទ្យានេះរួចមកហើយ ក្រុមមួយសិស្សសរសេររបាយការណ៍អំពី សៀវភៅបណ្ណាល័យដែលគេបានអាន ។ ក្រុមមួយទៀតសិស្សជួយគ្នាទៅវិញទៅមក អានប័ណ្ណពាក្យក្នុងធនាគារពាក្យហើយក្រុមមួយទៀតឈរនៅកៀនវិទ្យាសាស្ត្រ-អនុវត្តដោយប្រើសម្ភារដូចជា : មេដែក កែវពង្រីក . . . ។

- សិស្សចូលរួមលេងល្បែងសិក្សាដើម្បីពង្រឹងការយល់ដឹងចំណេះដឹងទូទៅ ។

## សកម្មភាពបញ្ច្រាបជាមួយមុខវិជ្ជាផ្សេងទៀត

- ពេលដែលគ្រូបង្រៀនមេរៀនវិទ្យាសាស្ត្រអនុវត្ត ស្តីអំពីសត្វ គ្រូអាចរៀបចំប័ណ្ណ ពាក្យទាក់ទងនិងសត្វសម្រាប់ដាក់ក្នុងធនាគារពាក្យ( ភាសាខ្មែរ: សមត្ថភាពអាន ) ហើយពិភាក្សាជាមួយសិស្សអំពីលក្ខណៈនៃសត្វនីមួយៗ ( ភាសាខ្មែរ : សមត្ថភាពនិយាយ ) ។

- សិស្សធ្វើរបាយការណ៍ព័ត៌មានប្រចាំថ្ងៃ ( ភាសាខ្មែរ : សមត្ថភាពនិយាយ) ហើយ និង កត់ត្រាព័ត៌មាននេះ ( សិក្សាសង្គម : ភូមិវិទ្យា ) ។

- សិស្សប្រើព័ត៌មានដែលសរសេររួចមកហើយលើតារាងស្តីអំពីអាកាសធាតុ កម្ពស់សិស្ស ទម្ងន់សិស្ស( សិក្សាសង្គម : អាកាសធាតុ និង សុខភាព )ពេលដែលគេធ្វើ លំហាត់គណិតវិទ្យាទាក់ទងនឹងមធ្យមភាគ ទម្ងន់ បរិមាត្រនិងចំណុះ ។

- សិស្សប្រើកែវពង្រីកដើម្បីត្រួតពិនិត្យផ្នែករបស់ផ្កា (វិទ្យាសាស្ត្រអនុវត្ត ) គូរ រូបភាពនៃផ្កា (គូរគំនូរ)ហើយសរសេរស្លាកដាក់លើផ្នែកនីមួយៗរបស់ផ្កា( ភាសាខ្មែរ :ការអភិវឌ្ឍន៍ពាក្យ ការអាន ការសរសេរ ) ។

- ក្រុមសិស្សរៀបចំផែនទីជាក្រដាសធំ ដែលបង្ហាញចំណុចសំខាន់ៗ ក្នុងភូមិ ឬ ឃុំរបស់គេ ( សិក្សាសង្គម បរិស្ថានមូលដ្ឋាន )សរសេរស្លាកលើផែនទី ( ភាសាខ្មែរ ការអាន និង ការសរសេរ )។ សិស្សប្រើត្រីវិស័យដើម្បីកំណត់ទិស ( សិក្សាសង្គម និង គណិតវិទ្យា ) និង ប៉ាន់ស្មានចម្ងាយពីកន្លែងមួយទៅកន្លែងមួយទៀត ក្នុងភូមិ ( គណិតវិទ្យា បរិមាត្រ) ។

## សកម្មភាពគិតដោយវិភាគ

- ក្រុមសិស្សបង្កើតសំណួរទាក់ទងនឹងមេរៀនក្នុងសៀវភៅសិក្សាដោយប្រើពាក្យឃ្លា សំណួរជាច្រើន អោយក្រុមសិស្សផ្សេងទៀតឆ្លើយ ។
- សកម្មភាពចំណាត់ថ្នាក់ ផ្គូផ្គង និង ជ្រើសរើស ។
- ក្រុមសិស្សសរសេរសេចក្តីណែនាំ ស្តីអំពីជំហាននីមួយៗ ក្នុងការអនុវត្តកិច្ចការ ដូចជា ការដាំបាយ ការដាំស្ល ការស្ទូងស្រូវ ។

- ការពិភាក្សាស្តីអំពីអត្ថបទ ដើម្បីកំណត់អ្វីៗ ដែលជាការពិត និង អ្វីៗ ដែលជាគំនិតយោបល់របស់អ្នកសរសេរ ។
- សិស្សវិភាគតម្លៃ ខ្ពង់ ក្នុងចំនួន ។
- ការពិភាក្សាស្តីអំពីលទ្ធផលនៃការស្រាវជ្រាវ និង វិភាគមូលហេតុដែលនាំអោយ មានលទ្ធផលសន្និដ្ឋានចេញ ឬ មូលហេតុដែលពន្យល់ពីការសង្កេត( ស្រង់ព័ត៌មាន ស្តីអំពីការប្រែប្រួលរបស់ទំនិញផ្សេងៗ ឬ ការសង្កេតលើការពិសោធន៏វិទ្យាសាស្ត្រអនុវត្ត ) ។

**សកម្មភាពគិតដោយច្នៃប្រឌិត**

- មេរៀនដែលមានល្បែនគ ។
- ការសរសេររឿងនិទានដោយប្រើរូបារម្មណ៍ ។ ក្នុងមេរៀននេះគ្រូសង្កត់ធ្ងន់ ទៅលើគំនិតយោបល់របស់សិស្ស មិនមែនសង្កត់ធ្ងន់ទៅលើការប្រកបពាក្យ និង វេយ្យាករណ៍ ត្រឹមត្រូវនោះទេ ។
- ការគូរ និង ផាត់ពណ៌រូបភាព ដែលមានប្រធានបទទាក់ទងនឹងមេរៀនភាសាខ្មែរ ឬ សិក្សាសង្គម ។
- ក្រុមសិស្សបំផុសគំនិត ដើម្បីរៀបចំបញ្ជីពាក្យ ( កិរិយាស័ព្ទ គុណកិរិយា នាម និង គុណនាម ) ដើម្បីរៀបរាប់អំពីមនុស្ស ឬ សត្វ ។
- កសាងល្បះ ឬ ឃ្លា ជុំវិញពាក្យ ដែលគ្រូដាក់អោយ ។
- ក្រុមសិស្សរៀបចំចំណោទទាក់ទងនឹងជីវភាពជាក់ស្តែងដែលក្រុមសិស្សផ្សេងៗ ទៀតដោះស្រាយដោយប្រើបំណិនគណិតវិទ្យា ។

**លំហាត់នៅផ្ទះ និង ការស្រាវជ្រាវក្រៅសាលា**

- សិស្សថ្នាក់ទី ៥ - ៦ ប្រមូលព័ត៌មានពីឪពុកម្តាយ ឬ បងរបស់គេដែលគេបាន ស្តាប់វិទ្យុ មើលទូរទស្សន៍ ឬ អានកាសែត ។ សិស្សកត់ត្រាព័ត៌មាននៅក្តារ ខៀនក្នុងបន្ទប់រៀន ។
- ការវាស់កម្ពស់ ថ្លឹងទម្ងន់ ចំណុះ និង មាឌ នៃវត្ថុផ្សេងៗនៅផ្ទះគេ ។
- ក្រុមសិស្សជួបគ្នានៅក្រៅសាលារៀន ដើម្បីជួយគ្នាសរសេរសំបុត្រផ្ញើទៅសិស្ស ផ្សេងទៀតនៅសាលាដទៃ ។
- សិស្សប្រមូលវត្ថុ និងសម្ភារផ្សេងៗដែលសមស្របនឹងមេរៀនវិទ្យាសាស្ត្រ អនុវត្ត ។
- សិស្សកត់ត្រាតម្លៃនៃទំនិញផ្សេងៗនៅផ្សារ ។

**ការវាយតម្លៃជាដំណាក់ៗ និង កម្រងស្នាដៃសិស្ស**

- សិស្សម្នាក់ៗជ្រើសរើសកិច្ចការរបស់ខ្លួន (ឧ. រូបភាពរឿងនិទានដែលគេបាន សរសេរលទ្ធផលស្រាវជ្រាវនៅផ្ទះ របាយការណ៍អំពីសៀវភៅ . . . ) ដើម្បីដាក់ បញ្ចូលក្នុងសឺមីរបស់គេ ។

- ក្រុមសិស្សបង្ហាញលទ្ធផលដែលបានសិក្សាតាមបែបសហការ ជាក្រុមតូចបិទលើជញ្ជាំងជិតតុរបស់គេ ។
  ឧទាហរណ៍ : លំហាត់បំផុសគំនិត ការរៀបចំផែនទី ការបង្កើតសំណួរឱ្យសិស្សផ្សេងទៀតឆ្លើយការគូររូបភាពធំ ។ ក្រោយពី ២ ឬ ៣ សប្តាហ៍សិស្សបិទស្នាដៃថ្មីលើជញ្ជាំងនឹងទុកស្នាដៃចាស់នៅក្នុងសឺមីធំរបស់ ក្រុម ។
- គ្រូតាមដានស្នាដៃរបស់សិស្សហើយពិភាក្សាជាមួយសិស្សដើម្បីសរសើរចំណុចខ្លាំង និង ជួយកែលំអចំណុចខ្សោយ ។ គ្រូសម្រួលកិច្ចតែងការរបស់ខ្លួន និង វិធី បង្រៀនដើម្បីជួយដោះស្រាយទៅតាមតម្រូវការរបស់សិស្ស ។

## ឯកសារទី៥: សេចក្តីណែនាំស្តីពីការរៀបចំផែនការថ្នាក់កុមារមេត្រី

### *<u>សេចក្តីណែនាំ ស្តីពីការរៀបចំផែនការថ្នាក់កុមារមេត្រី</u>*

- គ្រូរៀបចំផែនការថ្នាក់កុមារមេត្រីសម្រាប់គ្រប់មេរៀនទាំងអស់ បើគេយល់ឃើញថា វាសមស្រប ។
- ម្យ៉ាងទៀត គ្រូអាចរៀបចំផែនការថ្នាក់កុមារមេត្រីសម្រាប់ផ្នែក ឬ ជំពូកក្នុងសៀវភៅសិក្សានីមួយៗសម្រាប់ភាសាខ្មែរ វិទ្យាសាស្រ្តអនុវត្ត សិក្សាសង្គម និង គណិតវិទ្យា ធ្វើចំណាត់ថ្នាក់មេរៀនទាំងអស់ក្នុងសៀវភៅតាមប្រធានបទ ។ **<u>តារាងទី ១</u>** : ជូនជាគំនិតអំពីរបៀបដែលគ្រូនៅថ្នាក់ទី ១ និង ទី ២ ថ្នាក់ទី ៥ និង ទី ៦ រៀបចំការសរសេរផែនការថ្នាក់កុមារមេត្រី ។

**<u>តារាងទី ១</u> : សេចក្តីណែនាំស្តីការរៀបចំនៃផែនការថ្នាក់កុមារមេត្រី**

| ថ្នាក់ | **ភាសាខ្មែរ**<br>( ផែនការថ្នាក់កុមារមេត្រីមួយសម្រាប់ជំពូកនីមួយៗក្នុងសៀវភៅសិក្សា ) | **គណិតវិទ្យា**<br>( ផែនការថ្នាក់កុមារមេត្រីមួយសម្រាប់ក្រុមមេរៀនដែលមានប្រធានបទស្រដៀងគ្នា ) | **សិក្សាសង្គម**<br>( សម្រាប់ការរៀបចំមេរៀនសិក្សាសង្គមតាមប្រធានបទ ចូរពិនិត្យមើលផែនការថ្នាក់កុមារមេត្រីគំរូនៅ **ឧបសម្ព័ន្ធ ច** ) | **វិទ្យាសាស្រ្តអនុវត្ត**<br>( ផែនការថ្នាក់កុមារមេត្រីមួយសម្រាប់ ផ្នែក ឬ ជំពូកនីមួយៗក្នុងសៀវភៅសិក្សា ) |
|---|---|---|---|---|
| **ថ្នាក់ទី ១** | ជំពូកទី១<br>ជំពូកទី២<br>ជំពូកទី៣<br>ជំពូកទី៤<br>ជំពូកទី៥ | មេរៀនទី ២ ៥ ៨ ១៤ ១៧<br>មេរៀនទី ៣ ៦ ៩ ១១<br>មេរៀនទី ៤<br>មេរៀនទី ៧ ១២<br>មេរៀនទី ១០<br>មេរៀនទី ១៣<br>មេរៀនទី ១៥<br>មេរៀនទី ១៦ | | ផ្នែកទី១<br>ផ្នែកទី២<br>ផ្នែកទី៣<br>ផ្នែកទី៤ |
| **ថ្នាក់ទី ២** | ជំពូកទី១<br>ជំពូកទី២<br>ជំពូកទី៣<br>ជំពូកទី៤<br>ជំពូកទី៥ | មេរៀនទី ១<br>មេរៀនទី ២ ៣<br>មេរៀនទី ៤<br>មេរៀនទី ៥ ១០<br>មេរៀនទី ៦ ៧ ៩ ១២<br>មេរៀនទី ៨<br>មេរៀនទី ១១<br>មេរៀនទី ១៣<br>មេរៀនទី ១៤ | | ជំពូកទី១<br>ជំពូកទី២<br>ជំពូកទី៣<br>ជំពូកទី៤<br>ជំពូកទី៥<br>ជំពូកទី៦<br>ជំពូកទី៧<br>ជំពូកទី៨ |

| | | | | |
|---|---|---|---|---|
| | | មេរៀនទី ១៥ | | |
| **ថ្នាក់ទី ៥** | ជំពូកទី១<br>ជំពូកទី២<br>ជំពូកទី៣<br>ជំពូកទី៤ | មេរៀនទី ១<br>មេរៀនទី ២<br>មេរៀនទី ៣<br>មេរៀនទី ៤ ៥ ១៥<br>មេរៀនទី ៦<br>មេរៀនទី ៧<br>មេរៀនទី ៨<br>មេរៀនទី ៩ ១០<br>មេរៀនទី ១១ ១២ ១៣<br>មេរៀនទី ១៤<br>មេរៀនទី ១៥<br>មេរៀនទី ១៦<br>មេរៀនទី ១៧<br>មេរៀនទី ១៨ | | ជំពូកទី១<br>ជំពូកទី២<br>ជំពូកទី៣<br>ជំពូកទី៤<br>ជំពូកទី៥<br>ជំពូកទី៦<br>ជំពូកទី៧<br>ជំពូកទី៨ |
| **ថ្នាក់ទី ៦** | ជំពូកទី១<br>ជំពូកទី២<br>ជំពូកទី៣<br>ជំពូកទី៤<br>ជំពូកទី៥<br>ជំពូកទី៦<br>ជំពូកទី៧ | មេរៀនទី ១<br>មេរៀនទី ២<br>មេរៀនទី ៣ ៤<br>មេរៀនទី ៥ ៦<br>មេរៀនទី ៧ ៨<br>មេរៀនទី ៩<br>មេរៀនទី ១០<br>មេរៀនទី ១១<br>មេរៀនទី ១២<br>មេរៀនទី ១៣ | | ជំពូកទី១<br>ជំពូកទី២<br>ជំពូកទី៣<br>ជំពូកទី៤<br>ជំពូកទី៥<br>ជំពូកទី៦<br>ជំពូកទី៧<br>ជំពូកទី៨ |

**ឯកសារទី៦ A: ផែនការថ្នាក់កុមារមេត្រី ( ភាសាខ្មែរថ្នាក់ ទី១ ទី២ ទី៥ និង ទី៦**

**ថ្នាក់ទី ១ : ភាសាខ្មែរ**

**មេរៀន ជំពូកទី ១ : (មេរៀនទី ១_៦) ដកស្រង់ចេញពីទំព័រទី ១_៣៧**

**ខ្លឹមសារ : យើងត្រៀមខ្លួន**

| | |
|---|---|
| ការរៀបចំបរិស្ថានក្នុងបន្ទប់រៀន | • ការបិទប័ណ្ណអក្សរលើតុ<br>• ការបិទឈ្មោះសិស្សក្នុងក្រុមលើជញ្ជាំងនៅជិតតុគេ<br>• ការរៀបចំធនាគារពាក្យ ការដាក់ប្រអប់លើតុរបស់ក្រុមនីមួយៗ ដាក់ពាក្យនិងឃ្លាសំខាន់ៗក្នុងប្រអប់ដូចជា : ជំរាបសួរ សុខសប្បាយ អរគុណ លោកគ្រូ អ្នកគ្រូ . . .<br>• បិទតារាងព្យញ្ជនៈ និង ស្រៈ<br>• ផ្ទាំងក្រដាសពាក្យសំខាន់ៗ ឧទាហរណ៍ : ពណ៌ គ្រួសារ ពេលវេលា ធាតុអាកាស ទីកន្លែង . . .<br>• ការរៀបចំប្រអប់ដីខ្សាច់ សម្រាប់ក្រុមនីមួយៗ<br>• កៀនភាសាខ្មែរ : រៀបចំតុនៅជ្រុងបន្ទប់ ។ បិទប័ណ្ណអក្សរដែលបង្ហាញអំពីព្យញ្ជនៈ បីតួ នៅជិតតុ សិស្សអាច ប្រមូលវត្ថុផ្សេងៗដាក់លើតុនេះ ដែលមានសូរព្យញ្ជនៈដើម ។ ម៉្យាងទៀតគ្រូរៀបចំប័ណ្ណពាក្យសំខាន់ៗ និង ស្រួល អានចាប់ផ្តើមដោយព្យញ្ជនៈនេះ ។ ឧទាហរណ៍ : អក្សរ " ក " សិស្សអាចប្រមូលវត្ថុ ដូចជា កា កៅស៊ូកង គ្រូ អាចសរសេរប័ណ្ណពាក្យដាក់តាមវត្ថុ ឬ រូបភាពនេះ ។<br><u>ចំណាំ</u> :គួរតែជ្រើសរើសពាក្យដែលសិស្សស្គាល់ហើយតែគេមិនទាន់ចេះសរសេរ( ទាក់ទងនឹងការរស់នៅប្រចាំថ្ងៃ ) ។ |
| សកម្មភាពពង្រីកបន្ថែមក្នុងសៀវភៅសិក្សា | • សរសេរអក្សរក្នុងលំហ<br>• គូរអក្សរលើតុដោយប្រើចង្អុលដៃ |

| | |
|---|---|
| | • ប្រអប់ដីខ្សាច់ សម្រាប់ហាត់សរសេរអក្សរ<br>• សរសេរ និង គូររូបភាពតាមអក្សរនេះ ។<br>• គ្រូរៀបចំប័ណ្ណឈ្មោះសិស្សធំៗបិទលើតុ ( សរសេរតែ នាម របស់សិស្ស )<br>• ល្បែងសិក្សា : (ខ្ញុំមើលឃើញដោយប្រើភ្នែករបស់ខ្ញុំនូវអ្វីៗមួយក្នុងបន្ទប់ដែលចាប់ផ្តើមដោយអក្សរ "ក" មុនដំបូង គ្រូជាអ្នកហៅ ហើយបន្ទាប់មកទៀតសិស្សជាអ្នកដឹកនាំដោយខ្លួនឯង<br>• ការសង្កេតវត្ថុក្រៅថ្នាក់រៀន ។ គ្រូដឹកនាំសិស្សដើរជុំវិញទីធ្លាសាលា ដើម្បីកំណត់វត្ថុ ឬ កន្លែងចាប់ផ្តើមដោយ អក្សរ ឧទាហរណ៍ : "ក"<br>• រៀបចំប័ណ្ណអក្សរមួយសម្រាប់មួយក្រុម ។ ឱ្យសិស្សបិទប័ណ្ណព្យញ្ជនៈដើមនេះលើរូបភាព ឬ វត្ថុជាក់ស្តែងមួយក្នុង បន្ទប់ដែលផ្តើមដោយអក្សរនេះ។ ធ្វើដូចនេះនៅដើមឆ្នាំសិក្សា សម្រាប់ចុងឆ្នាំសិក្សាយើងធ្វើប័ណ្ណពាក្យ<br>• បិទរូបភាពជាច្រើនក្នុងបន្ទប់រៀន ឱ្យសិស្សរៀបរាប់អំពីរូបភាព ឱ្យសិស្សសួរសំណួរពីគ្នាទៅវិញទៅមកអំពីរូបភាព ។ |
| សកម្មភាពបញ្ជ្រាបមុខវិជ្ជាផ្សេងទៀត | • សិក្សាសង្គម<br>• គណិតវិទ្យា<br>• នាំសិស្សចូលបណ្ណាល័យ ។ |
| សកម្មភាពគិតដោយវិភាគ | • សិស្សជ្រើសរើសព្យញ្ជនៈមួយដែលបានកំណត់ដោយគ្រូក្នុងចំណោមប័ណ្ណព្យញ្ជនៈច្រើន<br>• ការជ្រើសរើសអ្វីផ្សេងៗ ក្នុងរូបភាព ឬ ក្នុងបន្ទប់រៀន ឬ ក្នុងទីធ្លាសាលារៀនដែលចាប់ផ្តើមសូរព្យញ្ជនៈដើម ដែលបានកំណត់ ឬ ដែលមានស្រៈដែលបានកំណត់<br>• ការស្រាវជ្រាវចេញពីផ្ទាំងក្រដាសឬសៀវភៅ លើអ្វីដែលមានអក្សរ ដើម្បីរកព្យញ្ជនៈ ឬ ស្រៈដែលបានកំណត់ |

| | |
|---|---|
| | • ការរៀបចំវត្ថុផ្សេងៗ ដោយសិស្សតាមលំដាប់លំដោយ ដោយគិតអំពីទំហំ ( មើលលំហាត់នៅទំព័រទី ១៥ សៀវភៅ សិស្ស ថ្នាក់ទី ១ )<br>• គ្រូបិទប័ណ្ណអក្សរលើវត្ថុ ឬ លើរូបភាពផ្សេងៗ ក្នុងបន្ទប់រៀន ។ ប័ណ្ណអក្សរមួយចំនួនបញ្ជាក់អំពីព្យញ្ជនៈដើមរបស់វត្ថុឬ រូបភាពនេះ ប៉ុន្តែគ្រូដាក់ប័ណ្ណព្យញ្ជនៈ ឬប័ណ្ណពាក្យមួយចំនួនទៀតលើវត្ថុខុសពីព្យញ្ជនៈនេះ ។ ឱ្យសិស្សប្រាប់ ប័ណ្ណព្យញ្ជនៈប័ណ្ណពាក្យដែលត្រូវ ឬ ប័ណ្ណខុស ។<br>• បង្ហាញប័ណ្ណពាក្យ ស្តីពីពាក្យងាយៗ ដែលគេធ្លាប់អាន ។ ប័ណ្ណពាក្យមួយសរសេរត្រឹមត្រូវ ប៉ុន្តែប័ណ្ណពាក្យមួយ ចំនួនទៀតសរសេរខុស ។ ឱ្យសិស្សកំណត់ប័ណ្ណពាក្យខុស ។ សិស្សអាចកែកំហុសសំណេររបស់គ្រូ ។<br>• លំហាត់ប្រហាក់ប្រហែលនឹងទំព័រទី ១៧ ២២ ២៩ និង ៣៥ នៅសៀវភៅសិស្ស ។ |
| សកម្មភាពគិតដោយច្នៃប្រឌិត | • គ្រាប់កាយវិការ ( សំដែងតួ ) អំពីស្ថានភាពនៅសាលារៀន ឬ នៅផ្ទះ<br>• គូរគំនូរអំពីស្ថានភាពនៅផ្ទះ ឬ នៅសាលារៀន<br>• តែងឃ្លា និង ពាក្យមួយដែលគ្រូបានសរសេរលើប័ណ្ណពាក្យ ។ |
| ការវាយតម្លៃជាដំណាក់ៗ និង កម្រងស្នាដៃសិស្ស | • រូបភាពដែលសិស្សបានគូរ ដើម្បីបង្ហាញព្យញ្ជនៈណាមួយ<br>• ព្យញ្ជនៈដែលសិស្សបានសរសេរ<br>• ពាក្យដែលសិស្សបានសរសេរ<br>• ឃ្លាងាយៗ ដែលសិស្សព្យាយាមសរសេរ ( ទោះបីជាខុសអាចដាក់បាន ) ។ |
| លំហាត់នៅផ្ទះ និង ការស្រាវជ្រាវក្រៅសាលា | • សិស្សប្រមូលវត្ថុផ្សេងៗ សម្រាប់ " តុអក្សរ " ។ ក្រុមសិស្សផ្សេងៗមានភារកិច្ចប្រមូលវត្ថុសម្រាប់អក្សរដទៃទៀត ។ |

<table>
<tr><td colspan="2">ថ្នាក់ទី២ : ភាសាខ្មែរ ជំពូកទី១<br>មេរៀន ទី១ ដល់ទី៥ ដកស្រង់ចេញពីទំព័រទី ១-៤១<br>ខ្លឹមសារ : ឆ្នាំសិក្សាថ្មី</td></tr>
<tr><td>ការរៀបចំបរិស្ថានក្នុងបន្ទប់រៀន</td><td>• ធនាគារពាក្យដាក់ពាក្យសំខាន់ៗ ដូចជាពាក្យ ( បវេសនកាល ខែកញ្ញា មិត្តភក្តិ . . . )<br>• វិចនានុក្រមរូបភាពធ្វើដោយសិស្សម្នាក់ៗ ( ចូរអានខាងក្រោម )<br>• សីមីឃ្លា ឬ ល្បះសំរាប់ក្រុមនីមួយៗ ។ ក្នុងសីមីនេះមានក្រដាស ស រៀបចំជាប័ណ្ណតូចៗ សម្រាប់សិស្សសរសេរល្បះឬឃ្លា<br>• ផ្ទាំងក្រដាសពាក្យសំខាន់ៗ ឧទាហរណ៍ : ពណ៌ គ្រួសារ ពេលវេលា ធាតុអាកាស ទីកន្លែង ខែក្នុងឆ្នាំ ហើយយកទៅបិទលើជញ្ជាំង<br>• ពាក្យ និង ឃ្លា សំខាន់ៗ : កិរិយាស័ព្ទដែលប្រើញឹកញាប់ គុណនាម ដែលប្រើញឹកញាប់ ពាក្យដែលរៀបរាប់អំពីស្ថានភាពដូចជា ( ក្នុង ក្រៅ ស្តាំ ក្រោម ) បិទលើជញ្ជាំង<br>• ការបង្កើតកៀនបណ្ណាល័យក្នុងថ្នាក់ដោយខ្ចីសៀវភៅមួយចំនួនពីបណ្ណាល័យរបស់កម្រង<br>• ក្តារខៀនជូនព័តិមានផ្ទាល់ខ្លួន<br>• ក្តារខៀនជូនព័តិមានពីធាតុអាកាស : សិស្សផ្លាស់ប្តូរឈ្មោះថ្ងៃរៀងរាល់ថ្ងៃហើយ និង ជ្រើសរើសពាក្យសមស្របដើម្បីរៀបរាប់ធាតុអាកាសដែលមាននៅថ្ងៃនេះ ។ ម្យ៉ាងទៀតសិស្សអាចផ្លាស់ប្តូរឈ្មោះខែ និង កាលបរិច្ឆេទ<br>• ពាក្យប្រចាំថ្ងៃ<br>• វិចនានុក្រមរូបភាពប្រចាំថ្នាក់ដែលអាចរៀបចំក្នុងក្រឡូ<br>• គ្រូសរសេរមេសូត្រលើផ្ទាំងក្រដាសធំដែលដកស្រង់ចេញពីទំព័រទី ១៥ ៣១ ៣៩ បិទលើជញ្ជាំង<br>✵ <u>ចំណាំ</u> : គួរតែធ្វើតម្រង់ទិសជាមួយសិស្សយ៉ាងញឹកញាប់នាំឱ្យគេយល់ដឹងពីកៀនបណ្ណាល័យ ធនាគារពាក្យ</td></tr>
</table>

| | |
|---|---|
| | វចនានុក្រមរូបភាព សីមីឈ្មោះឃ្លាសម្ភារសិក្សាផ្សេងៗបិទលើជញ្ជាំង ។ ជំរុញឱ្យសិស្សធ្វើយ៉ាងណាអាចទទួលលទ្ធផលពីបរិស្ថានក្បែនជញ្ជាំង បន្ទប់រៀននៅពេលទំនេរនៃម៉ោងសិក្សាដើម្បីស្វ័យសិក្សាបន្ថែមលើសមត្ថភាពអាន និង សរសេរ ។ |
| សកម្មភាពពង្រីកបន្ថែមក្នុងសៀវភៅសិក្សា | • ឱ្យសិស្សគូររូបបង្ហាញពាក្យថ្មី ក្នុងសៀវភៅសិក្សា : អាចបង្កើតវចនានុក្រមរូបភាពសម្រាប់សិស្សនីមួយៗដោយប្រើសៀវភៅសរសេរធម្មតាដោយគូសក្នុងទំព័រជា ៣ ផ្នែកសម្រាប់គូររូបតាមពាក្យកំណត់នីមួយៗ<br>• ល្បែងសិក្សា : ( ខ្ញុំមើលឃើញដោយប្រើភ្នែកតូចរបស់ខ្ញុំលើអ្វីមួយមាននៅក្នុងបន្ទប់ដែលចាប់ផ្តើមដោយអក្សរ "ក" ) មុនដំបូងគ្រូជាអ្នកហៅហើយបន្ទាប់មកទៀតសិស្សជាអ្នកដឹកនាំដោយខ្លួនឯង<br>• បិទរូបភាពជាច្រើនក្នុងបន្ទប់រៀនឱ្យសិស្សរៀបរាប់អំពីរូបភាព និង សួរសំណួរគ្នាទៅវិញទៅមកអំពីរូបភាពនោះ<br>• ឱ្យសិស្សនិយាយពីអ្វីៗ ដែលគេចងចាំ នៅពេលបវេសនកាលឆ្នាំមុនពេលដែលគេចូលរៀនថ្នាក់ទី ១ ឱ្យគេនិយាយពីអ្នកណាខ្លះដែលគេជួប ? គេស្គាល់មិត្តភក្តិដំបូងរបៀបណា ? តើគេមានអារម្មណ៍យ៉ាងណាពេលថ្ងៃចូលរៀនដំបូង ? តើគេបានស្គាល់មិត្តថ្មីៗ ដែលកំពុងរៀនថ្នាក់ទី១ ឆ្នាំនេះដែរឬទេ ? តើគេធ្វើយ៉ាងដូចម្តេចដើម្បីជួយសិស្សថ្មីៗឱ្យអ្នកទាំងនោះចូលចិត្តសាលារៀន ?<br>• ឱ្យសិស្សរៀបរាប់លើសៀវភៅបណ្ណាល័យដែលគេកំពុងអានក្នុងក្រុមរបស់គេ និង ឱ្យរៀបរាប់អំពីឧបទ្ទវហេតុមួយក្នុងសៀវភៅសិក្សាឬអានផ្នែកណាមួយក្នុងសៀវភៅដែលគេចាប់អារម្មណ៍ឬនិយាយអំពីរូបភាពក្នុងសៀវភៅ<br>• គ្រូឱ្យសិស្សអានប្រធានបទដូចដែលមានលើទំព័រទី៨ ១១ ១៩ ២៣ ២៧ ៣៥ គ្រូគួរតែកំណត់នូវគោលបំណងឱ្យបានច្បាស់លាស់ជាជាងគ្រាន់តែឱ្យសិស្សអានទទេ ។ ឧ- គ្រូសួរសំណួរសិស្សអានប្រធានបទដោយស្ងាត់ជាបុគ្គល ឬជាដៃគូដើម្បីរកចម្លើយ ។ សិស្សណាអាចរកចម្លើយត្រូវអានឃ្លានោះឱ្យឮ ។ គ្រូអាច បង្កើតសំណួរផ្សេងៗ<br>• ឱ្យសិស្សគូររូបភាពនៃបវេសនកាល និង ឱ្យគេនិទានរឿងតាមរូបភាពនេះជាមួយសិស្សក្នុងក្រុមខ្លួនឯង |

| | |
|---|---|
| | • សិស្សសរសេរឃ្លា ( ៣- ៤ ល្បះ ឬ ឃ្លា ) ដើម្បីរៀបរាប់រូបភាពតាមសមត្ថភាពរបស់សិស្ស<br>• ល្បែងសិក្សានិយាយខ្សឹប : គ្រូនិយាយខ្សឹបឃ្លាមួយជាមួយសិស្សម្នាក់ និង សិស្សក្នុងក្រុមខ្សឹបបន្ត ។ ពេលរួចហើយផ្ទៀងផ្ទាត់ឃ្លាដំបូងជាមួយឃ្លាចុងបញ្ចប់ ( ឧ- នៅថ្ងៃបវេសនកាលខ្ញុំបានជួបគ្រូបង្រៀនរបស់ខ្ញុំនិងមិត្តថ្មីមួយចំនួនក្នុងបន្ទប់រៀន )<br>• ការអាន និង ការពិភាក្សាអំពីរូបភាពសិក្សាបិទនៅជញ្ជាំងក្នុងបន្ទប់រៀន<br>• ឱ្យសិស្សផ្សព្វផ្សាយព័ត៌មានផ្ទាល់ខ្លួន តើគេបានធ្វើអ្វីខ្លះពីម្សិលមិញ ? តើគេទៅណា ? តើគេជួបអ្នកណា ? តើគេមានមនុស្សឈឺនៅផ្ទះដែរឬទេ ? តើគេជួបសំណាងល្អដែរឬទេ ? ពិភាក្សារយៈពេល ៥ នាទី ។រួចឱ្យសិស្សសរសេរឃ្លា ៣-៥ អំពីព័ត៌មាននេះ ។ នាំសិស្សមើលបញ្ជីពាក្យដែលបិទលើជញ្ជាំងដើម្បីឱ្យការសរសេរឃ្លានេះត្រឹមត្រូវ ម្យ៉ាងទៀតគ្រូអាចសរសេរពាក្យថ្មីៗ ដែលធ្លាប់ជួបប្រទះក្នុងការពិភាក្សាលើក្តារខៀន<br>• ពិភាក្សាអំពីពាក្យផ្ទុយ ពាក្យមានន័យដូចគ្នា ពាក្យដែលមានសូរដូចគ្នា<br>• វាក្យស័ព្ទ ( ប៊ីងហ្គោ )<br>• ការពិភាក្សាអំពីរូបភាពក្នុងសៀវភៅសិក្សា :ជុំរុញឱ្យសិស្សសួរសំណួរអំពីរូបភាពពីគ្នាទៅវិញទៅមកក្នុងក្រុម<br>• ផ្តល់ឱកាសឱ្យសិស្សនិយាយអំពីឪពុកម្តាយ និង មិត្តភក្តិរបស់គេ ។ |
| សកម្មភាពបញ្ច្រាបមុខវិជ្ជាផ្សេងទៀត | • សិក្សាសង្គម ( គូរគំនូរ . . . )<br>• ទស្សនកិច្ចចូលបណ្ណាល័យ |
| សកម្មភាពគិតដោយវិភាគ | • បង្ហាញសិស្សនូវបញ្ជីពាក្យស្តីអំពីពាក្យងាយៗដែលគេធ្លាប់អាន ។ ពាក្យមួយប្រកបត្រឹមត្រូវប៉ុន្តែពាក្យមួយចំនួនទៀតប្រកបខុស ។ ឱ្យសិស្សកំណត់បញ្ជីពាក្យខុស ។ សិស្សអាចកែកំហុសសំណេររបស់គ្រូ<br>• ការរៀបចំតាមលំដាប់លំដោយព្យញ្ជនៈ ( ដូចមានពាក្យក្នុងវចនានុក្រម ) |

| | |
|---|---|
| | • គ្រូហៅពាក្យមួយម្តង១ ឱ្យសិស្សស្តាប់ ។ រួចសិស្សនិយាយពាក្យផ្សេងទៀតចាប់ផ្តើមដោយព្យញ្ជនៈដូចគ្នា ឧ-គ្រូហៅពាក្យសាលា សិស្សអាចឆ្លើយ សៀវភៅ ស្ករ . . .។<br>• ផ្តល់ឱកាសឱ្យសិស្សសួរសំណួរពីគ្នាទៅវិញទៅមក អំពីអត្ថបទ ឬ រូបភាព<br>• គ្រូរៀបចំអត្ថបទនៅលើក្តារខៀន ដោយលុបពាក្យមួយចំនួនចេញ ឱ្យសិស្សបំពេញឡើងវិញ ក្រោយពីវិភាគខ្លឹមសារ ( ដូចមានក្នុងលំហាត់ទំព័រ ទី ៥-៧-៩-១២-១៤-២៥-៣០-៣៣-៣៨ ក្នុងសៀវភៅសិក្សារបស់សិស្ស )<br>• លំហាត់ពាក្យផ្គូផ្គងដាក់ជាគូ ( ទំព័រទី១៦ និង ទំព័រ ទី ២០- ២២- ៣២ ក្នុងសៀវភៅសិក្សារបស់សិស្ស )<br>• ការរៀបចំល្បែះតាមលំដាប់លំដោយហេតុការណ៍ដូចដែលមានក្នុងទំព័រទី ២៤<br>• ល្បែងសិក្សា : " លើកដៃ " គ្រូហៅបញ្ជីពាក្យជាច្រើន និង ឱ្យសិស្សលើកដៃពេលដែលឮឈ្មោះវត្ថុដែលអាចរកក្នុងផ្ទះ ឬ ក្នុងសាលា<br>• ឱ្យសិស្សពិចារណាអំពី " តើប្អូនធ្វើអ្វីខ្លះប្រសិនបើ " គ្រូរបស់ប្អូនមិនមកសាលារៀន ប្អូនភ្លេចយកសៀវភៅសិក្សា មក ប្អូនបាត់សៀវភៅសិក្សាភាសាខ្មែរ ?<br>• ការយល់ន័យនៃពាក្យថ្មី១ ដោយវិភាគខ្លឹមសារ ក្នុងល្បែះ ឬ អត្ថបទ<br>• ការដោះស្រាយបញ្ហា : សិស្សថ្មីរកបន្ទប់រៀនរបស់គេមិនឃើញ តើគេត្រូវធ្វើដូចម្តេច ?<br>• កាតាបដែលសិស្សថ្នាក់ទី១ មានផ្ទុកសៀវភៅធ្ងន់ពេកពេលគេស្ពាយ តើគេត្រូវធ្វើដូចម្តេច ? |
| សកម្មភាពគិតដោយច្នៃប្រឌិត | • ការធ្វើកាយវិការត្រាប់តាម ការសំដែងតួ អំពីស្ថានភាពនៅសាលារៀន ឬ នៅផ្ទះ ។ ឧ : សំដែងតួមួយអំពីគ្រូជួបជាមួយសិស្ស ពេលនោះសិស្សខ្លាចគ្រូ ពេលដែលសិស្សថ្មីទើបចូលរៀនដំបូង<br>• ធ្វើត្រាប់តាម ឬ ល្ខោនដោយប្រើតុក្កតាដែលធ្វើពីក្រដាស ឬ កំណាត់<br>• គូររូបភាពអំពីបរិវេសនកាលនៅក្នុងសាលារៀន |

| | |
|---|---|
| | • បង្កើតឃ្លាជុំវិញពាក្យថ្មីដែលមាននៅក្នុងសៀវភៅសិក្សា ឬ ជុំវិញរូបភាពដូចលំហាត់ក្នុងទំព័រទី ៤១<br>• ឱ្យសិស្សបិទភ្នែក និង ប្រើរូបារម្មណ៍គិតស្រមៃដល់សំលេងដែលទាក់ទងនឹងពេលបើកបវេសនកាល ។ ដូចជាក្មេង ឬ សិស្សតូច១ កំពុងយំ ម្តាយកំពុងលួង មិត្តភក្តិចាស់ជួបគ្នាម្តងទៀត សំឡេងជួងចូលរៀន ។ល។<br>• គ្រប់ក្រុមទាំងអស់ត្រូវមានសឺមីឈ្មោះ ឃ្លា ហើយក្នុងនោះមានចំរៀកប័ណ្ណ ស ច្រើនសន្លឹក ។ ពេលជួបប្រទះពាក្យថ្មី សិស្សក្នុងក្រុមសហការ ជាមួយគ្នា តែងឃ្លាដោយប្រើពាក្យនេះ ហើយសរសេរលើប័ណ្ណពាក្យនេះទុកក្នុងសឺមី<br>• គ្រូនិទានរឿងឱ្យសិស្សស្តាប់កាលណាគាត់និទានរឿងគាត់សរសេរពាក្យសំខាន់ៗដូចជាឈ្មោះមនុស្សក្នុងរឿងនិទានលើក្តារខៀន និង ឱ្យសិស្សគូររូបភាពអំពីឧបទ្ទវហេតុមួយដែលសិស្សចាប់អារម្មណ៍ ។ សិស្សអាចសរសេរពាក្យសំខាន់ៗជាមួយរូបភាព<br>• រៀបចំពាក្យតាមលំដាប់ឱ្យត្រូវតាមឧបទ្ទវហេតុដកស្រង់ចេញពីការនិទាន<br>• និទានរឿងមួយផ្នែកឱ្យសិស្សស្តាប់ និង ឱ្យសិស្សទាយអំពីអ្វីៗ ដែលអាចកើតមានឡើងនៅផ្នែកខាងក្រោយ<br>• បង្កើតកាយវិការ និង ចលនាផ្សេងៗ ដើម្បីបង្ហាញន័យក្នុងមេសូត្រលើទំព័រទី១៥-៣១-៣៩<br>• កំណត់ពាក្យដែលមានសូរសំណេរចាប់ចុងចួនឱ្យសិស្សជាអ្នករកពាក្យចួនបន្ត ( ឧ-ចាន→ បាន→ឡាន ...) ។ |
| ការវាយតម្លៃជាដំណាក់ៗ និង កម្រងស្នាដៃសិស្ស | • សិស្សជ្រើសរើសស្នាដៃរបស់ខ្លួនដាក់ចូលក្នុងសឺមី<br>• ទុកសឺមីឃ្លាឈ្មោះរបស់ក្រុមលើតុ និង ពេលណាដែលជួបនឹងពាក្យថ្មីឱ្យក្រុមច្នៃប្រឌិតឃ្លាជុំវិញពាក្យនេះ គ្រូត្រូវឆ្លៀតឱកាសតាមដានស្នាដៃសឺមី<br>• វចនានុក្រមរូបភាពអាចទុកវាក្នុងកម្រងស្នាដៃសិស្ស និង យកចេញពេលដែលត្រូវការ ។ |
| លំហាត់នៅផ្ទះ និង ការស្រាវជ្រាវក្រៅសាលា | • យកវចនានុក្រម រូបភាព បង្ហាញឪពុកម្តាយ ឬ បងប្អូននៅផ្ទះ និង ពិភាក្សាជាមួយគ្នា<br>• ការតែងឃ្លាជុំវិញពាក្យថ្មីៗ ក្នុងវចនានុក្រមរូបភាព ។ |

| **ថ្នាក់ទី ៥ ទី ៦ : ភាសាខ្មែរ** | |
|---|---|
| ការរៀបចំបរិស្ថានក្នុងបន្ទប់រៀន | • បញ្ជីពាក្យមានន័យប្រហាក់ប្រហែលនឹងពាក្យដែលប្រើញឹកញាប់<br>• បញ្ជីពាក្យជួយឱ្យសំណេរបែបពិពណ៌នាអំពីឧបទ្ទវហេតុដែលកើតមានឡើងដូចជា " ជាបឋម ជាដំបូង រំពេចនោះ ភ្លាមនោះ រួចមកហើយ កន្លងមក ទោះបីជាយ៉ាងណាក៏ដោយ. . .ហាក់ដូច ហាក់បីដូចជា . . .<br>• បញ្ជីពាក្យជួយរៀបរាប់អំពីចំនួន និង ទំហំ ដូចជា : តិចតួច ច្រើន លើសលប់ ទាំងឡាយ ទាំងមូល ទាំងពួង ឥតគណនា . . .<br>• ចែកជូនសៀវភៅពិសេសសម្រាប់សិស្សម្នាក់ៗ ប្រើជាសៀវភៅកំណត់ហេតុ<br>• ការដាក់សៀវភៅពិសេសមួយលើតុប្រើជាសៀវភៅ " ធនាគារពាក្យ " ដើម្បីកត់ត្រាពាក្យវប្បធម៌ និង ពាក្យពិបាក<br>• បញ្ជីពាក្យទាក់ទងនឹងការសួរសំណួរដូចជា : តើ ? យ៉ាងដូចម្តេច ? ពេលណា ? នៅឯណា ?<br>• បញ្ជីភាសាបច្ចេកទេស ស្តីអំពីវេយ្យាករណ៍តាមកម្មវិធីសិក្សា ដូចជា : កិរិយាវិសេសន៍ គុណកិរិយា<br>• រៀបចំបណ្ណាល័យតូចក្នុងបន្ទប់រៀន : ការបង្ហាញរបាយការណ៍សរសេរដោយសិស្ស ស្តីពីសៀវភៅដែលគេបានអាន<br>• ការរៀបចំធ្នើពិសេសក្នុងបណ្ណាល័យនេះ សម្រាប់ថែរក្សាទុក កាសែតចាស់ៗ ទស្សនាវដ្តីចាស់ៗ ហើយ និង លិខិតឆ្លើយឆ្លងទៅមិត្តភក្តិ ( ពីកម្រងមួយទៅកម្រងមួយផ្សេងទៀត )<br>• បង្កើតប្រព័ន្ធខ្ចីសៀវភៅពីបណ្ណាល័យ<br>• វិចនានុក្រមតូចនៅលើតុរបស់ក្រុមសិស្សនីមួយៗ |

| | |
|---|---|
| | • វចនានុក្រមធំមួយទុកនៅបន្ទប់បណ្ណាល័យ<br>• ផ្ទាំងក្រដាសបង្ហាញពាក្យប្រចាំថ្ងៃ<br>• ផ្ទាំងក្រដាសបង្ហាញសំណួរប្រចាំសប្តាហ៍ដែលសិស្សត្រូវស្រាវជ្រាវក្នុងបណ្ណាល័យរបស់សាលា<br>• ក្តារខៀនជូនព័ត៌មាន ( ព័ត៌មានផ្ទាល់ខ្លួន ជាតិ និង អន្តរជាតិ ) ។ |
| សកម្មភាពពង្រីកបន្ថែមក្នុងសៀវភៅសិក្សា | • អំណានឮមាន គោលបំណងជាក់លាក់ ។ ចូររកកថាខ័ណ្ឌដែលបង្ហាញអំពីការរំភើប ទុក្ខព្រួយ ចរិកមនុស្ស សកម្មភាព . . . ។ សិស្សរកបានត្រូវអានឮ<br>• ឱ្យសិស្សបង្ហាញកថាខ័ណ្ឌក្នុងរឿងនិទាន ជាឆាកល្ខោន ដែលសិស្សនេះបានជ្រើសរើស ។ សិស្សផ្សេងទៀតព្យាយាមរកក្នុងកថាខ័ណ្ឌដែលស្របទៅនឹងឆាកល្ខោននេះ ។ សិស្សដែលរកបានត្រូវអានឮ<br>• ពិភាក្សា : ប្រៀបធៀបខ្លឹមសារក្នុងអត្ថបទទៅនឹងបទពិសោធន៍របស់សិស្ស<br>• អានកថាខ័ណ្ឌទី ១ ដំបូងក្នុងរឿង ។ មុននឹងអានតទៅទៀតឱ្យសិស្សទាយអំពីអ្វីដែលគេយល់ថា អាចកើតមានឡើងក្នុងរឿងនេះ ។ កត់ត្រាការទាយនេះក្នុងសៀវភៅកំណត់ហេតុពិសេស ។ អាចបន្តទៀតហើយនឹងប្រៀបធៀបការទាយនេះទៅនឹងហេតុផលជាក់ស្តែងក្នុងរឿង<br>• ការផ្តល់គោលបំណងជាក់លាក់សម្រាប់អំណានស្ងាត់ ។ មុននឹងឱ្យសិស្សអានគ្រូដាក់សំណួរឱ្យសិស្សរកព័ត៌មានជាក់ស្តែងក្នុងអត្ថបទ<br>• គ្រូសរសេរបញ្ជីពាក្យលើក្តារខៀន ។ សិស្សអានអត្ថបទដោយស្ងាត់ស្ងៀមដើម្បីរកឱ្យឃើញពាក្យដែលមានន័យផ្ទុយនឹងន័យរបស់ពាក្យនៅលើក្តារខៀន ។ ម្យ៉ាងទៀតសិស្សអាចរកពាក្យក្នុងអត្ថបទដែលមានន័យស្រដៀងនឹងពាក្យលើក្តារខៀន<br>• ឱ្យសិស្សពន្យល់រឿង ឬ ព័ត៌មាន ក្នុងអត្ថបទឡើងវិញ ដោយប្រើជាភាសាផ្ទាល់ខ្លួន |

| | |
|---|---|
| | • ឱ្យសិស្សសួរសំណួរគ្នាទៅវិញទៅមកអំពីអត្ថបទ<br>• ឱ្យក្រុមសិស្សបង្កើតសំណួរ សិស្សក្រុមផ្សេងទៀតឆ្លើយលើក្រដាសធំ ។ ហើយក្រុមសិស្សផ្សេងទៀតកែលំហាត់ ( ចំណាំ : កុំឱ្យកែជាបុគ្គល )<br>• ជំរុញសិស្សឱ្យរក និង ស្គាល់ពាក្យថ្មីៗ ហើយនឹងកត់ត្រាពាក្យនេះក្នុងសៀវភៅធនាគារពាក្យ ។ |
| សកម្មភាពបញ្ច្រាបមុខវិជ្ជាផ្សេងទៀត | • គ្រប់មុខវិជ្ជាតាមខ្លឹមសារមេរៀន ។ |
| សកម្មភាពគិតដោយវិភាគ | • ការយល់ន័យនៃពាក្យថ្មីៗ ដោយវិភាគខ្លឹមសារក្នុងល្បះ ឬ អត្ថបទ<br>១. រៀបចំប័ណ្ណពាក្យ ២ សម្រាប់ : ១ សម្រាប់ ១០ ប័ណ្ណ ។ សម្រាប់ទី ១ មានពាក្យថ្មីៗ ឬ ពាក្យពិបាកយល់ដក ស្រង់ចេញពីអត្ថបទមិនទាន់អាន ។ សម្រាប់ទី ២ មាននិយមន័យ ឬ ការពន្យល់ពាក្យឱ្យសិស្សផ្គូផ្គងទាំង២ សម្រាប់រួចឱ្យសិស្សអានអត្ថបទ ។ ពេលគេជួបពាក្យថ្មី សរសេរលើប័ណ្ណពាក្យក្នុងអត្ថបទ គេគួរតែវិភាគ ខ្លឹមសារក្នុងល្បះ ឬ អត្ថបទ ដើម្បីជួយឱ្យគេយល់ពីពាក្យថ្មី ។ ក្រៅពីការវិភាគនេះ តើគេបានផ្គូផ្គងប័ណ្ណពាក្យទៅ នឹងនិយមន័យ ឬ ការពិពណ៌នាបានសមស្របដែរឬទេ ?<br>២. គ្រូកំណត់ពាក្យថ្មីៗ ពិបាកយល់ក្នុងអត្ថបទ ហើយសរសេរលើក្តារខៀន ។ សិស្សអានអត្ថបទជាក្រុមតូច ពេលគេជួបពាក្យដែលគ្រូបានសរសេរលើក្តារខៀនគេគួរតែពិភាក្សាជាមួយគ្នាដើម្បីជួយគ្នាឱ្យបានយល់<br>• ការធ្វើចំណាត់ថ្នាក់ពាក្យដោយវិភាគទម្រង់វេយ្យាករណ៍ ។ តើពាក្យនេះជាកិរិយាស័ព្ទ ឬនាម ឬ គុណនាម ? កំណត់ពាក្យពិពណ៌នាក្នុងអត្ថបទ<br>• ការបញ្ចេញគំនិតយោបល់ ស្តីអំពីរឿងនិទាន ឬ សៀវភៅដែលបានអាន<br>• ពិគ្រោះយោបល់របស់សិស្ស តើគេអាចដោះស្រាយបញ្ហាក្នុងរឿងនេះ ប្រសិនបើគេប្រឈមមុខនឹងបញ្ហានេះ |

| | |
|---|---|
| | ក្នុងជីវិតជាក់ស្តែងរបស់គេ ?<br>• ឱ្យសិស្សញែក វាជាការពិត ឬ ជាគំនិតយោបល់របស់អ្នកសរសេរអត្ថបទ ។ គ្រូអាចព្យាយាមធ្វើដូចនេះសម្រាប់អត្ថបទទាំងអស់<br>• បំណិនក្នុងការប្រើប្រាស់វចនានុក្រម<br>• ឱ្យក្រុមសិស្សវិភាគកិច្ចការមួយ ហើយនឹងសរសេរសេចក្តីណែនាំសម្រាប់បំពេញកិច្ចការនេះបានត្រឹមត្រូវ ។ ជួយសិស្សគិតអំពីជំហាននីមួយៗ និង សកម្មភាពទាំងអស់សម្រាប់បំពេញកិច្ចការមួយដូចជា ការចំអិនម្ហូបអាហារ សំអាតផ្ទះ ការសរសេរសំបុត្រ . . . ។ ក្នុងសកម្មភាពនេះសិស្សប្រើកិរិយាស័ព្ទជាច្រើនដើម្បីបញ្ជាក់លំអិតលំអានពីសកម្មភាពនីមួយៗ<br>• គ្រូពន្យល់អំពីប្រធានបទក្នុងរឿង ។ ពេលសិស្សអានអត្ថបទ ឬ រឿង សិស្សគួរតែពិភាក្សាអំពី ប្រធានបទចម្បង នៃរឿងនេះ ។ ឧទាហរណ៍ : មនុស្សជួយគ្នាទៅវិញទៅមក មនុស្សឈ្លោះគ្នា មនុស្សប្រឈមមុខទៅនឹង គ្រោះធម្មជាតិ<br>• គ្រូរៀបចំអត្ថបទនៅក្តារខៀន ដោយលុបពាក្យមួយចំនួនចេញឱ្យសិស្សបំពេញឡើងវិញ ក្រោយពីវិភាគខ្លឹមសារ<br>• គ្រូសរសេរអត្ថបទលើក្តារខៀនដែលមានពាក្យខុសអក្ខរាវិរុទ្ធ ឬ ខុសវណ្ណយុត្តិ រួចឱ្យសិស្សកែ ។ |
| សកម្មភាពគិតដោយច្នៃប្រឌិត | • ការបង្កើតពាក្យប្រៀបធៀប និង ពាក្យប្រដូច ។ ឧទាហរណ៍ : ក្រហមដូចឈាម ឃ្លានស្ទើរដាច់ពោះ ភ័យស្ទើរលោះព្រលឹង . . .<br>• ការប្រណាំងរវាងក្រុមនីមួយៗ ដើម្បីរកពាក្យដូច ( សទិសន័យ ) ដោយប្រើចំណេះដឹងដែលមានរួចហើយ ឬ ប្រើវចនានុក្រម |

| | |
|---|---|
| | • បង្ហាញសកម្មភាពក្នុងរឿងនិទាន តាមរយៈឈុតល្ខោន<br>• គំនូររូបភាពបង្ហាញសកម្មភាព ( រឿងនិទានបានអាន )<br>• ជ្រើសរើសប្រធានបទនៃមេរៀនក្នុងសៀវភៅសិក្សា ដូចជា ទឹកជំនន់ ។ ឱ្យសិស្សគិតស្រមៃលើស្ថានភាពដូចនេះនឹងសរសេររឿងនិទានអំពីស្ថានភាពនេះជាក្រុមតូច ។ ឱ្យក្រុមសិស្សមួយសរសេរអំពីទស្សនៈរបស់មនុស្សចាស់ ក្មេង មេភូមិ រដ្ឋអំណាច ជនពិការ . . .<br>• បំផុសគំនិតរៀបចំបញ្ជីគុណនាម ដើម្បីរៀបរាប់អំពីចរិតលក្ខណៈរបស់មនុស្សក្នុងរឿងនិទាន ឱ្យសិស្សមួយចំនួនបង្ហាញសកម្មភាពក្នុងរឿងនិទានតាមរយៈល្ខោនគ ។ ឱ្យសិស្សផ្សេងទៀតទាយអំពីកាយវិចារដែលបានសម្តែង ហើយនឹងអានកថាខ័ណ្ឌក្នុងអត្ថបទដែលត្រូវនឹងសកម្មភាពនេះ ។<br>• សរសេរល្បះងាយៗលើក្តារខៀន ។ ឧទាហរណ៍ : " ខ្ញុំទៅផ្ទះមិត្តខ្ញុំ " ឱ្យសិស្សសរសេរឃ្លាដែលមានខ្លឹមសារ និង ន័យដូចគ្នា ក៏ប៉ុន្តែជាឃ្លាដែលបង្ហាញព័ត៌មានកាន់តែច្បាស់លាស់ ដូចជា : " ខ្ញុំជិះកង់លឿនបំផុតទៅផ្ទះមិត្តជាទីស្រឡាញ់របស់ខ្ញុំ "<br>• ក្រុមសិស្សគូររូបភាពលើក្រដាសបិទលើជញ្ជាំង ដើម្បីបង្ហាញព្រឹត្តិការណ៍ក្នុងរឿងនិទាន<br>• គ្រូអានអត្ថបទខ្លីៗនៃរឿងនិទានឱ្យសិស្សស្តាប់ រួចឱ្យសិស្សគូររូបភាពអំពីអ្វីៗដែលគេអាចនឹកឃើញ<br>• គ្រូអានរឿងនិទានខ្លីៗ ឱ្យសិស្សស្តាប់ រួចឱ្យក្រុមសិស្សនីមួយៗបង្កើតចំណងជើងដែលសមស្របនឹងរឿងនិទាននេះ<br>• គ្រូអានកថាខ័ណ្ឌចុងក្រោយក្នុងរឿងនិទាន ។ ឱ្យក្រុមសិស្សពិភាក្សាជាមួយគ្នា ដោយប្រើរូបារម្មណ៍ដើម្បីរកឱ្យឃើញហេតុផលនៃកថាខណ្ឌខាងមុខ ដែលអាចចេញលទ្ធផលក្នុងកថាខណ្ឌចុងក្រោយ ។ ប្រៀបធៀបចម្លើយរបស់ក្រុមផ្សេងៗ |

| | |
|---|---|
| | • ជ្រើសរើសមនុស្ស កន្លែង ឬ វត្ថុ ដែលសិស្សធ្លាប់ស្គាល់ ។ ឱ្យក្រុមសិស្សនីមួយៗ សរសេរពាក្យច្រើនបំផុតតាមលទ្ធភាពដែលអាចរកបាន ដើម្បីរៀបរាប់អំពីមនុស្ស វត្ថុ ឬ ទីកន្លែងនោះ ។ |
| ការវាយតម្លៃជាដំណាក់ៗ និង កម្រងស្នាដៃសិស្ស | • សិស្សម្នាក់ៗ ដាក់បញ្ចូល " ទម្រង់អានសៀវភៅ " ក្នុងសឺមីរបស់គេ<br>• សិស្សម្នាក់ៗ ដាក់អត្ថបទរឿងនិទានដែលគេបានសរសេរក្នុងសឺមីរបស់គេ<br>• សិស្សដាក់សំណួរ ឬ គំនិតយោបល់របស់គេក្នុងសឺមីក្រុម ។ |
| លំហាត់នៅផ្ទះ និង ការស្រាវជ្រាវក្រៅសាលា | • ការខ្ចីសៀវភៅបណ្ណាល័យអាននៅផ្ទះ<br>• ឱ្យសិស្សបំពេញទម្រង់បែបបទ រាយការណ៍អំពីសៀវភៅដែលគេបានអាន<br>• ក្រុមសិស្សជួបគ្នាក្រៅសាលា ដើម្បីសរសេរសំបុត្រផ្ញើទៅក្រុមសិស្សនៅកម្រងដទៃទៀត ។ |

**ឯកសារទី៦ B: ផែនការថ្នាក់កុមារមេត្រី ( គណិតវិទ្យាថ្នាក់ទី១ ទី២ ទី៥ និង ទី៦)**

| **ថ្នាក់ទី ១ : គណិតវិទ្យា**<br>**មេរៀន : ដកស្រង់ចេញពីទំព័រទី ១-១២**<br>**ខ្លឹមសារ : សញ្ញាណដំបូង ( សៀវភៅ គណិតវិទ្យា ថ្នាក់ទី ១ )** | |
|---|---|
| ការរៀបចំបរិស្ថានក្នុងបន្ទប់រៀន | • កៀនគណិតវិទ្យា : វត្ថុ និង សម្ភារ ដូចជា កែវ ដប ប្រអប់ កំប៉ុង ដែលប្រើសម្រាប់ការពិភាក្សាអំពីខ្លឹមសារផ្សេងៗ ក្នុងផ្ទាំងក្រដាសវាក្យស័ព្ទ<br>• វត្ថុផ្សេងៗមានលក្ខណៈប្រហាក់ប្រហែលគ្នា ដូចជា : រូបរាងធរណីមាត្រ ( រង្វង់ ចតុកោណកែង ការេ . . . ) ពណ៌ ទំហំផ្សេងៗ ដែលប្រើសម្រាប់មេរៀនចំណាត់ថ្នាក់<br>• ផ្ទាំងសម្រាប់បិទរូបភាព ឬ ដាក់សម្ភារ " រូបភាពបង្ហាញពីវត្ថុវែងជាង វត្ថុខ្លីជាង វត្ថុនៅពីលើ ពីក្រោម ពីចំហៀង . . " ចំណាំ : រូបភាពនេះជាស្នាដៃរបស់សិស្ស . . .<br>• ប័ណ្ណពាក្យតូចៗ ដូចជា : វែង ខ្លី លើ ក្រោម ក្រាស់ ស្តើង ខ្ពស់ ទាប ក្នុង ក្រៅ មុខ ក្រោយ ស្តាំ ឆ្វេង មាន គ្មាន ច្រើន តិច ស្មើ វែងជាង ខ្លីជាង . . . ។<br>• ប័ណ្ណពាក្យស្តីពីពាក្យគន្លឹះ សម្រាប់ដាក់ក្នុងធនាគារពាក្យរបស់ក្រុមសិស្សនីមួយៗ ដូចជា តើ មួយណា នៅឯណា មាន គ្មាន . . . ។ |
| សកម្មភាពពង្រីកបន្ថែមក្នុងសៀវភៅសិក្សា | • ឱ្យសិស្សដើរក្នុងទីធ្លាសាលារៀន រួចរកអ្វីមួយដែលបង្ហាញពី : វែងជាង ខ្លីជាង ធ្ងន់ជាង . . . ការពិភាក្សាអំពីវត្ថុផ្សេងៗ ក្នុងកាតាបរបស់សិស្ស . . .<br>• ឱ្យសិស្សរៀបចំបំពង់បឺត ឬ បន្ទាត់ តាមលំដាប់លំដោយពីខ្លីជាងគេ ដល់ វែងជាងគេ . . . |

| | |
|---|---|
| | • គ្រូចែកជូនគំនូរវត្ថុ ឬ វត្ថុជាក់ស្តែងឱ្យសិស្សគូររូបនេះម្តងទៀត ប៉ុន្តែគូរវែងជាង ខ្លីជាង ធំជាង ឬ តូចជាង . . . សកម្មភាពនេះអាចធ្វើជាក្រុមតូច ប្រសិនបើចំនួនសិស្សច្រើនពេក ។ លទ្ធផលនៃសកម្មភាពនេះអាចទុកក្នុងកម្រង ស្នាដៃសិស្ស ឬ បិទលើជញ្ជាំងជារូបភាពបង្ហាញពីវត្ថុវែងជាង ធំជាង . . .<br>• ប្រសិនបើមានសួនកុមារ គ្រូគួរតែបង្រៀនសិស្ស ស្តីពីធ្ងន់ជាង ស្រាលជាង នៅលើដងថ្លឹងសួនកុមារ ។ |
| សកម្មភាពបញ្ច្រាបមុខវិជ្ជាផ្សេងទៀត | • គូរគំនូរ<br>• ការអភិវឌ្ឍពាក្យ និង សមត្ថភាពនិយាយ<br>• អំណាន ។ |
| សកម្មភាពគិតដោយវិភាគ | • លំហាត់ចំណាត់ថ្នាក់វត្ថុ ( ដូចទំព័រទី ១០ )<br>• លំហាត់ផ្គូផ្គង ( ដូចទំព័រទី ១១ ) ។<br>• សំណួរដែលធ្វើឱ្យសិស្សប្រៀបធៀប ( ឧ. វត្ថុមួយណាវែងជាង . . . ដូចលំហាត់ទំព័រទី ១២ )<br><u>ចំណាំ</u> : ឱ្យសិស្ស និង គ្រូ ប្រមូលវត្ថុជាច្រើនក្នុងបរិវេណសាលា ផ្ទះ ដើម្បីឱ្យសិស្សមានឱកាសធ្វើសកម្មភាព ដូចខាងលើ ។ |
| សកម្មភាពគិតដោយច្នៃប្រឌិត | • ការធ្វើផ្ទាំងក្រដាសបិទរូបភាព វត្ថុ (តាំង ): ការប្រើប្រាស់រូបរាងផ្សេងៗ ដូចជា រង្វង់ ការេ ត្រីកោណ . . . ដើម្បីបង្កើតរូបភាពដូចជា : ឆ្កែ មនុស្ស តុ ទូ . . .<br>• ការប្រើរូបារម្មណ៍ : គ្រូបង្ហាញវត្ថុមួយឱ្យសិស្សមើល ។ ឱ្យសិស្សបិទភ្នែកនឹកឃើញពីវត្ថុផ្សេងៗទៀត ដែលជាវត្ថុ វែងជាង ខ្លីជាង ក្រាសជាង . . .។ សិស្សរៀបរាប់អំពីអ្វីដែលគេនឹកឃើញ ។ គ្រូបំផុសសំណួរដើម្បីជួយសិស្ស ក្នុងការពិពណ៌នា ។ ឧទាហរណ៍ : ប្អូនរកឃើញនៅឯណា ? របស់អ្នកណា ? ប្រើសម្រាប់ធ្វើអ្វី ? . . .។ |

| | |
|---|---|
| ការវាយតម្លៃជាដំណាក់ និង កម្រងស្នាដៃសិស្ស | • គ្រូឱ្យសិស្សជ្រើសរើសរូបភាពដែលគេបានគូរ ដើម្បីបញ្ចូលក្នុងកម្រងស្នាដៃរបស់គេ ។ |
| លំហាត់នៅផ្ទះ និង ការស្រាវជ្រាវក្រៅសាលា | • គ្រូឱ្យសិស្សប្រមូលវត្ថុតូចៗ ផ្សេងៗនៅផ្ទះ ។ |

**ថ្នាក់ទី ១ : គណិតវិទ្យា**

**មេរៀន : ដកស្រង់ចេញពីទំព័រទី ១៣ ~ ២០**

**ខ្លឹមសារ : ចំនួន ០ ដល់ ៥ ( សៀវភៅ គណិតវិទ្យា ថ្នាក់ទី ១ )**

| | |
|---|---|
| ការរៀបចំបរិស្ថានក្នុងបន្ទប់រៀន | • កៀនគណិតវិទ្យា ។<br>• ផ្ទាំងរូបភាព វត្ថុ ចំនួនមួយ ចំនួន ពីរ ចំនួន បី ចំនួន បួន ចំនួន ប្រាំ<br>• ផ្ទាំងក្រដាសបង្ហាញពីចំនួនជាលេខ ចំនួនជាអក្សរ ចំនួនតាងវត្ថុសម្រាប់ មួយ ពីរ បី បួន ប្រាំ និង សូន្យ<br>• ប័ណ្ណពាក្យសំខាន់ៗ ដាក់ក្នុងធនាគារពាក្យរបស់ក្រុមសិស្ស គឺ មួយ ពីរ បី បួន ប្រាំ សូន្យ និង ប័ណ្ណចំនួន ។ |
| សកម្មភាពពង្រីកបន្ថែមក្នុងសៀវភៅសិក្សា | • ល្បែងសិក្សា : ការបង្កើតក្រុម " មនុស្សក្រៅក្រុម " ។ គ្រូហៅចំនួន :<br>- សូន្យ ពីរ បី បួន ឬ ប្រាំ<br>- សិស្សរៀបចំជាក្រុមតាមចំនួនដែលគ្រូហៅដោយខ្លួនឯង<br>- ពេលដែលសិស្សយល់ពីខ្លឹមសារល្បែងនេះ គេអាចកំណត់សិស្សម្នាក់ជាអ្នកដឹកនាំល្បែងជំនួសគ្រូ<br>• ការចេញអង្កេតក្រៅថ្នាក់ : ឧ . : " រឿងនិទានស្តីអំពីចំនួនពីរ " គ្រូពន្យល់ថា " ថ្ងៃនេះយើងនឹងដើរក្នុងទីធ្លាសាលារៀនខ្ញុំចង់ឱ្យប្អូនទាំងអស់រើស ថ្មចំនួនពីរ ស្លឹកឈើចំនួនពីរ មែកឈើចំនួនពីរ ស្មៅចំនួនពីរ . . .។ |
| សកម្មភាពបញ្ជ្រាបមុខវិជ្ជាផ្សេងទៀត | • គូរគំនូរ ( មើលសកម្មភាពខាងក្រោម ) |

| | |
|---|---|
| | • ការអភិវឌ្ឍពាក្យ និង សមត្ថភាពនិយាយ<br>• អំណាន<br>• សិក្សាសង្គម ( មើលសកម្មភាពខាងក្រោម ) ។ |
| សកម្មភាពគិតដោយវិភាគ | • ឱ្យសិស្សមើលចំនួនវត្ថុច្រើន ។ គ្រូហៅចំនួន ហើយជ្រើសរើសវត្ថុតាមចំនួនដែលគ្រូហៅ ។ សិស្សអាចធ្វើសកម្មភាពនេះជាក្រុមតូច ដោយមានសិស្សម្នាក់ជាអ្នកហៅ ហើយសិស្សផ្សេងទៀតជាអ្នកជ្រើសរើស ។<br>• ពិនិត្យមើលរូបភាព ហើយរៀបរាប់ពីចំនួនវត្ថុផ្សេងៗ នៅក្នុងរូបភាព ( ឧទាហរណ៍ : ទំព័រទី ២០) គ្រូប្រើរូបភាព ផ្សេងៗ ជាការល្អមួយប្រសិនជាគ្រូអាចប្រើស្នាដៃរបស់សិស្សខ្លួនឯង ។ |
| សកម្មភាពគិតដោយច្នៃប្រឌិត | • បិទផ្ទាំងក្រដាសច្រើនផ្ទាំងលើជញ្ជាំង ។ គ្រូជ្រើសរើសប្រធានបទមួយចេញពីសៀវភៅភាសាខ្មែរ ឬ សិក្សាសង្គមដែលសិស្សកំពុងសិក្សា ។ សិស្សគូររូបតាមប្រធានបទនេះ ។ គ្រូឱ្យសិស្សគូរ ឧទាហរណ៍ : ព្រះអាទិត្យមួយសត្វស្លាបពីរ កុមារី បី នាក់ កុមារា បួន នាក់ ឆ្កែ ប្រាំ ក្បាល ។ |
| ការវាយតម្លៃជាដំណាក់ៗ និង កម្រងស្នាដៃសិស្ស | • សិស្សជ្រើសរើសរូបដែលគេបានគូរ ឬ កិច្ចការផ្សេងតាមសកម្មភាពបានធ្វើរួចមកដាក់បញ្ចូលក្នុងកម្រងស្នាដៃរបស់គេ ។ |
| លំហាត់នៅផ្ទះ និង ការស្រាវជ្រាវក្រៅសាលា | • ឱ្យសិស្សស្រាវជ្រាវវត្ថុ ឬ សត្វដែលមានចំនួន ១ ២ ៣ ៤ ៥ ដោយគូររូបភាព ។ |

**ថ្នាក់ទី២ : គណិតវិទ្យា**

**មេរៀនទី ១ : ដកស្រង់ចេញពីទំព័រទី ១ ដល់ ៩**

**ខ្លឹមសារ : ចំនួន ដល់ ១០០០**

| | |
|---|---|
| ការរៀបចំបរិស្ថានក្នុងបន្ទប់រៀន | • ផ្ទាំងក្រដាស់បង្ហាញឧទាហរណ៍នៃការប្រើប្រាស់ចំនួនដល់ ១០០០ ក្នុងជីវិតជាក់ស្តែង ( ចំនួនគ្រូក្នុងសាលារៀន ចំនួនសិស្សក្នុងថ្នាក់ ចំនួនសិស្សក្នុងសាលា តម្លៃអង្ករ ១ គ.ក តម្លៃអំបិល ១ គ.ក តម្លៃស្ករស ១ គ.ក<br>• ផ្ទាំងក្រដាសដូចទំព័រទី ៤ បង្ហាញអំពីខ្ទង់ ផ្ទាំងក្រដាសបង្ហាញលេខជាអក្សរ ០ ១ ២ ៣ . . . ១០ ២០ ៣០ . . . ១០០ ១០០០<br>• កៀនគណិតវិទ្យា : ផ្ទាំងក្រដាសបង្ហាញអំពីខ្ទង់ វត្ថុតូចៗ ដូចជា : ដុំគ្រួស ដើម្បីជួយបំពេញផ្ទាំងក្រដាស ស្តីអំពី ខ្ទង់បន្ទះរយ បន្ទះដប់ បន្ទះរាយ ជាច្រើនសម្រាប់<br>• ក្រដាសប្រាក់សិប្បនិម្មិត ( ១០០រៀល ២០០រៀល ៥០០រៀល ១០០០រៀល )<br>• ផ្ទាំងក្រដាសបង្ហាញលេខ ខ្មែរ និង លេខ សកល<br>• តារាងធាតុអាកាស តារាងវត្តមាន តារាងថ្លឹងទម្ងន់ តារាងវាស់កម្ពស់ .......។ |
| សកម្មភាពពង្រីកបន្ថែមក្នុងសៀវភៅសិក្សា | • គ្រូចែកប័ណ្ណក្រដាស ស ច្រើនសន្លឹក ក្រុមសិស្សសរសេរលេខ ដែលបង្ហាញចំនួនដល់ ១០០០ ។ ក្រុមសិស្សផ្លាស់ប្តូរ ប័ណ្ណនេះជាមួយក្រុមផ្សេង ។ ក្រុមមួយសរសេរជាលេខ ហើយក្រុមមួយទៀតសរសេរចំនួនជាអក្សរ នៅម្ខាងទៀត ដោយផ្លាស់ប្តូរ និង កែទៅវិញទៅមក ។<br>• ការកត់ត្រាព័ត៌មាន តើមានសិស្សចំនួនប៉ុន្មាននាក់ដែលវត្តមាននៅថ្ងៃនីមួយៗ ក្នុងសប្តាហ៍ ? តើមានសិស្សចំនួនប៉ុន្មាននាក់ដែលអវត្តមាននៅថ្ងៃនីមួយៗ ក្នុងសប្តាហ៍ ? តើមានសិស្សសរុបចំនួនប៉ុន្មាននាក់នៅចុងសប្តាហ៍ ? តើសិស្សម្នាក់ៗ ក្នុងក្រុមមានកម្ពស់ប៉ុន្មាន ? |

| | |
|---|---|
| | ( កត់ត្រាចម្លើយ ជា ស.ម ) ។ |
| សកម្មភាពបញ្ជ្រាបមុខវិជ្ជាផ្សេងទៀត | • ភាសាខ្មែរ ការអភិវឌ្ឍវាក្យស័ព្ទ<br>• សិក្សាសង្គម ( ការបកស្រាយព័ត៌មានអំពីតម្លៃទំនិញ ) ។ |
| សកម្មភាពគិតដោយវិភាគ | • ការវិភាគតម្លៃតាមខ្ទង់ ( ដូចសំណួរទំព័រ ទី៤ )<br>• ការដាក់សញ្ញាត្រឹមត្រូវ ( < , > , = ) រវាងចំនួនពី 0 ដល់ ១000 ដូចលំហាត់នៅក្នុងទំព័រទី៨<br>• ការរៀបចំចំនួនតាមលំដាប់លំដោយពីតូចទៅធំ និង ពី ធំមកតូច ( ចូរមើលទំព័រ ទី ៩ )<br>• ក្រុមសិស្សប្រើបន្ទះរាយ បន្ទះដប់ និង បន្ទះរយ ដើម្បីបង្ហាញលេខដែលគ្រូបាននិយាយរួចមកហើយ ។ ពេលសិស្ស យល់អំពីលំហាត់នេះសិស្សជាអ្នកហៅលេខ<br>• សិស្សអានលេខជាទម្រង់មួយ ( អក្សរ ឬ លេខខ្មែរ ឬ លេខសកល ) ហើយសរសេរលេខឡើងវិញជាទម្រង់ពីរ ផ្សេងទៀត<br>• សិស្សកំណត់ចំនួនវត្ថុដោយប្រាប់ថាចំនួនគូឬចំនួនសេស ដោយប្រើវត្ថុជាក់ស្តែង ដូចការបង្ហាញនៅទំព័រទី ៦ ។ |
| សកម្មភាពគិតដោយច្នៃប្រឌិត | • ការរៀបចំផ្សារប្រឌិត ។ សិស្សមួយចំនួនដើរតួជាម្ចាស់ហាង និង ជាអ្នកលក់ ។ សិស្សផ្សេងទៀតដើរតួជាអ្នកទិញ ។ គ្រូអាចរៀបចំវត្ថុ ឬ សម្ភារដែលមានតម្លៃក្រោម ១000 រៀល ។ គួរតែមានសម្ភារជាច្រើនដើម្បីនាំឱ្យសិស្សមាន ការចាប់អារម្មណ៍ ។ |
| ការវាយតម្លៃជាដំណាក់ៗ និង កម្រងស្នាដៃសិស្ស | • បញ្ចូលលំហាត់ ធ្វើដោយសិស្ស បញ្ជីទំនិញដែលមានតម្លៃក្រោម ១000 រៀល ។ |
| លំហាត់នៅផ្ទះ និង ការស្រាវជ្រាវក្រៅសាលា | • ឪពុកម្តាយ និង បងប្អូន អាចជួយសិស្សរៀបចំបញ្ជីតម្លៃទំនិញនៃវត្ថុ ដែលមានតម្លៃក្រោម ១000 រៀលនៅផ្សារដែលស្ថិតក្នុងភូមិជាក់ស្តែង ។ សិស្សអាចរាយការណ៍ដល់សិស្សផ្សេងទៀតព្រមទាំងគ្រូស្តាប់ ។ គ្រូអាចណែនាំសិស្សឱ្យចេះជជែកគ្នាពីតម្លៃទំនិញជាក់ស្តែង ។ |

| **ថ្នាក់ទី ៥ : គណិតវិទ្យា**<br>**មេរៀនទី ១ : ដកស្រង់ចេញពីទំព័រទី ១ ដល់ ១៣**<br>**ខ្លឹមសារ : ចំនួនលើសពី ១០០០០០០** | |
|---|---|
| ការរៀបចំបរិស្ថានក្នុងបន្ទប់រៀន | • ផ្ទាំងក្រដាសបង្ហាញឧទាហរណ៍ការប្រើប្រាស់ចំនួនលើសពី ១ លាន ក្នុងជីវិតជាក់ស្តែងរបស់យើង ( ចំនួនប្រជាជននៅប្រទេសកម្ពុជា ខេត្តកំពង់ចាម ទីក្រុងភ្នំពេញ ប្រទេសវៀតណាម ប្រទេសថៃ តំលៃម៉ូតូ ចំនួនឆ្នាំកន្លង មកដែលមានសត្វដាយណូស័ររស់នៅ<br>• ផ្ទាំងក្រដាសដូចទំព័រទី ១ ដែលបង្ហាញអំពីខ្ទង់<br>• ផ្ទាំងក្រដាសដែលបង្ហាញរូបភាព " គ្រាប់ក្បាច់ " ដែលមានចំនួនលើសពី ១ លាន<br>• កៀនគណិតវិទ្យា :គ្រាប់ក្បាច់ ផ្ទាំងក្រដាសដែលបង្ហាញអំពីខ្ទង់ វត្ថុតូចៗ ដូចជា ដុំក្រួស ដើម្បីជួយបំពេញផ្ទាំងក្រដាសស្តីអំពីខ្ទង់<br>• ក្រដាសប្រាក់សិប្បនិម្មិត ( ១០០ រៀល ២០០ រៀល ៥០០ រៀល ១០០០ រៀល ៥០០០ រៀល ១០០០០ រៀល ២០០០០ រៀល ៥០០០០ រៀល និង ១០០០០០ រៀល ) សម្រាប់មេរៀននេះ គួរតែមានសន្លឹកក្រដាសប្រាក់ជាច្រើន ។ សិស្សអាចជួយក្នុងការផលិតក្រដាសប្រាក់សិប្បនិម្មិតនេះ<br>• តារាងធាតុអាកាស តារាងវត្តមាន តារាងថ្លឹងទម្ងន់ តារាងវាស់កម្ពស់ . . . ។ |
| សកម្មភាពពង្រីកបន្ថែមក្នុងសៀវភៅសិក្សា | • គ្រូចែកប័ណ្ណក្រដាស ស ច្រើនសន្លឹក ក្រុមសិស្សសរសេរលេខ បង្ហាញចំនួនលើសពី ១ លាន ។ ក្រុមសិស្សផ្លាសប្តូរប័ណ្ណនេះជាមួយក្រុមផ្សេង ។ ក្រុមមួយសរសេរចំនួនជាលេខ ហើយក្រុមមួយទៀតសរសេរចំនួនជាអក្សរនៅម្ខាង ទៀត ដោយផ្លាស់ប្តូរ និង កែទៅវិញទៅមក ។ |

| | |
|---|---|
| | • គ្រូចែកជូនក្រដាសរ៉ាមតូច ដោយចែកជាពីរ ។ ក្រុមសិស្សសរសេរលេខ។ គេផ្លាស់ប្ដូរជាមួយក្រុមសិស្សផ្សេងទៀតក្រុមសិស្សផ្សេងទៀតមើលលេខ ហើយគូរតារាងតាមខ្ទង់តាមគ្រាប់ក្បាច់ ។ មុននឹងគូរតារាងសិស្សអាចបញ្ជាក់ អំពីចំនួនដោយប្រើតារាងលំដាប់ខ្ទង់ និង គ្រាប់ក្រួស ។ម្យ៉ាងទៀតអាចធ្វើសកម្មភាពនេះគ្រាន់តែគូរតារាងមុន ហើយសរសេរលេខជាក្រោយ ។<br>• ការគិតមធ្យមភាគ : ចូរមើលព័ត៌មានលើតារាងអាកាសធាតុ វត្តមាន កម្ពស់ ទម្ងន់ ។ តើចំនួនសិស្សវត្តមានជាមធ្យមក្នុងសប្ដាហ៍មានប៉ុន្មាននាក់ ?តើសប្ដាហ៍មុនអាកាសធាតុជាមធ្យមមានប៉ុន្មានអង្សារ ? តើសិស្សក្នុងក្រុមនេះមានកម្ពស់ជាមធ្យមប៉ុន្មាន ? តើសិស្សក្នុងក្រុមនេះមានទម្ងន់ជាមធ្យមប៉ុន្មាន ? |
| សកម្មភាពបញ្ច្រាបមុខវិជ្ជាផ្សេងទៀត | • ភាសាខ្មែរ ( ការសរសេរពិពណ៌នា )<br>• សិក្សាសង្គម ( ការបកស្រាយព័ត៌មានអំពីអាកាសធាតុ ) ។ |
| សកម្មភាពគិតដោយវិភាគ | • ការវិភាគតំលៃតាមខ្ទង់ ( ដូចសំណួរទី ៤ ក្នុងទំព័រទី ២ ) ។<br>• ការដាក់សញ្ញាត្រឹមត្រូវ (< ; > ; = ) រវាងចំនួនពីរ លើសពី មួយលាន ( អាចប្រើសញ្ញាទាំងនោះជាមួយលេខ និង លេខ លេខជាមួយអក្សរ អក្សរជាមួយអក្សរ )<br>• ការរៀបចំចំនួនតាមលំដាប់លំដោយពីតូចទៅធំ និង ពីធំមកតូច ( ចូរមើលទំព័រទី ៦ )<br>• ការរៀបចំក្រដាសប្រាក់ឱ្យត្រូវទៅនឹងចំនួន មួយលាន ( ឧទាហរណ៍ : ក្រដាស ១០០០០០ រៀល ៩ សន្លឹក និងក្រដាស ១០០០០ រៀល ១០ សន្លឹក ) តើក្រុមសិស្សមួយណាអាចកំណត់វិធីរៀបបានច្រើនជាងគេ ? ។ |
| សកម្មភាពគិតដោយច្នៃប្រឌិត | • គ្រូពន្យល់ និង បង្ហាញ លំហាត់មួយ ឱ្យក្រុមសិស្សបង្កើតចំណោទបន្ថែមទៀតលើក្រដាសខាងឆ្វេង គេសរសេរចំនួនជាលេខលើសពី មួយលាន ( ដប់ចំនួន ) ហើយខាងស្ដាំ គេសរសេរល្បះលេខដែលមានផលបូកស្មើនឹងចំនួននីមួយៗ នៅខាងឆ្វេង ( ឧទាហរណ៍ : ៩០០០០០ + ៥០០០០ + ៥០០០០ ) ។ គេត្រូវតែចៀសវាងកុំឱ្យ |

| | |
|---|---|
| | ចម្លើយនៅ ក្បែរចំនួនដែលត្រូវផ្គូផ្គង ។ សិស្សបង្កើតលំហាត់នេះត្រូវតែធានាថាមានចម្លើយត្រឹមត្រូវពិតប្រាកដ ។<br>• ក្រុមសិស្សផ្លាស់ប្តូរលំហាត់នេះទៅវិញទៅមក ។ តើក្រុមសិស្សមួយណាអាចដោះស្រាយលំហាត់បានមុនគេ<br>• ចូររៀបចំបញ្ជីទំនិញនៅផ្សារដោយចាយលុយស្មើនឹង មួយលានរៀល ។ ចូរបង្ហាញវិធីគិតលេខ ស្តីពីការចំណាយ ចូរសរសេរពិពណ៌នាពីមូលហេតុដែលអ្នកត្រូវការទិញទំនិញនោះ ។<br>តើក្រុមសិស្សមួយណាចំណាយបានលទ្ធផលល្អជាងគេក្នុងការចំណាយអស់មួយលានរៀលនេះ ? ។ |
| ការវាយតម្លៃជាដំណាក់៧ និង កម្រងស្នាដៃសិស្ស | • ដាក់បញ្ចូលរូបភាព គ្រាប់ក្បាច់ ខ្ទង់លេខ ចំណោទបង្កើតដោយក្រុមសិស្ស បញ្ជីទិញទំនិញ ។ |
| លំហាត់នៅផ្ទះ និង ការស្រាវជ្រាវក្រៅសាលា | • ក្រុមសិស្សសហការជាមួយគ្នា ដើម្បីរៀបចំបញ្ជីទិញទំនិញដោយចាយលុយមួយលានរៀល ។<br>សិស្សត្រូវតែស្រាវជ្រាវតម្លៃជាក់ស្តែងនៅទីផ្សារ ។ សិស្សត្រូវតែរួមបញ្ចូលតម្លៃធ្វើដំណើរ តម្លៃដឹកជញ្ជូន<br>• សិស្សបង្ហាញវិធីចាយលុយលើផ្ទាំងក្រដាសធំ ។ តើក្រុមសិស្សមួយណាឆ្លាតជាងគេក្នុងការចាយលុយ ១ លានរៀល ? |

**ថ្នាក់ទី ៦ : គណិតវិទ្យា**

**មេរៀនទី ៣ : ដកស្រង់ចេញពីទំព័រទី ២៤ ~ ៣៣**

**ខ្លឹមសារ : វិធីបូក និង វិធីដក ចំនួនចំរុះ**

| | |
|---|---|
| ការរៀបចំបរិស្ថានក្នុងបន្ទប់រៀន | • បន្ទាត់លេខ ៣ សម្រាប់ បង្ហាញចំនួនលេខ ពី 0 ដល់ ១០ បិទលើជញ្ជាំង ។ មួយសម្រាប់មាន ៤ បន្ទាត់លេខ ( ឯកតា $\frac{1}{2}$ , $\frac{1}{4}$ , $\frac{1}{8}$ ) ។ មួយសម្រាប់ទៀតក៏មាន ៤ បន្ទាត់លេខដែរ ( ឯកតា $\frac{1}{3}$ , $\frac{1}{6}$ , $\frac{1}{9}$ ) ។ ហើយសម្រាប់ទី ៣ មាន ៣ បន្ទាត់លេខ ( ឯកតា $\frac{1}{5}$ , $\frac{1}{10}$ ) |

| | |
|---|---|
| | • ផ្ទាំងក្រដាសដែលបង្ហាញអំពីប្រភាគ ( ពីឯកតា $\frac{1}{2}$ រហូតដល់ $\frac{1}{10}$ )<br>• កៀនគណិតវិទ្យា :ល្បែងសិក្សាដើម្បីពង្រឹងការយល់ដឹងអំពីប្រភាគគួបជាច្រើនសម្រាប់ ល្បែងសិក្សាបង្ហាញនៅទំព័រទី ៣៣ បន្ទាត់ ម៉ែត្រឈើ កែវក្រិត ជញ្ជីងរឺស័រ<br>• ផ្ទាំងក្រដាសបង្ហាញជំហានក្នុងការបូកចំនួនចំរុះដូចដែលមាននៅទំព័រទី ២៤ និង ទី ២៦<br>• ផ្ទាំងក្រដាសដែលបង្ហាញជំហានក្នុងការដកចំនួនចំរុះដូចទំព័រទី ២៨ ដល់ ទី ៣០ ។ |
| សកម្មភាពពង្រីកបន្ថែមក្នុងសៀវភៅសិក្សា | • សិស្សក្រុមតូចរៀបចំផ្ទាំងក្រដាសប្រភាគដោយខ្លួនឯង ដោយប្រើក្រដាសរ៉ាមតូច គូល័រទៀន និង បន្ទាត់ដើម្បីបង្ហាញឯកតា $\frac{1}{2}, \frac{1}{3}...$ អាចបិទលទ្ធផលនៃសកម្មភាពនេះលើជញ្ជាំង<br>• សិស្សក្រុមតូចបង្កើតបន្ទាត់លេខរបស់ខ្លួន រាប់ពី 0 ដល់ ៥<br>• ការវាស់បរិមាត្រក្នុងបន្ទប់រៀន ដោយសរសេរចម្លើយជាប្រភាគនៃម៉ែត្រ ។ អាចធ្វើសកម្មភាពនេះក្នុងការវាស់តុ បង្អួច ឬ ទ្វារ . . . ប្រសិនជាខ្វះ ម៉ែត្រឈើ អាចរៀបចំ បន្ទាត់ម៉ែត្រកដាស ឬ អំពីខ្សែ<br>• ការវាល់ចំណុះនៃកែវ ដប ធុង ផ្សេងៗ ដោយសរសេរចម្លើយជាប្រភាគនៃលីត្រ<br>• ការថ្លឹងទម្ងន់សិស្សសរុបក្នុងក្រុម ដោយសរសេរចម្លើយជាប្រភាគគីឡូក្រាម ។ គួរតែមើលព័ត៌មាននៅតារាងវាស់កម្ពស់ ថ្លឹងទម្ងន់ ដែលបិទលើជញ្ជាំងរួចមកហើយ<br>• ការថ្លឹងទម្ងន់នៃវត្ថុផ្សេងៗ ក្នុងបន្ទប់<br>• ការវាស់កម្ពស់សិស្សជាសរុបក្នុងក្រុម ។ |
| សកម្មភាពបញ្ច្រាបមុខវិជ្ជាផ្សេងទៀត | • គូរគំនូរ និង ហត្ថកម្ម<br>• ការអភិវឌ្ឍភាសា<br>• រួមបញ្ចូលខ្លឹមសារគណិតវិទ្យាផ្សេងៗ ដូចជា បរិមាត្រ ទម្ងន់ និង ចំណុះ ។ |

| | |
|---|---|
| សកម្មភាពគិតដោយវិភាគ | • ល្បែងសិក្សា ស្តីអំពីប្រភាគ ដូចជា ល្បែងសិក្សានៅទំព័រទី ៣៣ ។ |
| សកម្មភាពគិតដោយច្នៃប្រឌិត | • ក្រុមសិស្សបង្កើតចំណោទ ទាក់ទងនឹងជីវភាពជាក់ស្តែង ទាក់ទងនឹងចំនួនចំរុះដូចទំព័រទី ៣២ ។ ក្រុមសិស្សផ្សេងទៀតដោះស្រាយចំណោទនេះ ។ |
| ការវាយតម្លៃជាដំណាក់ៗ និង កម្រងស្នាដៃសិស្ស | • ទម្រង់បែបបទស្រាវជ្រាវនៅផ្ទះ<br>• ទម្រង់បែបបទ ស្រាវជ្រាវនៅបន្ទប់រៀន<br>• ការបង្កើតចំណោទ ។ |
| លំហាត់នៅផ្ទះ និង ការស្រាវជ្រាវក្រៅសាលា | • ការវាស់បរិមាត្រនៃផ្ទះ ( គិតជាប្រភាគនៃម៉ែត្រ )<br>• ការវាស់ចម្ងាយពីផ្ទះរបស់ខ្លួនទៅផ្ទះអ្នកជិតខាង ទៅអណ្តូង ទៅកន្លែងផ្សេងៗទៀត នៅជិតផ្ទះ<br>• ការវាស់ចំណុះនៃវត្ថុផ្សេងៗ នៅផ្ទះ ដូចជា ពាង ធុង . . . ។ គិតជាលីត្រ និង ប្រភាគនៃលីត្រ ។ |

## ឯកសារទី៦ C: ផែនការថ្នាក់កុមារមេត្រី (សិក្សាសង្គមថ្នាក់ទី១ ទី២ ទី៥ និង ទី៦)

<table>
<tr><td colspan="2">ថ្នាក់ទី ១ : សិក្សាសង្គម<br>មេរៀន : ២៥,២៨,៣៤,៣៧,៤៣,៤៦,៤៩,៥៣ ដកស្រង់ចេញពីទំព័រទី ២៧,៣០,៣១,៣៩,៤០,៤៤,៤៥,៥២,៥៣,៥៦,៥៩,៦០,៦៦,៦៧<br>ខ្លឹមសារ : សុខភាព អនាម័យសុវត្ថិភាពផ្ទាល់ខ្លួន</td></tr>
<tr><td>ការរៀបចំបរិស្ថានក្នុងបន្ទប់រៀន</td><td>• ទីធ្លាសាលារៀន : ពាងទឹកស្អាត បន្ទប់ដែលមានអនាម័យ ( ប្រភពទឹក ធ្មិល សាប៊ូ កន្សែង )<br>• បន្ទប់រៀន : កន្លែងដាក់លាក់សម្រាប់វាស់កម្ពស់ និង ថ្លឹងទម្ងន់ (ឧបករណ៍ដើម្បីវាស់កម្ពស់ តារាងបិទលើជញ្ជាំងដែលបង្ហាញឈ្មោះសិស្សនីមួយៗ ហើយឱ្យគេបំពេញកម្ពស់ និង ទម្ងន់របស់គេមួយខែម្ដងៗ នៅលើតារាងខាងលើទៅតាមកាលបរិច្ឆេទដែលបានកំណត់ ( មិនបង្ខំ គ្រូឱ្យជួយសិស្សបំពេញតារាងតាមលក្ខណៈក្រៅផ្លូវការ )<br>• ការផ្ដល់ទឹកស្អាតសម្រាប់កុមារ<br>• ការផ្ដល់សាប៊ូ កន្សែង និង ច្រាសដុសធ្មេញ<br>• ផ្ទាំងក្រដាសដែលបង្ហាញពាក្យសំខាន់ៗ ទាក់ទងនឹងអនាម័យ ដូចជា : លាង សំអាត បោស សុខភាព ច្រាស សាប៊ូ កន្សែង សំរាម . . .<br>• វេនសំអាតបន្ទប់រៀន ( ថ្ងៃដែលបានកំណត់ ហើយនិងឈ្មោះសិស្សដែលជួយសំអាតបន្ទប់រៀនរៀងរាល់ថ្ងៃដូចជាប្រមូលសំរាម )<br>• ការផ្ដល់ធុងសំរាមសម្រាប់បន្ទប់រៀន<br>• រូបភាពមូសខាំ គ្រុនចាញ់ គ្រុនឈាម មុង . . .<br>• បញ្ជីពាក្យសំខាន់ៗទាក់ទងនឹងម្ហូបល្អ ព្រមទាំងរូបភាព បើមាន</td></tr>
</table>

| | |
|---|---|
| | • រូបភាព និង ឈ្មោះ សត្វ និង រុក្ខជាតិ ដែលត្រូវប្រយ័ត្ន<br>• សញ្ញាចរាចរ ។ |
| សកម្មភាពពង្រីកបន្ថែមក្នុងសៀវភៅសិក្សា | • ការបង្ហាញអំពីវិធីដុសធ្មេញយ៉ាងត្រឹមត្រូវ<br>• ការបង្ហាញពីវិធីថែរក្សាអនាម័យក្នុងបង្គន់ដើម្បីឱ្យមនុស្សដទៃទៀតអាចប្រើបានដែរ<br>• ការបង្ហាញវិធីថែទាំពាងទឹក និង អណ្តូងទឹក ឱ្យមានអនាម័យ និង កុំឱ្យមានមូស<br>• " ដំណើរចេញស្រាវជ្រាវ " ក្នុងទីធ្លាសាលារៀន ដើម្បីឱ្យកុមារស្គាល់កន្លែង និង វត្ថុដែលត្រូវប្រយ័ត្ន ។ |
| សកម្មភាពបញ្ជ្រាបមុខវិជ្ជាផ្សេងទៀត | • ការបង្កើតបរិស្ថានដើម្បីទាក់ទាញអារម្មណ៍សិស្សឱ្យចង់អាន និង សរសេរ ( ចំណាំ : ការបង្ហាញពាក្យជាច្រើនក្នុងបន្ទប់រៀនមានសារសំខាន់ ទោះបីជាកុមារថ្នាក់ទី១ មិនចេះអានពាក្យទាំងអស់ភ្លាមៗ ។ គ្រូនាំសិស្សមើល និងអាន ពាក្យជាក់ស្តែងដែលបានបិទលើជញ្ជាំង គ្រូបង្រៀនព្យញ្ជនៈ ឬ ស្រៈមួយ ។ ការបិទពាក្យលើជញ្ជាំង ដែលមានទំនាក់ ទំនងជាមួយជីវិតរបស់កុមារធ្វើឱ្យគេកាន់តែចាប់អារម្មណ៍ចំពោះអំណាន និងធ្វើឱ្យមានឱកាសប្រើសមត្ថភាពអានក្នុង ជីវិតជាក់ស្តែងរបស់គេ ។ គ្រូបង្រៀនពាក្យសំខាន់ៗ មួយចំនួនដែលហៅថា " ឃើញភ្លាមចេះអាន " ដូចជា : សាលា រៀន បន្ទប់ ខ្ញុំ ដើរ . . .។ )<br>• ការអភិវឌ្ឍសមត្ថភាពនិយាយ<br>• គូរគំនូរ ។ |
| សកម្មភាពគិតដោយវិភាគ | • មើលបញ្ជីរុក្ខជាតិមួយចំនួនរួចជ្រើសរើសរុក្ខជាតិដែលអាចញ៉ាំកើត និងរុក្ខជាតិដែលញ៉ាំមិនកើត ( រៀបចំបញ្ជីខ្លីប្រហែល ៣ ៤ ឬ ៥ មុខ ប្រសិនជាមានរូបភាព ) ។ មើលបញ្ជីសត្វមួយចំនួន ឱ្យសិស្សជ្រើសរើសសត្វណាមួយដែលគេយល់ថា ជាសត្វដែលត្រូវប្រយ័ត្នច្រើនជាងគេ (ឧ. សត្វរុយ សត្វមូស ពីងពាង )ឱ្យសិស្សពន្យល់មូលហេតុដែលគេបានជ្រើសរើសសត្វនេះ |

| | |
|---|---|
| | • ឱ្យក្រុមសិស្សរៀបចំខ្លួនដើម្បីឈរតាមលំដាប់លំដោយពីតូចទៅធំ ( តំរង់ជួរ )<br>• ដោយមើលប័ណ្ណពាក្យមួយចំនួនឱ្យសិស្សជ្រើសរើសពាក្យណាខ្លះដែលទាក់ទងនឹងម្ហូបអាហារ និង សត្វ<br>ចំណាំ : សម្រាប់សកម្មភាពនេះ គ្រូប្រើពាក្យដែលមានស្រាប់ក្នុងធនាគារពាក្យរបស់ក្រុមនីមួយៗ ។<br>• ពិគ្រោះយោបល់របស់សិស្សក្នុងការកំណត់បទបញ្ជាអំពីអាកប្បកិរិយាក្នុងទីធ្លាសាលារៀនដើម្បីទប់ស្កាត់គ្រោះថ្នាក់ ។<br>គ្រូសរសេរគំនិតយោបល់របស់សិស្សលើផ្ទាំងក្រដាសធំបិទលើជញ្ជាំង ។ |
| សកម្មភាពគិតដោយច្នៃប្រឌិត | • សិស្សគូររូបភាពដែលបង្ហាញអំពីស្ថានភាពដែលត្រូវប្រយ័ត្ន ឬ ដែលមានគ្រោះថ្នាក់<br>• ការពិភាក្សាពីរូបភាពដែលជាស្នាដៃរបស់សិស្ស ។ គ្រូបំផុសសំណួរ ដើម្បីនាំឱ្យសិស្សពិចារណាពីអ្វីដែលគេធ្វើបាន<br>ដើម្បីចៀសវាងគ្រោះថ្នាក់ ឬ ដោះស្រាយបញ្ហាក្នុងស្ថានភាពដែលគេស្រមៃ<br>• ត្រាប់តាម ដុសធ្មេញ លាងដៃ បោកខោអាវ គ្រោះថ្នាក់ចរាចរ ទះមូស . . . ។ គ្រូ ឬ សិស្ស ធ្វើត្រាប់<br>ហើយសិស្សផ្សេងទៀតទាយ ។ |
| ការវាយតម្លៃជាដំណាក់ៗ និង កម្រងស្នាដៃសិស្ស | • រូបភាពដែលបានគូរយកទៅដាក់ក្នុងសឺមីផ្ទាល់ខ្លួន ។ |
| លំហាត់នៅផ្ទះ និង ការស្រាវជ្រាវក្រៅសាលា | • គ្រូឆ្លៀតឱកាសខ្លះពិនិត្យអំពីអនាម័យសិស្សមុនពេលបង្រៀន ។ |

| **ថ្នាក់ទី ២ : សិក្សាសង្គម**<br>**មេរៀន : ១ ៤ ៨ ១១ ១៥ ដកស្រង់ចេញពីទំព័រ ទី ១ ៤ ៥ ៩ ១០ ១៣ ១៤ ១៨**<br>**ខ្លឹមសារ : ចេះគួរសម ចេះជួយគ្នា ចេះគោរពគ្នា សុជីវធម៌ ប្រពៃណីសង្គម** | |
|---|---|
| ការរៀបចំបរិស្ថានក្នុងបន្ទប់រៀន | • គ្រូសរសេរឃ្លាដែលបង្ហាញអំពីការគួរសម លើប័ណ្ណពាក្យ ឬ ប័ណ្ណឃ្លា បិទលើជញ្ជាំង ( ពាក្យមានដូចជា : អរគុណ សុំទោស ជំរាបសួរ បាទ ចាំស )<br>• គ្រូរៀបចំប័ណ្ណឃ្លា ដែលបង្ហាញអំពីពាក្យគួរសមជាមួយព្រះសង្ឃដូចជា : ប្រគេន ថ្វាយបង្គំ តេជគុណ . . .<br>• គ្រូសរសេរមេសូត្រមានក្នុងទំព័រទី៤ លើប័ណ្ណក្រដាស់បិទលើជញ្ជាំង<br>• គ្រូរៀបចំទីសក្ការៈសាសនា ក្នុងបន្ទប់រៀន ( មានរូបព្រះពុទ្ធ ផ្កា ទៀន ធូប ) ។ |
| សកម្មភាពពង្រីកបន្ថែមក្នុងសៀវភៅសិក្សា | • សិស្សសួរសំណួរគ្នាទៅវិញទៅមក ហើយសួរគ្រូអំពីរូបភាពក្នុងសៀវភៅសិក្សា<br>• គ្រូជាអ្នកហៅពាក្យមួយ និង ឱ្យសិស្សផ្តល់គំនិតពេលដែលសិស្សស្តាប់ពាក្យនេះ ។ គ្រូហៅពាក្យនេះមួយម្តងៗ ហើយ សរសេរចម្លើយលើក្តារខៀន ។ គ្រូត្រូវតែសរសេរចម្លើយទាំងអស់ និង សង្កត់ធ្ងន់ទៅលើគំនិតស្តីអំពីការគោរពមនុស្ស និង ការចេះគួរសម ។ ( ពាក្យដូចជា : ឪពុកម្តាយ ព្រះសង្ឃ បងប្អូន . . .)<br>• គ្រូសួរសិស្សអំពីមធ្យោបាយដែលគេអាចជួយសិស្សថ្មីក្នុងសាលាជាពិសេសសិស្សថ្នាក់ទី១ ទើបតែចូលរៀនតើ អាកប្បកិរិយា យ៉ាងដូចម្តេចដែលគួរសម ?<br>• គ្រូគួរតែសរសើរ និង ផ្សព្វផ្សាយ អំពីអាកប្បកិរិយាល្អ និង លើកជាគំរូសម្រាប់សិស្សទាំងអស់<br>• ឱ្យសិស្សបំផុសគំនិតជាក្រុមតូច ស្តីអំពីប្រធានបទដូចជា " មធ្យោបាយជួយឪពុកម្តាយនៅផ្ទះ " និង "មធ្យោបាយជួយ គ្រូនៅសាលារៀន " ។ សិស្សសរសេរគំនិតងាយៗ នៅលើក្រដាស<br>• គ្រូគួរតែជំរុញឱ្យសិស្សព្យាយាមសរសេរ ប្រកបពាក្យពិបាកៗ ទោះបីជាការព្យាយាមរបស់សិស្សមិនត្រឹមត្រូវ |

| | |
|---|---|
| | ក៏ដោយ ។ ( អ្វីដែលសំខាន់ក្នុងមេរៀនសិក្សាសង្គម គឺ គ្រូត្រូវផ្តល់ឱកាសឱ្យសិស្សបញ្ចេញគំនិតរបស់ខ្លួន )<br>• និមន្តព្រះសង្ឃពីវត្តនៅជិតសាលារៀនឱ្យជួយពន្យល់សិស្សអំពីអាកប្បកិរិយា និង សកម្មភាពសមស្របពេលដែលសិស្ស ចូលវត្ត ។ និមន្តឱ្យព្រះសង្ឃប្រើភាសាងាយៗដល់សិស្ស ។ វាជាការល្អមួយ បើគ្រូជូនសិស្សទៅទស្សនកិច្ចជាក់ស្តែង ប្រសិនបើមានវត្តនៅជិតសាលារៀន<br>• គ្រូនិទានរឿងដើម្បីពង្រឹងការយល់ដឹងផ្នែកសីលធម៌ដល់សិស្ស ( ឧ-រឿងកូនទន្សាយមិនស្តាប់មេ )<br>• បង្ហាញអំពីអាកប្បកិរិយាល្អចំពោះបរិស្ថាន ។ ឱ្យសិស្សដាក់សំរាមក្នុងធុងសំរាម ។ ប្រសិនបើមិនមានធុងសំរាម ឱ្យសិស្ស កាន់សំរាមរហូតដល់កន្លែងទុកសំរាម ។ ឱ្យសិស្សពិចារណាអំពីការថែរក្សាអនាម័យក្នុងកន្លែងសាធារណៈសម្រាប់ផ្តល់ ប្រយោជន៍ល្អដល់មនុស្សផ្សេងទៀត ។ ពេលជិតចេញទៅផ្ទះគ្រូគួរឱ្យសិស្សសំអាតបន្ទប់រៀនការថែទាំ និង ស្រោចទឹក ដល់រុក្ខជាតិក្នុងបន្ទប់រៀន ឬ ទីធ្លាសាលារៀន ។ |
| សកម្មភាពបញ្ច្រាបមុខវិជ្ជាផ្សេងទៀត | • ភាសាខ្មែរការអភិវឌ្ឍវាក្យស័ព្ទ<br>• ការគូរគំនូរ<br>• បណ្ណាល័យ : រឿងនិទាន . . .<br>• សុខភាព និង អនាម័យ<br>• ការថែទាំបរិស្ថាន ។ |
| សកម្មភាពគិតដោយវិភាគ | • គ្រូណែនាំការពិភាក្សាអំពីករណី "ប្រសិនបើ . . ." ឧ- តើមានអ្វីកើតឡើងប្រសិនបើមានមនុស្សចេះគួរសម និងចេះរាប់ អានគ្នាទៅវិញទៅមក ? តើមានអ្វីកើតឡើងប្រសិនបើយើងមិនចេះគួរសមចំពោះមនុស្សចាស់ ? តើមានអ្វីកើតឡើង ប្រសិនបើប្រទេសកម្ពុជាមិនមានព្រះសង្ឃ ? តើមានអ្វីកើតឡើងប្រសិនបើមនុស្សមិន ចេះគោរពព្រះសង្ឃ ? តើមានអ្វី កើតឡើងពេលសិស្សមួយចំនួន មិនគោរពវិន័យ និងបទបញ្ជាផ្ទៃក្នុងរបស់សាលា |

| | |
|---|---|
| | រៀន? ។ តើមានអ្វីកើតឡើងប្រសិនបើ មនុស្សមិនគោរពច្បាប់ចរាចរ និង មិនគិតអំពីមនុស្សផ្សេងៗទៀតដែលកំពុងធ្វើដំណើរតាមផ្លូវដូចគ្នា ?<br>• គ្រូពិគ្រោះយោបល់សិស្ស " តើយើងអាចមានបទបញ្ជាអ្វីខ្លះក្នុងបន្ទប់រៀនរបស់យើង ដើម្បីផលប្រយោជន៍យើង |
| សកម្មភាពគិតដោយច្នៃប្រឌិត | • សិស្សគូររូបភាពបង្ហាញអំពីស្ថានភាពដែលគេអាចប្រើពាក្យ ឬ ឃ្លាគួរសម ។ អាចសរសេរពាក្យ ឬ ឃ្លានេះលើរូបភាព<br>• រៀបចំឈុតបង្ហាញពីសកម្មភាពគួរសមដោយសិស្សដើរតួ ឪពុក ម្តាយ មនុស្សចាស់ ព្រះសង្ឃ និង ភ្ញៀវ រៀបចំឈុត ឬ ល្ខោន អោយសិស្សដើរតួជាមនុស្សឈ្លើយ ។ ពិភាក្សាជាមួយសិស្សតើគេមានអារម្មណ៍យ៉ាងណាដែរពេលដែលមនុស្សនេះមិនចេះគួរសម ?<br>• ពិភាក្សាជាមួយសិស្សតើគេធ្វើដូចម្តេចពេលគេជួបប្រទះជាមួយមនុស្សឈ្លើយ ?តើគេអាចរកដំណោះស្រាយគួរសមរបៀបណាជាមួយមនុស្សឈ្លើយបែបនេះ ?<br>• គូររូបភាពអំពីស្ថានភាពដែលមនុស្សបង្ហាញពីអាកប្បកិរិយាគួរសម ( ដូចជាការគោរពព្រះសង្ឃនៅវត្ត ឬនៅផ្ទះជាមួយ ឪពុកម្តាយ ឬ នៅសាលារៀន<br>• តែងឃ្លាជុំវិញពាក្យសំខាន់ៗដែលដកស្រង់ចេញពីសៀវភៅសិក្សាដូចជា ឪពុកម្តាយ គោរព គួរសម ព្រះសង្ឃ ។ល។ សិស្សតែងឃ្លាជាភាសានិយាយ ឬ សរសេរប្រសិនបើអាចធ្វើបាន ។ |
| ការវាយតម្លៃជាដំណាក់ៗ និង កម្រងស្នាដៃសិស្ស | • ការបញ្ចូលរូបភាព ឬ គំនិតយោបល់របស់សិស្សក្នុងសឺមី ។ |
| លំហាត់នៅផ្ទះ និង ការស្រាវជ្រាវក្រៅសាលា ។ | • ឱ្យសិស្សពិចារណា អំពីរបៀបដែលគេអាចជួយអ្នកជិតខាង ឬ អ្នកណាម្នាក់ក្នុងផ្ទះពេលគេត្រឡប់ទៅផ្ទះវិញ ថ្ងៃបន្ទាប់ឱ្យសិស្សម្នាក់រាយការណ៍ពីអ្វីដែលគេបានធ្វើ ។ ឱ្យសិស្សបញ្ចេញយោបល់រៀបរាប់អំពីអារម្មណ៍របស់គេពេលដែលគេបានជួយ ។ ម្យ៉ាងទៀតឱ្យសិស្សរៀបរាប់អំពីអារម្មណ៍របស់មនុស្សដែលគេត្រូវបានជួយនោះ ។ |

| **ថ្នាក់ទី ៥ : សិក្សាសង្គម**<br>**មេរៀនទី ២ ៥ ៨ ១១ ២០ ៥២ ដកស្រង់ចេញពីទំព័រទី ២ ៣ ៦ ៩ ១០ ១៣ ២៣ ២៤ ៦៤**<br>**ខ្លឹមសារ : ពិភពខាងក្រៅកម្ពុជា** | |
|---|---|
| ការរៀបចំបរិស្ថានក្នុងបន្ទប់រៀន | • បិទផែនទីតូចៗ នៃពិភពលោកលើតុរបស់ក្រុមសិស្សនីមួយៗ<br>• បិទផែនទីធំពិភពលោកលើជញ្ជាំង<br>• ប័ណ្ណអក្សរដែលបង្ហាញឈ្មោះនៃទ្វីបនីមួយៗ<br>• ប័ណ្ណអក្សរដែលបង្ហាញឈ្មោះប្រទេសនៅសមាគមអាស៊ាន និង រដ្ឋធានីរបស់គេ<br>• ប័ណ្ណអក្សរដែលបង្ហាញឈ្មោះប្រទេសផ្សេងៗ ដែលមានទំនាក់ទំនងខ្លាំងជាមួយប្រទេសកម្ពុជា ដូចជា បារាំង សហរដ្ឋអាមេរិក អង់គ្លេស អូស្ត្រាលី ជប៉ុន និង រាជធានី រដ្ឋធានីរបស់គេ ។<br>• កៀនភូមិវិទ្យា : មានរូបភាពដកស្រង់ចេញពីសារព័ត៌មានបង្ហាញពីប្រទេសផ្សេងៗ រូបិយវត្ថុ ពីប្រទេសផ្សេងៗ តែម ( Timbre ) ពីប្រទេសផ្សេងៗ ស្លាក និង កញ្ចប់ទំនិញផ្សេងៗ<br>• ក្តារខៀនជូនព័ត៌មានអន្តរជាតិ : សិស្សអាចសរសេរឃ្លាងាយៗ អំពីទស្សនកិច្ចរបស់ភ្ញៀវបរទេសសំខាន់ៗ នៅកម្ពុជា និង ទស្សនកិច្ចរបស់មន្ត្រីកម្ពុជានៅក្រៅប្រទេសអាចសរសេរឈ្មោះសិស្សដែលជាអ្នករាយការណ៍ព័ត៌មាននេះ<br>• ផ្ទាំងក្រដាសដែលបង្ហាញពាក្យថ្មីដែលទាក់ទងនឹងភូមិវិទ្យា ដូចជា : អេក្វាទ័រ អឌ្ឍគោល ខ្សែស្រប ខ្សែបណ្តោយ រយៈទទឹង រយៈបណ្តោយ . . .<br>• ផ្ទាំងក្រដាសដែលជាបញ្ជីពាក្យមហាសមុទ្រ និង សមុទ្រសំខាន់ៗ |

| | |
|---|---|
| | • ផ្ទាំងក្រដាសដែលបង្ហាញពាក្យថ្មីៗ ទាក់ទងនឹងអាកាសធាតុ ដូចជា ត្រូពិច មូសុង . . .<br>• ពាក្យប្រចាំថ្ងៃ ( ជ្រើសរើសពាក្យក្នុងវចនានុក្រម ឬ បច្ចេកទេស ឬ វប្បធម៌ )<br>• សំណួរប្រចាំសប្តាហ៍គ្រូអាចដាក់សំណួរឱ្យសិស្សរកចម្លើយក្នុងបណ្ណាល័យដោយមើលសៀវភៅឬរូបភាពសិក្សាដែលមាន ។ |
| សកម្មភាពពង្រីកបន្ថែមក្នុងសៀវភៅសិក្សា | • គ្រូសួរសិស្សរាល់ថ្ងៃ តើគេមានព័ត៌មានអន្តរជាតិឬទេ ? សិស្សមានព័ត៌មាននេះ សរសេរលើក្តារខៀនជូនព័ត៌មាន សិស្សផ្សេងទៀតអាចរកឃើញទីតាំង គ្រូបំផុសសំណួរ ដូចជា តើប្រទេសនេះស្ថិតនៅទ្វីបមួយណា ?តើរដ្ឋធានី-រាជធានី ប្រទេសនេះឈ្មោះអ្វី ? តើប្អូនធ្លាប់ដឹងព័ត៌មានផ្សេងៗ ទៀតពីប្រទេសនេះដែរឬទេ ? . . ។ |
| សកម្មភាពបញ្ជ្រាបមុខវិជ្ជាផ្សេងទៀត | • ការអភិវឌ្ឍសមត្ថភាពក្នុងការអាន ការសរសេរ និង ស្រាវជ្រាវ<br>• គណិតវិទ្យា ( ការយល់ដឹងអំពី ផ្ទៃក្រលា មាត្រដ្ឋាន . . . ) ។ |
| សកម្មភាពគិតដោយវិភាគ | • ក្រុមសិស្សមួយបង្កើតសំណួរ ស្តីអំពីអត្ថបទក្នុងសៀវភៅសិក្សាឱ្យសិស្សផ្សេងទៀតឆ្លើយ<br>• សិស្សជ្រើសរើសប័ណ្ណពាក្យសំខាន់ៗ ដើម្បីរៀបរាប់អំពីប្រទេសមួយក្រៅពីគ្រូបង្ហាញប្រទេសនេះលើផែនទីពិភពលោក( ពាក្យទាក់ទងនឹងអាកាសធាតុ ប្រទេសជិតខាង ចម្ងាយពីសមុទ្រ ទំហំ ពូជសាសន៍ កំណត់ខ្សែស្រប និង ខ្សែទទឹងរបស់ទីតាំងប្រទេស ការកំណត់ទីតាំងទៅនឹងប្រទេសកម្ពុជា . . . )<br>• ធ្វើដំណើរពីប្រទេសមួយទៅប្រទេសមួយទៀត : ក្នុងការធ្វើដំណើរនេះ តើអ្នកធ្វើដំណើរឆ្លងកាត់ប្រទេសណាខ្លះ ? តើយើងអាចធ្វើដំណើរតាមផ្លូវគោក ផ្លូវទឹក និង ផ្លូវអាកាស បានដែរឬទេ ? |
| សកម្មភាពគិតដោយច្នៃប្រឌិត | • ឱ្យសិស្សគិតស្រមៃអំពីការរស់នៅប្រទេសផ្សេងទៀត ដូចជា : ប្រទេសត្រជាក់ខ្លាំង ។ បំផុសគំនិតរបស់គេទាក់ទងនឹងអារម្មណ៍របស់គេ និង សកម្មភាពប្រចាំថ្ងៃក្នុងប្រទេសនោះ ។ ឧទាហរណ៍ : |

| | |
|---|---|
| | ម្ហូបអាហារ ផ្ទះ សត្វ ដែលអាចមាន . . .<br>• គិតស្រមៃថា អ្នកបានធ្វើដំណើរទៅបរទេស តើប្អូនៗ អាចជួបប្រទះនឹងបញ្ហាអ្វីខ្លះ ? តើប្អូនៗ អាចដោះស្រាយបញ្ហានេះយ៉ាងដូចម្ដេច ?<br>• បង្ហាញរូបភាព ស្ដីអំពីប្រទេសផ្សេងៗ ។ ឱ្យសិស្សបង្កើតសំណួរជាច្រើនអំពីរូបភាពនេះ ។ ឱ្យសិស្សផ្សេងទៀតប្រើចំណេះដឹង ឬ រូបារម្មណ៍ ដើម្បីឆ្លើយសំណួរនេះ ។ |
| ការវាយតម្លៃជាដំណាក់ៗ និង កម្រងស្នាដៃសិស្ស | • ដាក់ស្នាដៃរបស់សិស្ស ស្ដីអំពីសំណួរដែលគេបានបង្កើត ឬ ព័ត៌មានដែលគេបានរាយការណ៍ ឬ ស្លាកទំនិញដែលគេបានប្រមូលក្នុងសឺមីសិស្ស ។ សិស្សគួរតែរៀបរាប់ខ្លីៗ អំពីស្លាកទំនិញដែលបាន ប្រមូល : ប្រភេទទំនិញ ប្រភពទំនិញតម្លៃទំនិញ វិធីនាំចូល ឈ្មោះក្រុមហ៊ុនយ៉ាងដូចម្ដេច ?...។ |
| លំហាត់នៅផ្ទះ និង ការស្រាវជ្រាវក្រៅសាលា | • សិស្សសួរឪពុកម្ដាយ អំពីព័ត៌មានដែលគេបានស្ដាប់តាមវិទ្យុ ឬ មើលតាមទូរទស្សន៍ សារព័ត៌មាន សិស្សរាយការណ៍ព័ត៌មាន ដោយប្រើឃ្លាងាយៗ ។<br>• ប្រមូលស្លាកទំនិញ កញ្ចប់ទំនិញ ដែលនាំចូលពីបរទេស ។ |

| **ថ្នាក់ទី ៦ : សិក្សាសង្គម**<br>**មេរៀនទី ២ ៥ ៦ ១១ ២០ ២៦ ដកស្រង់ចេញពីទំព័រទី ៤ ៥ ៩ ១០ ១១ ២១ ២២ ៣៥ ៣៦ ៤៧ ៤៨ ៤៩**<br>**ខ្លឹមសារ : ភូមិវិទ្យានៃប្រទេសកម្ពុជា** | |
|---|---|
| ការរៀបចំបរិស្ថានក្នុងបន្ទប់រៀន | • បិទផែនទីធំ ប្រទេសកម្ពុជាលើជញ្ជាំង និង ផែនទីតូចលើតុសិស្ស<br>• ឈ្មោះខេត្ត ក្រុង ទាំងអស់ សរសេរលើប័ណ្ណពាក្យ<br>• ឈ្មោះភ្នំ ទន្លេ និង ស្ទឹងសំខាន់ៗ លើប័ណ្ណពាក្យ<br>• ឈ្មោះក្រុមជនជាតិភាគតិចលើប័ណ្ណពាក្យ<br>• បិទផែនទីខេត្ត លើជញ្ជាំងដែលបង្ហាញទីតាំង និង ឈ្មោះស្រុកទាំងអស់<br>• ឱ្យសិស្សបំពេញតារាងព័ត៌មានអំពីធាតុអាកាសបិទលើជញ្ជាំង ( សីតុណ្ហភាព កម្រិតភ្លៀងដែលបានធ្លាក់ ហើយនិងទិសនៃខ្យល់ )។ រៀបចំដបមានក្រិតចំណុះទឹកភ្លៀងដែលបានធ្លាក់ ( ដាក់ក្នុងទីធ្លា ) រៀបចំសញ្ញាព្រួញដឹងទិសនៃខ្យល់ រៀបចំទែម៉ូម៉ែត្រ បិទលើជញ្ជាំងក្នុងបន្ទប់រៀន<br>• ក្តារខៀនជូនព័ត៌មាន ជាតិ និង អន្តរជាតិ<br>• បង្ហាញវត្ថុពិសេសគួរឱ្យចាប់អារម្មណ៍ វត្ថុអាចមកពីតំបន់ផ្សេងៗនៅកម្ពុជា ដាក់ឈ្មោះតំបន់ ដាក់ឈ្មោះសិស្ស ដែលបានរក ដោយសរសេរដាក់លើតុ<br>• ដាក់ប័ណ្ណពាក្យលើជញ្ជាំងក្នុងបន្ទប់រៀនដើម្បីបង្ហាញទិសផ្សេងៗ (ខាងជើង ខាងកើត ខាងត្បូងនិងខាងលិច)<br>• ប័ណ្ណពាក្យដែលបង្ហាញទំនិញ ម្ហូប និង ផលិតផលឧស្សាហកម្មផ្សេងៗរបស់ប្រទេសកម្ពុជា<br>• សំណួរប្រចាំសប្តាហ៍<br>• ផ្ទាំងក្រដាសបង្ហាញអំពីរចនាសម្ព័ន្ធនយោបាយ និងរដ្ឋបាលក្នុងប្រទេសកម្ពុជា ( ព្រឹទ្ធសភា រដ្ឋសភា |

| | |
|---|---|
| | រាជរដ្ឋាភិបាល ក្រុមប្រឹក្សាឃុំ តុលាការ ) ។ |
| សកម្មភាពពង្រីកបន្ថែមក្នុងសៀវភៅសិក្សា | • សិស្សគូរផែនទីនៃភូមិ ឬ ឃុំរបស់ខ្លួន ។ ផែនទីនេះអាចបង្ហាញចំណុចសំខាន់ៗ ដូចជា ផ្លូវ ភ្នំ ស្ទឹង រោងចក្រតូច សាលារៀន វត្ត . . . ។ ( គេធ្វើនៅពេលទំនេរពី ២ ទៅ ៥ នាទី ជារៀងរាល់ថ្ងៃ )<br>• រៀបចំកាលវិភាគ ដើម្បីឱ្យសិស្សទាំងអស់បំពេញព័ត៌មានអំពីធាតុអាកាសទៅតាមវេនរបស់គេ<br>• ក្ដារខៀនជូនព័ត៌មានជាតិ : សិស្សអាចសរសេរឃ្លាងាយៗ អំពីឧបទ្ទវហេតុដែលកើតមាននៅតំបន់ផ្សេង ៗ ក្នុងប្រទេសកម្ពុជា គួរតែដាក់ឈ្មោះសិស្សដែលជាអ្នករាយការណ៍ ។ ពេលមានព័ត៌មានថ្មី គ្រូគួរតែណែនាំសិស្សមើល ផែនទីខេត្ត ផែនទីប្រទេសកម្ពុជា ដើម្បីរកឃើញតំបន់ក្នុងរបាយការណ៍<br>• ស្រាវជ្រាវក្នុងបណ្ណាល័យ ដើម្បីឆ្លើយសំណួរប្រចាំសប្ដាហ៍<br>• ក្រុមសិស្សគូរផែនទីប្រទេសកម្ពុជាដោយខ្លួនឯង ។ ក្រុមផ្សេងៗ អាចយកប្រធានបទផ្សេងៗ ។ ឧទាហរណ៍ ក្រុមមួយរៀបចំផែនទីនយោបាយ ក្រុមមួយទៀត រៀបចំផែនទីដែលរៀនពី ស្ទឹង ភ្នំ ទន្លេ . . . ( សកម្មភាពនេះធ្វើបន្តិចម្ដងៗ ជារៀងរាល់ថ្ងៃ ) ។ |
| សកម្មភាពបញ្ជ្រាបមុខវិជ្ជាផ្សេងទៀត | • ការអភិវឌ្ឍពាក្យ<br>• សិក្សាសង្គម ព្រឹត្តិការណ៍បច្ចុប្បន្នរបស់ជាតិ<br>• គណិតវិទ្យា<br>• វិទ្យាសាស្ត្រអនុវត្ត / ស្រែពិសោធសិស្សានុសិស្ស ( IPM/SFS ) ។ |
| សកម្មភាពគិតដោយវិភាគ | • ចូរពិភាក្សា និង បំផុសគំនិតអំពីមូលហេតុ ដែលគេបានជ្រើសរើស ទីក្រុងភ្នំពេញ ធ្វើជារាជធានីរបស់ប្រទេសកម្ពុជា<br>• ចូរពិភាក្សា អំពីមូលហេតុដែលដំណាំមួយចំនួនអាចដុះបាននៅតំបន់មួយចំនួន ប៉ុន្តែដុះមិនបាននៅតំបន់ផ្សេង |

| | |
|---|---|
| | ទៀត ( គ្រូគួរតែលើកឧទាហរណ៍ តំបន់ខ្លះធ្វើស្រែក្នុង១ឆ្នាំ ២ ដង រីឯតំបន់ខ្លះទៀតធ្វើស្រែបានតែ ១ ដង )<br>• ការស្រាវជ្រាវទីផ្សារ ( មើលខាងក្រោម ) ការរៀបចំសំណួរសម្រាប់ធ្វើការស្រាវជ្រាវយ៉ាងទៀងទាត់ ។ កត់ត្រាតម្លៃនៃទំនិញសំខាន់ៗ មួយចំនួន ។ ពិភាក្សាអំពីមូលហេតុដែលធ្វើឱ្យទំនិញខ្លះថ្លៃជាងទំនិញផ្សេងទៀត ។ចូរគិតអំពីប្រភពដើមនៃទំនិញ ។ ចូរមើលផែនទី ដើម្បីគូសបន្ទាត់ពីការដឹកទំនិញពីប្រភពដើមមកផ្សារក្នុងមូលដ្ឋាន ហើយពិភាក្សាអំពីផលលំបាកដែលអាចកើតមានឡើងក្នុងការ ធ្វើដំណើរនេះ ។ បង្ហាញព័ត៌មានដែលបានប្រមូលជាក្រាប ( តម្លៃនៃទំនិញ និង ខែ ) កំណត់ការប្រែប្រួលក្នុងតំលៃទំនិញ ហើយ និងពិភាក្សាអំពីមូលហេតុនៃការប្រែប្រួលនេះ<br>• ទម្រង់សង្កេតឧស្សាហកម្ម ការតែងសំណួរងាយៗ និង ចំណុចគួរតែសង្កេតដើម្បីយល់កាន់តែច្បាស់អំពីឧស្សាហកម្មក្នុងមូលដ្ឋាន ( ឧទាហរណ៍ : ចំការកៅស៊ូ រោងចក្រទឹកកក ម៉ាស៊ីនកិនស្រូវ . . . )<br>• ក្រុមសិស្សនីមួយៗ បង្កើតសំណួរឱ្យក្រុមសិស្សផ្សេងទៀតឆ្លើយ អំពីអត្ថបទក្នុងសៀវភៅសិក្សា ។ ការកំណត់ផ្លូវធ្វើដំណើរផ្សេងៗ ប្រើផែនទី និង ត្រីវិស័យ ។ តើផ្លូវមួយណាដែលជិតជាងគេក្នុងការធ្វើដំណើរពីទីរួមខេត្តកំពង់ចាម ទៅទីរួមខេត្តបន្ទាយមានជ័យ? ក្នុងការធ្វើដំណើរនេះ តើអ្នកធ្វើដំណើរតាមទិសណាខ្លះ ? តើការធ្វើដំណើរនេះមានចម្ងាយប៉ុន្មានគីឡូម៉ែត្រ ? ប្រសិនជាអ្នកធ្វើដំណើរជិះតាក់ស៊ី ដែលមានល្បឿន ៥០ គីឡូម៉ែត្រ ក្នុងមួយម៉ោងជាមធ្យម តើចំណាយពេលវេលាប៉ុន្មាន ? តើអ្នកធ្វើដំណើរអាចជួបការលំបាកអ្វីខ្លះតាមផ្លូវ ? តើការធ្វើដំណើរ នេះឆ្លងកាត់ខេត្តណាខ្លះ ? តើការធ្វើដំណើរនេះមិនឆ្លងកាត់ខេត្តណាខ្លះ ? |
| សកម្មភាពគិតដោយច្នៃប្រឌិត | • ចូរស្រមៃការធ្វើដំណើរតាមដងទន្លេមេគង្គ ពីខាងត្បូងប្រទេសកម្ពុជា ទៅខាងជើងនៃប្រទេសកម្ពុជា ។ តើប្អូនៗ អាចជួបការលំបាកអ្វីខ្លះ ? តើរុក្ខជាតិប្រែប្រួលដូចម្តេចខ្លះ ?<br>• ចូរស្រមៃពិភពលោកដែលគ្មានផ្លូវ តើប្រជាជនអាចមានការលំបាកអ្វីខ្លះ ? បំផុសគំនិតជាក្រុមតូចៗ |

| | |
|---|---|
| | • ចូរស្រមៃថា ទន្លេមេគង្គនឹងរីងហួតទឹកអស់ តើនឹងមានអ្វីកើតឡើង ? បំផុសគំនិតជាក្រុមតូច ។ |
| ការវាយតម្លៃជាដំណាក់ៗ និង កម្រងស្នាដៃសិស្ស | • ទម្រង់បែបបទនៃការអង្កេតឧស្សាហកម្ម ឬ សិប្បកម្មនៅក្នុងតំបន់<br>• លទ្ធផលនៃការស្រាវជ្រាវទីផ្សារ<br>• តែងសេចក្តី ( រូបារម្មណ៏ ) ។<br>• លំហាត់ឱ្យសិស្សគិតអំពីអ្វីៗ ដែលអាចកើតមានឡើង<br>• លទ្ធផលសកម្មភាពបំផុសគំនិតជាក្រុមតូចៗ<br>• សំណួរបង្កើតដោយក្រុមសិស្ស ស្តីអំពីអត្ថបទក្នុងសៀវភៅសិក្សា ។ |
| លំហាត់នៅផ្ទះ និង ការស្រាវជ្រាវក្រៅសាលា | • ការពិភាក្សាលើសំណួរគិតដោយវិភាគ នៅផ្ទះជាមួយ បង និង ឪពុកម្តាយ ។ តើកុមារអាចមានគំនិតយោបល់ថ្មីៗ អ្វីខ្លះបន្ថែមទៀត ?<br>• ការស្រាវជ្រាវទីផ្សារ : ការកំណត់ប្រភពទំនិញផ្សេងៗ ដែលមានលក់នៅផ្សារ ការលំបាកក្នុងការទុកដាក់ទំនិញ វិធានការត្រួតពិនិត្យគុណភាពទំនិញ តើគេដោះស្រាយយ៉ាងដូចម្តេច ប្រសិនជាទំនិញខូចតិចតួចតាមផ្លូវ ?<br>• ការយល់ដឹងស្តីអំពីឧស្សាហកម្មក្នុងមូលដ្ឋាន : ការអង្កេត " ថ្ងៃធម្មតាក្នុងជីវិតរបស់កម្មករចំការកៅស៊ូ " " ថ្ងៃធម្មតាក្នុងជីវិតរបស់កម្មកររោងចក្រទឹកកក " " ថ្ងៃធម្មតាក្នុងជីវិតរបស់កម្មករម៉ាស៊ីនកិនស្រូវ " " ថ្ងៃធម្មតាក្នុងជីវិតរបស់អ្នកតំបាញ " . . . ។ |

## ឯកសារទី៦ D: ផែនការថ្នាក់កុមារមេត្រី (វិទ្យាសាស្ត្រអនុវត្តថ្នាក់ទី១ ទី២ ទី៥ និង ទី៦)

| **ថ្នាក់ទី ១ : វិទ្យាសាស្ត្រអនុវត្ត**<br>**មេរៀនផ្តើម : ដកស្រង់ចេញពីទំព័រទី ១-៦**<br>**ខ្លឹមសារ : ភាវៈមានជីវិតនិងគ្មានជីវិត ( សៀវភៅ វិទ្យាសាស្ត្រអនុវត្តថ្នាក់ទី ១ )** | |
|---|---|
| ការរៀបចំបរិស្ថានក្នុងបន្ទប់រៀន | • ក្បៀនវិទ្យាសាស្ត្រអនុវត្ត ( រូបភាព ឬ គំរូ នៃវត្ថុភាវៈមានជីវិត និង គ្មានជីវិត ) ។<br>• រូបភាពលើជញ្ជាំងនៅជិតក្បៀនវិទ្យាសាស្ត្រអនុវត្ត ។<br>• រូបភាពគូរដោយសិស្សលើជញ្ជាំង ។ |
| សកម្មភាពពង្រីកបន្ថែមក្នុងសៀវភៅសិក្សា | • សិស្សប្រមូលវត្ថុផ្សេងៗ នៅតាមទីធ្លាសាលារៀន ។<br>• សិស្សគូររូបភាព ។ |
| សកម្មភាពបញ្ជ្រាបជាមួយមុខវិជ្ជាផ្សេងទៀត | • គូររូបភាព ( គំនូរ )<br>• ការអភិវឌ្ឍសមត្ថភាពនិយាយ ( ពិភាក្សាអំពីវត្ថុបានប្រមូល ) ។ |
| សកម្មភាពគិតដោយវិភាគ | • សំណួរស្តីអំពីវត្ថុផ្សេងៗ : តើនេះជាភាវៈមានជីវិត ឬ គ្មានជីវិត ? បើមានជីវិត ឬ គ្មានជីវិត ចូរប្អូនពន្យល់ ។ |
| សកម្មភាពគិតដោយច្នៃប្រឌិត | • សំណួរស្តីអំពីវត្ថុផ្សេងៗ : - តើវត្ថុនេះប្អូនប្រើសម្រាប់ធ្វើអ្វី ?<br>• ការប្រើរូបារម្មណ៍ :<br>- ចូរប្អូនគូរវត្ថុមួយដែលបានរកឃើញ រួចហើយគូរវត្ថុផ្សេងទៀតដែលអាចរកឃើញនៅជុំវិញវត្ថុនោះ ។ |
| ការវាយតម្លៃជាដំណាក់ៗ និង កម្រងស្នាដៃសិស្ស | • សិស្សជ្រើសរើសរូបភាពបញ្ចូលក្នុងកម្រងស្នាដៃសិស្ស ។ |
| លំហាត់នៅផ្ទះ និង ការស្រាវជ្រាវក្រៅសាលា | • សិស្សប្រមូលសម្ភារទាក់ទងនឹងមេរៀននេះនៅផ្ទះ ដើម្បីដាក់ក្បៀនវិទ្យាសាស្ត្រអនុវត្ត ។ |

| **មេរៀនទី ១ : ដកស្រង់ចេញពីទំព័រទី ៧ ~ ២០ នៃសៀវភៅ វិទ្យាសាស្ត្រអនុវត្តថ្នាក់ទី ១**<br>**ខ្លឹមសារ : រុក្ខជាតិ** | |
|---|---|
| ការរៀបចំបរិស្ថានក្នុងបន្ទប់រៀន | • កៀនវិទ្យាសាស្ត្រអនុវត្ត ( ឧ. រុក្ខជាតិ ផ្កាផ្សេងៗ និង កែវពង្រីកឱ្យសិស្សប្រើ )<br>• កៀនវិទ្យាសាស្ត្រអនុវត្ត ( បង្ហាញការពិសោធស្តីពីការលូតលាស់របស់រុក្ខជាតិ " ទំព័រទី ១៨ " )<br>• បិទប័ណ្ណពាក្យ រូបភាពនៃរុក្ខជាតិ និង ផ្កានានាលើជញ្ជាំង<br>• ប័ណ្ណពាក្យ និង រូបភាពផ្លែឈើ បិទលើជញ្ជាំង ។<br>• រូបភាពបង្ហាញពីផ្នែកផ្សេងៗ នៃរុក្ខជាតិ ( ស្លឹក ដើម រឹស ) បិទនៅលើជញ្ជាំង<br>• ផ្ទាំងប័ណ្ណពាក្យងាយៗ ( ពណ៌ ទំហំ ទ្រង់ទ្រាយផ្សេងៗ ) ។ |
| សកម្មភាពពង្រីកបន្ថែមក្នុងសៀវភៅសិក្សា | • ការរៀបចំពិសោធន៍ជាក់ស្តែង ដូចក្នុងសៀវភៅសិក្សាទំព័រទី ១៨ ។ ណែនាំសិស្សឱ្យចេះសង្កេតស្តីពីការប្រែប្រួល ការលូតលាស់របស់រុក្ខជាតិ<br>• ការចេញសង្កេតក្រៅថ្នាក់ស្តីពីរុក្ខជាតិ ។ សំណួរ : តើប្អូនអាចសរសេរឈ្មោះលើរុក្ខជាតិ ផ្កា ដើមឈើ ផ្សេងៗ ក្នុងទីធ្លាសាលារៀនបានដែរឬទេ ?<br>• ការប្រើប្រាស់កែវពង្រីកដើម្បីពិនិត្យមើលរុក្ខជាតិ ផ្កា និង ស្មៅ ដែលសិស្សបានប្រមូល ។<br>• សិស្សគូររូបភាពបង្ហាញអំពីអ្វីដែលគេបានប្រមូល ។ |
| សកម្មភាពបញ្ច្រាបជាមួយមុខវិជ្ជាផ្សេងទៀត | • គ្រូសរសេរប័ណ្ណពាក្យស្តីអំពីពាក្យដែលអាចប្រើបានញឹកញាប់ដើម្បីបញ្ចូលក្នុងប្រអប់ធនាគារពាក្យរបស់ក្រុមសិស្ស ( ធនាគារពាក្យ : ឧ. ប្រើលើមុខវិជ្ជាផ្សេងៗ មាន : ធំ តូច ទាប ខ្ពស់ ក្រហម ស . . .<br>• ការទាញអារម្មណ៍របស់សិស្សឱ្យគិតទៅដល់ផ្ទាំងក្រដាសកថាខណ្ឌដែលបានបិទប័ណ្ណពាក្យលើជញ្ជាំងឱ្យសិស្សពិភាក្សា ។ |

| | |
|---|---|
| សកម្មភាពគិតដោយវិភាគ | • សកម្មភាព ៖<br>– ចូរធ្វើចំណាត់ថ្នាក់រុក្ខជាតិដែលមានផ្កា និង រុក្ខជាតិគ្មានផ្កា ។<br>• សំណួរ ៖<br>– តើរុក្ខជាតិមានលក្ខណៈដូចគ្នាត្រង់ណាខ្លះ ? ( ប្រសិនបើសិស្សឆ្លើយមិនរួច គ្រូគួរប្រើពាក្យបង្អើបដូច ជា ៖ " ចុះពណ៌ , ចុះទំហំ . . . " ) ។<br>– តើរុក្ខជាតិមានលក្ខណៈខុសគ្នាត្រង់ណា ?<br>– តើរុក្ខជាតិណាខ្លះមានផ្កា ?<br>– តើរុក្ខជាតិណាខ្លះគ្មានផ្កា ?<br>• ល្បែងសិក្សា ៖ គ្រូរៀបរាប់លំអិតអំពីវត្ថុ ឬ រុក្ខជាតិណាមួយឱ្យសិស្សស្តាប់ដោយយកចិត្តទុកដាក់ ។ក្រោយពីធ្វើការរៀបរាប់គ្រូបានហៅឱ្យសិស្សទាយ តើខ្ញុំចង់និយាយអំពីអ្វី ? ពេលដែលសិស្សយល់ពីល្បែងសិក្សានេះឱ្យសិស្សម្នាក់ជាអ្នករៀបរាប់ ឯសិស្សដទៃទៀតជាមួយគ្រូជាអ្នកទាយ ។ អាចសាកល្បងល្បែងសិក្សានេះជាក្រុមតូច ។ |
| សកម្មភាពគិតដោយច្នៃប្រឌិត | • ការប្រើរូបារម្មណ៍ ៖<br>– ប្រសិនបើប្អូនកើតជា ផ្កា តើប្អូនចង់កើតជាផ្កាអ្វី ? ហេតុអ្វី ?<br>– ប្រសិនបើប្អូនកើតជាផ្លែឈើ តើប្អូនចង់កើតជាផ្លែអ្វី ? ហេតុអ្វី ?<br>• ការធ្វើត្រាប់តាម ៖<br>– ចាប់ផ្តើមដោយឱ្យសិស្សអោនធ្វើរាងដូចគ្រាប់រុក្ខជាតិ ។ ពេលនោះគ្រូជាអ្នករៀបរាប់ចលនាផ្សេងៗ ហើយសិស្សធ្វើតាមរហូតដល់រូបរាង កាយវិការ ដូចដើមឈើលូតលាស់ធំ ។ |

| | |
|---|---|
| ការវាយតម្លៃជាដំណាក់ៗ និង កម្រងស្នាដៃសិស្ស | • សិស្សជ្រើសរើសរូបភាពដែលគេបានគូរ ដើម្បីដាក់ក្នុងកម្រងស្នាដៃរបស់គេ ។<br>• ក្រុមសិស្សបង្ហាញផ្កា និង រុក្ខជាតិ ដែលបានប្រមូលដោយស្ម័គ្រចិត្តក្នុងក្រុមនេះដាក់នៅជិតតុ ។ |
| លំហាត់នៅផ្ទះ និង ការស្រាវជ្រាវក្រៅសាលា | • សិស្សសួរឪពុកម្តាយ និង បងគេ អំពីឈ្មោះផ្កា និង រុក្ខជាតិដែលមាននៅជិតផ្ទះ ។<br>• សិស្សគូររូបភាព ដែលបង្ហាញផ្ទះ និង បរិស្ថានជុំវិញផ្ទះរបស់គេ ។ |

| **មេរៀនទី ២ : ដកស្រង់ចេញពីទំព័រទី ២១ ~ ៣៥**<br>**ខ្លឹមសារ : សត្វ ( សៀវភៅ វិទ្យាសាស្ត្រអនុវត្តថ្នាក់ទី១ )** | |
|---|---|
| ការរៀបចំបរិស្ថានក្នុងបន្ទប់រៀន | • កៀនវិទ្យាសាស្ត្រអនុវត្ត : ប្រអប់កែវពង្រីក (សម្រាប់សង្កេតសត្វល្អិតលើរុក្ខជាតិ) និង ការប្រមូលត្រីតូចៗ ឬ កូនក្អុក សត្វកង្កែបដាក់ក្នុងកែវ និង ទុកកែវពង្រីកកៀនវិទ្យាសាស្ត្រអនុវត្តឱ្យសិស្សប្រើ ។<br>• ការបិទសម្ភារសិក្សា ស្តីអំពីសត្វផ្សេងៗលើជញ្ជាំង ។ |
| សកម្មភាពពង្រីកបន្ថែមក្នុងសៀវភៅសិក្សា | • ការចេញសង្កេតក្រៅថ្នាក់រួចហើយបង្កើតការពិភាក្សាក្នុងថ្នាក់រៀន (ពេលដែលប្អូនដើរចេញតើប្អូនបានឃើញសត្វអ្វីខ្លះ ?) ។ |
| សកម្មភាពបញ្ជ្រាបជាមួយមុខវិជ្ជាផ្សេងទៀត | • គ្រូសរសេរប័ណ្ណពាក្យ ដែលប្រើញឹកញាប់ ដើម្បីបញ្ចូលក្នុងធនាគារពាក្យរបស់ក្រុមសិស្ស ។<br>• ទាញអារម្មណ៍សិស្សឱ្យគិតដល់ផ្ទាំងក្រដាសប័ណ្ណពាក្យ ដែលបានបិទលើជញ្ជាំងឱ្យសិស្សពិភាក្សា ។<br>• គូរគំនូរ ( ដាក់ក្រដាសលើជញ្ជាំងឱ្យសិស្សគូររូបភាពអំពីព្រៃឈើដែលបង្ហាញអំពីរុក្ខជាតិ និង សត្វផ្សេងៗ ) ។ |

| | |
|---|---|
| សកម្មភាពគិតដោយវិភាគ | • សំណួរស្តីអំពីសត្វ :<br>– តើសត្វណាខ្លះដែលប្អូនឃើញក្នុងសម្ភារសិក្សាលើជញ្ជាំងដែលជាសត្វរស់នៅក្នុងផ្ទះ ភូមិ ទឹក វាលស្រែ ចំការ ព្រៃ និង សួនសត្វ ?<br>– តើសត្វនីមួយៗ មានប្រយោជន៍ដូចម្តេចខ្លះសម្រាប់មនុស្ស ? |
| សកម្មភាពគិតដោយច្នៃប្រឌិត | • ការធ្វើត្រាប់តាម :<br>– គ្រូដើរតួធ្វើជាសត្វ ឧ. បង្ហាញលក្ខណៈចលនាសត្វ សំលេងសត្វ ។ ឱ្យសិស្សទាយថា នេះជាសត្វអ្វី ? រួចហើយឱ្យសិស្សដើរតួជាសត្វផ្សេង សិស្សដទៃទៀតជាអ្នកទាយ ។<br>• ការពង្រឹងរូបារម្មណ៍ :<br>ចូរប្អូនបិទភ្នែកស្រមៃថា ខ្លួនប្អូនកំពុងដើរ ហើយបានជួបនឹងសត្វដែលស្លូត ។ តើសត្វនេះជាសត្វអ្វី ? ហេតុអ្វីបានជាប្អូនថា សត្វនេះជាសត្វស្លូត ។ បន្ទាប់មកប្អូនបានជួបសត្វកាច តើសត្វនេះជាសត្វអ្វី ? តើសត្វនេះមានមុខដូចម្តេច? តើសត្វនេះមានសំលេងដូចម្តេច ? |
| ការវាយតម្លៃជាដំណាក់ៗ និង កម្រងស្នាដៃសិស្ស | • ក្រុមសិស្សបិទរូបភាពព្រៃឈើ ដែលបង្ហាញអំពីរុក្ខជាតិ និង សត្វលើជញ្ជាំងនៅជិតតុគេ ។ មួយរយៈក្រោយមក គ្រូត្រូវ ការកន្លែងបិទស្នាដៃថ្មីលើជញ្ជាំង រូបភាពចាស់ដកដាក់ក្នុងកម្រងស្នាដៃក្រុមសិស្ស ។ |
| លំហាត់នៅផ្ទះ និង ការស្រាវជ្រាវក្រៅសាលា | • សិស្សគូររូប សត្វ ដែលគេមើលឃើញនៅជិតផ្ទះគេ ។ សិស្សសួរឪពុកម្តាយ និង បងគេ អំពីឈ្មោះសត្វដែលគេបាន ឃើញនៅជិតផ្ទះគេ ហើយរាយការណ៍ប្រាប់សិស្សទាំងអស់ក្នុងថ្នាក់។ គ្រូអាចរៀបចំប័ណ្ណពាក្យដែលមានសរសេរ ឈ្មោះសត្វសម្រាប់ដាក់បញ្ចូលក្នុងធនាគារពាក្យ ។ |

| **មេរៀនទី ៣ : ដកស្រង់ចេញពីទំព័រទី ៣៦_៦១**<br>**ខ្លឹមសារ : ផលប្រយោជន៍នៃរុក្ខជាតិ និង សត្វ (សៀវភៅវិទ្យាសាស្ត្រអនុវត្តថ្នាក់ទី ១)** | |
| --- | --- |
| ការរៀបចំបរិស្ថានក្នុងបន្ទប់រៀន | • បរិស្ថានសាលារៀន : ផ្កា ឬ រុក្ខជាតិនៅទីធ្លាសាលារៀន ( នៅមុខបន្ទប់រៀន ) ។<br>• កៀនវិទ្យាសាស្ត្រអនុវត្ត : គ្រាប់ផ្លែឈើ និង បន្លែផ្សេងៗ ស្រូវ អង្ករ ត្រីងៀតមួយដុំ បាយមួយកូនចានតូច ស្ករស អំបិល ប៊ីចេង ។ វត្ថុផ្សេងៗក្នុងផ្ទះដែលធ្វើពីរុក្ខជាតិ ឈើ កំណាត់ធ្វើពីរុក្ខជាតិ កំណាត់ធ្វើពីរោមសត្វ ទុកកែវ ពង្រីកឱ្យសិស្សប្រើប្រាស់<br>• រូបភាព និង ប័ណ្ណពាក្យ : ផ្លែឈើ បន្លែ និង សត្វជាប្រភពអាហារ<br>• ស្លាកបិទលើកំប៉ុងម្ហូប ឬ កញ្ចប់ម្ហូបផ្សេងៗ ដូចជា : មី , ត្រីខ . . .<br>• ពាក្យនៅលើផ្ទាំងក្រដាស : មុខម្ហូប សត្វ បន្លែ និង ផ្លែឈើ ដែលកុមារធ្លាប់ញ៉ាំ<br>• ផ្ទាំងក្រដាសបង្ហាញអំពីវិធីធ្វើកំណាត់ពីរុក្ខជាតិ ( មើលទំព័រទី ៤៧ )<br>• ផ្ទាំងក្រដាសបង្ហាញអំពីវិធីប្រើប្រាស់រុក្ខជាតិដើម្បីផលិតវត្ថុ និង ឧបករណ៍ផ្សេងៗ ( មើលទំព័រ ៤៨ ) ។ |
| សកម្មភាពពង្រីកបន្ថែមក្នុងសៀវភៅសិក្សា | • ការចេញសង្កេតក្រៅថ្នាក់ក្នុងទីធ្លាសាលារៀន ឬ ភូមិជិតៗ : តើប្អូនសង្កេតឃើញប្រភពម្ហូបអាហារប៉ុន្មានមុខ នៅពេល ដែលប្អូនធ្វើដំណើរ ?<br>• គ្រូបំផុសគំនិតកុមារ និង រៀបចំបញ្ជី ស្តីពីវត្ថុផ្សេងៗនៅផ្ទះធ្វើពីរុក្ខជាតិ ។ រៀបចំផ្ទាំងក្រដាសដែលមានពាក្យ ដកស្រង់ចេញពីបញ្ជីខាងលើ ។ គ្រូអាចសរសេរប័ណ្ណពាក្យសំរាប់ពាក្យដែលប្រើប្រាស់ញឹកញាប់បញ្ចូលទៅក្នុង ប្រអប់ធនាគារពាក្យនៃក្រុមសិស្ស នីមួយៗ ។ |
| សកម្មភាពបញ្ជ្រាបមុខវិជ្ជាផ្សេងទៀត | • ការអភិវឌ្ឍន៍វាក្យស័ព្ទ |

| | |
|---|---|
| | • អំនាន : អានប័ណ្ណពាក្យដែលមានក្នុងធនាគារពាក្យ<br>• សិក្សាសង្គម ។ |
| សកម្មភាពគិតដោយវិភាគ | • ការពិភាក្សា : កំណត់លក្ខណៈប្រហាក់ប្រហែលគ្នា កំណត់លក្ខណៈខុសគ្នារវាងផ្លែឈើ និង បន្លែ<br>• ការពិភាក្សា : តើវត្ថុណាខ្លះក្នុងបន្ទប់រៀនរបស់យើងធ្វើពីរុក្ខជាតិ ?<br>• បង្កើតប័ណ្ណពាក្យ ពីរ សម្រាប់ ( មួយសម្រាប់ជាប្រភេទម្ហូប និង មួយសម្រាប់ទៀតជាប្រភពម្ហូប )ហើយនឹងឱ្យ សិស្សផ្គុំប្រភេទម្ហូបជាមួយប្រភពម្ហូប ( មើលទំព័រទី ៥៧ និង ៥៨ )<br>• បង្កើតប័ណ្ណពាក្យ ៣ សម្រាប់ ( បន្លែ ផ្លែឈើ និង ម្សៅផ្សេងៗ ) ហើយឱ្យសិស្សធ្វើចំណាត់ថ្នាក់ប័ណ្ណពាក្យតាមក្រុម ម្ហូបទាំង ៣ ខាងលើ<br>• ប្រមូលវត្ថុផ្សេងៗជាច្រើនឱ្យសិស្សធ្វើចំណាត់ថ្នាក់ តើវត្ថុនេះធ្វើពីដែក រុក្ខជាតិ ឬប្លាស្ទិក ?( មើលទំព័រទី ៥៩ )<br>• ការពិភាក្សា : តើឆ្កែ និង ឆ្មា នៅផ្ទះផ្តល់ផលប្រយោជន៍ និង មានផលវិបាកយ៉ាងដូចម្តេច ? |
| សកម្មភាពគិតដោយច្នៃប្រឌិត | • បំផុសគំនិតយោបល់របស់សិស្ស ដើម្បីរៀបចំបញ្ជីពាក្យដែលរៀបរាប់អំពីចរឹករបស់សត្វ :<br>១. ឆ្មា<br>២. ឆ្កែ<br>៣. គោ<br>៤. គោ<br>៥. សត្វស្លាប<br>• គូរគំនូរដែលបង្ហាញពីសត្វឆ្លាត សត្វស្លូត សត្វមានមុខក្រញូវ ។ |
| ការវាយតម្លៃដំណាក់ៗ និង កម្រងស្នាដៃសិស្ស | • សិស្សជ្រើសរើសរូបភាព ដើម្បីដាក់ក្នុងកម្រងស្នាដៃសិស្ស |

| | |
|---|---|
| | • សិស្សជ្រើសរើសប័ណ្ណពាក្យទាក់ទងសត្វ រុក្ខជាតិ ដោយដកចេញពីប្រអប់ធនាគារពាក្យរបស់ក្រុម ពេលដែលសិស្សទាំងអស់អានបាន ។ សិស្សបិទប័ណ្ណពាក្យនេះលើផ្ទាំងក្រដាសដាក់ក្នុងកម្រងស្នាដៃ របស់ក្រុមយូរៗម្តង គ្រូគួរតែជ្រើស យកមកឱ្យសិស្សអានឡើងវិញ តើគេចាំឬទេ ? |
| លំហាត់នៅផ្ទះ និង ការស្រាវជ្រាវក្រៅសាលា | • សិស្សប្រមូលស្លាក ឬ កញ្ចប់នៃម្ហូបអាហារ ។ សិស្សរកគ្រាប់រុក្ខជាតិ ឬ បន្លែ ផ្សេងៗ តាមលទ្ធភាព ។ សិស្សរក ផ្លែឈើព្រៃតាមលទ្ធភាព ។ |

| **ថ្នាក់ទី២ : វិទ្យាសាស្ត្រអនុវត្ត ជំពូកទី ១ ដកស្រង់ចេញពីទំព័រទី ១-១៤**<br>**ខ្លឹមសារ : សង្កេតលើដំណើរប្រែប្រួលរបស់រុក្ខជាតិ** | |
|---|---|
| ការរៀបចំបរិស្ថានក្នុងបន្ទប់រៀន | • ប័ណ្ណពាក្យដែលបានបង្ហាញពាក្យថ្មីៗដូចជារុក្ខជាតិ ដើម ស្លឹក គ្រាប់ ឬ មើម ។ល។<br>• សៀវភៅវិទ្យាសាស្ត្រអនុវត្ត : រុក្ខជាតិ និង ផ្កាផ្សេងៗ ផ្លែឈើតាមរដូវកាលនីមួយៗ បណ្តុះគ្រាប់ក្នុងជើង រៀបចំថ្នាលដាំបន្លែ ឬ សួនដាំផ្កាក្នុងទីធ្លាសាលារៀន<br>• ការប្រើប្រាស់កែវពង្រីក និង ប្រអប់សត្វល្អិត : សៀវភៅវិទ្យាសាស្ត្រអនុវត្តគួរតែមានរបស់ផ្សេងៗដែលសិស្សអាចសង្កេតដោយប្រើកែវពង្រីក ដូចជា ស្លឹក ផ្កា ដើម ឬសឈើ<br>• បរិស្ថានសាលារៀន : ការរៀបចំកន្លែងពិសេសក្នុងទីធ្លាសាលារៀនសម្រាប់ការសាកល្បងដាក់ស្តែងអំពីវិធីផ្សេងៗ តាមការបណ្តុះ រុក្ខជាតិដូចទំព័រទី៥<br>• សម្ភារសិក្សាបិទលើជញ្ជាំងបង្ហាញពីឈ្មោះ និង រូបភាពនៃផ្លែឈើ ឬ បន្លែផ្សេងៗ ។ |
| សកម្មភាពពង្រីកបន្ថែមក្នុងសៀវភៅសិក្សា | • ការចេញសង្កេតក្រៅថ្នាក់រយៈពេល ១ខែម្តង ។ តើយើងអាចរករុក្ខជាតិប៉ុន្មានប្រភេទក្នុងបរិស្ថានសាលារៀន ? |

| | |
|---|---|
| | តើយើងមានការចាប់អារម្មណ៏ក្នុងការប្រែប្រួលលើរុក្ខជាតិនោះយ៉ាង ដូចម្តេច ? តើមានសត្វល្អិត និង សត្វផ្សេងៗ ដែលអាចរកឃើញនៅជិត ឬ លើរុក្ខជាតិនោះដែរឬទេ ?<br>• ការស្រោចទឹក និង ថែទាំរុក្ខជាតិក្នុងបន្ទប់រៀន និង ទីធ្លាសាលារៀន<br>• ការបណ្តុះគ្រាប់រុក្ខជាតិផ្សេងៗ ក្នុងផើងក្នុងបន្ទប់រៀន<br>• ការបណ្តុះគ្រាប់ពោត ឬ បន្លែផ្សេងៗទៀត និង បំពេញតារាងសង្កេតនៃដំណើរប្រែប្រួលរបស់រុក្ខជាតិដែលមានក្នុងទំព័រទី ១៣<br>• ការពិសោធន៏ : រុក្ខជាតិដែលបណ្តុះដូចគ្នាដែលមាននៅក្នុងផើង៣ ផើងទី១ រក្សានៅកន្លែងងងឹត ផើងទី២ រក្សានៅកន្លែងមានពន្លឺព្រះអាទិត្យ ( មិនស្រោចទឹក) និង ផើងទី៣ មាននៅកន្លែងមាន ពន្លឺព្រះអាទិត្យ និង ស្រោចទឹករាល់ថ្ងៃ ចូរសរសេរការប្រែប្រួលនៃរុក្ខជាតិទាំង៣ ផើងនេះ ។ (ដូចមាននៅក្នុងទំព័រទី ១០ ១១ ១២ ១៣ ក្នុងសៀវភៅសិស្ស ) ។ |
| សកម្មភាពបញ្ជ្រាបមុខវិជ្ជាផ្សេងទៀត | • ការអភិវឌ្ឍភាសា<br>• សំណេរបែបពិពណ៌នា<br>• គំនូរ<br>• កម្មវិធី IPM/SFS ( ស្រែពិសោធន៍សិស្សានុសិស្ស )<br>• គណិតវិទ្យា ( កម្ពស់ និង រូបរាងរុក្ខជាតិ ចំនួនផ្កា ចំនួនស្លឹក ។ |
| សកម្មភាពគិតដោយវិភាគ | • ចំណាត់ថ្នាក់រុក្ខជាតិតាមទំហំ ពណ៌ ចំនួនគ្រាប់ រូបរាង<br>• ចំណាត់ថ្នាក់លើរុក្ខជាតិតាមការប្រើប្រាស់ ឧ . រុក្ខជាតិជាម្ហូបរបស់មនុស្ស ចំណីរបស់សត្វ សម្រាប់ផលិតសម្ភារ និង សម្រាប់តុបតែងលំអ ។ |

| | |
|---|---|
| សកម្មភាពគិតដោយច្នៃប្រឌិត | • ការគូរគំនូរ រុក្ខជាតិ និង សត្វ ។ សិស្សប្រើរូបារម្មណ៍ដើម្បីគូរបន្ថែមជុំវិញរុក្ខជាតិនិងសត្វ<br>• ការបង្ហាញវិធីពង្រាយគ្រាប់ដោយ មនុស្ស សត្វ ខ្យល់ ទឹក ដោយប្រើវិធីធ្វើគ្រាប់តាមដូចក្នុងទំព័រទី ៣ (ស.ស)<br>• ការរៀបចំសំដែងតួតាមសត្វស៊ីស្លឹករុក្ខជាតិ ។ |
| ការវាយតម្លៃជាដំណាក់ៗ និង កម្រងស្នាដៃសិស្ស | • ការបញ្ចូលរូបភាពដែលសិស្សបានគូរក្នុងសឺមីផ្ទាល់ខ្លួន ។ |
| លំហាត់នៅផ្ទះ និង ការស្រាវជ្រាវក្រៅសាលា | • សិស្សសង្កេតឃើញរុក្ខជាតិប្រភេទផ្សេងៗដែលមាននៅជិតផ្ទះរបស់គេ ។ សិស្សរាយការណ៏ដោយនិយាយ ឬ ក៏ឱ្យ បងៗ ឬ ឪពុកម្តាយ ជួយសរសេរឈ្មោះរុក្ខជាតិទាំងនោះ<br>• សិស្សសួរសំណួរពីមនុស្សក្នុងមូលដ្ឋានអំពី ពេលណាដែលគេបានដាំបន្លែផ្សេងៗ ពេលណាគេច្រូតស្រូវនិងវិធីថែទាំ ។ |

| | |
|---|---|
| **ថ្នាក់ទី ៥ : វិទ្យាសាស្ត្រអនុវត្ត**<br>**មេរៀន ជំពូកទី ១ : ( មេរៀនទី ១ ដល់ ទី ២ ) ដកស្រង់ចេញពីទំព័រទី ១ ដល់ ទី ១៥**<br>**ខ្លឹមសារ : រុក្ខជាតិ និង បរិស្ថាន** | |
| ការរៀបចំបរិស្ថានក្នុងបន្ទប់រៀន | • ប័ណ្ណពាក្យដែលបង្ហាញពាក្យថ្មីៗ ក្នុងមេរៀននេះ : ផ្នែក និង លក្ខណៈផ្សេងៗ នៃរុក្ខជាតិ<br>• កៀនវិទ្យាសាស្ត្រអនុវត្ត : រុក្ខជាតិ និង ផ្កា ផ្សេងៗ ការបណ្តុះពូជក្នុងផើង ការរៀបចំថ្នាលតូចៗ ដើម្បីដាំផ្កា បន្លែក្នុងទីធ្លាសាលារៀន<br>• ការប្រើប្រាស់កែវពង្រីក និង ប្រអប់ពង្រីកសត្វល្អិត : កៀនវិទ្យាសាស្ត្រអនុវត្ត គួរតែមានរបស់ផ្សេងៗដែល សិស្សសង្កេតដោយប្រើកែវពង្រីក ដូចជា ស្លឹកឈើ ផ្កា ដើមផ្កា ឫសរុក្ខជាតិ . . .<br>• ទីធ្លាសាលារៀន : ការរៀបចំកន្លែងក្នុងទីធ្លាសាលារៀន ដើម្បីអនុវត្តពិសោធន៍សម្រាប់វិធីបន្តពូជរុក្ខជាតិ |

| | |
|---|---|
| | ដូចដែល បានរៀបរាប់ទំព័រទី ១០ ទី ១១ និង ទី ១២<br>• តារាងក្រដាសដែលជូនព័ត៌មានអំពីការបន្តពូជរបស់រុក្ខជាតិ ដូចទំព័រទី ១៣ ។ |
| សកម្មភាពពង្រីកបន្ថែមក្នុងសៀវភៅសិក្សា | • ការរៀបចំពិសោធន៍ ដែលសង្កេតអំពីស្ថានភាពផ្សេងៗ ពីគ្នា ដើម្បីស្វែងយល់ពីការលូតលាស់របស់រុក្ខជាតិ ។ ផើងមួយក្នុងកន្លែងងងឹតមិនស្រោចទឹក ផើងមួយទៀតក្នុងកន្លែងងងឹតនិងស្រោចទឹក ផើងមួយទៀត ក្នុងទីមានពន្លឺនិងស្រោចទឹក ម្យ៉ាងទៀតគេអាចសាកល្បងដោយប្រើផើងដែលមានដីធម្មតា ផើងមានដីលាយជីនិង មួយទៀតផើងដាក់ដីខ្សាច់<br>• កត់ត្រាការសង្កេតរៀងរាល់សប្តាហ៍លើការប្រែប្រួលក្នុងការលូតលាស់របស់រុក្ខជាតិ<br>• ការសង្កេតក្រៅថ្នាក់ មួយខែម្តងលើបរិស្ថានតាមផ្លូវដែលគេដើរ តើមានការប្រែប្រួលដូចម្តេច ? ឧទាហរណ៍ : ប្រែប្រួលទៅលើបរិមាណ រុក្ខជាតិ និង ដំណាំ ទំហំ ពណ៌ ជំរក . . .។ ម្យ៉ាងទៀតគួរតែកត់ត្រាសកម្មភាពផ្សេងៗរបស់កសិករ ។ អាចបកស្រាយព័ត៌មានដោយប្រើតារាង ដូចទំព័រទី ៦ និង ទី ៧ ។<br>• ការពិសោធន៍ជាក់ស្តែង ដើម្បីស្វែងយល់អំពីវិធីផ្សេងៗ សម្រាប់ការបន្តពូជ ។ បិទតារាង ដូចតារាងនៅទំព័រទី ១៣ លើជញ្ជាំងដើម្បីបញ្ជាក់អំពីសកម្មភាពសាកល្បងពីការបន្តពូជ<br>• ការគូរគំនូរ រុក្ខជាតិ និង ផ្កា : គួរតែប្រើប្រាស់កែវពង្រីកដើម្បីជួយគូររូបភាពឱ្យបានលំអិតតាមផ្នែកផ្សេងៗរបស់វា។ គូររួចហើយសរសេរស្លាកឈ្មោះដោយប្រើពាក្យបច្ចេកទេសថ្មីៗ ដែលបានរៀនក្នុងសៀវភៅសិក្សា ។ |
| សកម្មភាពបញ្ជ្រាបមុខវិជ្ជាផ្សេងទៀត | • ការអភិវឌ្ឍភាសា<br>• ការសរសេរបែបពិពណ៌នា<br>• ការគូរគំនូរ<br>• ស្រែពិសោធន៍សិស្សានុសិស្ស ( IPM/SFS ) ។ |

| | |
|---|---|
| សកម្មភាពគិតដោយវិភាគ | • ការពិភាក្សា គួរតែសង្កត់ធ្ងន់លើការប្រែប្រួល ដែលត្រូវបានសង្កេតក្នុងបរិស្ថាន ។ ពេលដែលសិស្សបង្ហាញលទ្ធផល នៃការសង្កេតសិស្សពន្យល់មូលហេតុសម្រាប់ការប្រែប្រួលដែលគេបានសង្កេតឃើញ<br>• ក្រុមសិស្សអានអត្ថបទក្នុងសៀវភៅសិក្សា ហើយដាក់សំណួរឱ្យក្រុមសិស្សផ្សេងទៀតឆ្លើយ<br>• ការបកស្រាយលទ្ធផលនៃការពិសោធន៍ពីការលូតលាស់របស់រុក្ខជាតិ តើសិស្សធ្វើការវិនិច្ឆ័យពីស្ថានភាពលូតលាស់ នីមួយៗ យ៉ាងដូចម្តេច ? |
| សកម្មភាពគិតដោយច្នៃប្រឌិត | • គូររូបភាពលើក្រដាសបិទលើជញ្ជាំង : ទេសភាពក្នុងមូលដ្ឋានរបស់យើងតាមរដូវកាល<br>• គូររូបភាពរុក្ខជាតិ ផ្កាផ្សេង ៗ ។ ប្រើរូបារម្មណ៍ ដើម្បីគូររូបភាពបន្ថែមទៀត ។ |
| ការវាយតម្លៃជាដំណាក់ៗ និង កម្រងស្នាដៃសិស្ស | • របាយការណ៍នៃការសង្កេត<br>• រូបភាពដែលបានគូរ<br>• របាយការណ៍អំពីការពិសោធន៍ ។ |
| លំហាត់នៅផ្ទះ និង ការស្រាវជ្រាវក្រៅសាលា | • ឱ្យសិស្សកត់ត្រាការប្រែប្រួលក្នុងបរិស្ថាននៅជិតផ្ទះរបស់គេមួយខែម្តងៗ ។ |

**ថ្នាក់ទី ៦ : វិទ្យាសាស្ត្រអនុវត្ត**

**មេរៀន ជំពូកទី ៤ : ( មេរៀនទី ១០ ដល់ ទី ១១ ) ដកស្រង់ចេញពីទំព័រទី ៦៣ ដល់ ៧៤**

**ខ្លឹមសារ : រូបធាតុ**

| | |
|---|---|
| ការរៀបចំបរិស្ថានក្នុងបន្ទប់រៀន | • គ្រឿងវិទ្យាសាស្ត្រអនុវត្ត : ប្រភេទថ្មផ្សេងៗ មេដែក កែវពង្រីក សីតុណ្ហមាត្រ អតិសុខុមទស្សន៍ វត្ថុផ្សេងៗ ឱ្យសិស្សត្រួតពិនិត្យមើល ដូចជា : ខ្សែ អំបិល ស្ករ ដីខ្សាច់ ថ្ម ដីគីមី<br>• ប័ណ្ណបង្ហាញពាក្យបច្ចេកទេស ដូចជា : រូបធាតុ ធាតុគីមី ភាគល្អិតនៃរូបធាតុ អង្គធាតុសមាស និង ល្បាយ |

| | |
|---|---|
| | អង្គធាតុទោល . . .<br>• បញ្ជីធាតុគីមីដែលជួបប្រទះញឹកញាប់ ដូចទំព័រទី ៦៦ និង ទី ៦៧ ។ |
| សកម្មភាពពង្រីកបន្ថែមក្នុងសៀវភៅសិក្សា | • ការធ្វើពិសោធបង្ហាញនៅទំព័រទី ៦៤ និង ទី ៦៥ ។ ការត្រួតពិនិត្យរូបធាតុ ជាដុំធំ ដោយប្រើកែវពង្រីក បំបែកជា ភាគល្អិតតូចៗ ហើយត្រួតពិនិត្យម្តងទៀត ។ តើប្អូនៗ សង្កេតឃើញលក្ខណៈខុសគ្នាដូចម្តេច ? ប្រហាក់ប្រហែលគ្នាដូចម្តេច ? ឱ្យសិស្សសរសេរពិពណ៌នាខ្លីៗ ដើម្បីរៀបរាប់អំពីការសង្កេតនេះ<br>• ប័ណ្ណពាក្យ ២ សម្រាប់ មួយសម្រាប់ មានឈ្មោះរូបធាតុ មួយសម្រាប់ទៀតមានការពន្យល់រៀបរាប់អំពី រូបធាតុ ឱ្យសិស្សផ្គូផ្គងរវាង សម្រាប់ទី១ ទៅ សម្រាប់ទី ២<br>• ឱ្យក្រុមសិស្សធ្វើតេស្តលើរូបធាតុផ្សេងៗ ដើម្បីស្វែងយល់ តើរូបធាតុណាខ្លះដែលមានប្រតិកម្មជាមួយមេដែក<br>• ការធ្វើពិសោធលើរូបធាតុផ្សេងៗ ដើម្បីស្វែងយល់អំពីប្រតិកម្មនៃរូបធាតុផ្សេងៗ ចំពោះកំដៅ ។ ឧទាហរណ៍ : ទឹក អាល់កុល ស្ករ អំបិល ប្រេង កាបូន និង បឺរ៉េត ។ ប្រើសីតុណ្ហមាត្រ ដើម្បីកត់ត្រា លើការប្រែប្រួលដែលកើតមានឡើងនៅអង្សាទីប៉ុន្មាន ? កត់ត្រាការសង្កេត<br>• ត្រួតពិនិត្យរូបធាតុផ្សេងៗ ដោយប្រើកែវពង្រីក ដូចជា : ក្រដាស ស្ករ អំបិល ប្រេង ដីខ្សាច់ ទឹក និង ខ្សែកត់ត្រាការសង្កេត និង គូររូបភាព<br>• តើយើងប្រើសារធាតុអ្វីខ្លះ ដើម្បីថែរក្សាអនាម័យបង្គន់ ? ចូរត្រួតពិនិត្យព័ត៌មានដែលបានសរសេរលើដប ដែលមានទឹកគេប្រើសំអាតបង្គន់ ។ ចូររៀបរាប់អំពីក្លិននៃទឹកនេះ ។<br>• តើគេប្រើសារធាតុអ្វីខ្លះ ដើម្បីជួយសំអាតទឹកក្នុងអណ្តូង ? ចូរត្រួតពិនិត្យដបនៃសារធាតុនេះ តើសារធាតុ នេះមានក្លិនដូចម្តេច ?<br>• ចូរធ្វើបញ្ជីខ្លីៗ នៃឱសថផ្សេងៗ ដែលប្អូនធ្លាប់លេប ឬ ប្រើពេលប្អូនឈឺ ? ចូរពិនិត្យព័ត៌មានលើដប កញ្ចប់ |

| | |
|---|---|
| | ឬ ប្រអប់ឱសថ ។ |
| សកម្មភាពបញ្ច្រាបមុខវិជ្ជាផ្សេងទៀត | • ការអភិវឌ្ឍភាសា និង បំណិនសរសេរ បែបពិពណ៌នា<br>• សិក្សាសង្គម : ការយល់ដឹងអំពីរូបធាតុផ្សេងៗក្នុងបរិស្ថាន ។ |
| សកម្មភាពគិតដោយវិភាគ | • មុននឹងធ្វើការពិសោធ និង ការសង្កេតដូចខាងលើឱ្យសិស្សទាយទៅលើលទ្ធផលនៃការសង្កេតសិន ។ ក្រោយពីធ្វើការ ពិសោធន៍ និង ការសង្កេតឱ្យសិស្សប្រៀបធៀបលទ្ធផលជាក់ស្តែងទៅនឹងការទាយរបស់គេ ។ តើមានអ្វីដែលត្រូវ ឬ ខុស នឹងការទាយ ?<br>• ឱ្យសិស្សផ្តល់មូលហេតុ ដើម្បីពន្យល់បាតុភូត ឬ ការប្រែប្រួលក្នុងការពិសោធ ។ |
| សកម្មភាពគិតដោយច្នៃប្រឌិត | • ការងារក្រុមតូច ។ ចូរពិនិត្យរូបធាតុ ដោយប្រើកែវពង្រីក ។ ពេលដែលប្អូនមើលរូបធាតុក្រោមកែវពង្រីក តើប្អូនៗបានពិនិត្យឃើញយ៉ាងដូចម្តេច ? តើប្អូនៗប្រើរូបារម្មណ៍ និង គិតស្រមៃយ៉ាងដូចម្តេចខ្លះ ? ឱ្យក្រុមសិស្សបំផុសគំនិត និង សរសេរពីអ្វីដែលមានក្រោមកែវពង្រីកតាមការស្រមៃរបស់ប្អូន<br>• លាយរូបធាតុ ២ ជាមួយគ្នា ដូចជា : ថ្នាំពណ៌ និង ទឹក ប្រេង និង ទឹក ទឹក និង ដីហើយចាក់ទៅលើក្រដាសដែលអាចបង្កើតរូបភាពមិនច្បាស់លាស់ ឬ អាចផ្លុំដោយប្រើបំពង់បឺត ហើយបំផុសគំនិតឱ្យគេស្រមៃឃើញ ពីអ្វីៗដែលគេនឹកឃើញ ។ |
| ការវាយតម្លៃជាដំណាក់ៗ និង កម្រងស្នាដៃសិស្ស | • បិទស្លាកកញ្ចប់ ដប ប្រអប់ លើផ្ទាំងក្រដាស ។ ចូរសរសេរពិពណ៌នាខ្លីៗ ពីសារធាតុដែលមាន : ឈ្មោះ ប្រភព ក្លិន ជាតិគីមី ប្រើសម្រាប់ធ្វើអ្វី ?<br>• ការស្រាវជ្រាវក្នុងផ្សារអំពីធាតុគីមីដែលមានក្នុងរបស់ផ្សេង ៗ<br>• របាយការណ៍ និង រូបភាព អំពីការពិសោធ និង ការសង្កេត ។ |
| លំហាត់នៅផ្ទះ និង ការស្រាវជ្រាវក្រៅសាលា | • ចូរស្រាវជ្រាវឈ្មោះជីគីមី ដែលមានលក់នៅទីផ្សារ ។ ចូរកត់ត្រាអំពីការប្រើប្រាស់ តើអ្នកលក់អាចពន្យល់ |

| | |
|---|---|
| | ពីការប្រើប្រាស់ជីគីមីនេះដែរឬទេ ?តើអាចមានសមាជិកសហគមន៍ណាម្នាក់ អាចពន្យល់បានពីធាតុផ្សំ ក្នុងជីគីមីនេះដែរឬទេ ?<br>• ទស្សនកិច្ចនៅកន្លែងលក់ឱសថ ។ សួរឈ្មោះឱសថ ៣ ប្រភេទ ដែលសិស្សធ្លាប់ស្គាល់ និង ធ្លាប់ប្រើ ដូចជា ៖ ប្រេងកូឡា ថ្នាំក្រហមលាបរបួស ឬ ក៏ប្រភេទវីតាមីន ...តើអ្នកលក់អាចជួយប្អូនឱ្យរកឃើញឈ្មោះនៃសារធាតុគីមីផ្សេងៗ ក្នុងឱសថទាំងនេះបានដែរឬទេ ?<br>• ចូរប្រមូលប្រអប់ថ្នាំពេទ្យ ឬ សំបកថង់ជីគីមីមកទុកក្នុងបន្ទប់រៀន ។ តើគេអាចស្រង់បានព័ត៌មានអ្វីខ្លះពីវត្ថុដែលគេបានប្រមូលមកនេះ ? ។ |

## ឯកសារទី៧: ភាពខុសគ្នារវាងផែនការថ្នាក់កុមារមេត្រី និង កិច្ចតែងការបង្រៀន

| កត្តាប្រៀបធៀប | កិច្ចតែងការបង្រៀន | ផែនការថ្នាក់កុមារមេត្រី |
|---|---|---|
| ១. រយៈពេល | កំណត់ច្បាស់លាស់ | មិនបានកំណត់ទេ ( សកម្មភាពមួយចំនួនអាចមានលក្ខណៈអចិន្ត្រៃយ៍ ) |
| ២. គោលបំណង | តែងល្បះច្បាស់ស្តីអំពីលទ្ធផលដែលចង់បាន តាមខ្លឹមសារមេរៀន ។ | " គ្រប់មេរៀនទាំងអស់មានភាពកុមារមេត្រី ។" |
| ៣. ខ្លឹមសារ | បញ្ញត្តិ បំណិន និងសកម្មភាពជាក់ស្តែងកំណត់ដោយកម្មវិធីសិក្សា ។ | ប្រធានបទទូលាយ ស្តីអំពីមុខវិជ្ជាមួយដែលពាក់ព័ន្ធនឹងផ្នែក ឬ ជំពូកធំក្នុងសៀវភៅសិក្សា ។ |
| ៤. មុខវិជ្ជា | សង្កត់ធ្ងន់លើមេរៀនមួយ ។ | ប្រធានបទទូលាយនៃមុខវិជ្ជាមួយ ប៉ុន្តែគ្រូត្រូវជំរុញពិចារណាអំពីសកម្មភាពបញ្ច្រាបជាមួយមុខវិជ្ជាផ្សេងៗ ។ |
| ៥. ការរៀនសូត្រក្រៅម៉ោង ឬ ក្រៅសាលា | ជាទូទៅ គ្រូដាក់លំហាត់ឱ្យសិស្សធ្វើដើម្បីពង្រឹងការយល់ដឹងលើបញ្ញត្តិដែលសិស្សបានរៀននៅសាលា ។ គ្រូទាមទារឱ្យសិស្សទាំងអស់ធ្វើលំហាត់ ។ | គ្រូជំរុញឱ្យសិស្សស្រាវជ្រាវ និង ចាប់អារម្មណ៍លើបរិស្ថានរបស់គេ ។ សិស្សមានសេរីភាព និង បង្ហាញលទ្ធផលនៃការស្រាវជ្រាវ ហើយនឹងបញ្ចេញគំនិតយោបល់អំពីខ្លឹមសារក្រៅកម្មវិធីសិក្សា ។ |
| ៦. ទំនាក់ទំនងរវាងគ្រូ និង សិស្ស | គ្រូដឹកនាំសម្របសម្រួល និង ពន្យល់កិច្ចការផ្សេងៗ ដោយដាក់កិច្ចការឱ្យសិស្សធ្វើ ។ | គ្រូដឹកនាំសម្របសម្រួល ហើយនិងពន្យល់កិច្ចការ ក៏ប៉ុន្តែមានតួនាទីមួយទៀតដែលមានលក្ខណៈមិនផ្ទាល់ ។ ក្នុងតួនាទីនេះគ្រូរៀបចំបរិស្ថានឱ្យសិស្សរៀនសូត្រ និង ស្រាវជ្រាវដោយមានលក្ខណៈសេរី ។ |
| ៧. ប្រភពខ្លឹមសារ | ដកស្រង់ចេញពីសៀវភៅគ្រូ និង សៀវភៅសិស្ស | ទាមទារឱ្យគ្រូពិចារណាអំពីខ្លឹមសារក្នុងសៀវភៅគ្រូ និង សៀវភៅសិស្សយកទៅអនុវត្តរួមបញ្ចូលនឹងគំនិតច្នៃប្រឌិតរបស់គ្រូ ។ |
| ៨. ផលប្រយោជន៍ | ជួយឱ្យគ្រូពិចារណាអំពីជំហាននីមួយៗ ក្នុងការបកស្រាយខ្លឹមសារដល់សិស្ស ។ | ជួយឱ្យគ្រូកែសំរួលខ្លឹមសារនៃកម្មវិធីសិក្សាស្របតាមសេចក្តីត្រូវការរបស់កុមារដោយមានលក្ខណៈច្នៃប្រឌិត ។ |
| ៩. ភាពញឹកញាប់នៃការ | វាជាការល្អ ប្រសិនជាគ្រូបានសរសេរកិច្ចតែងការមេរៀនទាំងអស់ ។ | មិនចាំបាច់សរសេរសម្រាប់គ្រប់មេរៀនទាំងអស់ ប៉ុន្តែវាជាការល្អមួយ ប្រសិន |

| | | |
|---|---|---|
| សរសេរ | | ជាអាចរៀបចំបានសម្រាប់ផ្នែក ឬ ជំពូកនិមួយៗ ក្នុងសៀវភៅភាសាខ្មែរ នឹង វិទ្យាសាស្ត្រអនុវត្ត ។ សម្រាប់សិក្សាសង្គម នឹងគណិតវិទ្យាអាចរៀបចំតាមប្រធានបទរួមមួយ ។ |

- ដើម្បីបញ្ជាក់ថា ការប្រើប្រាស់ផែនការថ្នាក់កុមារមេត្រី ជាឧបករណ៍មួយដែលគ្រូអាចជ្រើសរើសដើម្បីបំពេញបន្ថែមសម្រួលខ្លឹមសារក្នុងកម្មវិធីសិក្សាឱ្យមានលក្ខណៈកុមារមេត្រី អ្នកសម្របសម្រួល អាចបង្ហាញដ្យាក្រាមខាងក្រោម ÷

**ទំនាក់ទំនងរវាងផែនការថ្នាក់កុមារមេត្រី និង កម្មវិធីសិក្សា**



**ការរៀបចំបរិស្ថានក្នុងបន្ទប់**

- គ្រូវិទ្យាសាស្ត្រអនុវត្ត ដែលមានសម្ភារដូចជាៈមេដែក កែវ ពង្រីក រុក្ខជាតិ គ្រាប់រុក្ខជាតិផ្សេងៗ មីក្រូស្កូប ត្រីវិស័យ ។ល ។

- រៀបចំសិស្សជាក្រុមតូចៗ ដែលមានសមត្ថភាពចម្រុះ និង មិនរើសអើង ។

- តុបតែងជញ្ជាំងក្នុងបន្ទប់រៀន ដោយប្រើសម្ភារសិក្សា ផ្ទាំងក្រដាស ប័ណ្ណពាក្យ ។ គួរតែផ្លាស់ប្តូរសម្ភារលើជញ្ជាំងយ៉ាងទៀងទាត់ ដែលសមស្រប ទៅនឹងខ្លឹមសារក្នុងកម្មវិធីសិក្សា ដើម្បីធានាការទាក់ទាញអារម្មណ៍របស់សិស្ស ។

- កន្លែងពិសេសដែលមានតារាងកត់ត្រាកម្ពស់ ទម្ងន់ របស់សិស្សយ៉ាងទៀងទាត់ ។

- ផ្ទាំងក្រដាសដើម្បីពង្រឹងការប្រើប្រាស់ពាក្យ ល្បះ ដូចជា ពណ៌ ចំនួន គុណនាម គុណកិរិយាហើយ និង កិរិយាស័ព្ទជំនួស ។ ( ឧ-សម្រាប់ជំនួសពាក្យដែលប្រើញឹកញាប់ ដូចជា និយាយ ទៅ មើល . . . ) ។

- ដាក់ប្រអប់តូចអោយក្រុមសិស្សនីមួយៗ ប្រើជាធនាគារពាក្យ។ គ្រូគួរតែរៀបចំប័ណ្ណពាក្យមួយចំនួនតូច រៀងរាល់ថ្ងៃ (ពីរឬបី ប័ណ្ណពាក្យ ) ។

- ជាការងាយស្រួល ដកតុទាបដាក់នៅកៀនជញ្ជាំងជាបណ្តោះអាសន្នសម្រាប់មេរៀនមួយចំនួន ។

- មានកន្លែងពិសេស សម្រាប់ទុកកម្រងស្នាដៃសិស្ស និងបង្ហាញស្នាដៃសិស្ស ។

- មានកន្លែងពិសេសរៀបចំជាកៀនបណ្ណាល័យតូច ។

- ក្តារខៀនជូនព័ត៌មានៈ ព័ត៌មានងាយស្រួលរបស់សិស្សថ្នាក់ទី១ដូចជា " ថ្ងៃនេះសុខដើរទៅលេងផ្ទះរបស់យាយគាត់ " ព័ត៌មាន ផ្ទាល់ខ្លួន ជាតិ និង អន្តរជាតិ សម្រាប់សិស្សថ្នាក់ទី ៥ និង ទី ៦ ។

**សកម្មភាពពង្រីកបន្ថែមក្នុងសៀវភៅសិក្សា**

- គ្រូដឹកនាំសិស្សធ្វើសកម្មភាព ក្រៅថ្នាក់ដើម្បីសង្កេតក្នុងបរិវេណសាលា ឬ ក្រៅសាលា ។

- សិស្សធ្វើសកម្មភាពបំផុសគំនិតជាក្រុមតូច ។ ឧទាហរណ៍ ÷ មុននឹងអាន អត្ថបទស្តីអំពីទឹកជំនន់ ( ភាសាខ្មែរ ថ្នាក់ទី៥ ) សិស្ស ពិភាក្សាជាមួយគ្នា ហើយ និង សរសេរពាក្យដែលគេស្គាល់រួចមក ហើយទាក់ទងនឹងទឹកជំនន់ ។

- អោយសិស្សម្នាក់បង្ហាញសកម្មភាពមួយក្នុងរឿងនិទានតាមរយៈវិធីល្ខោនគ ។ សិស្សផ្សេងទៀតមើលអត្ថបទឡើងវិញ ដើម្បីរកក្នុងកថាខណ្ឌដែលរៀបរាប់ពីសកម្មភាពនេះ ។ សិស្សណាដែលរក ឃើញមុនគេឱ្យអានផ្នែកផ្សេងៗ ទៀត ។

- ក្នុងបន្ទប់ជាសរុបមាន ៦ ក្រុមសិស្ស ។ ក្នុង ២ ក្រុមសិស្សសហការជាមួយគ្នា ដើម្បីធ្វើលំហាត់គណិតវិទ្យាកំណត់ ដោយគ្រូ ។ គ្រូអង្គុយជាមួយនឹងក្រុមមួយទៀត ដែលកំពុងជួបការលំបាកក្នុង លំហាត់គណិតវិទ្យានេះ ។ បីក្រុមផ្សេងទៀតបានធ្វើលំហាត់គណិតវិទ្យានេះរួចមកហើយ ក្រុមមួយសិស្សសរសេររបាយការណ៍ អំពីសៀវភៅបណ្ណាល័យដែល គេបានអាន ។ ក្រុមមួយទៀតសិស្សជួយគ្នាទៅវិញទៅមក អានប័ណ្ណពាក្យក្នុងធនាគារពាក្យហើយក្រុមមួយទៀតឈរនៅកៀនវិទ្យាសាស្រ្ត-អនុវត្តដោយប្រើសម្ភារដូចជា : មេដែក កែវពង្រីក . . . ។

- សិស្សចូលរួមលេងល្បែងសិក្សាដើម្បីពង្រឹងការយល់ដឹងចំណេះដឹងទូទៅ ។

**សកម្មភាពបញ្ច្រាបជាមួយមុខវិជ្ជាផ្សេងទៀត**

- ពេលដែលគ្រូបង្រៀនមេរៀនវិទ្យាសាស្ត្រអនុវត្ត ស្តីអំពីសត្វ គ្រូអាចរៀបចំប័ណ្ណពាក្យទាក់ទងនិងសត្វសម្រាប់ ដាក់ក្នុងធនាគារពាក្យ (ភាសាខ្មែរៈ សមត្ថភាពអាន) ហើយពិភាក្សាជាមួយសិស្សអំពីលក្ខណៈនៃសត្វនីមួយៗ (ភាសាខ្មែរ : សមត្ថភាពនិយាយ) ។

- សិស្សធ្វើរបាយការណ៍ព័ត៌មានប្រចាំថ្ងៃ (ភាសាខ្មែរ : សមត្ថភាពនិយាយ) ហើយ និង កត់ត្រាព័ត៌មាននេះ (សិក្សាសង្គម : ភូមិវិទ្យា) ។

- សិស្សប្រើព័ត៌មានដែលសរសេររួចមកហើយ លើតារាងស្តីអំពីអាកាសធាតុ កម្ពស់សិស្ស ទម្ងន់សិស្ស(សិក្សាសង្គម : អាកាសធាតុ និង សុខភាព) ពេលដែលគេធ្វើ លំហាត់គណិតវិទ្យាទាក់ទងនឹងមធ្យមភាគ ទម្ងន់ បរិមាត្រ និងចំណុះ ។

- សិស្សប្រើកែវពង្រីកដើម្បីត្រួតពិនិត្យផ្នែករបស់ផ្កា (វិទ្យាសាស្ត្រអនុវត្ត ) គូររូបភាពនៃផ្កា (គូរគំនូរ) ហើយ សរសេរស្លាកដាក់លើផ្នែកនីមួយៗរបស់ផ្កា (ភាសាខ្មែរ ៈការអភិវឌ្ឍន៏ពាក្យ ការអាន ការសរសេរ ) ។

- ក្រុមសិស្សរៀបចំផែនទីជាក្រដាសធំ ដែលបង្ហាញចំណុចសំខាន់ៗ ក្នុងភូមិ ឬ ឃុំរបស់គេ( សិក្សាសង្គម បរិស្ថាន មូលដ្ឋាន) សរសេរស្លាកលើផែនទី ( ភាសាខ្មែរ ការអាន និង ការសរសេរ )។ សិស្សប្រើត្រីវិស័យដើម្បីកំណត់ទិស (សិក្សាសង្គម និង គណិតវិទ្យា ) និង ប៉ាន់ស្មានចម្ងាយពីកន្លែងមួយទៅកន្លែងមួយទៀតក្នុងភូមិ ( គណិតវិទ្យា បរិមាត្រ) ។

**សកម្មភាពគិតដោយវិភាគ**

- ក្រុមសិស្សបង្កើតសំណួរទាក់ទងនឹងមេរៀនក្នុងសៀវភៅសិក្សាដោយប្រើពាក្យឃ្លា សំណួរជាច្រើន អោយក្រុម សិស្សផ្សេងទៀតឆ្លើយ ។

- សកម្មភាពចំណាត់ថ្នាក់ ផ្គូផ្គង និង ជ្រើសរើស ។

- ក្រុមសិស្សសរសេរសេចក្តីណែនាំ ស្តីអំពីជំហានទីមួយៗ ក្នុងការអនុវត្តកិច្ចការ ដូចជា ការដាំបាយ ការដាំស្ល ការស្ទូងស្រូវ ។

- ការពិភាក្សាស្តីអំពីអត្ថបទ ដើម្បីកំណត់អ្វីៗ ដែលជាការពិត និង អ្វីៗ ដែលជាគំនិតយោបល់របស់អ្នកសរសេរ ។

- សិស្សវិភាគតម្លៃ ខ្ពង់ ក្នុងចំនួន ។

- ការពិភាក្សាស្តីអំពីលទ្ធផលនៃការស្រាវជ្រាវ និង វិភាគមូលហេតុដែលនាំអោយ មានលទ្ធផលសន្និដ្ឋានចេញ ឬ មូលហេតុដែលពន្យល់ពីការសង្កេត (ស្រង់ព័ត៌មាន ស្តីអំពីការប្រែប្រួលរបស់ទំនិញផ្សេងៗ ឬ ការសង្កេតលើការពិសោធន៍វិទ្យាសាស្ត្រអនុវត្ត) ។

## សកម្មភាពគិតដោយច្នៃប្រឌិត

- មេរៀនដែលមានល្បែងគ ។

- ការសរសេររឿងនិទានដោយប្រើរូបារម្មណ៍ ។ ក្នុងមេរៀននេះគ្រូសង្កត់ធ្ងន់ទៅលើគំនិតយោបល់របស់សិស្ស មិនមែនសង្កត់ធ្ងន់ទៅលើការប្រកបពាក្យ និង វេយ្យាករណ៍ ត្រឹមត្រូវនោះទេ ។

- ការគូរ និង ផាត់ពណ៌រូបភាព ដែលមានប្រធានបទទាក់ទងនឹងមេរៀនភាសាខ្មែរ ឬ សិក្សាសង្គម ។

- ក្រុមសិស្សបំផុសគំនិត ដើម្បីរៀបចំបញ្ជីពាក្យ ( កិរិយាស័ព្ទ គុណកិរិយា នាម និង គុណនាម ) ដើម្បីរៀបរាប់អំពី មនុស្ស ឬ សត្វ ។

- កសាងល្បះ ឬ ឃ្លា ជុំវិញពាក្យ ដែលគ្រូដាក់អោយ ។

- ក្រុមសិស្សរៀបចំចំណោទទាក់ទងនឹងជីវភាពជាក់ស្តែងដែលក្រុមសិស្សផ្សេងៗទៀតដោះស្រាយដោយប្រើបំណិន គណិតវិទ្យា ។

## លំហាត់នៅផ្ទះ និង ការស្រាវជ្រាវក្រៅសាលា

- សិស្សថ្នាក់ទី ៥ - ៦ ប្រមូលព័ត៌មានពីឪពុកម្តាយ ឬ បងរបស់គេដែលគេបានស្តាប់វិទ្យុ មើលទូរទស្សន៍ ឬ អានកាសែត ។ សិស្សកត់ត្រាព័ត៌មាននៅក្តារខៀនក្នុងបន្ទប់រៀន ។

- ការវាស់កម្ពស់ ថ្លឹងទម្ងន់ ចំណុះ និង មាឌ នៃវត្ថុផ្សេងៗនៅផ្ទះគេ ។

- ក្រុមសិស្សជួបគ្នានៅក្រៅសាលារៀន ដើម្បីជួយគ្នាសរសេរសំបុត្រផ្ញើទៅសិស្ស ផ្សេងទៀតនៅសាលាដទៃ ។

- សិស្សប្រមូលវត្ថុនិងសម្ភារផ្សេងៗដែលសមស្របនឹងកៀនវិទ្យាសាស្ត្រអនុវត្ត ។

- សិស្សកត់ត្រាតម្លៃនៃទំនិញផ្សេងៗនៅផ្សារ ។

**ការវាយតម្លៃជាដំណាក់ៗ និង កម្រងស្នាដៃសិស្ស**

- សិស្សម្នាក់ៗជ្រើសរើសកិច្ចការរបស់ខ្លួន (ឧ. រូបភាពរឿងនិទានដែលគេបាន សរសេរលទ្ធផលស្រាវជ្រាវនៅផ្ទះ របាយការណ៍អំពីសៀវភៅ . . . . ) ដើម្បីដាក់ បញ្ចូលក្នុងសឺមីរបស់គេ ។

- ក្រុមសិស្សបង្ហាញលទ្ធផលដែលបានសិក្សាតាមបែបសហការ ជាក្រុមតូចបិទលើជញ្ជាំងជិតតុរបស់គេ ។ ឧទាហរណ៍ ៖ លំហាត់បំផុសគំនិត ការរៀបចំផែនទី ការបង្កើតសំណួរឱ្យសិស្សផ្សេងទៀតឆ្លើយការគូររូបភាពធំ ។ ក្រោយពី ២ ឬ ៣ សប្តាហ៍សិស្សបិទស្នាដៃថ្មីលើជញ្ជាំងនឹងទុកស្នាដៃចាស់នៅក្នុងសឺមីធំរបស់ ក្រុម ។

- គ្រូតាមដានស្នាដៃរបស់សិស្សហើយពិភាក្សាជាមួយសិស្សដើម្បីសរសើរចំណុចខ្លាំង និង ជួយកែលំអចំណុចខ្សោយ។ គ្រូសម្រួលកិច្ចតែងការរបស់ខ្លួន និងវិធី បង្រៀនដើម្បីជួយដោះស្រាយទៅតាមតម្រូវការរបស់សិស្ស ។

កម្មវិធីគាំទ្រសេវាអប់រំកុមារនៅតំបន់ដាច់ស្រយាល ( អេស្កាប់ )

## ឯកសារបណ្តុះបណ្តាលគ្រូថ្នាក់កុមារមេត្រី
## សម្រាប់បឋមសិក្សា

# វិធីអភិវឌ្ឍន៍ទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព

# Procedures for developing Effective Communication



ខេត្តកំពង់ចាម ប្រទេសកម្ពុជា

ខែ សីហា ឆ្នាំ ២០០៦

**ឯកសារដើមពីអង្គការខេប**

## ឯកសារទី១: ឧបសគ្គដែលរារាំងទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព

**◈ តើអាចមានឧបសគ្គអ្វីខ្លះដែលរារាំងទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព ?**

- ឱ្យសិក្ខាកាមទាំងអស់ចាប់ដៃគូ ។ ឱ្យគូទាំងអស់អង្គុយទល់ខ្នងគ្នា ។ ក្នុងគូនីមួយៗ ម្នាក់ដើរតួជាគ្រូ និងម្នាក់ទៀតធ្វើជាសិស្ស ។ អ្នកសម្របសម្រួលបែងចែក ដ្យាក្រាម ឬ រូបភាព ឱ្យក្រុមនីមួយៗ ។ គ្រូត្រូវតែណែនាំឱ្យសិស្សគូររូបភាព ឬ ដ្យាក្រាមដោយមិនអនុញ្ញាតឱ្យសិស្សមើលរូបភាព ដ្យាក្រាមដែលបានចែក។ ម៉្យាងទៀត សិស្សមិនមានសិទ្ធិសួរសំណួរដើម្បីបញ្ជាក់ការណែនាំរបស់គ្រូ ។ គ្រូមិនមានសិទ្ធិមើលស្នាដៃរបស់សិស្ស ឱ្យគូនីមួយៗប្រៀបធៀបរូបភាពដែលបានចែកទៅនឹងស្នាដៃរបស់សិស្ស ។ អ្នកសម្របសម្រួលគួរតែសួរសំណួរ ២ ដូចតទៅ ÷
  - តើគ្រូ និង សិស្ស បានជួបឧបសគ្គអ្វីខ្លះក្នុងកិច្ចការនេះ ?
  - តើគ្រូអាចចៀសវាង ឬ ទប់ស្កាត់ឧបសគ្គនេះបានយ៉ាងដូចម្តេច ?

  <u>**គំនិតគន្លឹះ**</u> **: គ្រូត្រូវតែមានព័ត៌មានត្រឡប់ពីសិស្ស ដើម្បីវាយតម្លៃការរៀនសូត្ររបស់សិស្ស។ ការត្រួតពិនិត្យកិច្ចការសិស្សដោយគ្រូ និង ការផ្តល់ឱកាសឱ្យសិស្សសួរសំណួរ គឺជាវិធី ២ យ៉ាង ដើម្បីធានាថា គ្រូមានព័ត៌មានត្រឡប់ពីសិស្ស ។**

- អ្នកសម្របសម្រួល គួរតែបន្តសកម្មភាពនេះ ដោយសួរសំណួរ ÷
  តើមានឧបសគ្គអ្វីខ្លះទៀតដែលរារាំងដល់ទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព ?
  អ្នកសម្របសម្រួល គួរតែកត់ត្រាគំនិតយោបល់របស់សិក្ខាកាមលើក្តារខៀន ។
  អ្នកសម្របសម្រួលគួរតែបំភ្លឺចម្លើយដល់សិក្ខាកាមដែលនិយាយពីទម្លាប់របស់សិស្ស និង គ្រូក្នុងការសួរសំណួរ ។ ប្រសិនជាគ្មានចម្លើយរបស់សិក្ខាកាមដែលនិយាយអំពីការសួរនិងចម្លើយរបស់សំណួរ អ្នកសម្របសម្រួលគួរតែសួរសំណួរ : **" តើទម្លាប់របស់យើងក្នុងការសួរ ឆ្លើយ ឬ ស្តាប់សំណួរ អាចជះឥទ្ធិពលលើប្រសិទ្ធភាពនៃទំនាក់ទំនងយ៉ាងដូចម្តេច ? "** បញ្ហាផ្សេងទៀតដែលអ្នកសម្របសម្រួលគួរតែបញ្ជាក់ ÷
  - ភាពសមស្របនៃកិច្ចការដែលគ្រូឱ្យសិស្សធ្វើ ( ពិបាកខ្លាំង ឬ ស្រួលពេក )
  - គ្រូប្រើវាក្យស័ព្ទដែលមានកម្រិតខ្ពស់ជាងវាក្យស័ព្ទដែលសិស្សធ្លាប់ប្រើ
  - កត្តាផ្សេងៗក្នុងបរិស្ថាន
  - សិស្សខ្វាចធ្លាក់មធ្យមភាគ ខ្វះឆន្ទៈក្នុងការបញ្ចេញស្នាដៃដែលខ្លួនមាន
  - គ្រូខ្វះភាពស្និទស្នាលជាមួយសិស្ស ។

## ឯកសារទី២: ឧបសម្ព័ន្ធ ក-តារាងវាស់ទំនាក់ទំនងប្រកបដោយប្រសិទ្ធភាពសម្រាប់គ្រូធ្វើការស្វ័យវាយតម្លៃ

ចូរអានខ្លឹមសារតារាងខាងក្រោម ពិចារណាពីឈ្មោះនីមួយៗ ដែលរៀបរាប់អំពីស្ថានភាពប្រចាំថ្ងៃក្នុងថ្នាក់របស់លោកគ្រូអ្នកគ្រូ ។ ដោយមើលសេចក្តីណែនាំខាងក្រោមនេះ ចូរដាក់ពិន្ទុលើប្រសិទ្ធភាពនៃទំនាក់ទំនងក្នុងថ្នាក់របស់លោកអ្នក ។ ចូរដាក់ពិន្ទុដោយស្មោះត្រង់ ។ លទ្ធផល គឺជាព័ត៌មានសម្រាប់លោកគ្រូអ្នកគ្រូផ្ទាល់ខ្លួន ។ គ្មានអ្នកណាទាមទារអោយលោកគ្រូ អ្នកគ្រូប្រកាសជាសាធារណៈទេ ។

<u>ការដាក់ពិន្ទុ</u> :

**១ ពិន្ទុ** : ខ្លឹមសារនេះមិនត្រូវនឹងថ្នាក់របស់ខ្ញុំទេ ។ នេះគឺជាសកម្មភាព ឬ ទម្លាប់ដែលខ្ញុំគួរតែព្យាយាមបញ្ចូលក្នុងការបង្រៀនរបស់ខ្ញុំក្នុងពេលខាងមុខ ។

**២ ពិន្ទុ** : ខ្លឹមសារនេះត្រឹមត្រូវម្យ៉ាង ក៏ប៉ុន្តែខ្ញុំគួរតែខិតខំថែមទៀតក្នុងការបញ្ចូលសកម្មភាព ឬ ទម្លាប់នេះក្នុងការបង្រៀនរបស់ខ្ញុំ ។

**៣ ពិន្ទុ** : ខ្លឹមសារនេះត្រូវនឹងថ្នាក់របស់ខ្ញុំ ខ្ញុំពេញចិត្តថា ខ្ញុំបានបញ្ចូលសកម្មភាព ឬ ទម្លាប់នេះក្នុងការបង្រៀនរបស់ខ្ញុំរួចមកហើយ ។

ក្រោយពីដាក់ពិន្ទុក្នុងការបូកសរុបពិន្ទុទាំងអស់លោកគ្រូ អ្នកគ្រូអាចទទួលបានពិន្ទុ៩០ជាពិន្ទុអតិបរមា ។

- **៧០ ដល់ ៩០ ពិន្ទុ** : ហាក់បីដូចជាលោកអ្នក មានទំនាក់ទំនងប្រកបដោយប្រសិទ្ធភាពហើយ ។ ប្រសិនជាលោកអ្នកមិនបានទទួល ៩០ ពិន្ទុ ចូរពិចារណាលើចំណុចខ្សោយរបស់លោកអ្នក ។ ក្នុងសប្តាហ៍ក្រោយចូរព្យាយាមកែលំអ ចំណុចទាំង នោះ ។
- **៣០ ដល់ ៦៩ ពិន្ទុ** : ហាក់បីដូចជាលោក អ្នកមានបំណិនទំនាក់ទំនងដូចជាមានទំនាក់ទំនងល្អហើយ ។ ចូរជ្រើសរើសខ្លឹមសារ ៥ យ៉ាងដែលលោកអ្នកនឹងខិតខំ ប្រឹងប្រែងកែលំអសប្តាហ៍ក្រោយ ។ ក្រោយពី ១ ទៅ ២ សប្តាហ៍លោកអ្នកអាចប្រើម្តងទៀតហើយនិង ជ្រើសរើសខ្លឹមសារផ្សេងៗទៀតសម្រាប់កែលំអ ។
- ០ **ដល់ ២៩ ពិន្ទុ** : ហាក់បីដូចជាលោកអ្នក មិនសូវមានទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព លោកអ្នកមិនគួរព្រួយបារម្ភដោយសារភាពស្មោះត្រង់របស់លោកអ្នកក្នុងការដាក់ពិន្ទុ គឺជាជំហានដំបូងក្នុងការចាប់ផ្តើមធ្វើអោយទំនាក់ទំនងរបស់លោកអ្នកកាន់តែប្រសើរឡើង ។ ចូរជ្រើសរើសខ្លឹមសារ៥ យ៉ាង ដែលលោកអ្នកនឹងខិតខំប្រឹងប្រែងកែលំអសប្តាហ៍ក្រោយ ។ ក្រោយពី១ ទៅ ២ សប្តាហ៍ លោកអ្នកអាចប្រើម្តងទៀត ហើយនឹងជ្រើសរើស ខ្លឹមសារផ្សេងៗទៀតសម្រាប់កែលំអ ។

| សកម្មភាព ឬ ទម្លាប់របស់គ្រូដែលយើងចង់បាន | ពិន្ទុ | | |
|---|---|---|---|
| | ១ | ២ | ៣ |
| ១. ខ្ញុំព្យាយាមនិយាយមិនញាប់មិនយឺត ជាពិសេសពេលដែលខ្ញុំកំពុងពន្យល់ខ្លឹមសារពិបាក ឬ ស្មុគស្មាញ | | | |
| ២. ខ្ញុំយល់ថា ខ្ញុំចេះវាក្យស័ព្ទច្រើនជាងសិស្សខ្ញុំ ។ ខ្ញុំយល់ដឹងអំពីពាក្យបច្ចេកទេសដែលកូនសិស្សខ្ញុំពិបាកយល់ ។ មុននឹងពន្យល់បញ្ញត្តិពិបាកៗ ខ្ញុំពន្យល់ពាក្យគន្លឹះបច្ចេកទេសមុន ។ | | | |
| ៣. ខ្ញុំព្យាយាមប្រែប្រួលសម្លេងខ្ញុំ ពេលដែលខ្ញុំកំពុងនិយាយដើម្បីទាក់ទាញអារម្មណ៍របស់សិស្ស ហើយ និង ដើម្បីបញ្ជាក់ព័ត៌មានសំខាន់ៗ ។ | | | |
| ៤. ពេលដែលខ្ញុំកំពុងពន្យល់បញ្ញត្តិថ្មីដែលពិបាក ខ្ញុំរៀបចំសម្ភារជាមុនដូចជា ដ្យាក្រាម ផែនទី រូបភាព . . . ដើម្បីជួយការពន្យល់របស់ខ្ញុំ ។ សម្ភារដែលខ្ញុំរៀបចំធំល្មម ហើយច្បាស់ ងាយស្រួលឱ្យសិស្សទាំងអស់មើលឃើញ ។ | | | |
| ៥. ខ្ញុំសួរសំណួរទៅសិស្ស ដើម្បីបំផុសគំនិតយោបល់របស់គេ ស្តីអំពីរូបភាពសិក្សា រូបភាពផ្សេងៗ ហើយ និង សម្ភារឧបទេសផ្សេងទៀតក្នុងថ្នាក់ ។ | | | |
| ៦. ខ្ញុំជំរុញសិស្សតែងឃ្លារបស់ខ្លួន ដោយប្រើពាក្យថ្មី ដើម្បីបញ្ជាក់ថាសិស្សយល់ច្បាស់អំពីអត្ថន័យ ។ | | | |
| ៧. ពេលដែលសិស្សជួបប្រទះពាក្យថ្មី ( ក្នុងការនិយាយ ឬ ក្នុងការអាន ខ្ញុំជំរុញឱ្យសិស្សវិភាគអត្ថន័យដើម្បីយល់ពីបញ្ហានេះជាជាងនិយាយប្រាប់គេត្រង់ពេក ។ | | | |
| ៨. ខ្ញុំផ្តល់ឱកាសឱ្យសិស្សសួរសំណួរទៅសិស្សដទៃទៀត ឬ ខ្ញុំ ។ ជាធម្មតាខ្ញុំលើកស្ទួយទម្លាប់នេះពេលដែលខ្ញុំត្រួតពិនិត្យសិស្សក្នុងពេលដែលគេធ្វើការជាក្រុមតូច ឬ ជាបុគ្គល ។ | | | |
| ៩. ក្រោយពីខ្ញុំបានពន្យល់កិច្ចការ ឬ បញ្ញត្តិ ខ្ញុំផ្តល់ឱកាសឱ្យសិស្សសួរសំណួរមកខ្ញុំ ។ | | | |
| ១០. មុននឹងចាប់ផ្តើមពន្យល់អំពីបញ្ញត្តិថ្មី ខ្ញុំវាយតម្លៃជាដំណាក់ៗ (Formative) លើការយល់ដឹងរបស់សិស្សស្តីអំពីខ្លឹមសារ និង ការយល់ដឹងអំពីបញ្ញត្តិចាស់ ។ | | | |
| សកម្មភាព ឬ ទម្លាប់របស់គ្រូដែលយើងចង់បាន | ពិន្ទុ | | |
| | ១ | ២ | ៣ |
| ១១. ខ្ញុំយកចិត្តទុកដាក់លើសំណួរ និង ចម្លើយរបស់សិស្ស ហើយនិងចាប់អារម្មណ៍ខ្លាំងលើគំនិតយោបល់របស់គេ ។ | | | |
| ១២. ខ្ញុំព្យាយាមសរសើរសិស្ស ហើយនិងលើកទឹកចិត្តសិស្សពេលដែលសិស្សបញ្ចេញគំនិតយោបល់ ។ | | | |

| | | | |
|---|---|---|---|
| ទោះបីជាចម្លើយ ឬ គំនិតរបស់គេមិនត្រឹមត្រូវ ហើយខ្ញុំត្រូវតែកែគំនិតនេះ ខ្ញុំសរសើរថា គេព្យាយាមឆ្លើយ ។ | | | |
| ១៣.ខ្ញុំស្គាល់ឈ្មោះសិស្សទាំងអស់ក្នុងថ្នាក់ ។ ខ្ញុំមានទម្លាប់ប្រើឈ្មោះសិស្សពេលនិយាយជាមួយគេ ។ ខ្ញុំគ្មានទម្លាប់ចង្អុលសិស្សដោយគ្មានហៅឈ្មោះ ។ | | | |
| ១៤. ខ្ញុំព្យាយាមជួយសិស្សទាំងអស់គ្នាចូលរួម ។ ចំពោះសិស្សដែលរៀនពូកែ និង មានសមត្ថភាពខ្ពស់ ខ្ញុំសួរសំណួរពិបាក និងស្មុគស្មាញ ។ ចំពោះសិស្សដែលមិនសូវពូកែឬមិនសូវមានភាពក្លាហាន ខ្ញុំសួរសំណួរស្តីអំពីខ្លឹមសារដែលគេអាចយល់ចម្លើយ ។ | | | |
| ១៥. ខ្ញុំព្យាយាមបង្កលក្ខណៈស្និទ្ធស្នាលដល់សិស្សរបស់ខ្ញុំ ។ ខ្ញុំព្យាយាមរកពេលនិយាយលេងជាមួយសិស្សរបស់ខ្ញុំ សួរអំពីចំណាប់អារម្មណ៍របស់គេ សួរអំពីព័ត៌មានក្នុងគ្រួសារគេ ( មនុស្សឈឺ ឬ មនុស្សរៀបអាពាហ៍ពិពាហ៍ហើយ) ឬសួរអំពីសៀវភៅដែលគេទើបបានអានក្នុងបណ្ណាល័យ ។ | | | |
| ១៦. ពេលដែលពន្យល់ ឬ បង្ហាញខ្លឹមសារថ្មីដល់សិស្សទាំងអស់ ខ្ញុំវាយតម្លៃការយល់ដឹងរបស់សិស្ស ជាបណ្តើរៗ ដោយសួរសំណួរដល់សិស្សជាបុគ្គល ។ | | | |
| ១៧. ពេលដែលសិស្សឆ្លើយសំណួរ ឬ ផ្តល់ព័ត៌មាន ខ្ញុំមានបច្ចេកទេសសួរសំណួរថែមទៀតដល់សិស្សដើម្បីឱ្យសិស្សផ្តល់ព័ត៌មានថែមទៀត ឬ ឆ្លុះបញ្ចាំងទៅលើចម្លើយដំបូងរបស់គេ ។ | | | |
| ១៨. ខ្ញុំមិនប្រើពាក្យសរសើរដដែលៗ ឬ វិធីលើកទឹកចិត្តដដែលៗ ( ដូចជា ទះដៃមួយ )ជានិច្ចកាលដោយសារខ្ញុំយល់ថា ប្រើល្បិចដដែលៗនាំឱ្យសិស្សធុញទ្រាន់ និង មិនសូវមានប្រសិទ្ធភាព ។ | | | |
| ១៩. ខ្ញុំស្គាល់សិស្សក្នុងថ្នាក់ ដែលមានបញ្ហាសម្រាប់ធ្វើទំនាក់ទំនងដូចជា ការអន់ភ្នែក ឬ អន់ត្រចៀក។ ខ្ញុំជួយសិស្សនេះឱ្យគេអង្គុយតាមកន្លែងសមស្រប ។ | | | |
| **សកម្មភាព ឬ ទម្លាប់របស់គ្រូដែលយើងចង់បាន** | **ពិន្ទុ** | | |
| | **១** | **២** | **៣** |
| ២០.ពេលដែលសិស្សម្នាក់ឆ្លើយសំណួរ ខ្ញុំចៀសវាងសួរសំណួរត្រឡប់ទៅសិស្សដទៃទៀតថា ចម្លើយនេះ " ត្រូវ ឬ ខុស " ដល់សិស្សដទៃទៀត ពេលដែលសិស្សម្នាក់ឆ្លើយសំណួរ ខ្ញុំចេះប្រើសំណួរដូចជា : " តើប្អូនឯកភាពនឹងចម្លើយរបស់ដារ៉ា ដែរឬទេ ? " ឬ " តើ ហួន មានគំនិតយោបល់ថែមទៀតទៅលើយោបល់របស់ឡុន ដែរឬទេ ? " | | | |
| ២១. ខ្ញុំចៀសវាងសំណួរ " យល់ឬទេ " ក៏ប៉ុន្តែខ្ញុំសួរថា " តើប្អូនណាអាចពន្យល់ខ្លឹមសារនេះឡើងវិញបាន ? " | | | |

| | | | |
|---|---|---|---|
| ២២. ខ្ញុំមិនថាតាមចម្លើយរបស់សិស្សឡើងវិញទេ ក៏ប៉ុន្តែខ្ញុំប្រើភាសាដូចតទៅ ÷<br>- តើប្អូនឯកភាពនឹងចម្លើយរបស់ ដារ៉ា ដែរឬទេ ?<br>- តើប្អូនមានគំនិតយោបល់ថែមទៀតទៅលើគំនិតរបស់ ឡុន ដែរឬទេ ?<br>ដូច្នេះសិស្សរបស់ខ្ញុំដឹងច្បាស់ថា គេត្រូវតែស្តាប់គំនិតយោបល់របស់សិស្សដទៃទៀត ។ | | | |
| ២៣. ខ្ញុំមិនចំណាយពេលវេលាយូរពេក ដើម្បីនិយាយ ឬ ពន្យល់ខ្លឹមសារលើក្តារខៀន ។ ក៏ប៉ុន្តែ មេរៀនរបស់ខ្ញុំត្រូវតែរួមបញ្ចូលក្នុងការពន្យល់ជាក្រុមធំ និង កិច្ចការជាក្រុមតូច ឬ ជាបុគ្គល ។ ជាធម្មតាការពន្យល់របស់ខ្ញុំដល់ក្រុមធំមិនលើសពី ១០ នាទី ( ៥ នាទី សម្រាប់ថ្នាក់ទី១ ទី ២) | | | |
| ២៤. ពេលដែលខ្ញុំកំពុងនិយាយជាមួយថ្នាក់ទាំងមូល ឬ ក៏មានសិស្សម្នាក់កំពុងនិយាយក្នុងក្រុមធំ ខ្ញុំ បង្ខំអោយសិស្សដទៃទៀតស្ងាត់ស្ងៀមហើយនឹងស្តាប់ ។ ខ្ញុំជួយឱ្យសិស្សនឹកឃើញអំពី សារសំខាន់នៃការគោរពអ្នកនិយាយ ដើម្បីផលប្រយោជន៍យើងទាំងអស់គ្នា ។ | | | |
| ២៥. ពេលដែលខ្ញុំ ឬ សិស្សម្នាក់កំពុងនិយាយ ហើយសិស្សដទៃទៀតរំខាន ខ្ញុំចេះដោះស្រាយបញ្ហា នេះភ្លាមៗ ដោយប្រើសញ្ញា ប្រើទឹកមុខ ខ្សែភ្នែក ប៉ុណ្ណោះដោយគ្មានរឿងវែងឆ្ងាយ ។ | | | |
| ២៦. ខ្ញុំពន្យល់សេចក្តីណែនាំឡើងវិញ ឬ ឱ្យសិស្សម្នាក់ពន្យល់ឡើងវិញដល់សិស្សទាំងអស់គ្នាយល់ ច្បាស់មុននឹងចាប់ផ្តើមសកម្មភាពជាក្រុមតូច ឬ ជាបុគ្គល ។ | | | |
| ២៧. មុននឹងចាប់ផ្តើមពន្យល់ខ្លឹមសារសំខាន់ ខ្ញុំពិនិត្យមើលថា សិស្សទាំងអស់កំពុងយកចិត្តទុកដាក់ និង មានស្មារតីមូលល្អដែរឬទេ ? ឧទាហរណ៍ : សិស្សពុំទាន់ឈប់សរសេរមេរៀនចាស់ ឬ សិស្សកំពុងមើលសៀវភៅ ឬ សិស្សលេងវត្ថុផ្សេងៗលើតុ ។ | | | |
| **សកម្មភាព ឬ ទម្លាប់របស់គ្រូដែលយើងចង់បាន** | **ពិន្ទុ** | | |
| | **១** | **២** | **៣** |
| ២៨. ខ្ញុំពិនិត្យតុរបស់សិស្សមានសណ្តាប់ធ្នាប់មិនល្អ ដោយមានសម្ភារច្រើនពេកធ្វើអោយស្មារតី របស់គេមិនហ្នឹងហ្ន ។ | | | |
| ២៩. ពេលដែលខ្ញុំកំពុងនិយាយជាមួយសិស្ស ខ្ញុំត្រូវសម្លឹងទៅរកសិស្ស ។ | | | |
| ៣០.ខ្ញុំព្យាយាមសួរសំណួរដល់សិស្សច្រើននាក់ តាមលទ្ធភាព មិនត្រឹមតែសិស្សដែលលើកដៃ និង មានភាពក្លាហានប៉ុណ្ណោះទេ ។ | | | |

ឯកសារទី៣: ឧបសម្ព័ន្ធ ខ-ទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព

## ទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព ~ ការសួរសំណួរ

**សេចក្តីផ្តើម :**

ទម្លាប់ក្នុងថ្នាក់រៀនកន្លងមក គ្រូជាអ្នកសួរសំណួរ ហើយសិស្សព្យាយាមឆ្លើយនឹងសំណួរទាំងនោះ ។ វាកម្រកើតមានឡើងណាស់ដែលសិស្សសួរសំណួរទៅដល់គ្រូ ។ ម្យ៉ាងទៀតសិស្សភាគច្រើនក្នុងថ្នាក់រៀន មិនដែលមានឱកាសសួរសំណួរគ្នាទៅវិញទៅមកទេ ។

ក្នុងបន្ទប់រៀនកុមារមេត្រី គ្រូគួរតែបង្កើតស្ថានភាពដែលមានលក្ខណៈដូចខាងក្រោម ៖

- កុមារមានភាពក្លាហានក្នុងការសួរសំណួរ
- កុមារស្តាប់សំណួរដែលត្រូវបានសួរពីមិត្តភក្តិ
- កុមារព្យាយាមឆ្លើយសំណួរដែលត្រូវបានសួរដោយមិត្តភក្តិរបស់គេ ដោយប្រើចំណេះ ដឹង និង បទពិសោធដែលគេមានរួចហើយ ឬ ក៏គេប្រើរូបមន្តដែលគេបានចេះ ។

ស្ថានភាពដូចខាងលើនេះ មិនមែនមានន័យថា គ្រូមិនសួរសំណួរនោះទេ ។ គ្រូគួរតែបន្តសួរសំណួរ ជាជំនួយសម្រាប់ណែនាំសិស្សក្នុងការរៀនសូត្រ ។ ទោះបីជាយ៉ាងណាក៏ដោយ គ្រូល្អ គួរតែផ្តល់ឱកាសឱ្យ សិស្សសួរសំណួរផងដែរ ។ ម្យ៉ាងទៀតគ្រូល្អគួរតែធានាថាសិស្សស្តាប់គ្នាទៅវិញទៅមកដោយយកចិត្តទុក ដាក់ ។ ការបង្រៀនបែបសហការមិនមែនជាស្ថានភាពមួយដែលសិស្សអង្គុយជាក្រុមតូចហើយប្រើប្រាស់ សម្ភារឧបទេសនោះទេ ។ គោលការណ៍ចម្បងនៃការសិក្សាបែបសហការ គឺជាទំនាក់ទំនងរវាងសិស្ស និង សិស្សប្រកបដោយប្រសិទ្ធភាព ។ ទំនាក់ទំនងប្រកបដោយប្រសិទ្ធភាពនេះ រួមបញ្ចូលទាំងបំណិននៃការ ស្តាប់ ( សំណួរ និង ចម្លើយ ) និង ការនិយាយ ( បង្កើតសំណួរ និង ចម្លើយ ) ។

ការកែទម្លាប់ចាស់ គឺជាការលំបាកមួយនៃការបង្កើតថ្នាក់រៀនកុមារមេត្រី ។ គ្រូ និង សិស្សអាចជួប ការលំបាកដោយសារទម្លាប់ចាស់ ។ ក៏ប៉ុន្តែប្រសិនជាគ្រូរំលឹកឡើងវិញពីប្រសិទ្ធភាពនៃសកម្មភាពក្នុងថ្នាក់ រៀន និង រៀបចំមេរៀនតាមសេចក្តីត្រូវការរបស់សិស្ស គ្រូអាចកែទម្លាប់បាន ហើយថ្នាក់គំរូកុមារមេត្រីអាច ក្លាយទៅជាគំរូសម្រាប់គ្រូដទៃទៀត ។

កម្មវិធីសាលាកុមារមេត្រីចង់សង្កត់ធ្ងន់ទៅលើការពង្រឹងបំណិនគិតដោយវិភាគ និងច្នៃប្រឌិតរបស់ កុមារ ។ គ្រូពង្រឹងការគិតនិងច្នៃប្រឌិតនេះដោយធ្វើជាអ្នកសម្របសម្រួលក្នុងស្ថានភាពដែលសិស្សមានឱកាស សួរសំណួរនិងឆ្លើយសំណួររបស់មិត្តភក្តិ ។ ស្ថានភាពដូចនេះអាចជួយធ្វើឱ្យមានទំនាក់ទំនងរវាងចំណេះដឹង និង បំណិនមុខវិជ្ជាផ្សេងៗកាន់តែប្រសើរឡើង ។

**លំនាំនៃការពង្រឹងទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព សម្រាប់ថ្នាក់ទី ៣ , ៤ , ៥ , ៦**

1. រៀបចំផ្ទាំងក្រដាសដែលមានបញ្ជីពាក្យ និង សំណួរ : ឧ : តើ ហេតុអ្វី ដូចម្តេច ... ( ពាក្យ និងឈ្មោះសំណួរ ត្រូវមានទំហំធំសមល្មមដែលសិស្សទាំងអស់អាចមើលឃើញ )

2. នៅចុងបញ្ចប់នៃមេរៀន គ្រូឱ្យសិស្សសហការជាមួយគ្នាជាក្រុមតូច ឬ ជាដៃគូ ដើម្បីបង្កើតសំណួរស្តីពីអត្ថបទដែលគេទើបបានសិក្សារយៈពេល ២ ឬ ៣ នាទី ។ “ តើមានចំណុចណាខ្លះក្នុងអត្ថបទដែលប្អូនមិនទាន់ច្បាស់ ?តើមានចំណុចណាខ្លះក្នុងអត្ថបទដែលប្អូនៗមានចម្ងល់ ឬ ចង់រៀនបន្ថែមទៀត ? ” អាចធ្វើសកម្មភាពនេះលើមុខវិជ្ជាសិក្សាសង្គម ភាសាខ្មែរ ឬ វិទ្យាសាស្ត្រអនុវត្ត

3. មុននឹងសិក្សាលំអិតពីអត្ថបទថ្មី គ្រូឱ្យសិស្សរកពាក្យថ្មីៗ ឬ ពាក្យពិបាកអាន និង យល់ ។ ម្យ៉ាងទៀតសិស្សអាចលើកចំណុចមួយចំនួនដែលគេឆ្ងល់ និង ឱ្យគ្រូពន្យល់បន្ថែម

4. សិស្សកត់ត្រាសំណួររបស់គេក្នុងសៀវភៅកម្រងសំណួរដែលអាចទុកលើតុរបស់ក្រុមជាអចិន្ត្រៃយ៍

5. គ្រូឱ្យសិស្សមួយចំនួនសួរសំណួរផ្ទាល់មាត់ ។ ជំរុញឱ្យសិស្សដទៃទៀតស្តាប់និងឆ្លើយសំណួរ ។ ដើម្បីឱ្យសិស្សមានបំរុងប្រយ័ត្ន គ្រូជ្រើសរើសសិស្សផ្សេងទៀតនិយាយឡើងវិញពីសំណួររបស់មិត្តភក្តិ ។

6. ក្រុមសិស្សអាចអានអត្ថបទដោយស្ងាត់ហើយបង្កើតសំណួរស្តីពីអត្ថបទសរសេរដាក់ក្នុង *សៀវភៅកម្រងសំណួរ* ។ សិស្សអាចប្រើផ្ទាំងក្រដាសបញ្ជីពាក្យ និង សំណួរជាជំនួយ ។ គ្រូអាចកំណត់ពេល ១០ នាទី សម្រាប់សកម្មភាពនេះ រួចក្រុមសិស្សផ្លាស់ប្តូរសៀវភៅរបស់គេទៅវិញទៅមក ។ ក្រុមសិស្សអាចពិភាក្សា ដើម្បីឆ្លើយនឹងសំណួរ ហើយប្រធានក្រុមកត់ត្រាចម្លើយលើផ្ទាំងក្រដាស ។

## ការសម្របសម្រួលប្រកបដោយប្រសិទ្ធភាព សម្រាប់ថ្នាក់ទី ៣ , ៤ , ៥ , ៦

1. មុនដំបូងសិស្សនៅមានភាពអៀនខ្មាសមិនសូវក្លាហាន គ្រូគួរតែលើកទឹកចិត្តគេហើយជំរុញឱ្យគេនិយាយឮៗ ។ ប្រសិនបើសិស្សបែរទៅរកជញ្ជាំង ឬ ក្ដារខៀន សិស្សដទៃទៀតពិបាកស្ដាប់ ដូចនេះ គ្រូត្រូវឱ្យសិស្សបែរមុខមករកមិត្តភក្ដិរបស់គេ ។

2. ជាការសំខាន់ គ្រូមិនត្រូវនិយាយឡើងវិញតាមសំណួរ និង ចម្លើយរបស់សិស្សទេ ។ ប្រសិនជាសិស្សដទៃទៀតដឹងថាគ្រូនិយាយឡើងវិញជានិច្ចកាលនូវអ្វីៗដែលសិស្សម្នាក់បាននិយាយ សិស្សដទៃទៀតមិនសូវយកចិត្តទុកដាក់លើសិស្សផ្សេងទៀត ប៉ុន្តែគេគ្រាន់តែរង់ចាំឱ្យគ្រូនិយាយឡើងវិញ ។ ទោះបីយ៉ាងណាក៏ដោយ គ្រូអាចជួយសិស្សកែសម្រួលសំណួរ ឬ ចម្លើយឡើងវិញ ប្រសិនបើសំណួរ ឬ ចម្លើយរបស់សិស្សនោះមិនច្បាស់លាស់ ។

3. គ្រូគួរតែត្រួតពិនិត្យខ្លឹមសារនៃសំណួរដែលបង្កើតដោយសិស្ស ។ ប្រសិនបើខ្លឹមសារសំណួរដូចគ្នានឹងខ្លឹមសារដែលមានក្នុងសៀវភៅ ឬ ដែលគ្រូបានសួររួចហើយគ្រូគួរតែជួយឱ្យសិស្សច្នៃប្រឌិតបង្កើតសំណួរផ្សេងទៀត ។ គ្រូអាចជួយឱ្យសិស្សមើលបញ្ជីពាក្យ សំណួរ ប្រសិនបើគេពិបាករក ។

4. គ្រូគួរតែត្រួតពិនិត្យលើប្រភេទសំណួរដែលសិស្សពេញចិត្តប្រើប្រសិនជាគេប្រើសំណួរតែមួយប្រភេទច្រើនពេក (ឧ . ជានិច្ចកាលគេចាប់ផ្ដើមសំណួរដោយប្រើពាក្យ " ហេតុអ្វី ? ") គ្រូគួរណែនាំសិស្សឱ្យមើលផ្ទាំងបញ្ជីពាក្យ សំណួរ ដើម្បីប្រើសំណួរប្រភេទផ្សេងទៀត ឧ . ដូចម្ដេច យ៉ាងណា ... ។

## <u>លំនាំនៃការពង្រឹងទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព សម្រាប់ថ្នាក់ទី ១</u>

1. គ្រូគួរតែរៀបចំប័ណ្ណពាក្យ មានពាក្យសំណួរ ដែលប្រើជាញឹកញាប់ក្នុងថ្នាក់ទី ១ ( ប័ណ្ណពាក្យគួរយកទំហំធំល្មមអាចសិស្សមើលឃើញ ) ឧ. អ្វី អ្នកណា ពណ៌អ្វី ប៉ុន្មាន ឯណា ...។ ពេលដែលគ្រូសួរសំណួរអំពីរូបភាព ឬ ស្ថានភាពណាមួយគ្រូអាចបង្ហាញប័ណ្ណពាក្យសំណួរឱ្យសិស្សមើល ។

2. ជំរុញឱ្យសិស្សមើលរូបភាព និងបង្កើតសំណួរងាយៗដោយផ្ទាល់មាត់ ។ ( ឧ . "តើសេះមានពណ៌អ្វី?" "តើកុមារានៅឯណា ?" "តើមានកុមារីប៉ុន្មាននាក់ ?" ។ ល ។ )

ពេលដែលសិស្សបង្កើតសំណួរ ផ្ទាល់មាត់ឱ្យគេចង្អុលបង្ហាញប័ណ្ណពាក្យ ដែលត្រូវនឹងសំណួរនេះ ។ ឱ្យសិស្សដទៃទៀតព្យាយាម ឆ្លើយ ។

3. ពេលគ្រូដឹងថា សិស្សស្គាល់ពាក្យ និង ល្បះសំណួរនេះ គ្រូអាចរៀបចំល្បះពេញលេញសរសេរលើក្រដាសតូចដើម្បីដាក់ក្នុងធនាគារពាក្យ ។ សំណួរនេះគួរតែឱ្យមានការទាក់ទងនឹងស្ថានភាពជាក់ស្តែងនៃជីវិតរបស់សិស្ស ( ឧ. តើប្អូនឈ្មោះអ្វី ? តើថ្ងៃនេះជាថ្ងៃអ្វី ? តើតុនេះពណ៌អ្វី ? តើផ្ទះប្អូននៅឯណា ? តើប្អូនមានបងប្អូនប៉ុន្មាននាក់ ? )

4. សិស្សនៅថ្នាក់ទី ១ មានបំរុងប្រយ័ត្នយកចិត្តទុកដាក់ក្នុងរយៈពេលខ្លី ដូចនេះពេលគ្រូប្រើសកម្មភាពសួរនិងឆ្លើយសំណួរអំពីរូបភាព ឬ ព្រឹត្តិការណ៍មួយមិនគួរចំណាយពេលច្រើនពេកទេ ។ វាអាចបានផលល្អជាប្រសិនបើគ្រូសម្របសម្រួលការពិភាក្សារយៈពេល ២ នាទីម្តងៗ ហើយ ៥ ដងក្នុង ១ ថ្ងៃ ( អស់ ១០ នាទី ) ជាជាងធ្វើសកម្មភាព ១ ដង រយៈ ពេល ១០ នាទី ។

5. គ្រូអាចពង្រឹងទំនាក់ទំនងដែលមានប្រសិទ្ធភាព ដោយប្រើពាក្យ ឬ ឃ្លាដែលធ្វើឱ្យសិស្សចាប់អារម្មណ៍ច្រើនជាងពាក្យបញ្ជាដើម្បីទាញអារម្មណ៍សិស្សឱ្យផ្តោតមកលើអ្វីៗដែលគ្រូចង់និយាយ ( ឧៈ ប្អូនៗ ទាំងអស់សូមស្ងាត់ដូចចោរលួចសេះ អង្គុយឱ្យស្ងៀមដូចដុំថ្ម ទះដៃ ក្រោកឡើងពត់ខ្លួនឈរដូចបង្គោលរបង ... ) ។

## ការសម្របសម្រួលប្រកបដោយប្រសិទ្ធភាព សម្រាប់ថ្នាក់ទី ១-២

១. ឱ្យសិស្សនិយាយជាបុគ្គល កុំឱ្យគេនិយាយ ឬ ស្រែកជាក្រុម ។ ជំរុញឱ្យសិស្សលើកដៃមុន និង និយាយហើយរងចាំការអនុញ្ញាតពីគ្រូ ។ ជាការភ័ន្តច្រឡំមួយដែលគិតថាសិស្សរៀនសូត្រដោយស្រែកឱ្យឮខ្លាំង។ ពេលដែលសិស្សស្រែកខ្លាំង១ជាក្រុម តើគេយល់អំពីអ្វីដែលគេកំពុងនិយាយនោះដែរឬទេ ? (ចូរពិចារណាអំពីមនុស្សដែលចូលរួមក្នុងពិធីសូត្រមន្តដោយប្រើភាសាបាលី ។ មនុស្សខ្លះអាចសូត្របាន តែពួកគេមិនយល់ន័យនៃពាក្យក្នុងនោះទេ ។ គ្រូត្រូវប្រុងប្រយ័ត្នពីស្ថានភាពនេះដែលអាចកើតមានឡើង ក្នុងបន្ទប់រៀន ) ។ ប្រសិនថ្នាក់រៀនដែលមានចំនួនសិស្សពី ៤៥ ដល់ ៥០នាក់សិស្សនិយាយ សូត្រព្រម១គ្នា តើគ្រូ អាចធានាថាសិស្សខ្សោយត្រូវបានសូត្រឬទេ ? គ្រូគួរប្រយ័ត្ន : សិស្សខ្សោយគ្រាន់តែនិយាយ ឬ ថា តាមសិស្សដែលនៅជិត១ ប៉ុន្តែគេមិនយល់ន័យ ។ ពេលដែលសិស្សនិយាយ ឬ អានព្រម១គ្នា តើគ្រូអាចធ្វើ ការវាយតម្លៃការរៀនសូត្ររបស់សិស្សបានឬទេ ? តើគ្រូអាចកំណត់បានថាសិស្សណាខ្លះមានការយល់ដឹង ពេញលេញ មានការយល់ដឹងខ្លះ ហើយនិងសិស្សណាខ្លះមិនយល់សោះ ? ពេលដែលសិស្សនិយាយ ឬ អាន ព្រម១គ្នា តើគ្រូអាចធានាថា សិស្សម្នាក់១បន្លឺសម្លេងបានត្រឹមត្រូវឬទេ ?

២. ពេលដែលសិស្សម្នាក់ឆ្លើយ គ្រូមិនគួរសួរទៅសិស្សដទៃទៀតជាក្រុមធំដោយប្រើពាក្យថា "ត្រឹមត្រូវឬទេ? " នោះទេ។ ក៏ប៉ុន្តែគ្រូអាចសួរទៅសិស្សម្នាក់ "តើប្អូនយល់ស្របជាមួយចម្លើយរបស់សុខាឬទេ ? " ។ គ្រូអាចសួរទៀត "បើយល់ស្រប ហេតុអ្វី ? " "បើមិនយល់ស្រប ហេតុអ្វី? " "តើប្អូនអាចលើកឧទាហរណ៍ ផ្សេងទៀតបញ្ជាក់បានឬទេ ? " (ធ្វើដូចនេះវាល្អជាងដែលគ្រូបដិសេធចម្លើយខុសរបស់សិស្សចំ១តែម្តង ) ។

៣.ពេលដែលគ្រូជំរុញសិស្សលើកដៃមុននិយាយ គ្រូមានឱកាសត្រួតពិនិត្យការចូលរួមរបស់សិស្សខ្សោយ។ ម្យ៉ាងទៀត គ្រូមានឱកាសធានាថាសិស្សទាំងអស់មានឱកាសនិយាយ ។

<u>ចំណាំ</u> : យើងទទួលស្គាល់ថា វាមានការលំបាកសម្រាប់សិស្សថ្នាក់ទី ១ ព្រោះសិស្សម្នាក់១មានការរំភើប និងចង់និយាយ ។ ក៏ប៉ុន្តែគ្រូគួរតែពង្រឹងទម្លាប់ល្អ ហើយដឹងសរសើរសិស្សដែលព្យាយាមស្តាប់ និង យកចិត្ត ទុកដាក់ ។ គ្រូប្រើពាក្យសរសើរ និងលើកទឹកចិត្តដូចខាងក្រោម :

"ល្អណាស់ ! សុខា ប្អូនអាចពន្យល់បានអំពីអ្វី១ ដែលគ្រូបាននិយាយ "តើប្អូនណាខ្លះទៀតអាច និយាយប្រាប់លោកគ្រូពីអ្វី១ ដែលដារ៉ាបាននិយាយទេ ?... អូ ! ល្អណាស់សុភាពប្អូនបានយកចិត្តទុកដាក់ ស្តាប់ដារ៉ានិយាយ ..." ។ ពេលដែលយើងមានទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព (គឺជាការនិយាយ និង ការស្តាប់ជាមួយមនុស្សផ្សេង ទៀត) គ្រូបានបង្កើតស្ថានភាពដែលសិស្សសន្ទនាបានល្អ ។ ដូចនេះគ្រូគួរតែផ្តល់ ឱកាសឱ្យសិស្សអនុវត្តការសន្ទនាជានិច្ចកាល មិនមែនគ្រូគ្រាន់តែធ្វើការសន្ទនាក្នុងមេរៀនសន្ទនាដែល បានកំណត់ក្នុងសៀវភៅសិក្សានោះទេ ។

## ឯកសារទី៤:  តារាងសង្ខេបខ្លឹមសារពីឯកសារទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព

| លក្ខណៈទំនាក់ទំនងដែលប្រកបដោយប្រសិទ្ធភាព | ឧបសគ្គរារាំងទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព | ល្បិចផ្សេងៗ សម្រាប់អភិវឌ្ឍសមត្ថភាពស្តាប់ និង និយាយ | ល្បិចផ្សេងៗ ដើម្បីបង្កើនវាក្យស័ព្ទរបស់សិស្ស |
|---|---|---|---|
| | | | |

## ឯកសារទី៥: សកម្មភាពរៀនសូត្រផ្សេងៗ ដែលអាចបង្កើនទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព

| សកម្មភាព | សមត្ថភាពស្តាប់ និង សមត្ថភាពនិយាយ | ការអភិវឌ្ឍវាក្យស័ព្ទ |
|---|---|---|
| អំណានស្ងាត់<br>ពិភាក្សាជាក្រុមតូច<br>**អំណានឮ**<br>ពិភាក្សាជាក្រុមធំ<br>សន្ទនកថា<br>សម្តែងតួ<br>ការប្រើប្រាស់តុក្កតា<br>ការសិក្សាកំណាព្យ<br>សង្កថា<br>ការប្រើប្រាស់ធនាគារពាក្យ<br>កៀនបណ្ណាល័យ<br>កត់ត្រាពាក្យក្នុងសៀវភៅធនាគារពាក្យ<br>ពាក្យថ្មី ដោយវិភាគអត្ថន័យ<br>បញ្ជីវាក្យស័ព្ទ<br>លំហាត់ដែលទាមទារឱ្យសិស្សយល់ន័យនៃ<br>ក្តារខៀនជូនព័ត៌មាន<br>ការប្រើប្រាស់វចនានុក្រម | | |

## ឯកសារទី៦: ការអភិវឌ្ឍបំណិនស្ដាប់ និងបំណិននិយាយ ក្នុងបរិស្ថានរៀនសូត្រដែលមានលក្ខណៈកុមារមេត្រី

• ដើម្បីអភិវឌ្ឍសមត្ថភាពស្ដាប់ និងសមត្ថភាពនិយាយរបស់សិស្ស គ្រូអាចសាកល្បងវិធីមួយ ដែលគេហៅថា ÷ " ការនិយាយជាតុមូល "។ ក្នុងការរៀបចំ " ការនិយាយជាតុមូល " គ្រូត្រូវតែប្រែប្រួលបរិស្ថាន ក្នុងថ្នាក់រៀន ដើម្បីធ្វើឱ្យសិស្សហ៊ានបញ្ចេញគំនិតយោបល់ច្រើនជាងពេលរៀនធម្មតា ។ ដូច្នេះថ្នាក់រៀនមានលក្ខណៈស្និទ្ធស្នាល។ ក៏ប៉ុន្តែទោះបីជាថ្នាក់មានលក្ខណៈស្និទ្ធស្នាលយ៉ាងនេះក៏ដោយគ្រូនៅតែរៀបចំលំនាំច្បាស់លាស់ក្នុងការបង្រៀន ។

• ក្នុងការពិភាក្សាជាតុមូល សិស្ស និង គ្រូ អង្គុយក្នុងរបៀបដែលគេទាំងអស់គ្នាអាចមើលឃើញ និងស្ដាប់គ្នាបានព្រោះថ្នាក់កុមារមេត្រីងាយស្រួលឱ្យសិស្សរៀបចំកៅអីអង្គុយជារង្វង់មូល ។

<u>**សេចក្ដីណែនាំក្នុងការរៀបចំការនិយាយជាតុមូល**</u>

- សិស្ស និង គ្រូគួរអង្គុយក្នុងរបៀបងាយស្រួលមើលមុខគ្នាទៅវិញទៅមក
- មិនគួរធ្វើសកម្មភាពនេះលើសពី ២០ នាទី
- គួរតែរៀបចំកាលវិភាគដើម្បីធានាថា សិស្សទាំងអស់មានឱកាសបាននិយាយម្នាក់ម្ដងៗ ពីមេរៀនមួយទៅមេរៀនមួយទៀត
- គ្រូគួរត្រួតពិនិត្យពេលវេលា
- ក្រោយពីសិស្សម្នាក់និយាយចប់ គ្រូគួរសួរសំណួរទៅសិស្សដទៃទៀតអំពីអ្វីដែលគេបាននិយាយ ។ ប្រសិនបើសិស្សដឹងថាគ្រូនឹងសួរសំណួរបែបនេះ សិស្សនឹងខិតខំស្ដាប់ដោយយកចិត្តទុកដាក់
- ក្នុងរយៈពេល ២០ នាទី សិស្សពី ៤ ទៅ ៥ នាក់ អាចមានឱកាសនិយាយ
- សិស្សដទៃទៀតចូលរួមក្នុងការនិយាយជាតុមូល ដោយសួរសំណួរទៅអ្នកនិយាយ ។ ជាលើកដំបូងដោយសារសិស្សគ្មានបទពិសោធក្នុងការសួរសំណួរ គ្រូគួរតែសួរសំណួរមួយចំនួនជាគំរូ ។

<u>ចំណាំ</u> : ពេលដែលសិស្សមានទម្លាប់ពីការនិយាយជាតុមូល សិស្សអាចចាប់ផ្ដើមរៀបចំដោយខ្លួនឯង ហើយគ្រូគ្រាន់តែជាអ្នកសម្របសម្រួល ។

- ខាងក្រោមនេះ មានខ្លឹមសារមួយចំនួនដែលគ្រូអាចសាកល្បងធ្វើជាមួយសិស្សក្នុងការរៀប ចំសកម្មភាពការនិយាយ ជាតុមូល ។ អ្នកសម្របសម្រួលគួរតែបែងចែកបញ្ជីដូចខាងក្រោម ដល់សិក្ខាកាមទាំងអស់ ។

<u>ប្រធានបទមួយចំនួនសម្រាប់សកម្មភាពការនិយាយជាតុមូល</u>

<u>ព័តិមានផ្ទាល់ខ្លួន និង ព័តិមានទូទៅ</u> :

- ថ្នាក់ទី ១ ដល់ ថ្នាក់ទី ៦ :

  សិស្សមានឱកាសនិយាយអំពីអ្វីមួយដែលបានកើតឡើងក្នុងសប្តាហ៍កន្លងមក

<u>ចំណាប់អារម្មណ៍ បំណិន សកម្មភាពកំសាន្ត</u> :

- ថ្នាក់ទី ១ ដល់ ថ្នាក់ទី ៦ :

  សិស្សមានឱកាសបង្ហាញអំពីអ្វីមួយដែលគេមានចំណេះដឹងពិសេស ឬ អ្វីមួយដែលគេចាប់អារម្មណ៍ដូចជា : សកម្មភាពកំសាន្ត សកម្មភាពកីឡា មុខរបរដែលគេពេញចិត្ត ។ល ។

<u>សៀវភៅ</u> :

- ថ្នាក់ទី ៣ ដល់ ថ្នាក់ទី ៦ :

  សិស្សមានឱកាសនិយាយអំពីសៀវភៅដែលគេទើបតែបានអាន ។ សិស្សអានឱ្យឮ ផ្នែកតូចមួយក្នុងសៀវភៅដែលគេពេញចិត្ត។ សិស្សផ្សេងទៀតអាចសួរសំណួរអំពីសៀវភៅ ។ គ្រូគួរតែរៀបចំកាលវិភាគដើម្បីផ្តល់ឱកាសឱ្យសិស្សទាំងអស់និយាយអំពីសៀវភៅដែលគេបានអាន ។ សិស្សអាចដកស្រង់ចេញពីគំនិតយោបល់ខ្លះៗ ដែលគេបានសរសេរក្នុងរបាយការណ៍អានសៀវភៅសម្រាប់សកម្មភាពនេះឱ្យសិស្សអង្គុយមើលក្បៀនបណ្ណាល័យ ។

<u>អត្ថបទក្នុងកាសែត</u> :

- ថ្នាក់ទី ៥ ដល់ ថ្នាក់ទី ៦ :

  សិស្សមានឱកាសនិយាយអំពីអត្ថបទមួយដែលគេបានអានក្នុងសារព័តិមាន ។ សិស្សអាចអានអត្ថបទនេះឱ្យឮ ហើយនឹងបញ្ចេញគំនិតយោបល់បន្ថែមទៀត ។ សិស្សអាចពន្យល់អំពីមូលហេតុដែលគេមានគំនិតនេះក្រោយពីបានអានកាសែត។ សិស្សដទៃទៀតអាចសួរសំណួរ ឬ បញ្ចេញគំនិតយោបល់អំពីគំនិតនេះ។ គ្រូគួរតែជួយឱ្យសិស្សញែកពីការពិត និង គំនិត ។ អាចភ្ជាប់សកម្មភាពនេះទៅនឹងសកម្មភាពក្តារខៀនជូនព័តិមាន

<u>កម្រងស្នាដៃសិស្ស</u> :

- ថ្នាក់ទី ១ ដល់ ថ្នាក់ទី ៦ :

  សិស្សមានឱកាសនិយាយអំពីស្នាដៃរបស់ខ្លួន ។ សិស្សអាចនិយាយអំពីរូបភាពដែលគេបានគូរ ឬ តែងសេចក្តីដែលគេបានសរសេរ ។ ម្យ៉ាងទៀត សិស្សអាចនិយាយអំពីការរីកចំរើនរបស់ខ្លួន ដោយប្រៀបធៀបស្នាដៃបច្ចុប្បន្នទៅនឹងស្នាដៃ ២-៣ ខែ កន្លងមក ។

កម្មវិធីគាំទ្រសេវាអប់រំកុមារនៅតំបន់ដាច់ស្រយាល( អេស្កាប់)

EQUIP1
Educational Quality Improvement Program
Classrooms • Schools • Communities

## ឯកសារបណ្តុះបណ្តាលគ្រូថ្នាក់កុមារមេត្រី
## សម្រាប់បឋមសិក្សា

# ការសិក្សាបែបសហការ
# Co-operative Learning



ខេត្តកំពង់ចាម ប្រទេសកម្ពុជា
ខែ សីហា ឆ្នាំ ២០០៦
**ឯកសារដើមពីអង្គការខេប**

**ឯកសារទី១: ការកំណត់បញ្ហា**

# ករណីសិក្សា និង សំណួរពិភាក្សា

អ្នកគ្រូថ្នាក់ទី ៣ ម្នាក់បានចាប់ផ្តើមមេរៀនរបស់គាត់សាឡើងវិញចំណុចមួយចំនួនអំពីវេយ្យាករណ៍ ដែលជាមេរៀនចាស់ពីថ្ងៃមុនដូចខាងក្រោមនេះ ÷

អ្នកគ្រូ : តើកូនៗមានអ្នកណាចាំបានទេថា ពាក្យថា ផ្លែ ឆ្មា និង ភូមិ មាននៅក្នុងថ្នាក់ពាក្យអ្វី ?

*( មានសិស្ស ២០ នាក់បានលើកដៃយ៉ាងរហ័ស និង មានសិស្ស ១០ នាក់ទៀតមិនបានលើកដៃហើយព្យាយាមលាក់ខ្លួនក្នុងចំណោមមិត្តភក្តិរបស់គេ ហើយសង្ឃឹមថាប្រហែលជាគ្រូមិនហៅចំពួកគេទេមើលទៅ ! ពេលនោះអ្នកគ្រូហៅសុខា ) ។*

សុខា : ជាសុភាសិត ។

( សិស្សទាំងអស់ក្នុងថ្នាក់សើចគិល )

អ្នកគ្រូ : ទេដូចជាមិនទាន់ត្រឹមត្រូវទេ ។

( មុខសុខាឡើងក្រហម ហើយសិស្សដទៃទៀតបានលើកដៃម្តងទៀត ។ សិស្សខ្លះកំពុងតែក្រោកឈរចេញពីតុរបស់ខ្លួន ហើយបានស្រែកថា . . . ) ។

សិស្ស : ខ្ញុំ ខ្ញុំ ខ្ញុំ ខ្ញុំ

អ្នកគ្រូ : មើលសុភាព កូនអាចជួយសុខាឆ្លើយសំណួរនេះបានទេ ?

ប្រភពមកពី : Slavin. R.E. (1993 ) ការសិក្សាបែបសហការ : ទ្រឹស្តីស្រាវជ្រាវ និង អនុវត្តន៍ ។

## សំណួរពិភាក្សា :

1. តាមយោបល់របស់អ្នក តើស្ថានភាពថ្នាក់រៀនបានបង្ហាញខាងលើក្នុងការបង្រៀនបានល្អឬទេ ? ពីព្រោះអ្វី ?
2. តើអ្នកគិតថាមានការប៉ះពាល់អ្វីទេ ចំពោះការប្រឡងប្រជែង សំណួរបែបនេះចំពោះការអភិវឌ្ឍផ្នែកសីលធម៌ របស់កុមារ? ( តើវាធ្វើឱ្យកុមារគិតជួយគ្នាដែរឬទេ ? តើវាធ្វើឱ្យកុមារចូលចិត្តរៀនដែរឬទេ ? )
3. សូមពិចារណាសំណួរដែលអ្នកគ្រូសួរផ្ទាល់ទៅសុភាព ( ឧ. មើលសុភាព កូនអាចជួយសុខាក្នុងការឆ្លើយសំណួរនេះបានទេ ?) តាមស្ថានភាពដែលបានកើតឡើង តើអ្នកគិតថា សុភាពពិតជាមានចិត្តចង់ជួយសុខាឬទេ ? ហេតុអ្វី ?
4. ប្រសិនបើអ្នកជាអ្នកគ្រូខាងលើនេះវិញ តើអ្នកគួរតែផ្លាស់ប្តូរវិធីបង្រៀនបែបណា ?

## ឯកសារទី២: ចំណុចសំខាន់ៗដែលជាលទ្ធផលនៃការពិភាក្សា លើករណីសិក្សាស្តីអំពី គ្រូ និង សុខា

– ស្ថានភាពពិពណ៌នាដែលធ្វើឱ្យមានការពេញចិត្ត : ស្ថានភាពប្រឡងប្រណាំងបានកើតឡើងនៅក្នុងថ្នាក់រៀន ។ មតិមួយចំនួនអះអាងថា ស្ថានភាពបែបនេះជារង្វាន់សម្រាប់សិស្សពូកែហើយអាចជំរុញឱ្យសិស្សខ្សោយកាន់តែខិតខំប្រឹងរៀនខ្លាំងឡើង ។

ឯមតិមួយចំនួនទៀតគិតថា សិស្សខ្សោយលែងមានការជិតស្និទ្ធដោយសារបទពិសោធន៍នេះ ហើយវាអាចនាំឱ្យមានអវត្តមានច្រើន ឬ រហូតដល់បោះបង់ចោលសាលារៀនតែម្តង ។ ការបោះបង់ការសិក្សាដោយសារមូលហេតុខាងលើនេះជាអំពើមួយដែលលោកគ្រូ-អ្នកគ្រូ ចង់ការពារមិនឱ្យមានបញ្ហានោះកើតឡើងទៀត ។

– ឥទ្ធិពលនៃវិធីសាស្ត្របង្រៀនពិពណ៌នាអំពីការអភិវឌ្ឍទឹកចិត្តរបស់សិស្សផ្នែកសីលធម៌ : ដូចបានកត់សំគាល់លើរួចមកហើយថា បរិយាកាសសិក្សាដែលកើតមាននៅក្នុងថ្នាក់រៀនគឺការប្រឡងប្រណាំង។ ប៉ុន្តែយើងគួរពិចារណា តើយើងគួរតែមានការពង្រឹងអាកប្បកិរិយា " សហការ " " ការជួយគ្នា " នៅក្នុងថ្នាក់រៀនដែរឬទេ ? តើយើងចង់បានអាកប្បកិរិយាជួយគ្នាទៅវិញទៅមកក្នុងសង្គមរបស់យើងដែរឬទេ ? វាជាការពិតណាស់អាកប្បកិរិយាបែបនេះដែលយើងចង់បាន ។ ប៉ុន្តែសិស្សមិនអាចចេះជួយគ្នាទៅវិញទៅមកទេ ប្រសិនបើគេចេះតែជួបប្រទះនូវស្ថានភាពប្រកួតប្រជែងគ្នាដូចមានរៀបរាប់នៅក្នុងករណីសិក្សាដែលបានអានរួចមកនោះ ។ ជាការពិតស្ថានភាពបែបនេះវានឹងជំរុញឱ្យមានអាកប្បកិរិយាយកខ្លួនឯងជាមូលដ្ឋានភាពឃោរឃៅគ្មានមេត្តាហើយនឹងគ្មានខ្វល់ដល់អ្នកដទៃ ។

– តើសុភាពពិតជាមានចិត្តចង់ជួយសុខាឬទេ ? : ប្រាកដណាស់ សុភាព គ្មានចិត្តចង់ជួយសុខាទេ ។ គ្រូមានវិធីជាច្រើនដែលអាចដោះស្រាយស្ថានភាពដែលបានកើតឡើងក្នុងករណីសិក្សានេះដោយមិនបានធ្វើទណ្ឌកម្មដល់សុខា ។ សុភាពគឺគ្រាន់តែឆ្លើយនឹងសំណួរមិនបានជួយសុខាទេ ប៉ុន្តែគេចង់បានការសរសើរពីគ្រូតែប៉ុណ្ណោះ ។ ដូចនេះការលើកទឹកចិត្តដែលនាំឱ្យសុខភាពឆ្លើយសំណួរនោះគឺ ដើម្បីខ្លួនឯង ហើយជាការសំខាន់ជាងនេះទៀតនោះគឺអ្នកគ្រូបានជំរុញឱ្យសុភាពមានគំនិតបែបនេះ ។

– តាមយោបល់អ្នកតើអ្នកគួរប្រែប្រួលរបៀបបង្រៀនក្នុងករណីសិក្សានេះយ៉ាងណា ? :

ឧទាហរណ៍ : អ្នកគ្រូឱ្យសិស្ស ដទៃទៀតដាក់ដៃចុះហើយព្យាយាមសួរសំណួរបំផុសដល់សុខាថែមទៀតដើម្បីរកចម្លើយមួយត្រឹមត្រូវ ឬក៏ប្រហែលជាគ្រូរៀបចំសិស្សជាក្រុម ហើយសិស្សផ្តល់ចម្លើយជាក្រុម ។ នៅក្នុងវិធីរៀបជាក្រុមសុខាទទួលបានចម្លើយត្រឹមត្រូវពីមិត្តភក្តិ ។ ប្រសិនបើសុខានៅតែឆ្លើយខុសទៀតពេលនោះក្រុមទាំងមូលជាអ្នករួមចំណែកជាមួយសុខាក្នុងការទទួលខុសត្រូវ។ កុមារក៏ដូចជាមនុស្សចាស់ដែរគេមានអារម្មណ៍ថា មានសុវត្ថិភាពប្រសិនបើគេទទួលខុសត្រូវជាក្រុម ។ វិធីចុងក្រោយដើម្បីដោះស្រាយស្ថានភាពនេះគឺត្រូវបានគេហៅថា " ការសិក្សាបែបសហការ " ។

**ឯកសារទី៣: លក្ខណៈសំខាន់ៗនៃការសិក្សាបែបសហការ**

# ការពិពណ៌នាយុទ្ធវិធីនៃការសិក្សាបែបសហការ

## I-ផ្តើមសេចក្តី :

*ការពិសោធជាមួយនឹងយុទ្ធវិធីនៃការសិក្សាបែបសហការគ្នានេះ អាចដឹកនាំទៅរកការបរាជ័យមួយដែរបើសិនគេមិនពឹងផ្អែកលើការយល់ដឹងពីគោលការណ៍នានាឱ្យបានត្រឹមត្រូវ ដែលជាមូលដ្ឋាននៃវិធីសាស្ត្របែបនេះ ។*

ការអនុវត្តរបៀបបង្រៀន ផ្តល់ឱកាសឱ្យសិស្សរៀនផ្តុំគ្នាជាក្រុមតូចៗមានឈ្មោះថា **ការសិក្សាបែបសហការ** ។ ការរៀនបែបសហការ គឺជាវិធីរៀនដែលសិស្សធ្វើការជាក្រុមដើម្បីរៀនសូត្រ ។ សមាជិកទាំងអស់ត្រូវសហការគ្នាទើបទទួលបានជោគជ័យ ។ សិស្សធ្វើការជាមួយគ្នាហើយទទួលខុសត្រូវការរៀនសូត្ររបស់ខ្លួន និង អ្នកដទៃទៀតក្នុងក្រុម ។ សព្វថ្ងៃនេះគ្រូមួយចំនួនកំពុងពិចារណាពិនិត្យឡើងវិញពីការអនុវត្តតាមបែបផែនចាស់ជាប្រពៃណីមកបញ្ជាក់ពីការប្រឡងប្រជែងខ្លាំងជាងកិច្ចសហការគ្នានៅក្នុងថ្នាក់រៀននីមួយៗ ។ គ្រូបង្រៀនកំពុងគិតថា តើការជំរុញសិស្សឱ្យធ្វើការដោយខ្លួនឯងមានប្រយោជន៍ដែរឬទេ ? ពួកគេយល់ឃើញថា ក្រៅពីអនុញ្ញាតឱ្យសិស្សជាច្រើន មានទំនាក់ទំនងគ្នាយ៉ាងសកម្មនៅក្នុងការសិក្សាបែបសហការនេះបានពង្រឹងគុណភាពបំណិនប្រសប់ក្នុងការប្រាស្រ័យទាក់ទងគ្នារបស់សិស្សថែមទៀតផង ព្រមទាំងបង្កើនសមត្ថភាពរបស់សិស្សឱ្យចេះរួមរស់ជាមួយគ្នាក្នុងសង្គមផងដែរ ។

ក៏ប៉ុន្តែជាការសំខាន់ការពិសោធជាមួយនឹងយុទ្ធវិធីនៃការសិក្សាបែបសហ-ការនេះអាចដឹកនាំទៅរកការបរាជ័យមួយដែរ បើសិនជាគេមិនពឹងផ្អែកលើការយល់ដឹងពីគោលការណ៍នានាបានត្រឹមត្រូវដែលជាមូលដ្ឋាននៃវិធីសាស្ត្របែបនេះ ។ ឧ. គ្រូមិនមែនត្រឹមតែរៀបចំសិស្សដោយបំបែបជាក្រុម ហើយគ្រាន់តែបញ្ជាឱ្យគេ " ធ្វើការរួមគ្នា " តែម៉្យាងប៉ុណ្ណោះទេ បើគ្រូមិនបានប្រាប់សិស្សពីវិធីរៀន ឬរបៀបធ្វើការរួមគ្នាសម្រាប់គោលដៅណាខ្លះនោះទេ យុទ្ធវិធីនៃការសិក្សានេះអាចមានគ្រោះថ្នាក់ជាមិនខាន ។ ឧទាហរណ៍ : ខាងក្រោមនេះបង្ហាញពីគ្រោះថ្នាក់ដែលកើតមានឡើង ។

មានគ្រូបង្រៀនថ្នាក់ទី ៤ ម្នាក់នៅក្នុងស្រុកមួយ គាត់ធ្លាប់ឃើញវិធីសិក្សាបែបសហការហើយគ្រូនោះបានគិតថា បង្រៀនបែបនេះគួរតែអនុវត្តក្នុងថ្នាក់រៀនរបស់គាត់ ។ ដូច្នេះគាត់បានបំបែកសិស្សក្នុងថ្នាក់របស់គាត់ជាក្រុមៗដោយមាន

សិស្សក្នុងមួយក្រុមៗ ៦ នាក់ ហើយគាត់បានប្រាប់ក្រុមនីមួយៗឱ្យហ្វឹកហ្វឺនវិធីបូក និង ដកប្រភាគសម្រាប់ប្រឡងដែលនឹងត្រូវធ្វើឡើងនៅពេលខាងមុខ ។ បន្ទាប់មក គេឃើញសិស្សបានពិភាក្សាគ្នាយ៉ាងច្របូកច្របល់ រួចហើយគេបានចាប់ផ្តើមធ្វើសកម្មភាពដាច់ដោយឡែកពីគ្នា សិស្សមួយចំនួនធំបានពិភាក្សាអំពីរឿងរ៉ាវផ្សេងៗក្រៅមេរៀន សិស្សមួយចំនួនផ្សេងទៀតបានបើក សៀវភៅសិក្សាហើយចាប់ផ្តើមធ្វើវិធីបូក និង ដកប្រភាគរៀងៗខ្លួន ។

ឧទាហរណ៍ខាងលើនេះបង្ហាញពីរបៀបសិក្សាបែបសហការដោយបង្កើតឱ្យមានភាពអនាធិបតេយ្យក្នុងថ្នាក់រៀនប្រសិនបើគ្រូមិនបានរៀបចំឱ្យបានត្រឹមត្រូវក្នុងការធ្វើសកម្មភាពរបស់សិស្ស ។ ការពារស្ថានភាពបែបនេះកុំឱ្យកើតឡើងគ្រូគួរតែសិក្សា និង អនុវត្តគោលការណ៍ណែនាំនៃការសិក្សាបែបសហការដែលមានពន្យល់ដូចខាងក្រោមនេះ ។

## II-គោលការណ៍នៃការសិក្សាបែបសហការ :

### 1. <u>ការជួយគ្នាទៅវិញទៅមក</u> :

សិស្សយល់ឃើញថា គេទាំងអស់គ្នាត្រូវជួយគ្នាទៅវិញទៅមកដើម្បីសម្រេចកិច្ចការមួយឱ្យបានជោគជ័យ ។សមាជិកម្នាក់ត្រូវយល់ថា " ខ្ញុំទទួលជោគជ័យប្រសិនបើអ្នកដទៃទៀតក្នុងក្រុមទទួលជោគជ័យផងដែរ " ។ គ្រូលើកស្ទួយគ្នាទៅវិញទៅមកដោយប្រើវិធីដូចតទៅ

- កំណត់គោលបំណងរួម
- ប្រើវិធីជូនរង្វាន់រួមដល់ក្រុម
- ផ្តល់ធនធាន និង សម្ភារដល់ក្រុម រួចរំលែកចែកគ្នា
- កំណត់តួនាទីច្បាស់លាស់សម្រាប់សមាជិកម្នាក់ៗក្នុងក្រុម
- មានការឯកភាពក្នុងការកំណត់អត្តសញ្ញាណរួមគ្នា ( ឱ្យសិស្សដាក់ ឈ្មោះក្រុមរបស់គេ . . . ) ។

### 2. <u>បំណិនទាក់ទងនឹងការរស់នៅក្នុងសង្គម</u> :

- ការសរសើរគ្នាទៅវិញទៅមក

- ការស្តាប់គ្នាទៅវិញទៅមក
- ការមានអំណត់ចំពោះអ្នកដទៃទៀត
- ការជួយគ្នាដោយសង្កត់ធ្ងន់លើកិច្ចការដែលត្រូវធ្វើ ។

3. <u>អន្តរកម្មរវាងសិស្ស និង សិស្សក្នុងក្រុម</u> :

នៅចុងបញ្ចប់មេរៀនឱ្យសិស្សឆ្លុះបញ្ចាំងទៅលើដំណើរការនៃការសហការក្នុងក្រុម ។

4. <u>ការទទួលខុសត្រូវរបស់សិស្សម្នាក់ៗក្នុងក្រុម</u> :

<u>ការរៀបចំក្រុមសិស្ស</u> :

ជាទូទៅសិស្សក្នុង ១ ក្រុម ត្រូវមានសមាជិកពី ៤ ទៅ ៥ នាក់ ( ក្នុង ១ ថ្នាក់ត្រូវមានសិស្ស ៣0 នាក់ ប៉ុន្តែនៅក្នុងប្រទេសកម្ពុជាយើងសិស្សក្នុង ១ ថ្នាក់ភាគច្រើនមានចំនួន ៥0 នាក់ តែបើចែកជាក្រុមយើងគួរយក ១ ក្រុមចាប់ពី ៦ ទៅ ៨ នាក់ ទើបមានភាពងាយស្រួលក្នុងការគ្រប់គ្រង ។ ការចែកសិស្សជាក្រុមតូចៗនេះគឺវាមានសារៈសំខាន់ណាស់ព្រោះយើងបានផ្តល់ឱកាសឱ្យគេបង្ហាញគំនិតពិភាក្សាគ្នានិងពន្យល់គ្នាទៅវិញទៅមកតាមរយៈភាសា និង កាយវិការរបស់ពួកគេផ្ទាល់ ហើយគ្រូក៏មានលក្ខណៈងាយស្រួលក្នុងការសម្របសម្រួល ។ ក្រោយពីចែកសិស្សជាក្រុមរួច យើងត្រូវណែនាំសិស្សឱ្យដាក់ឈ្មោះក្រុមរបស់ពួកគេតាមការឯកភាពពីសមាជិកក្រុម ដូចជា : ការឱ្យឈ្មោះក្រុមតាមពណ៌ ខែ សត្វ ឬ តាមលេខ . . . ។

ក. <u>ក្រុមសិស្សមិនគិតពីសមត្ថភាព និង ចំណង់ចំណូលចិត្ត</u> : ក្រុមនេះយើងរៀបឡើងដោយមិនផ្តោតលើសមត្ថភាពទេពកោសល្យ ប្រុស ឬ ស្រី និង បុគ្គលិកលក្ខណៈ ។

- <u>របៀបបង្កើតក្រុម</u> :
  - ចែកប័ណ្ណឈ្មោះក្រុម
  - រៀបចំបង្គុយជិតគ្នា
  - រាប់ចំនួនតាមលំដាប់ឡើងចុះ ។

ខ. <u>ក្រុមស្ម័គ្រចិត្ត</u> : ក្រុមនេះយើងត្រូវរៀបចំឡើងដោយទុកសិទ្ធិសេរីភាពឱ្យពួកគេចូលតាមចំណង់ចំណូលចិត្តតាមមិត្តភក្តិ ឬ អ្នកនៅជិតផ្ទះគ្នា ។

- <u>របៀបបង្កើតក្រុម</u> :
  - ប្រាប់ចំនួនសមាជិកក្នុង១ក្រុម
  - សរសេរឈ្មោះក្រុមតាមកន្លែងណាមួយ ដោយមានឈ្មោះក្រុមជាស្រេច
  - ឱ្យសិស្សចូលតាមចំណង់ចំណូលចិត្តរបស់គេ ។

គ. <u>ក្រុមតាមសមត្ថភាព</u> : ក្រុមនេះយើងត្រូវរៀបចំឡើងតាមសមត្ថភាព និង បំណិនរបស់គេ មានន័យថា សមាជិកក្រុមនីមួយៗមានកម្រិតយល់ដឹងប្រហាក់ប្រហែលគ្នា ។ យើងផ្តល់ការងារក្រុមផ្សេងៗគ្នា ក្រុមណាមានសមត្ថភាពខ្ពស់ត្រូវប្រគល់ការងារលំបាកបន្តិច និង ផ្ទុយមកវិញត្រូវជួយពន្យល់ក្រុមដែលមានសមត្ថភាពតិចតួច ។ ការងារក្រុមបែបនេះជួយឱ្យសិស្សរៀនលឿន និង យឺតបានរៀនតាមល្បឿនរបស់គេនិងមិនធ្វើឱ្យធុញទ្រាន់ ។

- <u>របៀបបង្កើតក្រុម</u> :
  - ជ្រើសរើសសិស្សពូកែធ្វើប្រធានក្រុម
  - ចែកក្រុមដោយផ្អែកលើកម្រងស្នាដៃសិស្សឬតារាងចំណាត់ថ្នាក់
  - ចែកក្រុមពូកែតាមមុខវិជ្ជា . . . ។

ឃ. <u>ក្រុមចម្រុះ</u> : ក្រុមនេះរៀបចំឡើងដោយមានសមត្ថភាពចម្រុះ មានន័យថា អ្នករៀនលឿន និង រៀនយឺតមានសមត្ថភាពមិនប្រកាន់បក្សពួក មិនរើសអើង អ្នកពិការ អ្នកមានជម្ងឺអេដស៍ . . .។ ការបែងចែកក្រុមគ្រូជាអ្នកសម្រេចចិត្តដោយផ្ទាល់ដើម្បីរើសអើងពីសិស្សដទៃ ។

❖ **<u>មុខងារក្រុម និង សមាជិកក្រុម</u> :**

សមាជិកក្នុងក្រុមនីមួយៗត្រូវមានភារកិច្ចជាក់លាក់មុនចាប់ផ្តើមពិភាក្សា ឬ ដោះស្រាយបញ្ហាអ្វីមួយដើម្បីធានាកាទទួលខុសត្រូវក្នុងក្រុមការងារ ។ យើងដឹងថា ការងារក្រុមពុំទទួលបានលទ្ធផលល្អបើកាលណាសមាជិកមិនបានសហការ និង ចូលរួមបញ្ចេញគំនិតយោបល់ ឬ ពិភាក្សាចាកប្រធានបទនោះនឹងចំណាយពេលវេលាច្រើន ដូចនេះយើងត្រូវបែងចែកភារកិច្ចដូចខាងក្រោម ÷

- អ្នកសម្របសម្រួល : ជាអ្នកដឹកនាំការពិភាក្សា និង លើកទឹកចិត្តសមាជិក

ឱ្យមានសកម្មភាពចូលរួមដ៏សកម្ម

- លេខាកត់ត្រា : ជាអ្នកសរសេររបាយការណ៍ ឬ កត់ត្រានូវអ្វីៗដែលក្រុមបានពិភាក្សា និង មានការឯកភាពគ្នា
- អ្នកផ្ទៀងផ្ទាត់ម៉ោង : ជាអ្នកធានា និង ទទួលខុសត្រូវឱ្យការងារពិភាក្សាបានចប់តាមម៉ោងកំណត់ និង ទទួលបានលទ្ធផលជាវិជ្ជមាន
- អ្នករាយការណ៍ : ត្រូវរាយការណ៍ពីលទ្ធផលការងារ ការពិភាក្សាក្នុងក្រុមដល់អ្នកដទៃ ឬ ក្នុងថ្នាក់ទាំងមូលតាមរយៈអ្នកកត់ត្រា
- អ្នកវិចិត្រ : សង់ដ្យាក្រាម ឬ ក្រាប តារាង និង គូររូបភាព . . .
- អ្នករៀបរៀង : រៀបចំតុបតែងរូបភាព កែពាក្យខុស រៀបចំល្បះ និងកថាខណ្ឌ
- អ្នកបញ្ជូន ប្រមូលព័ត៌មាន និង សម្ភារ : ជាអ្នកបញ្ជូននិងប្រមូលព័ត៌មានទៅគ្រូ និង ក្រុមដទៃទៀតនូវអ្វីៗដែលចាំបាច់ ដូចជា ការរកឯកសារ និងសម្ភារសម្រាប់រៀនសូត្រតាមក្រុម ។

## III-វត្ថុបំណងនៃការសិក្សាបែបសហការ :

ចំណុចល្អក្នុងការចាប់ផ្តើមសាកល្បងប្រើយុទ្ធវិធីនៃការសិក្សាបែបសហការឱ្យមានប្រសិទ្ធភាពគឺចាំបាច់ត្រូវយល់ពីវត្ថុបំណង ឬ មូលហេតុនៃការបង្រៀនមួយវិធីសាស្ត្រមួយនេះជាដំបូងសិន ។ មានហេតុផលធំៗ៤យ៉ាងដែលគេអាចយកមកប្រើប្រាស់ :

1. ការសិក្សាតាមបែបសហការជួយសិស្សឱ្យមានការចូលរួមយ៉ាងសកម្មថែមទៀតក្នុងការសិក្សាជាងវិធីបង្រៀនតាមបែបម៉ាស៊ីននិយមឬរាយរ៉ាប់សុទ្ធសាធរបស់គ្រូ ។ នៅក្នុងការប្រើវិធីតាមបែបរាយរ៉ាប់នេះគ្រាន់តែអាចបង្កលទ្ធភាពឱ្យសិស្សចូលរួមយ៉ាងសកម្មតែម្នាក់ ឬ ពីរ នាក់យ៉ាងច្រើនប៉ុណ្ណោះពេលគ្រូធ្វើការបង្រៀនម្តងៗ ។ ប៉ុន្តែការប្រើវិធីតាមបែបសហការរវាងសិស្ស និង សិស្ស ធ្វើការរួមគ្នាជាក្រុមៗបែបនេះសិស្សទាំងអស់មុខជានឹងបានចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចការរៀនសូត្រជាក់ជាមិនខាន ។ សិស្សចូលរួមក្នុងការរៀនសូត្រកាន់តែសកម្មផ្ទុយនឹងសិស្សដែលគ្រាន់តែទទួលព័ត៌មាន ឬ ចំណេះដឹងតាមរយៈការស្តាប់ ការសង្កេត ការសរសេរ និង ការចម្លងតាម ។

2. ការសិក្សាបែបសហការជំរុញឱ្យសិស្សគាំទ្រគ្នាជាក្រុមមិនមែនឱ្យប្រកួតប្រជែងគ្នានោះទេ ។ ដូច្នេះសិស្សអាចផ្ទេរសមត្ថភាពគ្នាហើយគេនឹងជួយគ្នាទៅវិញទៅមក ។

*ការសិក្សាបែបសហការនឹងផ្តល់ឱកាសល្អសម្រាប់សិស្សពូកែឱ្យជួយសិស្សខ្សោយបាន ។*

3. ការសិក្សាបែបសហការនេះនឹងផ្តល់ឱកាសល្អសម្រាប់សិស្សពូកែឱ្យជួយសិស្សខ្សោយបានសិស្សពូកែប្រាស្រ័យទាក់ទងជាមួយនឹងសិស្សខ្សោយបានងាយស្រួលជាងគ្រូ ។ ការជួយគ្នារបស់សិស្សពូកែនេះនឹងបង្កើនចំនួននៃការពន្យល់ដែលមាននៅក្នុងថ្នាក់ទាំងមូលទៀតផង ។
4. ការសិក្សាបែបសហការនេះ នឹងជួយពង្រឹងកម្លាំងចិត្តរបស់សិស្សមួយចំនួនដោយផ្តល់ឱកាសល្អៗដល់សិស្ស ដើម្បីពិសោធយកឈ្នះដោយសប្បាយរីករាយ (សកម្មភាពទាំងឡាយដែលតម្រូវឱ្យមានល្បែងសិក្សា) និង ជោគជ័យក្នុងការសិក្សា ។ បើសិនវិធីបង្រៀនដាច់ដោយឡែកពីគ្នាវិញ មានតែសិស្សពូកែទេដែលបានទទួលការរីករាយជានិច្ច ។ ប៉ុន្តែក្នុងថ្នាក់រៀនដែលបានរៀបចំក្រុមសហការដែលមានសិស្សពូកែផងនិងសិស្សខ្សោយផង វាមានឱកាសល្អសម្រាប់សិស្សទាំងអស់ដណ្តើមជោគជ័យស្មើៗគ្នា ។

## IV-ផលប្រយោជន៍នៃការសិក្សាបែបសហការ :

លោក ( Johnson & Johson ) បានធ្វើការសន្និដ្ឋានអំពីផលប្រយោជន៍នៃការសិក្សាបែបសហការ ÷

- លទ្ធផលនៃការសិក្សាកាន់តែប្រសើរឡើង
- សមត្ថភាពគិតដោយវិភាគកាន់តែប្រសើរឡើង
- ទំនាក់ទំនងគ្នាទៅវិញទៅមកមានភាពអាធ្យាស្រ័យ និង យោគយល់គ្នារវាងសិស្សនៅក្នុងថ្នាក់ និង ក្រៅថ្នាក់
- សិស្សចំណាយពេលច្រើនលើការរៀនសូត្រ (ការកាត់បន្ថយភាពរវើរវាយរបស់សិស្ស)
- សិស្សជួយផ្សព្វផ្សាយព័ត៌មានគ្នា
- សិស្សចេះប្រើបំណិនទាក់ទងនឹងការរស់នៅក្នុងសង្គម
- សិស្សមានឥរិយាបថកាន់តែវិជ្ជមានចំពោះសាលារៀន
- សិស្សកាត់បន្ថយអាកប្បកិរិយាមិនល្អដែលរំខានដល់ថ្នាក់រៀន

- សិស្សចេះសម្របសម្រួលគំនិតយោបល់របស់អ្នកដទៃទៀត ។

<u>តួនាទីរបស់គ្រូក្នុងការសិក្សាបែបសហការមានដូចខាងក្រោម</u> ÷

- កំណត់វត្ថុបំណងនៃមេរៀន
- ជួយជំរុញបំណិនដែលទាក់ទងនឹងការរស់នៅក្នុងសង្គម
- ធ្វើការសម្រេចចិត្តអំពីចំនួនសិស្សក្នុងក្រុម
- រៀបចំបន្ទប់រៀន និង សម្ភារ
- កំណត់តួនាទីសិស្សម្នាក់ៗក្នុងក្រុម
- ពន្យល់កិច្ចការដែលត្រូវធ្វើ ( ពន្យល់ពីលំនា លើកឧទាហរណ៍ សួរសំណួរ ដើម្បីបញ្ជាក់ថា តើសិស្សយល់កិច្ចការ ដែលត្រូវធ្វើដែរឬទេ ? )
- ធ្វើតេស្ត និង សួរសំណួរដល់សិស្សជាបុគ្គល ( ដើម្បីលើកស្ទួយការទទួលខុសត្រូវរបស់សិស្សម្នាក់ៗក្នុងក្រុម )
- លើកស្ទួយការសហការរវាងក្រុម និង ក្រុមដទៃទៀត
- ត្រួតពិនិត្យសកម្មភាពរបស់សិស្ស ( ពេលដែលសិស្សកំពុងធ្វើការគ្រូដើរពីក្រុមមួយទៅក្រុមមួយទៀតដើម្បីដឹងថា តើសិស្សយល់ ឬ មិនយល់ ? គ្រូផ្តល់ព័ត៌មានត្រឡប់ភ្លាមៗដើម្បីជួយសិស្ស )
- សរសើរពេលដែលសិស្សសហការគ្នាបានល្អ ហើយលើកសកម្មភាពគំរូដើម្បីឱ្យសិស្សដទៃទៀតបានឃើញ
- ជួយសិស្សឱ្យសហការជាមួយគ្នាប្រកបដោយប្រសិទ្ធភាព
- ឱ្យសិស្សឆ្លុះបញ្ចាំងទៅលើដំណើការរបស់ក្រុមគេដោយឱ្យសិស្សលើកចំណុចល្អៗចំនួន ៣ ហើយកំណត់ចំណុចខ្សោយមួយដែលគេនឹងព្យាយាមកែលំអទៅថ្ងៃក្រោយ ។

*គ្រូត្រូវប្រាកដក្នុងចិត្តថាលទ្ធផលសិក្សានិងវិធីធ្វើការរួមគ្នាជាក្រុមៗមានលក្ខណៈច្បាស់លាស់ ។*

## V-វិធីប្រើប្រាស់ការសិក្សាបែបសហការនៅក្នុងថ្នាក់រៀន :

ចំណុចទាំងឡាយដូចតទៅនេះនឹងជួយគ្រូបង្រៀនឱ្យរៀបចំសកម្មភាពសិក្សាបែបសហការនៅក្នុងថ្នាក់រៀនទៅតាមរបៀបមួយដែលនឹងពង្រឹងគុណភាពដល់បរិយាកាសសិក្សាទាំងមូល ÷

1. គ្រូត្រូវប្រាកដក្នុងចិត្តថាលទ្ធផលសិក្សានិងវិធីធ្វើការរួមគ្នាជាក្រុមៗមានលក្ខណៈ

ច្បាស់លាស់ ។ មិនត្រូវជំរុញសិស្សដោយគ្រាន់តែបញ្ចូលទៅក្នុងក្រុមនីមួយៗ ហើយបញ្ជា " ឱ្យធ្វើការរួមគ្នា " នោះឡើយ ។ គ្រូត្រូវពន្យល់សិស្សឱ្យបានច្បាស់លាស់ពីលទ្ធផលដែលខ្លួនចង់បានពីសិស្សមកវិញ ។

2. គ្រូត្រូវបែងចែកភារកិច្ចរបស់សិស្សក្នុងក្រុមឱ្យច្បាស់ ។ សិស្សម្នាក់ៗត្រូវដឹងអ្វីដែលគេត្រូវធ្វើ ។
3. ព្យាយាមដាក់សិស្សដែលមានសមត្ថភាពខុសៗគ្នាលាយចម្រុះគ្នានៅគ្រប់ក្រុមនីមួយៗ ។
4. រក្សាចំនួនសមាជិកក្នុងក្រុមកុំឱ្យលើសពី ៨ ឬ ៩ នាក់ ឱ្យសោះ យកល្អមែនទែនមួយក្រុមៗគួរឱ្យមានត្រឹមតែ ៥ ទៅ ៦ នាក់ បានហើយ ។
5. គ្រូត្រូវផ្លាស់ប្តូរការបង្រៀនរបស់ខ្លួនពីក្រុមធំទៅក្រុមតូចច្រើនដងក្នុងពេលបង្រៀន ( ជំហានទី ៣ និង ជំហានទី ៤ ក្នុងទម្រង់កិច្ចតែងការបង្រៀនដែលក្រសួងបានកំណត់ )។ ការបង្រៀនបែបនេះនឹងផ្តល់ឱ្យមានសិស្សធ្វើសកម្មភាពបានច្រើនគ្នា ព្រមគ្នា ។
6. គ្រូត្រូវយល់ថា សិស្សទទួលខុសត្រូវដោយខ្លួនឯងនៅក្នុងការសិក្សា ។ ការសិក្សាបែបសហការពុំមែនមានន័យថា សិស្សម្នាក់ធ្វើការជំនួសឱ្យមិត្តភក្តិរបស់គេម្នាក់ទៀតនោះទេ ។ សិស្សត្រូវតែយល់ថា គេត្រូវធ្វើតេស្តប្រឡង និង ទទួលលទ្ធផលនៃតេស្តប្រឡងនោះទៅតាមការយល់ដឹងរបស់គេម្នាក់ៗ កាលណាគ្រូធ្វើការវាយតម្លៃសរុប ។

## VI-តួនាទីនៃការរៀបចំតុសិស្សនៅក្នុងការសិក្សាតាមបែបសហការ

*មានទំនៀមទម្លាប់មួយថែងថា "រៀបចំតុសិស្សបង្រៀន" នោះជាកត្តាគ្រឹះមួយនៅក្នុងការយល់ដឹងរបស់យើងពីគរុកោសល្យនោះឯង ។*

ជាការសំខាន់បំផុតសម្រាប់គ្រូយល់ឃើញនូវឥទ្ធិពលនៃការរៀបចំតុសិស្សទៅលើវិធីដែលគេបង្រៀន និង រៀន ។ មិនតែប៉ុណ្ណោះទំនៀមទម្លាប់មួយថែងថា " ការរៀបចំតុសិស្សដឹកនាំគឺវិធីសាស្ត្របង្រៀន " នោះជាកត្តាមូលដ្ឋានគ្រឹះមួយនៃការយល់ដឹងរបស់យើងពីគរុកោសល្យនោះឯង ។ ដូច្នេះបើគេរៀបចំតុសិស្សជាជួរៗបែរមុខទៅរកក្តារខៀនទាំងអស់គ្នាវិញនោះមានន័យថាវាដឹកនាំវិធីរបស់យើងឆ្ពោះទៅរកការបង្រៀនមួយដែលគ្រូដើរតួតែឯងយ៉ាងផ្តាច់មុខ ( Highly teacher-centered instructional approach ) ។




និយាយឱ្យចំទៅគឺថា គេដាក់ឱ្យសិស្សសម្លឹងមករកគ្រូរបស់ខ្លួនជាប់ជានិច្ចនិងមិនឱ្យបែរមុខមករកគូកនសិស្សគ្នាឯងឡើយ ។

ដូចនេះនៅក្នុងការប្រតិបត្តិតាមវិធីសិក្សាតាមបែបសហការនៅក្នុងការបង្រៀននេះសំខាន់ស្ថិតនៅត្រង់សិស្សត្រូវណែនាំខ្លួនឯងហើយរៀបចំតុសិស្សទៅតាមរូបភាពខាងលើនេះជាកំហិតដោយខានមិនបាន ។ បើលៃលកទៅបានតុសិស្សគួរឱ្យតូចខ្លីក្នុងការប្រើប្រាស់ផ្ដុំគ្នាជាក្រុមតូចៗមាន ៣តុ ដែលអាចឱ្យសិស្សទាំងអស់អង្គុយបែរមុខរកគ្នាដោយសំឡឹងមកចំកណ្ដាលក្រុមរបស់គេ ។ បើពុំមានតុខ្លីទេ តុវែងក៏អាចប្រើមានប្រសិទ្ធភាពដែរ ។

*ផ្ទៃកកណ្ដាលនៃថ្នាក់រៀនត្រូវរក្សាទុកឱ្យទំនេរ និងស្រឡះរហូតដើម្បីស្រួលដល់ការសង្កេតពិនិត្យនិងស្រាយបំភ្លឺដល់ក្រុមសិស្សទាំងឡាយ ។*

ក្នុងការរៀបចំសិស្សជាក្រុមៗដូចមានបង្ហាញក្នុងរូបខាងលើនេះសិស្សអាចធ្វើសកម្មភាពរួមគ្នាបានយ៉ាងងាយស្រួលដោយរៀបចំឡើងដោយគ្រូបន្ទុក ឬដោយសិស្សខ្លួនឯងក៏បាន ។ គ្រូគប្បីធ្វើការកត់សំគាល់ផងដែរថា ផ្ទៃកណ្ដាលនៃថ្នាក់រៀនត្រូវរក្សាទុកឱ្យទំនេរ និង ស្រឡះរហូតដើម្បីបង្កភាពងាយស្រួលដល់ការត្រួតពិនិត្យ និង ការស្រាយបំភ្លឺដល់ក្រុមទាំងឡាយ ។ គួរកត់សំគាល់ថា ត្រូវរៀបចំគេគួរធ្វើការកត់សំគាល់យ៉ាងណាឱ្យសិស្សមានលទ្ធភាពសំឡឹងមើលមកក្ដារខៀនបានដោយកុំឱ្យហួសកម្រិត ៩០ ដឺក្រេ ។ ការរៀបចំតុបែបនេះមានប្រសិទ្ធភាពខ្ពស់បានលុះណាតែគ្រូយកពេលវេលាបង្រៀនតាមរបៀបរ៉ាយរ៉ាប់សុទ្ធសាធកុំឱ្យហួសពី ១០នាទី ។ការងាររួមក្រុមតូចៗបែបនេះគប្បីប្រើពេលវេលាឱ្យច្រើនបំផុតនៅក្នុងការបង្រៀននិងរៀនតាមបែបសហការ ( កិច្ចតែងការបង្រៀនយកលំនាំតាមឯកសារណែនាំគរុកោសល្យសម្រាប់គ្រូបង្រៀនកម្រិតមូលដ្ឋានបង្រៀននៅបឋមសិក្សា ) ។

## VII-ការប្រតិបត្តិការសិក្សាបែបសហការនៅក្នុងថ្នាក់រៀន :

នៅក្នុងឧទាហរណ៍ខ្លះៗសម្រាប់គ្រប់កម្រិតថ្នាក់នៃការបង្រៀនមួយដែលបង្ហាញពីវិធីចាស់បុរាណ និង ការបង្រៀនបែបសហការ ។

**ការអនុវត្តនៅក្នុងថ្នាក់ទី ១ :**

មួយផ្នែកធំនៃកម្មវិធីសិក្សាថ្នាក់ទី ១ គឺរៀនឱ្យស្គាល់អក្សរ និង សម្លេងរបស់តួអក្សរនោះ ។ តាមការបង្រៀនបែបចាស់ពីមុនមក គ្រូពន្យល់សិស្សទាំងអស់គ្នានៅក្នុងថ្នាក់ឱ្យសិស្សអង្គុយមើលរូបរាង និង ស្តាប់សូររបស់តួអក្សរ "ក" និង "ត" ។ បន្ទាប់មកគ្រូហៅសិស្សម្នាក់ឱ្យឡើងមកកាន់ក្តារខៀនហើយឱ្យចង្អុលប្រាប់សិស្សដទៃ និង គ្រូ នូវពាក្យដែលផ្តើមដោយអក្សរ " ក " និង " ត " ដែលកំពុងបង្រៀននោះ ។

*សិស្សថ្នាក់ទី ១ សង្កត់ធ្ងន់លើការចុះសម្រុងគ្នានោះជាការធម្មតាទៅហើយ ដែលគេត្រូវបញ្ចូលកុមារឱ្យទៅក្នុងក្រុមសហការនៅដើមវ័យរបស់គេ ។*

សិស្សថ្នាក់ទី ១គ្រូសង្កត់ធ្ងន់លើការចុះសម្រុងគ្នា (Socialization) ជាដំបូងសំខាន់ជាងគេ តាមធម្មតាគេត្រូវបញ្ចូលកុមារឱ្យទៅក្នុង ក្រុមសហការនៅដើមវ័យសិក្សារបស់គេ ។ មេរៀនអក្សរ "ក" និង " ត " ដែលបានពណ៌នាខាងលើប្រែប្រួលការបង្រៀនតាមបែបសហការបានយ៉ាងងាយស្រួល ។ ក្រោយពីបង្រៀនរូបរាង និង សូររបស់តួអក្សររួច ជំនួការហៅសិស្សឱ្យឡើងមកកាន់ក្តារខៀន គ្រូឱ្យសិស្សធ្វើការនៅលើតុជាក្រុមតូចៗដើម្បីពង្រឹងចំណេះដឹងដោយក្តីសប្បាយរីករាយ ។ គ្រូអាចយកសម្ភារសំណង់អក្សរ (ខ្នាច់លើ ...) មកចែកឱ្យសិស្សផ្គុំជាតួអក្សរ "ក" និង "ត" ។ ក្រោយមកទៀតគ្រូប្រាប់សិស្សឱ្យរកប័ណ្ណជារូបសត្វ ឬ រូបភាពផ្សេងៗមួយចំនួនទៀតមកបិទជុំវិញតួអក្សរទៅតាមសូរព្យញ្ជនៈ ។ ក្នុងសកម្មភាពបែបនេះ គ្រូត្រូវបែងចែកភារកិច្ចសិស្សនីមួយៗឱ្យបានច្បាស់លាស់ ។ សិស្សខ្លះរើសប័ណ្ណរូបភាពទៅតាមសូររបស់ព្យញ្ជនៈហើយសិស្សខ្លះទៀតយកប័ណ្ណរូបភាពទៅតាមសូរមករៀបចំដាក់ជុំវិញព្យញ្ជនៈនោះ ដូចឧទាហរណ៍នៅខាងក្រោម ÷



**<u>ការអនុវត្តនៅក្នុងថ្នាក់ទី ២</u> :**

នៅថ្នាក់ទី ២ នេះ សិស្សចាប់ផ្ដើមរៀនពាក្យជ្រៅៗជាងមុន ។ សិស្សត្រូវចេះកំណត់និយមន័យរបស់ពាក្យថា តើពាក្យនោះស្ថិតក្នុងថ្នាក់ពាក្យ នាម.គុណនាម ឬ កិរិយាស័ព្ទ ឬ តែងល្បះដោយប្រើពាក្យនោះ ។ ពន្យល់ពាក្យដែលបានបង្រៀនតាមរបៀបចាស់គឺសិស្សសូត្រពីនិយមន័យ ឬ អត្ថន័យរបស់ពាក្យហើយប្រាប់ពីថ្នាក់ពាក្យម្ដងទៀត ។

រីឯបច្ចេកទេសតាមការសិក្សាបែបសហការវិញអាចណែនាំសកម្មភាពក្រុមសិស្សកាន់តែចូលរួមកុះករនិងជួយឱ្យគេបានយល់អត្ថន័យរបស់ពាក្យបានល្អប្រសើរច្រើនជាងមុនតាមរយៈការប្រើពាក្យ ឬ ភាសាដោយជាក់ស្ដែង ។ ការប្រើក្រដាសវ៉ាមយ៉ាងច្រើនសន្លឹកកាត់ចេញជា ៤ ចម្បៀក គ្រូអាចធ្វើប័ណ្ណអក្សរពី ១៥ ទៅ ២០ ពាក្យបាន ៥ ឈុតដូចគ្នាជាពាក្យដែលសិស្សទើបបានរៀនរួចនិងតាមរយៈមេរៀនជាច្រើនពីមុនៗមក ។ ក្រោយពីបានធ្វើការត្រួតពិនិត្យមើលពាក្យនីមួយៗឡើងវិញជាមួយនឹងសិស្សរួចរាល់ហើយគ្រូចែកឈុតប័ណ្ណអក្សរទាំងអស់ឱ្យដល់ក្រុមនីមួយៗ ហើយឱ្យគេរៀបចំប័ណ្ណពាក្យនោះជា ៤ ប្រភេទ ÷

ពាក្យទាំងឡាយណាជានាម

ពាក្យទាំងឡាយណាជាកិរិយាស័ព្ទ

ពាក្យទាំងឡាយណាជាគុណនាម

ពាក្យទាំងឡាយណាខុសពីថ្នាក់ពាក្យទាំង ៣ ខាងលើ ។

នៅពេលដែលក្រុមទាំងអស់បានកំណត់ថ្នាក់ពាក្យរួចហើយ ត្រូវមានសិស្សម្នាក់នៅក្នុងក្រុមនីមួយៗសរសេរពាក្យទាំងនោះនៅលើក្រដាសសម្រាប់ទុកជាឯកសារ ។ ជាមួយគ្នានោះដែរសិស្សដែលនៅសល់ក្នុងក្រុមនីមួយៗត្រូវនាំគ្នារៀបចំពាក្យឱ្យទៅជាល្បះមានន័យគ្រប់គ្រាន់តាមគេអាចធ្វើទៅបាន ។ នៅទន្ទឹមពេលសិស្សក្នុងក្រុមនីមួយៗធ្វើកិច្ចការនេះ គ្រូដើរតាមដានពិនិត្យដំណើរការរីកចំរើនរបស់សិស្ស ។ ជាថ្មីម្ដងទៀត យើងអាចមើលឃើញពីសារៈសំខាន់នៃការបែងចែកភារកិច្ច (Division of Labor) ច្បាស់លាស់មួយៗនៅក្នុងក្រុមនីមួយៗជាវិធានការមួយធ្វើឱ្យសិស្សទាំងអស់សកម្មក្នុងការងារ សមាជិកម្នាក់ត្រូវចាត់ឱ្យរកពាក្យជាកិរិយាស័ព្ទ ម្នាក់ផ្សេងទៀតឱ្យរកពាក្យជានាមជាដើម ។ ដូចគ្នានេះដែរ សិស្ស

*កាលណាគ្រូរៀបចំការប្រកួតក្រុមសិស្សបានត្រឹមត្រូវការប្រឡងប្រណាំងរវាងក្រុមនិងក្រុមអាចជួយពង្រឹងការចូលរួមរបស់សិស្សនៅក្នុងសកម្មភាពសិក្សាព្រមទាំងបង្កើនស្មារតីសាមគ្គីភាពនៅក្នុងចំណោមសមាជិកក្រុមជាមួយគ្នា ។*

សរសេរថ្នាក់ពាក្យលើក្រដាស ឯសិស្សផ្សេងទៀតនាំគ្នារៀបពាក្យជាល្បះ ។

កាលណាគ្រូរៀបចំការប្រកួតក្រុមសិស្សបានត្រឹមត្រូវដែលផ្ទុយនឹងការប្រជែងគ្នារវាងបុគ្គល និង បុគ្គល សកម្មភាពបែបនេះជួយពង្រឹងការចូលរួមរបស់សិស្សនៅក្នុងសកម្មភាពសិក្សា ព្រមទាំងបង្កើតស្មារតីសាមគ្គីភាពនៅក្នុងរង្វង់ក្រុមជាមួយគ្នាផងដែរ ។ ឧទាហរណ៍ដែលបានពណ៌នាខាងលើនេះ គ្រូអាចប្រាប់សិស្សឱ្យរៀបចំប័ណ្ណពាក្យឱ្យទៅជាល្បះមួយចំនួន ដែលចាត់ទុកជាការប្រឡងប្រណាំងមួយដែរ ក្រុមណាមួយមានសមត្ថភាពធ្វើល្បះបានច្រើនជាងគេបំផុតត្រូវចាត់ទុកជាក្រុមឈ្នះគេ ។

**<u>ការអនុវត្តនៅក្នុងថ្នាក់ទី ៣</u> :**

ពេលសិស្សរៀនដល់ថ្នាក់ទី ៣ សិស្សកំពុងតែចាប់ផ្តើមអានយ៉ាងប៉ិនប្រសប់ខ្លាំងជាងមុន ។ ដូចនេះការអានលឿន ព្រមទាំងយល់អត្ថន័យស្ទើរតែទាំងអស់ក្នុងល្បះ ឬ អត្ថបទសន្មតថាសិស្សអាចសម្រេចគោលបំណងសំខាន់មួយនៅក្នុងកម្មវិធីសិក្សា ។ ពេលគ្រូបង្រៀនអំណានដល់សិស្សទាំងអស់ក្នុងថ្នាក់គ្រូមានបញ្ហាក្នុងការត្រួតពិនិត្យមើលអំណានរបស់សិស្សមួយចំនួនក្នុងពេលបង្រៀន ។ ជាធម្មតាគ្រូឱ្យសិស្សម្នាក់អានអត្ថបទក្នុងរយៈពេលដ៏ខ្លីមួយ សិស្សឯទៀតត្រូវតែអានតាមដោយស្ងាត់ស្ងៀមជាមួយដែរ ។ បន្ទាប់មកគ្រូហៅសិស្សម្នាក់ផ្សេងទៀតឱ្យអានបន្តពីសិស្សមុន ។ ភាគច្រើនគ្រូផ្តល់ការប្រតិបត្តិជាសកម្មភាពដល់សិស្សបានត្រឹមតែ ១០ ទៅ ១២ នាក់ យ៉ាងច្រើនក្នុង ១ ថ្នាក់ ក្នុងរយៈពេល ៤០ នាទី ។ ឯសិស្ស ២ ភាគ ៣ ផ្សេងទៀតអាច ឬ មិនអាចបានចូលរួមនៅក្នុងការរៀនមេរៀនអំណាននេះនឹងគេទេ ។ ដូច្នេះគេមិនអាចស្តីបន្ទោសដល់សិស្សបានឡើយកាលបើសិស្សនោះមិនបានចូលរួម ឬ អានតាមគេដោយស្ងាត់ៗ ពីព្រោះអំណានបែបនេះធ្វើឱ្យសិស្សមានការធុញទ្រាន់ខ្លាំងណាស់ ។ សិស្សមានឱកាសច្រើននៅក្នុងការសិក្សាដោយសហការនេះឧទាហរណ៍មួយក្នុងមេរៀនអំណាន គឺមិនត្រឹមតែធ្វើឱ្យសិស្សមានល្បឿនទៅលើការអានតែប៉ុណ្ណោះទេ ប៉ុន្តែវាមានប្រយោជន៍ដោយគេបានចូលរួមនៅក្នុងអំណានអត្ថបទដែលមានទំនាក់ទំនងក្នុងជីវភាពរស់នៅរបស់សង្គមថែមទៀតផង ។ ម្យ៉ាងទៀតលំហាត់អំណានជាក្រុមៗ តាមបែបសហការទាក់ទងនឹងអំណានសារព័ត៌មានជាវិធីដ៏មានសារៈប្រយោជន៍យ៉ាងធំធេងតាមរយៈនោះធ្វើឱ្យ

*សិស្សមានឱកាសច្រើនក្នុងការសិក្សាបែបសហការ គឺមិនត្រឹមតែសិស្សមានល្បឿនលើការអានប៉ុណ្ណោះទេ តែមានប្រយោជន៍ដោយគេបានចូលរួមនៅក្នុងអំណានអត្ថបទដែលមានទំនាក់ទំនងក្នុងជីវិភាពរស់នៅរបស់សង្គមថែមទៀតផង ។*

សិស្សបានចូលរួមយ៉ាងសកម្មនៅក្នុងអំណាន ។ ពេលនេះសិស្សដក់ភ្នែកនឹងសារព័ត៌មានដោយចេះតែបង្កើនល្បឿនអានបន្តិចម្តងៗ និង ហាក់ដូចជា មានការចាប់អារម្មណ៍ជាខ្លាំងច្រើនជាងពួកគេអានអត្ថបទមួយក្នុងសៀវភៅអំណានទៅទៀត ។

នៅក្នុងលំហាត់អំណានតាមបែបសហការនេះគ្រូម្នាក់ៗ អាចចែកសារព័ត៌មានលេខដូចគ្នាឱ្យសិស្ស ៥ ឬ ៦ ក្រុមនៅក្នុងថ្នាក់ ។ ក្រុមនីមួយៗបានទទួលសារព័ត៌មាន ១ច្បាប់ដែលអាចមានចំនួន ៤ ឬ ៥ សន្លឹក ។ បន្ទាប់មកគ្រូឱ្យសេចក្តីសង្ខេបអត្ថបទ ១ យ៉ាងខ្លី ឬ អត្ថបទផ្សាយដំណឹង ឬ រូបភាពថ្លុកកំប្លែងមួយណាក៏បានហើយឱ្យក្រុមសិស្សនីមួយៗរកអត្ថបទក្នុងសារព័ត៌មាននោះ ។ក្នុងការប្រតិបត្តិសកម្មភាពនេះសិស្សម្នាក់ៗអាចរកមើលតាមលេខទំព័រសារព័ត៌មាននោះនិងមើលចុះឡើងវិភាគអត្ថបទដែលគ្រូបានពណ៌នារួចហើយ ។ បើជាក្រុមធំល្មមវិញសិស្ស ២ នាក់អាចមើលតែ ១ ទំព័ររួមគ្នា កាលបើសារព័ត៌មាននោះមានទំព័រធំ ។ ពេលក្រុមសិស្សណាមួយនាំគ្នារកឃើញអត្ថបទនោះរួចហើយ ពួកគេត្រូវលើកដៃទាំងអស់គ្នា ។ បើគ្រូរៀបចំសកម្មភាពនេះជាការប្រឡងប្រណាំងដៃរនោះ គ្រូអាចឱ្យ ១ ពិន្ទុដល់ក្រុមណាដែលរកឃើញអត្ថបទនោះមុនគេ ។ បន្ទាប់មកទៀត វិធី ឬ ល្បិចបង្រៀននេះត្រូវធ្វើឡើងវិញសម្រាប់អត្ថបទផ្សេងៗ ក្នុងសារព័ត៌មាននោះបន្ថែមទៀត ។

សកម្មភាពដូចមានរៀបរាប់ខាងលើនេះ ជួយបន្តឱ្យមានភាពងាយស្រួលនៅក្នុងទម្លាប់អានបានលឿន ព្រមទាំងយល់អត្ថន័យរបស់អត្ថបទទាំងមូលផងថែមទាំងធ្វើឱ្យមានទំនាក់ទំនងនឹងអំណានស្របតាមជីវភាពរស់នៅរបស់សង្គម ។ ព្រោះតែឯកសារអំណានសារព័ត៌មានមានទំនាក់ទំនងគ្នាជាមួយជីវភាពរស់នៅក្នុងសង្គម ( មិនដូចអំណានក្នុងសៀវភៅសិក្សា ) នាំឱ្យសិស្សទាំងអស់បានចូលរួមយ៉ាងសកម្ម ។ ម្យ៉ាងទៀតកិច្ចការដែលមានលក្ខណៈជាការប្រឡងប្រណាំងគ្នាបានផ្តល់ប្រយោជន៍លើល្បឿនអំណានព្រមទាំងការយល់បាននូវអត្ថន័យដែលគ្រូចង់បាន ។ សមាជិកម្នាក់ៗ នៅក្នុងក្រុមមើលត្រួសៗសារព័ត៌មានស្វែងរកអត្ថបទដើម្បីជួយក្រុមទាំងមូលរបស់គេឱ្យទទួលបានពិន្ទុ ។ ដូចនេះស្មារតីនៃសកម្មភាពជាក្រុមមានសារៈសំខាន់ជាថ្មីម្តងទៀតនៅក្នុងការសម្រួលការចូលរួមយ៉ាងកុះករពីសំណាក់សិស្សគ្នាឯង ។ ជាក់ស្តែងណាស់សិស្សទាំងអស់នៅក្នុងក្រុមនីមួយៗ

ដោយមិនគិតដល់កម្រិតសមត្ថភាពនឹងមានពិសោធន៍ក្នុងការដណ្តើមជោគជ័យគួរឱ្យរំភើបចិត្តនៅពេលដែលអត្ថបទក្នុងសារព័ត៌មានជាទីប្រាថ្នានោះត្រូវពួកគេបានរកឃើញ ។

**ការអនុវត្តនៅក្នុងថ្នាក់ទី ៤ :**

ភូមិវិទ្យា និង ប្រវត្តិវិទ្យា ជាមុខវិជ្ជា ២ ដែលគេមិនមានការយកចិត្តទុកដាក់ហើយគ្រាន់តែបង្រៀនឱ្យសិស្សចេះត្រឹមតែទីកន្លែង កាលបរិច្ឆេទ និង ឈ្មោះប៉ុណ្ណោះ ។ នៅប្រទេសកម្ពុជាការបង្រៀនមុខវិជ្ជាទាំង ២ នេះ ភាគច្រើនសាលារៀនសង្កត់ធ្ងន់ ឬ ផ្អែកលើអំណានតាមសៀវភៅសិក្សាសុទ្ធសាធ (អានអត្ថបទសរសេរលើក្តារខៀន បើសិស្សគ្មានសៀវភៅសិក្សានឹងគេ) បន្ទាប់មកទៀត គឺការចោទជាសំណួរខ្លះៗដែលគ្រូដឹកនាំសិស្សទាំងមូលនៅក្នុងថ្នាក់រៀន ។ ដូចថ្នាក់ដទៃទៀតដែរមានសិស្សតែ ១ នាក់ ឬ ២ នាក់ប៉ុណ្ណោះដែលចូលរួមយ៉ាងសកម្មក្នុងមេរៀនទាំង ២មុខវិជ្ជានេះក្នុងពេលរៀនម្តងៗ ។ យើងគួរគិតមើលថា តើការធុញទ្រាន់មានដល់កម្រិតណាទៅបើយើងបង្រៀនរបៀបនេះ ? ហើយតើគេមានការងឿងឆ្ងល់ដែរឬទេ ? មានសិស្សជាច្រើនចង់បោះបង់ចោលសាលានៅមុនពេលគេត្រូវចូលរៀនថ្នាក់ទី ៥ ។

វិធីសិក្សាតាមបែបសហការជួយបង្កើនការចូលរួមរបស់សិស្សនិងមានការយកចិត្តទុកដាក់មកលើមេរៀនភូមិវិទ្យា និង ប្រវត្តិវិទ្យា ព្រមទាំងនាំឱ្យការសិក្សានេះមានកម្រិតកាន់តែខ្ពស់ឡើងៗ ។ ឧទាហរណ៍ : ការឱ្យសិស្សនាំគ្នាធ្វើតារាង និង ដ្យាក្រាមជាសកម្មភាពសិក្សាយ៉ាងសកម្មនៅក្នុងមេរៀនស្តីពីរបៀបរស់នៅរបស់ប្រជារាស្ត្រទូទៅនៅតាមទីកន្លែងនីមួយៗដែលសិស្សធ្លាប់រៀន និង ធ្លាប់ដឹងរួចមកហើយដូចជា : ភូមិ ឃុំ ស្រុក ខេត្ត និង ក្រុង . . . ជាដើម ។ ប្រភេទ ឬ ព័ត៌មានទាំងឡាយនៅក្នុងតារាងគ្រូអាចធ្វើដោយខ្លួនឯង ឬ មួយសិស្សធ្វើដោយខ្លួនឯងបើគេមានលទ្ធភាព ។ ដើម្បីឱ្យក្រុមទាំងអស់ធ្វើតារាងព័ត៌មានដែលត្រូវស្រង់ពីមេរៀន គ្រូត្រូវចែកឱ្យក្រុមសិស្សនីមួយៗនូវខ្មៅដៃពណ៌ ២ ឬ ៣ ដើម និង ក្រដាសផ្ទាំងធំ ១ សន្លឹកដើម្បីឱ្យក្រុមទាំងអស់ធ្វើតារាងព័ត៌មានដែលត្រូវស្រង់ពីមេរៀន ។ វិធីធ្វើឱ្យសិស្សចូលរួមយ៉ាងសកម្មនៅក្នុងសកម្មភាពបែបនេះ

*វិធីសាស្ត្រនៃការសិក្សាតាមបែបសហការអាចជួយបង្កើនការចូលរួមរបស់សិស្ស និង មានការយកចិត្តទុកដាក់មកលើមេរៀនភូមិវិទ្យា និង ប្រវត្តិវិទ្យា ព្រមទាំងនាំអោយការសិក្សានេះមានកម្រិតកាន់តែខ្ពស់ឡើង ៗ ។*

គ្រូអាចផ្តល់យោបល់ណែនាំសិស្ស ១ នាក់ ឬ ២ នាក់ ទទួលខុសត្រូវរៀងៗខ្លួនក្នុងការស្រាវជ្រាវព័ត៌មានសម្រាប់ឱ្យក្រុមរបស់គេយកមកបំពេញតារាងនីមួយៗ ។ នៅពេលដែលព័ត៌មានសព្វបែបយ៉ាងបានប្រមូលរួចរាល់ហើយសិស្សនឹងនាំគ្នាធ្វើការពិភាក្សាលំអិតលើព័ត៌មាននោះ ហើយស្រង់បានព័ត៌មានថ្មីសរសេរបំពេញនៅក្នុងតារាងទៅតាមប្រភេទព័ត៌មាននីមួយៗ (សូមមើលតារាងខាងក្រោម) ។

ការគូរតារាង និង ដ្យាក្រាម ចាត់ទៅតាមប្រភេទព័ត៌មានដូចពណ៌នាខាងលើនេះជាកិច្ចការរៀនសូត្រមួយដែលទាមទារឱ្យមានការប្រៀបធៀបនឹងព័ត៌មានដែលបានរៀនក្នុងមេរៀន ។ នៅពេលសិស្សនាំគ្នាធ្វើកិច្ចការប្រៀបធៀបរបៀបនេះមានន័យថាសិស្សទាំងអស់នោះកំពុងតែនាំគ្នាចូលរួមមិនត្រឹមតែថាតាមគ្រូប៉ុណ្ណោះទេ ថែមទាំងចេះវិភាគព័ត៌មានដែលមានទំនាក់ទំនងគ្នារវាងសង្គមរស់នៅនីមួយៗទៀតផង ។ ដូចនេះកិច្ចការរបៀបនេះក្រៅពីដឹកនាំឱ្យសិស្សទាំងអស់បានចូលរួមយ៉ាងសកម្មក្នុងការសិក្សាមេរៀននោះវាថែមទាំងជួយនាំយកការយល់មេរៀនមួយដែលមានកម្រិតកាន់តែខ្ពស់ឡើងថែមទៀត ។

**<u>របៀបរស់នៅខុសកន្លែងគ្នា</u>**

*គម្រោងសិក្សាតាមការសហការ ស្តីពីសង្គមរស់នៅថ្នាក់ទី ៤*

| របៀបរស់នៅ / ក្រុម | កន្លែងរស់នៅ | ឧបករណ៍ប្រើប្រាស់ | មុខរបរ |
|---|---|---|---|
| អ្នកភូមិ | ជនបទ | ចាស់បុរាណ | កសិកម្ម |
| អ្នកព្រៃភ្នំ | ភ្នំ | ចាស់បុរាណ | បរបាញ់សត្វ |
| អ្នកសមុទ្រ | ឆ្នេរសមុទ្រ | ចាស់បុរាណលាយសម័យ | នេសាទ |
| | | ទាន់សម័យ | អ្នករាជការ |
| អ្នកទីក្រុង | ក្រុងធំ - តូច | | កម្មកររោងចក្រ |

**<u>ការអនុវត្តនៅក្នុងថ្នាក់ទី ៥</u> :**

*ការសិក្សាបែបសហការ ជាវិធីមួយបែបដែលមានលក្ខណៈសមស្របទៅនឹងលទ្ធភាពនៃការសម្របសម្រួលក្នុងការចូលរួមរបស់សិស្សនៅក្នុងការសិក្សាមុខវិជ្ជាវិទ្យាសាស្ត្រអនុវត្ត ។*

សាលារៀនភាគច្រើននៅប្រទេសកម្ពុជាបច្ចុប្បន្ននេះការបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រអនុវត្តពឹងផ្អែកលើក្បួន ឬ សៀវភៅសិក្សាតែ ។ ឯសកម្មភាពចោទសួរ និង ចម្លើយមានខ្លះៗដែលគេបានត្រឹមតែចងចាំ និង ថាតាមគ្រូប៉ុណ្ណោះមានការបង្ហាញពីគ្រូម្តងម្កាលដែរ ។ ប៉ុន្តែថ្មីៗនេះកម្មវិធីសិក្សាវិទ្យាសាស្ត្រអនុវត្តកំពុងតែពិនិត្យមើលឡើងវិញដើម្បីឱ្យមានការចូលរួមសកម្មភាពរបស់សិស្សថែមទៀតនៅក្នុងការសិក្សាពីបញ្ញត្តិកម្មវិទ្យាសាស្ត្រ ។ តាមពិតទៅការសិក្សាបែបសហការនេះជាវិធីសមស្របទៅនឹងលទ្ធភាពនៃការចូលរួមរបស់សិស្សនៅក្នុងការសិក្សាមុខវិជ្ជាវិទ្យាសាស្ត្រអនុវត្ត ។

បច្ចេកទេសថ្មីនៃការបង្រៀនបានធ្វើឱ្យសិស្សមានការចូលរួមរៀនវិទ្យាសាស្ត្រអនុវត្តដោយសង្កត់ធ្ងន់លើបំណិនប្រសប់ជាច្រើនយ៉ាង ដូចជាការសង្កេតពិនិត្យ ការកត់ត្រាទុកព័ត៌មាន ការចាត់ជាថ្នាក់ ការវាស់វែង និងការធ្វើសម្មតិកម្មជាដើម ។ បំណិនប្រសប់នីមួយៗនេះអាចឱ្យគេយកមកលៃលកប្រើប្រាស់បានយ៉ាងល្អដោយមានការបែងចែងការងារគ្នាធ្វើច្បាស់លាស់ ដែលគេអាចបង្កើតបាននៅក្នុងក្រុមសិក្សាតាមថ្នាក់រៀននីមួយៗ ។ ឧទាហរណ៍ក្នុងមេរៀនមួយស្តីពី " សិលា " គ្រូអាចសុំឱ្យសិស្សម្នាក់ៗយកដុំថ្ម ២ ឬ ៣ ដុំ ពីផ្ទះមកជាស្រេចដើម្បីបង្រៀន ។ នៅក្នុងក្រុមនីមួយៗគ្រូអាចឱ្យសិស្សបង្កើតប្រព័ន្ធចំណាត់ថ្នាក់ដោយផ្អែកលើលក្ខណៈសំគាល់មួយចំនួនរបស់ថ្មដែលបានប្រមូលពីផ្ទះ ។ សិស្ស ១នាក់ ឬ ២នាក់នៅក្នុងក្រុមនីមួយៗអាចចាប់ផ្តើមធ្វើប្រព័ន្ធចំណាត់ថ្នាក់របស់ថ្មទាំងនោះដោយផ្អែកលើវាវនយភាព( Texture ) ( គគ្រាត រលោង ស្អិត ពណិ និង កំហាប់ ( Hardhess ) ទន់ ជ្រាយ រឹង ស្រួយ ផុយ . . . ) ។ សិស្ស ២ នាក់ផ្សេងទៀតរៀបចំថ្មដែលមានតាមផ្អែកលើប្រព័ន្ធនេះ ។ ឯសិស្សដែលនៅសល់ធ្វើការកត់ត្រាពីចំណាត់ថ្នាក់លើផ្ទាំងក្រដាសធំ ១សន្លឹក ( សូមមើលតារាងខាងក្រោម ) ។

*ចំណាត់ថ្នាក់សិលាសម្រាប់
សកម្មភាពសិក្សាវិទ្យាសាស្ត្រ
អនុវត្តថ្នាក់ទី ៥ ។*




មេរៀនវិទ្យាសាស្ត្រអនុវត្តដទៃទៀត គ្រូអាចធ្វើឱ្យដូចខាងលើដែរ ។ ឧទាហរណ៍ : សិស្សធ្វើសកម្មភាពជាក្រុមអំពីការធ្វើក្រាបពីអាយុសិស្សទាំងអស់ក្នុងថ្នាក់រៀន ឬ អំពីជម្ងឺដែលគេធ្លាប់មាននេះជាលំហាត់ចំណាត់ថ្នាក់ដែរ ។ ម៉្យាងទៀតសិស្សធ្វើការពិសោធតាមរបៀបសង្កេតស្រាវជ្រាវធម្មតាមួយរួមជាក្រុម១មានដូចជាការដាក់វត្ថុទាំងឡាយចូលក្នុងកំប៉ុងទឹក ហើយនាំគ្នាសង្កេតឃើញថា តើមានវត្ថុណាខ្លះលិច ឬ អណ្តែត ។ សិស្សទាំងអស់នៅក្នុងក្រុមនីមួយ១ ត្រូវនាំគ្នាធ្វើកំណត់ត្រាពីអ្វី១ដែលពួកគេសង្កេតឃើញនិងនាំគ្នាពិភាក្សារកសេចក្តីសន្និដ្ឋានអ្វីខ្លះដែលគេអាចធ្វើបានក្នុងការរកដង់ស៊ីតេ ស្រាល ឬ ធ្ងន់ របស់វត្ថុនីមួយ១ ។ សិស្សគប្បីធ្វើការសន្និដ្ឋានវត្ថុទាំងឡាយណាដែលអណ្តែតលើទឹក ( ស្លឹកឈើ គម្របប៊ិច . . . ) មានដង់ស៊ីតេស្រាល មានវត្ថុខ្លះលិចក្នុងទឹក ( ដុំថ្ម ដែក . . . ) មានដេស៊ីតេធ្ងន់ ។ ការបែងចែកការងារគ្នាយ៉ាងច្បាស់លាស់មួយត្រូវតែប្រព្រឹត្តឡើងនៅក្នុងក្រុមនីមួយ១។ សិស្សម្នាក់ទទួលខុសត្រូវប្រមូលវត្ថុពិសោធ សិស្សម្នាក់ទៀតត្រូវដាក់វត្ថុទាំងនោះនៅក្នុងទឹក ហើយសិស្សដែលនៅសល់ទាំងប៉ុន្មានធ្វើការកត់ត្រាលទ្ធផលជាក់ស្តែង ។

## ឯកសារទី៤: ចំណុចសំខាន់ៗនៅក្នុងឯកសារ " ការពិពណ៌នាយុទ្ធវិធីនៃការសិក្សាបែបសហការ"

<u>ចំណុចមួយក្នុងឯកសារដែលអ្នកបានអានគឺ ការសិក្សាបែបសហការបានព្យាយាមសម្រេចនូវប្រសិទ្ធភាព ច្រើនជាងលំនាំបង្រៀនដទៃទៀតនៅក្នុងថ្នាក់រៀន</u> ។

- <u>តើការសិក្សាបែបសហការសម្រេចប្រសិទ្ធភាពនេះយ៉ាងដូចម្តេច</u> ?

  <u>**ចម្លើយ**</u> : ( វាអាចធ្វើឱ្យសិស្សជាច្រើនចំណាយពេលច្រើននៅក្នុងកិច្ចការនៅក្នុងពេលព្រមគ្នាកុមារដែលរៀនបានលឿនត្រូវបានជំរុញឱ្យជួយមិត្តភក្តិគេ តាមរយៈធ្វើការងារជាក្រុម ដូចនេះមានន័យថាបង្កើនចំនួនការពន្យល់កើតឡើងនៅក្នុងថ្នាក់រៀន ) ។

- <u>តើការសិក្សាបែបសហការបានលើកកម្ពស់អាកប្បកិរិយាជួយគ្នាយ៉ាងដូចម្តេច</u> ?

  <u>**ចម្លើយ**</u> : ( ដោយបង្កើតឱ្យមានស្ថានភាពមួយដែលសិស្សត្រូវតែធ្វើការជាមួយគ្នាដើម្បីសម្រេចកិច្ចការដែលគ្រូដាក់ឱ្យធ្វើ ដូចនេះការសហការបានចូលមកជំនួសការប្រឡងប្រជែង ) ។

- <u>តើការសិក្សាបែបសហការបានលើកទឹកចិត្តសិស្សដែលរៀនយឺតឬខ្សោយជាងគេបានដោយរបៀបណា</u> ?

  <u>**ចម្លើយ**</u> : ( ដោយមិនមានស្ថានភាពប្រកួតប្រជែង សិស្សដែលរៀនខ្សោយបានរួចពីការទទួលនូវភាពខ្មាស់អៀន បែបនេះសិស្សទាំងនោះបានឆ្លងកាត់ការទទួលបាននូវជោគជ័យជាបណ្តើរៗដោយដោះស្រាយកិច្ចការរៀនសូត្រជាក្រុមដែលអាចជួយឱ្យការសិក្សាមានលក្ខណៈជាវិជ្ជមានច្រើនជាងបទពិសោធន៍អវិជ្ជមាន ) ។

- <u>ចូរសរសេរល្បិចមួយចំនួនដែលប្រើសម្រាប់អនុវត្តការសិក្សាបែបសហការ</u> ?

  <u>**ចម្លើយ**</u> : ( ការរៀបចំអង្គុយជាក្រុម កំណត់កិច្ចការដែលសិស្សត្រូវធ្វើច្បាស់លាស់ បែងចែកភារកិច្ចការងារក្រុម រក្សាចំនួនសិស្ស ៨ - ៩ នាក់ក្នុង ១ ក្រុម ប្រើសមត្ថភាពសិស្សចម្រុះគ្នាក្នុងក្រុមបែរមុខចូលគ្នានៅក្នុងការបង្ហាញក្រុមតូច និង ក្រុមធំ ត្រួតពិនិត្យកិច្ចការក្រុមហើយជួយកែលំអបើចាំបាច់ អនុញ្ញាតឱ្យសិស្សជួយគ្នាទៅវិញទៅមក ពិសេសសិស្សម្នាក់ៗ មានការទទួលខុសត្រូវលើការរៀនសូត្ររបស់ខ្លួន ) ។

## ឯកសារទី៥: លំហាត់ប្រៀបធៀបវិធីបង្រៀនធម្មតា និង វិធីបង្រៀនបែបសហការ

| លក្ខណៈ | វិធីសាស្ត្របង្រៀនធម្មតា | វិធីសាស្ត្របង្រៀនបែបសហការ |
|---|---|---|
| វិធីរៀនសូត្ររបស់កុមារ | ( បុគ្គល និង ប្រកួតប្រជែង ) | (រៀនជាក្រុម និង សហការ ) |
| សិស្សទទួលផលជាងគេ | ( សិស្សពូកែ ) | ( សិស្សបង្គួរ និង សិស្សខ្សោយ ) |
| ប្រសិទ្ធភាពនៃការធ្វើឱ្យសិស្សធ្វើសកម្មភាព | ( កម្រិតទាប និង មានសិស្សចំនួនតិច ដែលធ្វើសកម្មភាពព្រមគ្នា ) | ( កម្រិតខ្ពស់ និង មានសិស្សជាច្រើន ដែលធ្វើសកម្មភាពព្រមគ្នា ) |
| ប្រើទំហំថ្នាក់ | ( ល្អសម្រាប់ ថ្នាក់សិស្សច្រើន ) | (ល្អសម្រាប់ថ្នាក់មានសិស្សចំនួនតិច ឬ មធ្យម) |
| លទ្ធភាពដែលបង្កឱ្យមានទម្លាប់ជួយគ្នាទៅវិញទៅមក | (ទាប់ ឬ គ្មាន ) | ( ខ្ពស់ ) |
| ប្រភេទនៃការវាយតម្លៃដែលប្រើញឹកញាប់ | ( ការវាយតម្លៃសរុប ) | ( ការវាយតម្លៃជាដំណាក់៧និងការវាយតម្លៃសរុប ) |
| តួនាទីរបស់គ្រូ | (អ្នកផ្សព្វផ្សាយព័ត៌មាននិងអ្នកផ្តាច់ការ) | ( សម្របសម្រួលនិងតាមដានការរៀនរបស់ក្រុមសិស្ស ) |

**ឯកសារទី៦: ប្រព័ន្ធចំណាត់ថ្នាក់យុទ្ធវិធីផ្សេងៗនៃការសិក្សាបែបសហការ**

# ប្រព័ន្ធចំណាត់ថ្នាក់យុទ្ធវិធីផ្សេងៗនៃការសិក្សាតាមបែបសហការ

ខាងក្រោមនេះ គឺជាប្រព័ន្ធចំណាត់ថ្នាក់ដែលមានសារៈសំខាន់មួយសម្រាប់ជួយសិក្ខាកាមនូវចំណាត់ថ្នាក់ជាល្បិចនៃការសិក្សាបែបសហការដើម្បីបង្កឱ្យថ្នាក់រៀនមានលក្ខណៈសហការ ។ ទោះបីមានប្រព័ន្ធចំណាត់ថ្នាក់មួយផ្សេងទៀតក៏ដោយក៏ប្រព័ន្ធនោះមានគោលបំណងផ្ដល់វិធីងាយបំផុត សម្រាប់ធ្វើចំណាត់ថ្នាក់នូវល្បិចបង្រៀនបែបសហការសម្រាប់គ្រូណាមួយដែលមិនទាន់ស្គាល់ការបង្រៀនតាមបែបសហការនេះ ។ ម៉្យាងទៀតប្រព័ន្ធចំណាត់ថ្នាក់នេះស្របនឹងថ្នាក់រៀននៅប្រទេសកម្ពុជាដែលមានចំនួនសិស្សច្រើន និង ស្ថានភាពលំបាកផ្សេងៗដែលជះឥទ្ធិពលឱ្យសិស្សធ្វើតាមគ្រូច្រើន ទោះជា សកម្មភាពសិស្សនោះធ្វើការងារជាក្រុមក៏ដោយ ។

<u>ប្រភេទល្បិចទី ១</u> : ការរៀបចំសកម្មភាពបង្រៀនជាក្រុមធំ

***ការពិពណ៌នាទូទៅ :*** ការបង្ហាញជាក្រុមធំគឺធ្វើមុនការងារក្រុមតូច ។ ជារឿយៗការងារក្រុមធំគឺការធ្វើសេចក្ដីផ្ដើមសម្រាប់គោលការណ៍ ឬ កិច្ចការនៃមេរៀនណាមួយ ។ គ្រូប្រើក្រុមធំសម្រាប់ធ្វើកិច្ចការគំរូហើយ បន្ទាប់មកទៀតទើបធ្វើការជាក្រុមតូច ។ ការប្រើទម្រង់កិច្ចតែងការ ៥ជំហានរបស់ក្រសួងអប់រំគ្រូបានចាប់ផ្ដើមចេញពីការងារក្រុមធំទៅក្រុមតូចជាច្រើនដងក្នុងការបង្រៀនរបស់ខ្លួន ។ ឯល្បិចនេះគឺបង្កើនចំនួនសិស្សឱ្យកាន់តែច្រើនបានធ្វើសកម្មភាពក្នុងពេលតែមួយព្រមគ្នា ។

<u>ល្បិច</u> :

**1.1.** គ្រូត្រូវធ្វើការពន្យល់ខ្លឹមសារខ្លីៗចាប់ផ្ដើមចេញពីងាយទៅលំបាកក្នុងការបង្រៀន ។ ការបង្ហាញនេះត្រូវធ្វើតាមសកម្មភាពពីក្រុមធំទៅក្រុមតូចវិញ ។

<u>ឧទាហរណ៍</u> : មេរៀនភាសាចាប់ផ្ដើមពីការស្ដាប់ ហើយបញ្ចប់ដោយការសរសេរ ។ មេរៀនគណិតវិទ្យាចាប់ផ្ដើមពីការគុណលេខដោយប្រើសម្ភាររូបី និង បញ្ចប់ដោយការគិតតាមរយៈរូបមន្ត ។

**1.2.** គ្រូធ្វើកិច្ចការបង្ហាញដែលជាគំរូសម្រាប់ការងារក្រុមតូច ។

<u>ឧទាហរណ៍</u> : គ្រូបង្ហាញពីរបៀបប្រកបពាក្យ សិស្សយកគំរូរបស់គ្រូធ្វើកិច្ចការនេះនៅក្នុងក្រុមតូចដោយប្រើប័ណ្ណអក្សរ ។

***1.3.*** គ្រូណែនាំពីរបៀបធ្វើការងារក្នុងក្រុម . . . ។

***1.4.*** គ្រូបញ្ចប់មេរៀនតាមរយៈការរំលឹកឡើងវិញមានការបំផុសសំណួរទៅក្រុមធំ . . . ។

***1.5.*** សិស្សបញ្ចប់មេរៀនតាមរយៈការធ្វើរបាយការណ៍តាមក្រុម ។

**ប្រភេទល្បិចទី ២ : ការរៀបចំការងារជាក្រុមតូច**

**ការពិពណ៌នាទូទៅ :**ការងារក្រុមតូចជាគន្លឹះមួយក្នុងការសិក្សាបែបសហការ ។ ជាគន្លឹះនេះមានប្រសិទ្ធភាពកម្រិតខ្ពស់ក្នុងការធ្វើឱ្យសិស្សមានសកម្មភាពជាច្រើនព្រមគ្នា ។ ដើម្បីធានាសកម្មភាពក្រុមតូចច្រើនជាងសកម្មភាពក្រុមធំនៅក្នុងមេរៀនណាមួយ គ្រូត្រូវរៀបចំកិច្ចតែងការបង្រៀនច្បាស់លាស់ជាមុន ។

ល្បិច :

**2.1.** គ្រូបង្កើតក្រុមសិស្ស :

ឧទាហរណ៍ : គ្រូរៀបចំតុសិស្សជាក្រុម ។ គ្រូប្រាប់ឱ្យសិស្សដែលអង្គុយជួរមុខបែរទៅក្រោយទល់មុខជាមួយសិស្សដែលអង្គុយជួរក្រោយ ។ គ្រូឱ្យសិស្សដាក់ឈ្មោះក្រុមរបស់ខ្លួន ។

**2.2.** គ្រូចែកសម្ភារ (ដែលរៀបចំទុកមុន) ទៅក្រុម :

ឧទាហរណ៍ : គ្រូចែកប័ណ្ណពាក្យ និង ផែនទីចល័តទៅក្រុមសិស្ស ។

**2.3.** គ្រូកំណត់កិច្ចការជាក់ស្តែងដែលសិស្សត្រូវធ្វើជាក្រុម : ( សំគាល់ : ល្បិចនេះដូច **1.3** )

ឧទាហរណ៍ : គ្រូឱ្យសិស្សរៀបចំល្បះដោយប្រើប័ណ្ណពាក្យនៅក្នុងរង្វង់ដែលបានគូរនៅចំកណ្តាលតុ ។

**2.4.** សិស្សអនុវត្តតាមការបែងចែកភារកិច្ចផ្សេងៗដែលបានកំណត់ក្នុងក្រុម :

ឧទាហរណ៍ : នៅក្នុងមេរៀនភាសា សិស្សមួយចំនួនកាន់ប័ណ្ណអក្សរ សិស្សមួយចំនួនទៀតកាន់ប័ណ្ណរូប ។ នៅក្នុងមេរៀនវិទ្យាសាស្ត្រអនុវត្ត សិស្ស២នាក់អនុវត្តពិសោធ (ក) ចំណែកឯសិស្ស២នាក់ទៀតអនុវត្តពិសោធ (ខ) ហើយសិស្ស២នាក់កត់ត្រាអ្វីដែលបានកើតឡើងនៅក្នុងពេលពិសោធនីមួយៗនោះ ។

**2.5.** សិស្សជួយគ្នាទៅវិញទៅក្នុងក្រុម :

ឧទាហរណ៍ : ពេលសិស្សម្នាក់បានដាក់ឈ្មោះប្រទេសខុសពីកន្លែងនៅលើផែនទីចល័តដែលគ្មានអក្សរមិត្តរបស់គេដែលអង្គុយនៅក្បែរនោះបានប្រាប់ពីទីតាំងដែលត្រូវ ។

**2.6.** សិស្សលេងល្បែងដែលទាក់ទងទៅនឹងមេរៀនក្នុងក្រុម :

**ប្រភេទនៃល្បិចទី ៣ : ការរៀបចំវាយតម្លៃ**

***ការពិពណ៌នាទូទៅ :*** ការវាយតម្លៃមាន ២ យ៉ាង គឺវាយតម្លៃជាដំណាក់ៗ (Formative) និង ការវាយតម្លៃសរុប (Summative) ។ តាមការពិតការងារក្នុងក្រុមទាំងអស់ជាការវាយតម្លៃជាដំណាក់ៗហើយធ្វើឱ្យប្រភេទល្បិចទី២និងប្រភេទល្បិចទី៣នេះមានទំនាក់ទំនងគ្នាយ៉ាងខ្លាំង ។ ប្រភេទនៃល្បិចនេះមានបំណងពង្រឹងការរៀនសូត្ររបស់សិស្សកែតម្រូវឱ្យសិស្សក្លាហាន គ្មានប្រើអំពើហឹង្សា និង ធ្វើឱ្យសិស្សទទួលខុសត្រូវលើការរៀនសូត្ររបស់ខ្លួន ។

ល្បិច :

**3.1.** គ្រូដើរសង្កេតត្រួតពិនិត្យការងារតាមក្រុម ។

**3.2.** គ្រូផ្តល់ជំនួយដល់សិស្សជាបុគ្គលឬជាក្រុមកាលណាគេមិនអាចបំពេញកិច្ចការបានឬមានជួបការលំបាក ។

ឧទាហរណ៍ : នៅពេលដែលក្រុមណាមួយមិនអាចរៀបចំដ្យាក្រាមចល័តអំពីការចម្លងរបស់ជំងឺគ្រុនចាញ់ពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតបាន គ្រូបំផុសសំណួរដើម្បីបំភ្លឺកិច្ចការនោះឡើងវិញ ។

**3.3.** សិស្សរាយការណ៍ ការងារក្រុមទៅថ្នាក់ទាំងមូល ។

**3.4.** ក្រុមសិស្សឆ្លើយសំណួរដែលក្រុមផ្សេងសួរ ដើម្បីបំភ្លឺលើការរាយកាណ៍របស់ខ្លួន ។

**3.5.** សិស្សជួយកែគ្នាទៅវិញទៅមកពេលបំពេញកិច្ចការជាក្រុម (សំគាល់ : ចំណុចនេះដូចល្បិច ២.៥ ) ។

**3.6.** ក្រុមនីមួយៗពិនិត្យលើការងារគ្នាទៅវិញទៅមក ។

ឧទាហរណ៍ : បន្ទាប់ពីក្រុមបានតែងអត្ថបទអំពីខ្សែរឿងរួចមកក្រុមនីមួយៗដូរកន្លែងអង្គុយគ្នាទៅវិញទៅមកដើម្បីត្រួតពិនិត្យការងារក្រុមនោះ ។

**3.7.** សិស្សធ្វើលំហាត់អនុវត្តលើក្តារខៀន ឬ នៅលើសៀវភៅសិស្សនៅចុងបញ្ចប់នៃមេរៀន ។

**3.8.** សិស្សលេងល្បែងដោយសួរសំណួរគ្នាទៅវិញទៅមកក្នុងក្រុមតូច (សំគាល់ : ដូចគ្នានឹងចំណុចល្បិច ២.៦) ។

**ឯកសារទី៧: កិច្ចតែងការគំរូអំពី “ទន្សាយស៊ីចេក”**

# ការរៀបចំគំនិតតាមលំដាប់លំដោយ

# និង ការស្តាប់ ( ថ្នាក់ទី ១ )

ចូរចំណាត់ ថ្នាក់ល្បិច ដែលបាន កំនត់ដោយ ប្រើប្រព័ន្ធ ចំណាត់ថ្នាក់ ល្បិចការ សិក្សាបែប សហការ ដែល បាន

គ

**I.**គោលបំណង :

⁕សិស្ស កំណត់រូបភាពតាមរយៈការពិពណ៌នាផ្ទាល់មាត់ដែលគេបានឮ

⁕សិស្ស រៀបចំព្រឹត្តិការណ៍តាមលំដាប់លំដោយ ប្រើរូបភាព ឬ ដោយគំនិត

⁕សិស្ស ពន្យល់ព្រឹត្តិការណ៍តាមលំដាប់លំដោយផ្ទាល់មាត់ ។

**II.**រយៈពេល :

⁕ ១ ម៉ោង

**III.**សម្ភារ :

⁕រូបភាពខ្មែរ (ឧទាហរណ៍ ទន្សាយស៊ីចេក) ដែលដាក់តាមលំដាប់រឿង(មាន ៥ សម្រាប់ ៥ ក្រុម )

**IV.**លំនាំបង្រៀន :

*1. ធ្វើសេចក្តីផ្តើមមេរៀនថ្មី « តើអ្វីជាការងារ? »*

⁕រៀបចំថ្នាក់ ដោយយក ដី ស គូសប្រអប់ការេនៅចំកណ្តាលតុរបស់ក្រុមនីមួយ ៗ ។ ធ្វើដូចនេះដើម្បីជួយធានាថា សិស្សទាំងអស់ត្រូវធ្វើការងារជាក្រុម ។

⁕ចាប់ផ្តើមមេរៀនដោយប្រាប់សិស្សថា គ្រូនឹងនិទានរឿងមួយឱ្យសិស្សស្តាប់សូមឱ្យសិស្សយកចិត្តទុកដាក់ស្តាប់ ។ ហើយរឿងនោះពិពណ៌នាដោយរូបភាពខ្មែររឿងដែលគេនឹងទទួលបាននៅពេលបន្តិចទៀត ។

⁕ចែករូបភាពទៅឱ្យក្រុមនីមួយ ៗ (មើលរូបខាងក្រោម) ។ ហើយឱ្យសិស្សដាក់តំរៀបរូបភាពនៅជុំវិញប្រអប់ដែលបានគូសនៅលើតុ ។ មើលកុំឱ្យសិស្សតែម្នាក់កាន់រូបភាពតែម្នាក់ឯង ។













*2. ពន្យល់ព្រឹត្តិការណ៍នៅក្នុងរូបភាពនីមួយៗ :*

ឃ

⁕ចូរប្រាប់សិស្សថាមុនពេលដែលគ្រូនិទានរឿងទាំងមូលប្រាប់ ដំបូងគ្រូនឹងពិពណ៌នាព្រឹត្តិការណ៍ និង រូបភាពវត្ថុនានាដែលបង្ហាញនៅក្នុងផ្ទាំងរូបភាពនេះសិន ។ គ្រូបង្ហាញរូប រួចពិពណ៌នាមួយម្ដងៗ សិស្សណាដែលកាន់រូប ដែលគ្រូបង្ហាញរូប ឱ្យគេដាក់ចូលក្នុងប្រអប់ដែលគួស ។

ចូរកត់សំគាល់ថា គ្រូមិនចាំបាច់ពិពណ៌នារូបភាពតាមលំដាប់លំដោយទេ ។ ខាងក្រោមនេះជាឃ្លាខ្លះៗ ដែលអាចប្រើក្នុងលំហាត់នេះ ÷

- យាយរើសបានទន្សាយងាប់មួយ
- ទន្សាយស៊ីចេក
- យាយដាក់ទន្សាយនៅក្នុងកញ្ជើ
- យាយភ្ញាក់ព្រើតនៅពេលដែលឃើញនៅក្នុងកញ្ជើសុទ្ធតែសំបកចេក
- ទន្សាយងាប់នៅតាមផ្លូវ
- យាយត្រឡប់ពីចំការមកផ្ទះវិញ
- ទន្សាយកំពុងអង្គុយនៅក្នុងកញ្ជើរបស់យាយ

ង

⁕គ្រួតពិនិត្យផ្ទាំងរូបភាពដែលជ្រើសរើសដោយសិស្ស បន្ទាប់ពីការពិពណ៌នា ។

| ច | ឆ | ជ | ឈ | ញ |
|---|---|---|---|---|
| | | | | |

*3.រៀបចំផ្ទាំងរូបភាពខ្សែរឿងតាមលំដាប់លំដោយ :*

✷នៅពេលដែលសិស្សអាចផ្គូផ្គងតាមរយៈការពិពណ៌នាបានហើយនោះ សូមលោកគ្រូនិយាយរឿងទន្សាយស៊ីចេក ពីដើមដល់ចប់ឱ្យសិស្សស្តាប់ ។

✷និយាយរឿងចប់ សូមសរសេរលេខ ១ ដល់លេខ ៤ នៅក្នុងប្រអប់លើតុសិស្ស ។

| ១ | ២ | ៣ | ៤ |
|---|---|---|---|

គ្រូឱ្យសិស្សរៀបរូបភាពតាមលំដាប់លេខ តាមរយៈរឿងដែលគេបានឮ ។ ផ្ទាំងរូបដែលបង្ហាញព្រឹត្តិការណ៍ ទី ១ ដាក់នៅក្នុងលេខ ១ ព្រឹត្តិការណ៍ទី ២ ដាក់នៅក្នុងលេខ ២ ហើយនឹង បន្តបន្ទាប់មក ។

✷គ្រូតពិនិត្យសកម្មភាពតាមក្រុមនីមួយ ៗ ។ ហើយបើក្រុមណារៀបចំផ្សេងមិនត្រូវតាមលំដាប់ព្យាយាមឱ្យសិស្សពន្យល់មកវិញនូវអ្វីដែលគេបានឃើញកើតឡើងនៅក្នុងរូបភាព ហើយបើការពន្យល់របស់គេស៊ីទៅនឹងរឿងដែលគេបានឮ សូមអនុញ្ញាតឱ្យក្រុមនោះរក្សាផ្ទាំងរូបភាពតាមលំដាប់លំដោយនៃការបកស្រាយរបស់គេចុះ ។

*4.និទានរឿង ( តាមលទ្ធភាព) :*

✷នៅពេលដែលសិស្សបញ្ចប់ការរៀបរូបភាពតាមលំដាប់មកសុំឱ្យតំណាងក្រុមនីមួយ ៗ និទានរឿងឡើងវិញ តាមរយៈរូបភាពរបស់គេ ។ អាចសួរក្រុមមួយថា អ្វីដែលកើតឡើងមុនគេ ហើយសួរក្រុមបន្ទាប់ថា អ្វីកើតឡើងបន្ទាប់ ហើយនឹងបន្តបន្ទាប់ ។

✷សិស្សក្នុងក្រុមនីមួយ ៗ អាចនិទានរឿងប្រាប់សមាជិកក្រុមរបស់គេម្តងម្នាក់ ៗ ដោយចង្អុលរូបភាព ដែលនៅក្នុងប្រអប់ ។ នៅពេលដែលសិស្សកំពុងធ្វើការងារនោះ គ្រូគួរតែដើរត្រួតពិនិត្យមើលតាមក្រុមនីមួយ ៗ ។

## ឯកសារទី៨៖ ការវិភាគសកម្មភាពក្នុងការបង្រៀនពិសោធន៍មេដែក ស្តីអំពីយុទ្ធវិធីការសិក្សាបែបសហការ

1. ថ្ងៃនេះយើងរៀនអំពីមេដែក
2. គ្រូសូមអោយប្អូនរៀបចំបែងចែកជាក្រុម
3. គ្រូណែនាំ : មាន ១ នាក់ ធ្វើពិសោធន៍ ២ នាក់ បំពេញតារាង និង ១ នាក់ ទៀត ជាអ្នករាយការណ៍
4. គ្រូពន្យល់ពីប៉ូលមេដែក និង ការបំពេញតារាង
5. គ្រូចែកសម្ភារអោយសិស្ស
6. ចាប់ផ្តើមពិសោធន៍ទី ១ ដាក់ប៉ូលដូចគ្នា ហើយ ២ នាក់ ទៀតបំពេញតារាង
7. គ្រូត្រួតពិនិត្យតាមក្រុម និង ជួយសិស្ស
8. គ្រូអោយសិស្សធ្វើពិសោធន៍ទី ២ ដាក់ប៉ូលខុសគ្នា ហើយ ២ នាក់ ទៀតបំពេញតារាង
9. គ្រូត្រួតពិនិត្យតាមក្រុម និង ជួយសិស្ស
10. អោយសិស្សម្នាក់ ៗ តំណាងក្រុមនីមួយ ៗ ឡើងរាយការណ៍
11. អោយក្រុមនីមួយ ៗ ពិភាក្សា និង ធ្វើសំណួរ ស្តីពីមេដែក
12. សំណួរឆ្លងក្រុម

## ឯកសារទី៩: ការប្រៀបធៀប: ការសិក្សាបែបសហការ ជាបុគ្គល និង បែបប្រកួតប្រជែង

| ខ្លឹមសារ | ការរៀនបែបសហការ | រៀនជាបុគ្គល | រៀនបែបប្រកួតប្រជែង |
|---|---|---|---|
| ការពឹងផ្អែកគ្នាទៅវិញទៅមក | លក្ខណៈវិជ្ជមាន | គ្មាន | លក្ខណៈអវិជ្ជមាន |
| លក្ខណៈនៃសកម្មភាពបង្រៀន | មានសកម្មភាពបង្រៀនបែបណាក៏ដោយ ។ កិច្ចការកាន់តែលំបាកការសហការកាន់តែប្រសើរ( នេះគឺជាផលប្រយោជន៍នៃការរៀនបែបសហការ ) ។ ការរៀនជាបុគ្គល និង ការរៀនបែបប្រកួតប្រជែងអត់មាន ។ | ជំនាញឬចំណេះដឹងមូលដ្ឋាន ។ កិច្ចការមានលក្ខណៈច្បាស់លាស់ ដូចនេះសិស្សភាគច្រើនមិនទាមទារជំនួយបន្ថែម ។ ការរៀនទទួលបានតែចំណេះដឹង បំណិន និងកិច្ចការងាយៗមួយចំនួនប៉ុណ្ណោះ ។ | ការអនុវត្តជំនាញ ការរំលឹកចំណេះដឹងឡើងវិញ និង កិច្ចការត្រូវគោរពតាមបទបញ្ជា និងមិនជួយអ្នកដទៃ ។ |
| ការយល់ឃើញពីសារៈសំខាន់នៃគោលបំណង | ការសំរេចគោលបំណងមានសារៈសំខាន់ណាស់ ។ អ្នកសិក្សាបានសម្រេចគោលបំណងគ្រប់ៗគ្នា ។ | អ្នកសិក្សាយល់ឃើញថា ការសំរេចគោលបំណងមានសារសំខាន់ចំពោះខ្លួនគេផ្ទាល់ ។ ប៉ុន្តែការសម្រេចគោលបំណងនេះទៅតាមការយល់ឃើញរបស់អ្នកសិក្សាម្នាក់ៗ ។ | អ្នកសិក្សាខ្លះសម្រេចគោលបំណងហើយអ្នកខ្លះទៀតមិនបានសម្រេចគោលបំណង ។ |
| អន្តរកម្មរវាងគ្រូ និង សិស្ស | គ្រូតាមដានការរៀន និង ជួយ កែលំអនៅក្នុងក្រុមសិក្សាដើម្បីបង្រៀនបំណិនក្នុងសង្គមមានលក្ខណៈសហការ ។ | សិស្សយល់ឃើញថាគ្រូជាប្រភពជំនួយនឹងគាំទ្រគេគ្រូពង្រឹងការរៀន និង ផ្តល់ព័ត៌មានត្រឡប់ទៅដល់គេវិញ | សិស្សយល់ឃើញថាគ្រូជាប្រភពជំនួយនឹងគាំទ្រគេជាអ្នកពង្រឹងការរៀនជាអ្នកផ្តល់ព័ត៌មានត្រឡប់ដល់គេ ។ ជាអ្នកធ្វើអាជ្ញាកណ្តាលវិនិច្ឆ័យចម្លើយខុស ឬត្រូវ និង |

| | | | |
|---|---|---|---|
| | | | ជាអ្នកផ្តល់រង្វាន់លើកទឹកចិត្ត ។ ម្យ៉ាងទៀត គ្មានអន្តរៈកម្ម រវាង បុគ្គល និង បុគ្គល ក្រុម និង ក្រុម....។ |
| ការណែនាំរបស់គ្រូ | " សុខា ! ប្អូនជួយពន្យល់ចម្លើយរបស់ក្រុមនេះដល់ក្រុមនោះបានទេ " " សុំប្អូនព្យាយាមជួយគ្នាទៅវិញទៅមកសិនមុននឹងអោយគ្រូពន្យល់ " ។ | " កុំរំខានសុខា ពេលដែល សុខាកំពុងធ្វើការ " ។ " ចូរប្អូនលើកដៃប្រសិនបើប្អូនចង់បានជំនួយ " ។ "ប្អូនប្រាប់គ្រូពេលប្អូនបញ្ចប់ការងារ " ។ | "តើអ្នកណាឆ្លើយបានមុនគេ"? " តើអ្នកណាធ្វើការងារបានច្រើនជាងគេ " ? " តើអ្នកត្រូវការអ្វីខ្លះដើម្បីឈ្នះគេនៅពេលក្រោយ " ? |
| អន្តរកម្មរវាងសម្ភារ និង សិស្ស | សម្ភារត្រូវតែរៀបចំតាមគោលបំណងនៃមេរៀន ។ ប្រើប្រាស់សម្ភារអស់លទ្ធភាព | សម្ភារមួយសម្រាប់ សម្រាប់សិស្សម្នាក់ ។ លំនាំការងារ និង ចម្លើយមានលក្ខណៈច្បាស់លាស់ ។ សិស្សម្នាក់ៗមានកន្លែងទូលាយសម្រាប់ធ្វើការងារ ។ | សម្ភារមួយសម្រាប់សម្រាប់ក្រុមតូច ឬ សម្រាប់សិស្សម្នាក់ៗ ។ |
| អន្តរកម្មរវាងសិស្ស និង សិស្ស | មានអន្តរកម្មញឹកញាប់ ការជួយគ្នាទៅវិញទៅមក ការនិយាយអំពីវិធីប្រើសម្ភារ ការជួយកែគ្នា ការជួយគាំទ្រគ្នា ការជួយពិភាក្សាគ្នា និង ការជួយជំរុញគ្នា ។ | គ្មានការពិភាក្សាគ្នាសិស្សធ្វើការម្នាក់ឯងដោយមានអន្តរកម្មតិចតួច ឬ គ្មានសោះជាមួយសិស្សដទៃទៀត ។ | ការត្រួតពិនិត្យសកម្ម-ភាពរបស់សិស្សក្នុងក្រុមដទៃទៀតមានការនិយាយខ្លះរវាងសិស្ស និង សិស្ស ។ |
| ការរំពឹងទុករបស់សិស្ស | ចង់អោយក្រុមទទួលជោគជ័យ ។ សិស្សទាំងអស់ក្នុងក្រុមចូលរួមដើម្បីទទួលជ័យជំនះ ។ អន្តរកម្មរវាង | -មិនចង់អោយសិស្សដទៃទៀតរំខាន<br>- ចង់ធ្វើការទៅតាមកម្រិតរបស់ខ្លួន | - សិស្សម្នាក់ៗមានសង្ឃឹមថាខ្លួននឹងអាចឈ្នះ<br>- មានចិត្តរីករាយក្នុង |

| | | | |
|---|---|---|---|
| | សិស្ស និង សិស្សមាន លក្ខណៈ វិជ្ជមាន ។ សិស្ស ទាំងអស់មានសមត្ថភាព យល់ខ្លឹមសារឬការប្រើ ប្រាស់សម្ភារក្នុងមេរៀន ។ | - ចង់ទទួលខុសត្រូវទាំងស្រុង លើកិច្ចការរបស់ខ្លួន<br>- ចង់ស្វ័យវាយតម្លៃការរីក ចំរើនរបស់ខ្លួនលើការរៀន សូត្រ ។ | ការធ្វើសកម្មភាព<br>-តាមដានការរីកចំរើន របស់អ្នកដទៃទៀត<br>- ប្រៀបធៀបសមត្ថ- ភាព ជំនាញ និង ចំណេះ ដឹងជាមួយអ្នកដទៃ ទៀត<br>- ធ្វើតាមបទបញ្ជា ។ |
| ការរៀបចំថ្នាក់ | ក្រុមតូចៗ | សិស្សម្នាក់មានតុមួយ ឬកន្លែង ទូលាយ ។ | |
| វិធីវាយតម្លៃ | លក្ខណៈវិនិច្ឆ័យដាច់ខាត | លក្ខណៈវិនិច្ឆ័យដាច់ខាត | ចំណាត់ថ្នាក់<br>ពិន្ទុ |

កម្មវិធីគាំទ្រសេវាអប់រំកុមារនៅតំបន់ដាច់ស្រយាល(អេស្កាប់)

Educational Quality Improvement Program
Classrooms • Schools • Communities

## ឯកសារបណ្តុះបណ្តាលគ្រូថ្នាក់កុមារមេត្រី
## សម្រាប់បឋមសិក្សា

# ការលើកស្ទួយសកម្មភាពគិតដោយវិភាគ
# និង  គិតដោយច្នៃប្រឌិត

## Promoting Critical and Creative Thinking



ខេត្តកំពង់ចាម ប្រទេសកម្ពុជា
ខែ សីហា ឆ្នាំ ២០០៦
ឯកសារដើមពីអង្គការខេប

## ឯកសារទី១៖ ការកំណត់ភាពខុសគ្នារវាងការគិតដោយច្នៃប្រឌិត និង ការគិតដោយវិភាគ

### លក្ខណៈនៃការគិតដោយវិភាគ

- ប្រើប្រាស់លក្ខណៈវិនិច្ឆ័យ ដើម្បីដោះស្រាយបញ្ហា
- ធ្វើចំណាត់ថ្នាក់
- បញ្ចេញគំនិតយោបល់ដោយលើកហេតុផល
- សង្កត់ធ្ងន់ទៅលើបញ្ហាពិសេស១
- វិភាគហេតុ និង ផល
- ញែករវាងការពិត និង គំនិត
- ប្រៀបធៀបខ្លឹមសារមួយទៅនឹងខ្លឹមសារមួយផ្សេងទៀត
- កំណត់ទំនាក់ទំនងរវាងបញ្ញត្តិពីរ ឬ ច្រើនជាង
- ធ្វើសេចក្តីសន្និដ្ឋានក្រោយពីធ្វើពិសោធ
- ពិចារណាលើបទពិសោធន៍កន្លងមក ដើម្បីដោះស្រាយបញ្ហាថ្មី
- រៀបចំព័ត៌មានជាដ្យាក្រាម ឬ ក្រាហ្វិច ។

### លក្ខណៈនៃការគិតដោយច្នៃប្រឌិត

- ភាពខុសគ្នាក្នុងការបញ្ចេញគំនិតយោបល់
- ការបញ្ចេញគំនិតដើមដំបូង
- សំណួរមួយអាចចេញជាចម្លើយច្រើនយ៉ាង
- ទស្សនៈថ្មីៗទាក់ទងនឹងខ្លឹមសារចាស់
- ការសំយោគគំនិតចាស់ៗ ដើម្បីបង្កើតគំនិតថ្មី
- ការទស្សន៍ទាយ
- ការកសាងនូវអ្វីដែលថ្មីៗ
- ការប្រើប្រាស់រូបារម្មណ៍ ។

<u>ចំណាំ ៖</u> លោកគ្រូ អ្នកគ្រូគួរយល់ថា គេមិនអាចញែក ១០០ % រវាងការគិតដោយវិភាគ និង ការគិតដោយច្នៃប្រឌិតបានទេ។ ជាញឹកញាប់វាអាចមានភាពត្រួតស៊ីគ្នាឬជាន់គ្នា។

## ឯកសារទី២: **លំហាត់តេស្តគិតដោយវិភាគ**

### ផ្នែកទី១ : លំដាប់លំដោយរូបរាង (៨ ពិន្ទុ)

<u>សេចក្តីណែនាំ</u> : ចូរមើលលំដាប់លំដោយរូបរាង ដែលបានបង្ហាញខាងក្រោមសម្រាប់សំណួរនីមួយៗ ។ តាមលំដាបលំដោយដែលប្អូនបានឃើញ ។ ចូរគូសរង្វង់ ◯ លើអក្សរនៃរូបភាពដែលប្អូនយល់ថាជារូបភាពត្រូវតាមលំដាប់លំដោយក្រោយគេ ។ មានឧទាហរណ៍បង្ហាញ សម្រាប់ប្អូនខាងក្រោម ÷

<u>ឧទាហរណ៍</u> : ក (ខ) គ ឃ



1. ក ខ គ ឃ



2. ក ខ គ ឃ



3. ក ខ គ ឃ



4. ក ខ គ ឃ



5. ក ខ គ ឃ



6. ក ខ គ ឃ



7. ក ខ គ ឃ



8. ក ខ គ ឃ



# ផ្នែកទី ២

## ក. លំដាប់លំដោយនៃរឿង (១០ ពិន្ទុ)

<u>សេចក្តីណែនាំ</u> : រូបភាពខាងក្រោមជាខ្សែរឿងមួយ ក៏ប៉ុន្តែរូបភាពទាំងនេះមិនទាន់បានរៀបចំតាមលំដាប់លំដោយនូវឡើយទេ ។ ចូរពន្យល់កំណត់លំដាប់លំដោយនៃហេតុការណ៍ក្នុងរឿងដោយត្រូវសរសេរលេខក្នុងប្រអប់នៅចំហៀងរូបភាព ។ ចូរជ្រើសរើសរូបភាពទី ១ ទី ២ រហូតដល់រូបភាពទាំងអស់ មានលេខតាមលំដាប់លំដោយសាច់រឿង ។

<u>រឿងទី ១</u> :













**រឿងទី ២** :

☐ 

☐ 

☐ 

☐ 

## ផ្នែកទី ២

## ខ-  លំដាប់លំដោយនៃរឿងនិទានជាអត្ថបទ ( ១០ ពិន្ទុ )

**សេចក្តីណែនាំ** : ល្បះខាងក្រោមនេះជាកម្រងអត្ថបទនិទានមួយ ក៏ប៉ុន្តែល្បះទាំងនោះមិនបានរៀបចំតាមលំដាប់លំដោយទៅតាមបម្រាប់នៃរឿងទេ ។ ចូរអ្នកព្យាយាមកំណត់លំដាប់លំដោយល្បះឱ្យត្រូវទៅតាមសាច់រឿង ដោយសរសេរលេខដាក់ក្នុងប្រអប់នៅចំហៀងល្បះ ។ ចូរជ្រើសរើសល្បះទី ១ រួច ទី ២ បន្តបន្ទាប់ទៀតរហូតដល់គ្រប់ប្រអប់ដើម្បីឱ្យសាច់រឿងមានលំដាប់លំដោយត្រឹមត្រូវ ។

**កម្រងអត្ថបទរឿងទី ១** :

☐ ជាបន្តបន្ទាប់ អ្នកភូមិកោះក្របីបានពង្រីកការដាំដុះផ្កាម្លិះជាចំការធំៗយ៉ាងច្រើនសម្រាប់យកទៅលក់នៅទីក្រុងភ្នំពេញ ។

☐ ប៉ុន្តែក្រោយមកមានតាម្នាក់នៅភូមិកោះក្របីបានទៅគាស់ដើមផ្កាម្លិះពីក្នុងព្រៃមកដាំនៅមុខផ្ទះគាត់ ។

☐ សព្វថ្ងៃនេះ ទឹកដីភូមិកោះក្របីបានក្លាយជាកន្លែងក្រអូបដោយក្លិនផ្កាម្លិះ ។ គេបានប្រសិទ្ធនាមភូមិកោះក្របីថា " ភូមិផ្កាម្លិះ " ។

☐ កាលដើមឡើយគេនិយាយថា " ផ្កាម្លិះមានដុះតែក្នុងព្រៃទេ ពុំមានអ្នកណាយកវាមកដាំក្នុងភូមិឡើយ"

☐ ក្លិនផ្កាម្លិះនៅមុខផ្ទះតាបានធ្វើឱ្យអ្នកភូមិគ្រប់ៗគ្នាចូលចិត្តហើយបានមកសុំដើមផ្កាម្លិះពីតាយកទៅដាំបន្តគ្រប់ៗគ្នា ។

<u>**កម្រងអត្ថបទរឿងទី ២**</u> :

☐ ក្រោយពីសង់ចេតិយរួចហើយ ព្រះរាជាក៏ជ្រើសរើសទីតាំងខាងត្បូងព្រះចេតិយ ឱ្យជាងកសាងព្រះវិហារមួយឡើងដែលមានបណ្តោយ ១០០ ម និង ទទឹង ៣០ម ចំនួនសសរ ១០០ តម្កល់លើខឿនកម្ពស់ជាង ១ ម ។

☐ ព្រះរាជាដឹងថា ព្រះរាជធីតាសុគតហើយទ្រង់ឱ្យបូជាសពព្រះនាងហើយរកទីស្ថានសមរម្យកសាងព្រះចេតិយមួយតម្កល់ព្រះអដ្ឋិធាតុតាមប្រពៃណី ។ ចំណែកឯក្រពើអាធន់ត្រូវគេចងឆ្លាងជាទង់ក្បែរព្រះចេតិយជាសញ្ញាសំគាល់ថា ព្រះនាងសុគតដោយសារក្រពើ ។

☐ ព្រះវិហារនេះ គេសង់បែទៅទិសខាងជើង និងកសាងព្រះពុទ្ធបដិមាករដ៏ធំមួយសម្លឹងចំព្រះចេតិយព្រះនាងវរភក្តិ ដើម្បីធ្វើយ៉ាងណាឱ្យព្រះចេតិយស្ថិតក្នុងរង្វង់ព្រះនេត្រាព្រះអង្គ និងឃុំគ្រងព្រលឹងព្រះនាងជានិច្ច។

☐ ព្រះរាជធីតាវរភក្តិ មានវ័យវឌ្ឍនាការធំកាលណា មានចិត្តនឹកភ្នកចង់មកក្រសាលទន្លេ ហើយចុះទៅស្រង់ទឹកក៏ត្រូវក្រពើនេនធន់ត្របាក់លេបសុគតទៅ ។

☐ តាមសេចក្តីដំណាលថា អស់កាលដ៏យូរលង់ណាស់មកហើយមានព្រះមហាក្សត្រមួយអង្គ ព្រះនាមព្រះអង្គច័ន្ទរាជាទី ២ ព្រះចៅក្រុងកម្ពុជាធិបតី សោយរាជ្យនៅរាជធានីឧត្តុង្គមានបុត្រីតែមួយគត់ ព្រះនាមព្រះនាងវរភក្តី ។

## ផ្នែកទី ៣ : ចំណាត់ថ្នាក់ ( ២១ ពិន្ទុ )

<u>សេចក្តីណែនាំ</u> : សំណួរខាងក្រោមនេះ មានខ្លឹមសារ៤ យ៉ាង។ ខ្លឹមសារ ៣ យ៉ាងមានទំនាក់ទំនងជាមួយគ្នា ប៉ុន្តែ ខ្លឹមសារទី ៤ មិនត្រូវនឹងទំនាក់ទំនងនេះទេ ។ ចូរគូសរង្វង់ ◯ លើអក្សរនៃរូបភាពដែលខុសពីគេ ។ មានឧទាហរណ៍បង្ហាញអ្នក ។ ឧទាហរណ៍ : ខ្លឹមសារ ក ខ គ ឃ ជាសត្វរស់នៅលើគោកដែលមិនចេះហើរ ប៉ុន្តែរូបភាពទី ២ ( ខ ) បង្ហាញសត្វមួយដែលមិនត្រូវនឹងទំនាក់ទំនងនេះ ។

| ក | (ខ) | គ | ឃ |
|---|---|---|---|
|  |  |  |  |

<u>សំណួរទី ១</u> :

| ក | ខ | គ | ឃ |
|---|---|---|---|
|  |  |  |  |

<u>សំណួរទី ២</u> :

| ក | ខ | គ | ឃ |
|---|---|---|---|
|  |  |  |  |

**សំណួរទី ៣ :**

| ក | ខ | គ | ឃ |
|---|---|---|---|
|  |  |  |  |

**សំណួរទី ៤ :**

| ក | ខ | គ | ឃ |
|---|---|---|---|
|  |  |  |  |

**សំណួរទី ៥ :**

| ក | ខ | គ | ឃ |
|---|---|---|---|
|  |  |  |  |

**សំណួរទី ៦ :**

| ក | ខ | គ | ឃ |
|---|---|---|---|
|  |  |  |  |

**សំណួរទី ៧** :

| ក | ខ | គ | ឃ |
|---|---|---|---|
|  |  |  |  |

**សំណួរទី ៨** :

| ក | ខ | គ | ឃ |
|---|---|---|---|
|  |  |  |  |

**សំណួរទី ៩** :

| ក | ខ | គ | ឃ |
|---|---|---|---|
| 9 | 24 | 27 | 81 |

**សំណួរទី ១០** :

| ក | ខ | គ | ឃ |
|---|---|---|---|
| = | + | - | 0 |

**សំណួរទី ១១** :

| ក | ខ | គ | ឃ |
|---|---|---|---|
| $\frac{8}{7}$ | $\frac{1}{4}$ | $\frac{19}{20}$ | $\frac{5}{6}$ |

**សំណួរទី ១២** :

| ក | ខ | គ | ឃ |
|---|---|---|---|
| 13 | 17 | 27 | 23 |

**សំណួរទី ១៣** :

| ក | ខ | គ | ឃ |
|---|---|---|---|
| 2 + 4 + 16 | 3 + 9 + 81 | 4 + 16 + 256 | 3 + 4 + 5 |

**សំណួរទី ១៤** :

| ក | ខ | គ | ឃ |
|---|---|---|---|
| 10 ÷1 | 2(3 + 2) | (2 x 3)+(2 x2) | 2 x 5 |

**សំណួរទី ១៥** :

| ក | ខ | គ | ឃ |
|---|---|---|---|
| $\frac{1}{100}$ | 0,001 | 1% | 0,01 |

**សំណួរទី ១៦** :

| ក | ខ | គ | ឃ |
|---|---|---|---|
| ស៊ី | មក | ទៅ | ចូល |

**សំណួរទី ១៧** :

| ក | ខ | គ | ឃ |
|---|---|---|---|
| វៀតណាម | ខ្មែរ | ថៃ | អង់គ្លេស |

**សំណួរទី ១៨** :

| ក | ខ | គ | ឃ |
|---|---|---|---|
| សាលារៀន | មន្ទីរពេទ្យ | ស្ពាន | ភោជនីយដ្ឋាន |

**សំណួរទី ១៩ :**

| ក | ខ | គ | ឃ |
|---|---|---|---|
| វេជ្ជបណ្ឌិត | គ្រូបង្រៀន | បណ្ណារក្ស | នាយកសាលា |

**សំណួរទី ២០ :**

| ក | ខ | គ | ឃ |
|---|---|---|---|
| ឧត្តមសេនីយ៍ | នាយក | រដ្ឋមន្ត្រី | កូនទាហាន |

**សំណួរទី ២១ :**

| ក | ខ | គ | ឃ |
|---|---|---|---|
| ដើមឈើ | ក្រដាស | សៀវភៅ | ប្លាស្ទិច |

## ផ្នែកទី ៤ : សទិសភាព ( ១៥ ពិន្ទុ )

**សេចក្តីណែនាំ** : ខាងក្រោមនេះ ប្អូននឹងមើលឃើញនូវខ្លឹមសារមួយគូ ដែលមានទំនាក់ទំនងជាមួយគ្នា ។ ទំនាក់ទំនងក្នុងខ្លឹមសារគូទី ២ មិនទាន់បំពេញទេ ។ ចូរជ្រើសរើសអក្សរខាងស្តាំមួយដែលបង្ហាញពីទំនាក់ទំនងក្នុងគូទី ២ ឱ្យដូចនឹងទំនាក់ទំនងដែលបង្ហាញក្នុងគូទី ១ មានឧទាហរណ៍មួយបង្ហាញអ្នកនៅខាងក្រោម :

**ឧទាហរណ៍ :**

| | | | | | |
|---|---|---|---|---|---|
| គូ ១ :<br>កូនប្រុស : ឪពុក | គូ ២<br>កូនស្រី :______ | ក : ជីដូន | (ខ) ម្តាយ | គ : ម្តាយមីង | ឃ : ប្រពន្ធ |

**សំណួរទី ១ :**

| | | | | | |
|---|---|---|---|---|---|
| គូ ១<br>ប៊ិច : ក្រដាស | គូ ២<br>ដីស :________ | ក : ក្តារខៀន | ខ : សាលារៀន | គ : ខ្មៅដៃ | ឃ:បន្ទប់រៀន |

**សំណួរទី ២ :**

| | | | | | |
|---|---|---|---|---|---|
| គូ ១<br>នាទី : ម៉ោង | គូ ២<br>ថ្ងៃ :________ | ក : ឆ្នាំ | ខ : វិនាទី | គ : ទសវត្សរ៍ | ឃ : ខែ |

**<u>សំណួរទី ៣</u>** :

| | | | | | |
|---|---|---|---|---|---|
| គូ ១<br>ក្តៅ : ត្រជាក់ | គូ ២<br>លឿន :_______ | ក : រត់ | ខ : យឺត | គ : ប្រញាប់ | ឃ : ហោះ |

**<u>សំណួរទី ៤</u>** :

| | | | | | |
|---|---|---|---|---|---|
| គូ ១<br>ភព : ផ្កាយ | គូ ២<br>ព្រះច័ន្ទ : | កៈ ផែនដី | ខៈព្រះអាទិត្យ | គៈ អាកាសធាតុ | ឃៈ ផ្កាយព្រះសុក្រ |

**<u>សំណួរទី ៥</u>** :

| | | | | | |
|---|---|---|---|---|---|
| គូ ១<br>ទឹកជ្រៅ :<br>មហាសមុទ្រ | គូ ២<br>វែង : _______ | ក . ខ្ពស់ | ខ . កៅអី | គ . ទន្លេ | ឃ . អាគារ |

**<u>សំណួរទី ៦</u>** :

| | | | | | |
|---|---|---|---|---|---|
| គូ ១<br>5 : 25 | គូ ២<br>6 : _______ | ក. 30 | ខ. 66 | គ. 35 | ឃ. 36 |

**<u>សំណួរទី ៧</u>**:

| | | | | | |
|---|---|---|---|---|---|
| គូ ១<br>0.25 : $\frac{1}{4}$ | គូ ២<br>0.5 : _______ | ក. $\frac{1}{5}$ | ខ. $\frac{1}{2}$ | គ. 50% | ឃ. 0.55 |

**<u>សំណួរទី ៨</u>** :

| | | | | | |
|---|---|---|---|---|---|
| គូ ១<br>$\frac{1}{2}$ : $\frac{1}{4}$ | គូ ២<br>10 : __________ | ក. 5 | ខ. 20 | គ. 25 | ឃ. 2.5 |

**<u>សំណួរទី ៩</u>** :

| | | | | | |
|---|---|---|---|---|---|
| គូ ១<br>$\frac{4}{6} : \frac{2}{3}$ | គូ ២<br>$\frac{2}{4}$ : ____ | ក. $\frac{3}{2}$ | ខ. $\frac{8}{12}$ | គ. $\frac{1}{2}$ | ឃ. $\frac{8}{16}$ |

**<u>សំណួរទី ១០</u>** :

| | | | | | |
|---|---|---|---|---|---|
| គូ ១<br>15 : 30 | គូ ២<br>10 : ____ | ក. 200 | ខ. 100 | គ. 15 | ឃ. 20 |

**<u>សំណួរទី ១១</u>** :




**<u>សំណួរទី ១២</u>**:




**<u>សំណួរទី ១៣</u>** :




**<u>សំណួរទី ១៤</u>** :




**<u>សំណួរទី ១៥</u>** :



## ផ្នែកទី ៥ :    ការវិភាគ ការពិត និង គំនិត ( ៦ ពិន្ទុ )

<u>សេចក្តីណែនាំ</u> : សំណួរខាងក្រោមនេះ ចង់ឱ្យប្អូនញែករវាងការពិត និង គំនិត ។ អត្ថបទខាងក្រោមដកស្រង់ពីសៀវភៅទេសចរណ៍ស្តីពីខេត្តកំពង់ចាម ។ សម្រាប់ល្បះនីមួយៗ ក្នុងអត្ថបទដែលមានគូសបន្ទាត់ពីក្រោម មានប្រអប់ទទេនៅចំហៀង ។ ចូរសរសេរអក្សរ " ព "ប្រសិនជាប្អូនយល់ថា ល្បះនេះជាការពិត ។ ចូរសរសេរអក្សរ " គ" ប្រសិនជាប្អូនយល់ថាល្បះនេះគ្រាន់តែជាគំនិត ។ ដើម្បីជួយប្អូនឱ្យយល់ពីការវិភាគនេះ ចូរមើលនិយមន័យនៃពាក្យ ថា"ការពិត"និង និយមន័យនៃពាក្យថា" គំនិត" ដែលសរសេរខាងក្រោម :

<u>ការពិត</u> : មានលក្ខណៈពិត ឬ មែនទែន គឺជាអ្វីមួយដែលកើតមានឡើងពិតប្រាកដ ឬក៏ជាអ្វីមួយដែលរស់នៅបច្ចុប្បន្ននេះ ។

<u>គំនិត</u> : គឺជាយោបល់របស់មនុស្សម្នាក់ ឬ មនុស្សដទៃទៀតអាចមានយោបល់ខុសពីនេះ ។

ឧទាហរណ៍មួយបានបង្ហាញក្នុងអត្ថបទខាងក្រោម :

*អញ្ជើញ និង ទស្សនាប្រាសាទបុរាណនៅខេត្តកំពង់ចាម*

<u>ឧទាហរណ៍</u> : <u>អ្នកទេសចរណ៍ដែលមកកម្ពុជា គួរតែឆ្លៀតឱកាសធ្វើទស្សនកិច្ចនៅខេត្តកំពង់ចាម</u> [ ១. គ ] មានប្រាសាទបុរាណជាច្រើនដែលគួរឱ្យចាប់អារម្មណ៍ខ្លាំង ។

<u>ប្រាសាទវត្តនគរបាជ័យ ស្ថិតនៅជិតជាង ៤ គ.ម ពីទីរួមខេត្តកំពង់ចាម</u> [ ២. ] <u>តាមគំនិតអ្នកឯកទេសខាងប្រវត្តិសាស្ត្រ ប្រាសាទនេះបានកសាងឡើងក្នុងសតវត្សទី ១១ ដើម្បីសុំខមាទោសកំហុសដោយស្តេចមួយអង្គដែលបានយកម្តាយរបស់ខ្លួនជាមហេសីដោយឥតដឹងខ្លួន</u> [ ៣. ] <u>ប្រាសាទផ្សេងៗ ទៀតដូចជា គុកនៅស្រុកព្រៃឈរ ហើយនិង ជើងអង នៅស្រុកពញាក្រែក ស្ថិតនៅឆ្ងាយបន្តិចបន្តួចពីទីរួមស្រុក</u> [ ៤. ]



<u>ក៏នៅតែស្ថិតក្នុងចំណោមប្រាសាទដែលស្អាតជាងគេនៅកម្ពុជា</u> [ ៥. ] <u>ប្រាសាទជាច្រើនទាំងនេះត្រូវបានកសាងឡើងមុនសម័យអង្គរ ដូច្នេះជាប្រាសាទបុរាណមែនពិត</u> [ ៦. ] សូមអញ្ជើញ និង ធ្វើទស្សនកិច្ចនៅខេត្តកំពង់ចាម ។ <u>អស់លោកមិនត្រូវស្តាយពេលវេលាដោយអញ្ជើញមកទីនេះឡើយ</u> [ ៧. ] ។

## ផ្នែកទី ៦ : ភាពវិលវល់ និង ល្បែងដោយគិត ( ១០ ពិន្ទុ )

<u>**សេចក្តីណែនាំ**</u> : ចូរដោះស្រាយលំហាត់ភាពវិលវល់ និង លំហាត់ល្បែងគំនិតខាងក្រោមនេះ :

<u>**សំណួរទី ១**</u> : ដោយប្រើខ្មៅដៃ ចូរប្អូនគូររកផ្លូវពីចំណុចចាប់ផ្តើមរហូតដល់ស្នូលកណ្តាលនៃរូបភាពវិលវល់នេះ ( ៤ ពិន្ទុ ) ។

ក.




ខ.



**<u>សំណួរទី ២</u>** : ចូរគូសរង្វង់មូល ◯ លើអក្សរ តើរូបភាពណាមួយដែលគ្មានគូ និង ពុំអាចត្រួតគ្នាបាន ( ២ ពិន្ទុ )

ក. 

ខ. 

គ. 

ឃ. 

**<u>សំណួរទី ៣</u>** : ចូរគូសរង្វង់មូល ◯ លើអក្សរ តើរូបភាពណាខ្លះដែលពុំអាចបត់ផ្គុំជាគូបបាន ( ២ ពិន្ទុ )

ក. 

ខ. 

គ. 

ឃ. 

**<u>សំណួរទី ៤</u>** : រូប ( ក ) និង ( ខ ) តើរូបណាមួយមានការេច្រើនជាងគេ ? ចូរគូសក្នុងប្រអប់ ☐

( ក ) ☐





( ខ ) ☐

# ផ្នែកទី ៧ :    ការវិភាគអត្ថបទ ( ១០ ពិន្ទុ )

<u>សេចក្តីណែនាំ</u> : អត្ថបទខាងក្រោមនេះ បានពិពណ៌នាពីរជ្ជកាលសម័យអង្គរក្រោយព្រះបាទជ័យវរ្ម័នទី ៧ ។ ផ្អែកតាមព័ត៌មានក្នុងអត្ថបទ ចូរបំពេញប្រអប់ដែលទទេក្នុងដ្យាក្រាមនៅទំព័រខាងក្រោយ ។

## <u>ព្រះមហាក្សត្រសម័យអង្គរក្រោយព្រះជ័យវរ្ម័នទី ៧</u>

មានព័ត៌មានតិចតួចណាស់ ស្តីពីរជ្ជកាលស្តេចសោយរាជ្យក្រោយៗព្រះបាទជ័យវរ្ម័នទី៧ ដ៏ល្បីល្បាញក្នុងសម័យអង្គរ ។ ជាការពិត សិលាចារឹកមិនសូវមានសោះក្នុងអាណាចក្រកម្ពុជា បន្ទាប់ពីរជ្ជកាលព្រះបាទជ័យវរ្ម័នទី ៩ ដែលបានសោយរាជ្យរយៈពេលខ្លី ១០ឆ្នាំ តែប៉ុណ្ណោះ ក្រោយព្រះបាទឥន្ទ្រវរ្ម័នទី ៤ ។ ព័ត៌មានមួយភាគក្នុងព័ត៌មានតិចតួចចេញពីកំណត់ហេតុរបស់រាជទូតចិនឈ្មោះជីវតាក្វាន់ដែលមកដល់ក្រុងអង្គរក្នុងឆ្នាំ ១២៩៦ បានប្រាប់យើងឱ្យដឹងថា ក្សត្រថ្មីនៅពេលនោះគឺ ព្រះឥន្ទ្រវរ្ម័នទី ៣មិនមែនជាបុត្ររបស់ព្រះបាទជ័យវរ្ម័នទី ៨ ទេ ប៉ុន្តែគឺជាបុត្រសុណិសារបស់ព្រះអង្គ ។ ជីវតាក្វាន់ បានសរសេរថាព្រះបាទឥន្ទ្រវរ្ម័នទី ៣ ពីមុនជាមេទ័ពម្នាក់ដែលបានអភិសេកជាមួយបុត្រីព្រះ បាទជ័យវរ្ម័នទី ៨ ឈ្មោះ ស្រីន្ទ្រភូរបស្វរចូឌា ។ ព្រះនាងស្រឡាញ់ស្វាមីណាស់ រហូតដល់ជួយដណ្តើមរាជបល្ល័ង្គពីបងប្រុសរបស់ព្រះនាងដែលជាក្សត្រសោយរាជពិតប្រាកដ ហើយកាត់ម្រាមជើងចោល និងយកទៅដាក់ក្នុងគុកមួយ ។ ទោះជាយ៉ាងណាក៏ដោយព្រះបាទឥន្ទ្រវរ្ម័នទី៣ គឺជាស្តេចពង្រឹងពុទ្ធសាសនាហិនយាននៅកម្ពុជាសម័យនោះ ។

ម្យ៉ាងទៀត យើងមានព័ត៌មានតិចតួចណាស់ ព្រះបាទឥន្ទ្រវរ្ម័នទី២ ដែលបានសោយរាជក្រោយព្រះបាទជ័យវរ្ម័នទី ៧ ។ ជាឧទាហរណ៍ យើងដឹងមិនច្បាស់សោះថា ព្រះបាទឥន្ទ្រវរ្ម័នទី២ ជាបុត្របង្កើតរបស់ព្រះបាទជ័យវរ្ម័នទី ៧ មែន ឬមិនមែន ឬប្រសិនបើជាបុត្របង្កើតរបស់ព្រះអង្គមែន តើព្រះអង្គជាបុត្ររបស់មហេសីមួយណា ? មានសិលាចារឹកតែមួយដែលបាននិយាយពី ព្រះបាទឥន្ទ្រវរ្ម័នទី២ ហើយបានប្រាប់ថា ព្រះអង្គចូលទិវង្គតនៅ គ.ស ១២៤៣ ។ មានអ្នកប្រវត្តិសាស្ត្រមួយចំនួនជូនយោបល់ថា ព្រះបាទឥន្ទ្រវរ្ម័នទី២ ជាស្តេចពុំសូវល្អប៉ុន្មានទេ ព្រោះព្រះអង្គព្យាយាមពង្រឹងសាសនាព្រាហ្មណ៍តែមិនបានសម្រេចជោគជ័យហើយ គាបសង្កត់ពុទ្ធសាសនាក្នុងរជ្ជកាលដ៏យូរអង្វែង ៤១ឆ្នាំ របស់ព្រះអង្គ ។


ព្រះមហាក្សត្រសម័យអង្គរក្រោយព្រះបាទជ័យវរ្ម័នទី ៧
ព្រះបាទជ័យវរ្ម័នទី ៧
1181-1218
1.
1202-1243
ជ័យរាជទេវី
ឥន្រ្ទទេវី
ព្រះបាទជ័យវរ្ម័នទី ៨
1243-1295
2.
1295-1307
ចក្រវិតីរាជទេវី
3. ______
ព្រះបាទឥន្ទ្រវរ្ម័នទី ៤
1307-1327
4.
1327-1336
កំណត់សំគាល់
ស្តេចគ្រងរាជ្យ
មហេសី

# ផ្នែកទី ៨ :    ការវិភាគអត្ថបទ ( ១៤ ពិន្ទុ )

<u>សេចក្តីណែនាំ</u> : ក្នុងផ្នែកនៃតេស្តនេះ សិស្សត្រូវតែរកគោលការណ៍មួយដែលអាចពន្យល់អំពីអ្វីៗដែលកើតមានឡើងតាមការសង្កេតរបស់គេក្នុងការធ្វើពិសោធមួយ ។ ដើម្បីចាប់ផ្តើមផ្នែកនេះគួរតែផ្តល់ឧទាហរណ៍នៃការពិសោធ និង គោលការណ៍ដែលអាចពន្យល់ពីការពិសោធ ។ ក្នុងការពិសោធខាងក្រោមនេះដែលធ្វើដោយអ្នកសម្ភាសន៍ សិស្សត្រូវតែរៀបរាប់ពីការសង្កេតរបស់គេហើយនឹងរកឃើញគោលការណ៍ដែលពន្យល់អំពីអ្វីៗដែលអាចកើតឡើងពីការពិសោធដូចមានឧទាហរណ៍មួយចំនួនខាងក្រោម ÷

<u>ចំណាំ</u> : ផ្នែកនេះក្នុងតេស្ត ត្រូវតែធ្វើដោយអ្នកសម្ភាសន៍ជាមួយសិស្សម្នាក់ៗ ។

<u>សេចក្តីណែនាំរបស់អ្នកសម្ភាសន៍</u> :

- ចូរចាប់ផ្តើមផ្នែកនេះដោយប្រាប់សិស្ស ដើម្បីឱ្យគេនឹងឃើញពិសោធមួយចំនួន ។ សិស្សត្រូវរៀបរាប់អំពីអ្វីៗដែលគេសង្កេតឃើញ ហើយនឹងត្រូវបង្កើតគោលការណ៍មួយដើម្បីពន្យល់ពីការសង្កេតនេះ ។ សិស្សត្រូវបំពេញតារាង ដូចខាងក្រោម ÷

<u>**តារាងចម្លើយរបស់សិស្ស**</u>

| ការសង្កេត | គោលការណ៍ពន្យល់ |
|---|---|
| ឧទាហរណ៍ :<br>១. ពេលដែលយើងដាក់ពងមាន់ក្នុងកែវដែលមានទឹកសាប ពងមាន់ធ្លាក់ចុះក្រោម ។<br>២. ពេលដែលយើងដាក់អំបិលក្នុងទឹក ពងមាន់អាចអណ្តែត ។ | - ពេលណាមានអំបិលលាយជាមួយទឹក វាអាចងាយស្រួលឱ្យវត្ថុអណ្តែត ។ |
| សំណួរទី១ : | |
| សំណួរទី២ : | |

- ចូរធ្វើឧទាហរណ៍ជាមួយសិស្សដែលត្រូវបង្ហាញក្នុងតារាងខាងលើ ÷

ឥឡូវនេះខ្ញុំនឹងបង្ហាញពីការពិសោធមួយស្តែងអំពីកែវទឹកមានអំបិល និង ពងមាន់ ។ ជាបឋមចូរមើលកែវទឹក ។ សុំភ្លក់ទឹក តើទឹកនេះជាទឹកសាប ឬ ទឹកប្រៃ ? (សិស្សគួរតែឆ្លើយថា ទឹកនេះជាទឹកសាប ។ តើពេលដែលខ្ញុំដាក់ស៊ុតក្នុងកែវទឹក តើមានអ្វីកើតឡើង ? ក្រោយពីដាក់ពងមាន់ក្នុងទឹកស៊ុតធ្លាក់ចុះទៅក្រោម) ។

- តឡូវតើមានអ្វីកើតឡើងពេលដែលខ្ញុំដាក់អំបិលក្នុងទឹក (ស៊ុតគួរតែអណ្តែតឡើង) ។ ដូចនេះខ្ញុំសន្និដ្ឋានថា ពេលដែលខ្ញុំដាក់អំបិលលាយជាមួយទឹកធ្វើឱ្យវត្ថុងាយអណ្តែត ។ នេះគឺជាការសន្និដ្ឋានរបស់ខ្ញុំដែលខ្ញុំត្រូវសរសេរក្នុងប្រអប់សមស្របក្នុងតារាងនេះ ។

<u>ចំណាំ</u> : ការសន្និដ្ឋាននេះគឺជាគោលការណ៍ មិនមែនជាការសង្ខេបនៃការសង្កេតនោះឡើយ ។

- ចូរបង្ហាញពិសោធផ្សេងៗ ឱ្យសិស្សមើលដូចខាងក្រោម ៖

<u>សំណួរទី ១</u> :

<u>សេចក្តីណែនាំ</u> : ចូរបង្ហាញមេដែកដល់សិស្ស ហើយ និង សម្ភារផ្សេងទៀតដូចជា កំណាត់ ប្លាស្ទិក ក្រដាស ឃ្នាប ថ្ម កំប៉ុង ។ ឱ្យសិស្សព្យាយាមស្ទួចវត្ថុនីមួយៗដោយប្រើមេដែក ។ រួចហើយឱ្យសិស្សសរសេរការសង្កេតរបស់គេ ហើយសន្និដ្ឋានបង្កើតជាគោលការណ៍ក្នុងតារាងចម្លើយ ។

<u>សំណួរទី ២</u> :

<u>សេចក្តីណែនាំ</u> : ចូរបង្ហាញកែវ ៤ ដែលមានបរិមាណទឹកខុសៗគ្នា ។

- កែវទី១ មានទឹក $\frac{1}{4}$
- កែវទី២ មានទឹក $\frac{1}{2}$
- កែវទី៣ មានទឹក $\frac{3}{4}$
- កែវទី៤ មានទឹក ពេញ

ឱ្យសិស្សគោះកែវនីមួយៗដោយប្រើខ្មៅដៃ ឬ ប៊ិច ។ ឱ្យសិស្សសរសេរការសង្កេតរបស់គេ និង ការសន្និដ្ឋានដោយបង្កើតគោលការណ៍ និង សរសេរចម្លើយដាក់ក្នុងតារាង ។

## ផ្នែកទី ៨ : ការពិសោធរកគោលការណ៍ ( ១៣ ពិន្ទុ )

*<u>តារាងចម្លើយរបស់សិស្ស</u>*

**សំណួរ :** ចូរពិនិត្យកែវទាំង ៣ ដែលមានទឹកក្តៅឧណ្ហៗ និង មានចំណុះស្មើគ្នា :

- កែវទី ១ : មានអំបិល១ ស្លាបព្រា ។ កែវទី ២ : មានអំបិល ២ ស្លាបព្រា ។ កែវទី ៣ : គ្មានអំបិល

- កែវទី១ និង កែវទី២ត្រូវកូរអំបិលឱ្យរលាយទាំងស្រុង ។ ដាក់សីតុណ្ហមាត្រក្នុងកែវទី ១ រួចទី ២ និង កែវទី ៣ ។ ចូរសរសេរពីការសង្កេតរបស់អ្នកដោយធ្វើការសន្និដ្ឋានហើយបង្កើតគោលការណ៍ និង សរសេរចម្លើយដាក់ក្នុងតារាង ។

| ការសង្កេត | គោលការណ៍ពន្យល់ |
|---|---|
| ឧទាហរណ៍ :<br>១. ពេលដែលយើងដាក់ពងទាក្នុងកែវដែលមានទឹកសាប ពងទាធ្លាក់ ។<br>២. ពេលដែលយើងដាក់អំបិលក្នុងទឹកពងទាអណ្តែត ។ | – ពេលណាមានអំបិលលាយជាមួយទឹកវាងាយស្រួលឱ្យវត្ថុអណ្តែត ។ |

<u>ចម្លើយ</u>

| ការសង្កេត | គោលការណ៍ពន្យល់ |
|---|---|
| | |

## ឯកសារទី៣: លំហាត់តេស្តគិតដោយច្នៃប្រឌិត

### ផ្នែកទី ១ : ការកំណត់លទ្ធផល ( ៦ ពិន្ទុ )

( ក្រដាសចម្លើយរបស់សិស្ស )

__សំណួរឧទាហរណ៍__ : តើអ្វីនឹងកើតឡើង បើមានព្រិលធ្លាក់នៅប្រទេសកម្ពុជា ? ចូរធ្វើបញ្ជីលទ្ធផលច្រើនបំផុតដែលអាចនឹកបានក្នុងកន្លែងកំណត់ ។

១. មានរុក្ខជាតិ និង សត្វជាច្រើនដែលត្រូវស្លាប់ ព្រោះវាគ្មានទម្លាប់ជួបភាពត្រជាក់ដល់កម្រិតនេះ

២. ថ្នល់ និង ផ្លូវដើរត្រូវរអិល

៣.ត្រូវមានឧបទ្ទវហេតុគ្រោះថ្នាក់ចរាចរជាច្រើន ពីព្រោះប្រជាជនគ្មានទម្លាប់បើកឡានលើផ្លូវរអិល

៤. ប្រជាជនត្រូវត្រជាក់យ៉ាងខ្លាំង ពីព្រោះគេគ្មានខោអាវរងា

៥. មានប្រជាជនជាច្រើនត្រូវឈឺផ្ដាសាយ ពីព្រោះគ្មានទម្លាប់នឹងអាកាសធាតុត្រជាក់

៦. ផ្ទះប្រជាជនត្រូវត្រជាក់ ពីព្រោះផ្ទះនៅកម្ពុជាគ្មានមធ្យោបាយការពារខ្យល់បក់នៅខាងក្នុង

៧. ប្រជាជនមិនអាចស្ទូងស្រូវ ព្រោះទឹកតាមវាលស្រែត្រូវកក

៨. ទន្លេ និង បឹងត្រូវកក

៩. ប្រជាជនត្រូវឈប់ប្រើទឹកកកដាក់ក្នុងភេសជ្ជៈ ។

__សំណួរ__ : តើអ្វីនឹងកើតឡើងនៅប្រទេសកម្ពុជា ? ប្រសិនបើភ្លៀងធ្លាក់ពេញមួយឆ្នាំដោយមិនឈប់ ។

១. ............................................................................................................................

២. ............................................................................................................................

៣. ............................................................................................................................

៤. ............................................................................................................................

៥. ............................................................................................................................

៦. ............................................................................................................................

៧. ............................................................................................................................

៨. ............................................................................................................................

៩. ............................................................................................................................

## ផ្នែកទី ២ : ការប្រើប្រាស់វត្ថុដោយរបៀបប្លែកៗ ( ៥ ពិន្ទុ )

( សន្លឹកចម្លើយសម្រាប់សិស្ស )

ឧទាហរណ៍ : ចូរប្អូននឹកឱ្យបានច្រើនបំផុតពីការប្រើប្រាស់ដុំថ្ម ។ ចូរសរសេរខាងក្រោម :

១. វាជាវត្ថុការពារកុំឱ្យក្រដាសប៉ើងពីលើតុ

២. វាជាវត្ថុសម្រាប់ដំបង្គោលស្នឹង កាលណាខ្ញុំត្រូវការចងគោ

៣. វាជាអាវុធការពារកុំអោយឆ្កែដេញខាំខ្ញុំ

៤. វាជាកាស់សម្រាប់រាប់ក្នុងការលេងល្បែងក្នុងបណ្ណាល័យ

៥. វាជាវត្ថុសម្រាប់គោះជួងពេលចេញ និង ចូលរៀន

៦. វាជារបស់សម្រាប់បង្ហាញថា ខ្ញុំបានចូលអានសៀវភៅក្នុងបណ្ណាល័យ

៧. វាជាវត្ថុសម្រាប់ដាក់ឱ្យធ្ងន់នៅលើដងជញ្ជីងម្ខាង

៨. វាជាវត្ថុដែលខ្ញុំត្រូវរៀនក្នុងមុខវិជ្ជា វិទ្យាសាស្ត្រអនុវត្ត

៩. វាជាវត្ថុមួយដែលខ្ញុំបោះទៅក្នុងទឹក ធ្វើឱ្យទឹកបែកខ្ទាយ និង ភាយឡើង

១០. វាជាឧបករណ៍សរសេរនៅលើជញ្ជាំង ។

សំណួរ : តើអ្នកអាចនឹកពីការប្រើប្រាស់ស្លឹកចេកមានប៉ុន្មាន ? ចូរកំណត់ឱ្យបានត្រឹមត្រូវបំផុត ។

១. ........................................................................................................

២. ........................................................................................................

៣. ........................................................................................................

៤. ........................................................................................................

៥. ........................................................................................................

៦. ........................................................................................................

៧. ........................................................................................................

៨. ........................................................................................................

៩. ........................................................................................................

១០. ......................................................................................................

# ផ្នែកទី ៣ : ការប្រើពាក្យដោយស្ទាត់ ( ១៥ ពិន្ទុ )

( សន្លឹកចម្លើយសម្រាប់សិស្ស )

**<u>សេចក្តីណែនាំ</u> :** ចូរកំណត់ពាក្យឱ្យបានត្រឹមត្រូវបំផុតដែលអាចធ្វើបាន ។ ចូរកំណត់ពាក្យដែលមានន័យស្រដៀង ឬ ន័យដូចត្រង់កន្លែងដែលមានគូសបន្ទាត់ពីក្រោយ ។ ចូរសរសេរពាក្យទាំងនោះត្រង់កន្លែងកំណត់ ។

<u>ឧទាហរណ៍</u> : <u>ស្រលាញ់</u> : ចូលចិត្ត ពេញចិត្ត រាប់អាន បេតី មេត្រី ស្មោះស្ម័គ្រ

<u>សំណួរទី ១</u> : ឧស្សាហ៍

១. .................. ២. .................. ៣. ................. ៤. .................. ៥. ................ ៦. .....................

<u>សំណួរទី ២</u> : លឿន

១. ................ ២. .................. ៣. .................. ៤. .................. ៥. ................ ៦. .....................

<u>សំណួរទី ៣</u> : ឃើញ

១. .................. ២. .................. ៣. .................. ៤. ................. ៥. ................. ៦. .....................

<u>សំណួរទី ៤</u> : រីកចំរើន

១. .................. ២. .................. ៣. ................... ៤. .................. ៥. ................ ៦. .....................

<u>សំណួរទី ៥</u> : ស្លូត

១. .................. ២. .................. ៣. ................... ៤. .................. ៥. ................ ៦. .....................

## ផ្នែកទី ៤ : ការបង្ហាញគំនិតដោយស្ទាត់ ( ១០ ពិន្ទុ )

( សន្លឹកចម្លើយរបស់សិស្ស )



<u>សំណួរជាគំរូ</u> : ចូរសរសេរពាក្យច្រើនបំផុតដែលអាចសរសេរបាន ដើម្បីពិពណ៌នារូបភាពខាងលើ ។

១. ទូក ២. រដូវក្តៅ ៣. ក្តៅ ៤. ព្រលប់ ៥. រំភើយ ៦. ស្ងប់ស្ងាត់ ៧. ត្រូពិច

៨. ភ្លឺ ៩. សមុទ្រ ១០. ក្តោង ១១. រំភើប ១២. ស្អាត ១៣. ឥន្ទធនូ ១៤. រុងរឿង

១៥. ជើងមេឃ ១៦. ទិនាវសាន ១៧. ឆ្នេរសមុទ្រ ១៨. ផ្ទាំងថ្ម ១៩. រីករាយ ២០. ផ្សងព្រេង

២១. ស្ងាត់ ២២. លង់លក់ ២៣. ដាច់ស្រយាល ២៤. សប្បាយ ២៥. ស្រគត់ស្រគំ ។

<u>សំណួរ</u> : ចូរសរសេរពាក្យច្រើនបំផុតដែលអាចរកបានសម្រាប់ពិពណ៌នារូបភាពខាងក្រោម ៖



១. ............... .......... ២. ................................ ៣. ............................ ៤. ..............................

៥. ............................៦. ................................ ៧. ............................ ៨. ..............................

៩. .......................... ១០. ............................១១. .......................... ១២. ..............................

១៣. ..................... ១៤ . ............................ ១៥. ............................១៦. ..............................

១៧. .......................១៧. ............................ ១៨. ...........................  ២០. ............................

២១. ..................... ២២. ............................. ២៣. .......................... ២៤. ..............................

២៥. ............................

## ផ្នែកទី ៥ : ការបញ្ចេញរូបារម្មណ៍ ( ១៥ ពិន្ទុ )

<u>សេចក្តីណែនាំ</u> : រូបរាងនេះមិនបានបង្ហាញពីអ្វីច្បាស់ទេ ក៏ប៉ុន្តែចូរព្យាយាមប្រាប់ខ្ញុំនូវអ្វីៗ ដែលរូបរាងនេះធ្វើឱ្យអ្នកស្រមៃឃើញ ។ ចូរប្រាប់ខ្ញុំពីអ្វីៗនោះអោយបានច្រើនបំផុតដែលអ្នកនឹកឃើញ ។



ក. ចូរសរសេរអ្វីៗដែលរូបរាងនេះ ធ្វើឱ្យអ្នកស្រមៃឃើញខាងក្រោម :

១.____________________________________

២.____________________________________

៣.____________________________________

៤..____________________________________

៥.____________________________________

៦.____________________________________

៧.____________________________________

៨.____________________________________

៩.____________________________________



ខ. ចូរសរសេរអ្វីៗដែលរូបរាងនេះ ធ្វើឱ្យអ្នកស្រមៃឃើញខាងក្រោម :

១.____________________________________

២.____________________________________

៣.____________________________________

៤. ____________________________________

៥.____________________________________

៦.____________________________________

៧.____________________________________

៨.____________________________________

៩.____________________________________

# ផ្នែកទី ៦ : ការច្នៃរូបរាង ( ៨ ពិន្ទុ )

<u>**សេចក្តីណែនាំ**</u> : ចូរប្អូនមើលរូបធរណីមាត្រ មានការច្នៃជាឧទាហរណ៍ក្នុងប័ណ្ណនេះ ។ គេច្នៃជារូបទន្សាយចេញពីរូបធរណីមាត្រ " ពងក្រពើ " ។



**សំណួរ** : ចូរអ្នកធ្វើរូបភាពឱ្យបានច្រើនបំផុតចេញពីរូបរាងខាងក្រោមមាន៤ កន្លែងសម្រាប់ការគូររបស់អ្នក ។



# ផ្នែកទី ៧ : ចំណោតស្រាយដោយប្រៀបធៀប ( ១៥ ពិន្ទុ )

( សន្លឹកសម្រាប់ចម្លើយរបស់សិស្ស )

**<u>សេចក្តីណែនាំ</u>** : ចូរមើលឃ្លាប្រៀបធៀបខាងក្រោម រួចរកពាក្យឱ្យបានច្រើនបំផុតដែលអាចរកបាន ដើម្បីបំពេញឃ្លា ប្រៀបធៀបដូចគេបានបង្ហាញក្នុងឧទាហរណ៍ ។

**<u>សំណួរជាគំរូ</u>** : ក្តៅដូច .............

១. ក្តៅដូចភ្លើង

២. ក្តៅដូចថ្ងៃ

៣. ក្តៅដូចអណ្តាតភ្លើង

៤. ក្តៅដូចចង្ក្រាន

៥. ក្តៅដូចភ្នំភ្លើង

**<u>សំណួរទី ១</u>** : លឿនដូច .............

១. .......................

២. ........................

៣. ........................

៤. .........................

៥ . ........................

**<u>សំណួរទី ២</u>** : សដូច .............

១. .....................................

២. ....................................

៣. ....................................

៤. ....................................

៥. ....................................

## ផ្នែកទី ៨ : ទំនាក់ទំនងរវាងពាក្យ ( ១៥ ពិន្ទុ )

( សន្លឹកចម្លើយរបស់សិស្ស )

<u>សេចក្តីណែនាំ</u> : ចូរអ្នកមើលពាក្យទាំង ៣ ដែលមាននៅខាងក្រោមនេះ ។ ចូរអ្នកកំណត់រូបសរសេរពាក្យទី ៤ ដែលទាក់ទងនឹងពាក្យទាំង ៣ និង ពាក្យទី ៤ នោះទាក់ទងគ្នា ។

ផ្កាយ ព្រះអាទិត្យ ទៀន

<u>ចម្លើយ</u> : អំពូលភ្លើង ទំនាក់ទំនងគ្នា : ទាំងអស់សុទ្ធតែផ្តល់ពន្លឺ

<u>សំណួរទី ១</u> :

លោត រត់ ឈរ

<u>ចម្លើយ</u> :...................................... ទំនាក់ទំនងគ្នា :.........................................

<u>សំណួរទី ២</u> :

សត្វស្លាប យន្តហោះ ឃ្មុំ

<u>ចម្លើយ</u> : ..................................... ទំនាក់ទំនងគ្នា : .......................................

<u>សំណួរទី ៣</u> :

ស្រះ បឹង ត្រពាំង

<u>ចម្លើយ</u> : .................................. ទំនាក់ទំនងគ្នា : .........................................

## ឯកសារទី៤: ការកំណត់សកម្មភាពនៃមុខវិជ្ជានីមួយៗ ដើម្បីលើកស្ទួយការគិតដោយវិភាគ

| “A” **ការកំណត់សកម្មភាព ឬ លំហាត់នៃមុខវិជ្ជាទាំង ៤ ដើម្បីពង្រឹងការគិតដោយវិភាគ** | | |
|---|---|---|
| ***១. លំដាប់លំដោយរូបរាង*** : សិស្សត្រូវមើលលំដាប់លំដោយរូបរាងមួយចំនួន ដែលមានទំនាក់ទំនងគ្នាទៅតាមលំដាប់លំដោយកំណត់ ។ រួចគេត្រូវជ្រើសរើសរូបភាពមួយក្នុងចំណោមរូបភាព ៤ ដែលបានបង្ហាញមកក្រោយ ។ | | |
| តើបំណិននេះអាចពង្រឹងក្នុងមុខវិជ្ជានីមួយៗ បានដែរឬទេ ? | ចូរកំណត់ បាទ ចាំ ឬ ទេ | ប្រសិន << បាទ ចាំ >> ចូរលើកឧទាហរណ៍ និង រៀបរាប់ពីសកម្មភាពរបស់សិស្ស |
| គណិតវិទ្យា | | |
| ភាសាខ្មែរ | | |
| សិក្សាសង្គម | | |
| វិទ្យាសាស្ត្រអនុវត្ត | | |
| ***២. ក/ លំដាប់លំដោយរឿង*** : ក្នុងកិច្ចការនេះ សិស្សត្រូវកំណត់លំដាប់លំដោយរូបភាពនៃរឿងមួយ ដោយសរសេរលេខ ដែលបង្ហាញលំដាប់លំដោយនៅខាងចំហៀងរូបភាព ។ | | |
| តើបំណិននេះអាចពង្រឹងក្នុងមុខវិជ្ជានីមួយៗ បានដែរឬទេ ? | ចូរកំណត់ បាទ ចាំ ឬ ទេ | ប្រសិន << បាទ ចាំ >> "ចូរលើកឧទាហរណ៍ និង រៀបរាប់ពីសកម្មភាពរបស់សិស្ស" |
| គណិតវិទ្យា | | |
| ភាសាខ្មែរ | | |
| សិក្សាសង្គម | | |
| វិទ្យាសាស្ត្រអនុវត្ត | | |
| ***២. ខ/ លំដាប់លំដោយនៃរឿងនិទានជាអត្ថបទ*** : ក្នុងកិច្ចការនេះ សិស្សត្រូវកំណត់លំដាប់លំដោយឈ្មោះនៃកម្រងរឿងមួយ ដោយសរសេរបង្ហាញលំដាប់លំដោយនៃសាច់រឿងនេះ ចំហៀងឈ្មោះទាំងនោះ។ | | |
| តើបំណិននេះអាចពង្រឹងក្នុងមុខវិជ្ជានីមួយៗ បានដែរឬទេ ? | ចូរកំណត់ បាទ ចាំ ឬ ទេ | ប្រសិន << បាទ ចាំ >> ចូរលើកឧទាហរណ៍ និង រៀបរាប់ពីសកម្មភាពរបស់សិស្ស |

| | | |
|---|---|---|
| គណិតវិទ្យា | | |
| ភាសាខ្មែរ | | |
| សិក្សាសង្គម | | |
| វិទ្យាសាស្ត្រអនុវត្ត | | |
| ***៣. ចំណាត់ថ្នាក់ :*** សិស្សត្រូវមើលធាតុ ៤ ( រូបភាព ពាក្យ សញ្ញា លេខ ) រួចកំណត់ធាតុ ដែលមិនត្រូវនឹងគេ ។ | | |
| តើបំណិននេះអាចពង្រឹងក្នុងមុខវិជ្ជានីមួយៗ បានដែរឬទេ ? | ចូរកំណត់ បាទ ចាំ ឬ ទេ | ប្រសិន << បាទ ចាំ >>ចូរលើកឧទាហរណ៍ និង រៀបរាប់ពីសកម្មភាពរបស់សិស្ស |
| គណិតវិទ្យា | | |
| ភាសាខ្មែរ | | |
| សិក្សាសង្គម | | |
| វិទ្យាសាស្ត្រអនុវត្ត | | |
| ***៤. សទិសភាព :*** សទិសភាពមានទម្រង់ថា : " ក ត្រូវនឹង ខ ដូច គ ត្រូវនឹង .......... " ធាតុ ក មានទំនាក់ទំនងជាមួយធាតុ ខ ។ សិស្សត្រូវកំណត់ចម្លើយដែលមានទំនាក់ទំនងជាមួយ គ ដូចទំនាក់ទំនងជាមួយ ក និង ខ ដែរ ។ | | |
| តើបំណិននេះអាចពង្រឹងក្នុងមុខវិជ្ជានីមួយៗ បានដែរឬទេ ? | ចូរកំណត់ បាទ ចាំ ឬ ទេ | ប្រសិន << បាទ ចាំ >>ចូរលើកឧទាហរណ៍ និង រៀបរាប់ពីសកម្មភាពរបស់សិស្ស |

| | | |
|---|---|---|
| គណិតវិទ្យា | | |
| ភាសាខ្មែរ | | |
| សិក្សាសង្គម | | |
| វិទ្យាសាស្ត្រអនុវត្ត | | |
| ***៥. ការវិភាគបញ្ញត្តិ  :  ការពិត និង គំនិត  :***  សិស្សទទួលនិយមន័យ  " ការពិត  " និង  " គំនិត  " រួចគេត្រូវកំណត់ថា  តើល្បះមួយចំនួនក្នុងអត្ថបទជាការពិត ឬ ជាគំនិត  ។ | | |
| តើបំណិននេះអាចពង្រឹងក្នុងមុខវិជ្ជានីមួយៗ បានដែរឬទេ ? | ចូរកំណត់ បាទ ចាំ ឬ ទេ | ប្រសិន << បាទ ចាំ >> ចូរលើកឧទាហរណ៍ និង រៀបរាប់ពីសកម្មភាពរបស់សិស្ស |
| គណិតវិទ្យា | | |
| ភាសាខ្មែរ | | |
| សិក្សាសង្គម | | |
| វិទ្យាសាស្ត្រអនុវត្ត | | |

| | | |
|---|---|---|
| ***៦. ការវិលវល់និងល្បែងដោយគិត :*** សំណួរនេះវាយតម្លៃសមត្ថភាពសិស្សរកផ្លូវវិលវល់ ព្រមទាំងដោះស្រាយចំណោទទំនាក់ទំនងបែបរូបភាព និង លេខ ។ | | |
| តើបំណិននេះអាចពង្រឹងក្នុងមុខវិជ្ជានីមួយៗ បានដែរឬទេ ? | ចូរកំណត់ បាទ ចាំ ឬ ទេ | ប្រសិន << បាទ ចាំ >> ចូរលើកឧទាហរណ៍ និង រៀបរាប់ពីសកម្មភាពរបស់សិស្ស |
| គណិតវិទ្យា | | |
| ភាសាខ្មែរ | | |
| សិក្សាសង្គម | | |
| វិទ្យាសាស្ត្រអនុវត្ត | | |
| ***៧. ការវិភាគអត្ថបទ :*** សិស្សត្រូវអានអត្ថបទខ្លីមួយ រួចបំពេញកិច្ចការមួយចំនួនទៅតាមអ្វីដែលគេយល់ពីអត្ថបទនោះ ។ កិច្ចការនេះ ស្ដីពីការបំពេញតារាងទៅតាមការពន្យល់ក្នុងអត្ថបទ ។ | | |
| តើបំណិននេះអាចពង្រឹងក្នុងមុខវិជ្ជានីមួយៗ បានដែរឬទេ ? | ចូរកំណត់ បាទ ចាំ ឬ ទេ | ប្រសិន << បាទ ចាំ >>ចូរលើកឧទាហរណ៍ និង រៀបរាប់ពីសកម្មភាពរបស់សិស្ស |
| គណិតវិទ្យា | | |
| ភាសាខ្មែរ | | |

<table>
<tr><td>សិក្សាសង្គម</td><td></td><td></td></tr>
<tr><td>វិទ្យាសាស្ត្រអនុវត្ត</td><td></td><td></td></tr>
<tr><td colspan="3">៨. ការពិសោធរកគោលការណ៍ : សំណួរបែបនេះ តម្រូវឱ្យសិស្សរកគោលការណ៍ទូទៅ ទៅតាមឧទាហរណ៍ដែលបានកំណត់ ។ ឧទាហរណ៍ : សិស្សទទួលមេដែកព្រមទាំងវត្ថុផ្សេងៗ ធ្វើពីក្រដាស ប្លាស្ទិក និង ដែក រួចគេត្រូវព្យាយាមស្ទួចវត្ថុនោះដោយមេដែក ។ ក្រោយពីបញ្ចប់ពិសោធន៍នេះ សិស្សត្រូវអះអាង ដោយធ្វើសន្និដ្ឋាន ឬ គោលការណ៍ទូទៅ ដែលបានពន្យល់ពីអ្វីដែលគេសង្កេតឃើញ ។</td></tr>
<tr><td>តើបំណិននេះអាចពង្រឹងក្នុងមុខវិជ្ជានីមួយៗ បានដែរឬទេ ?</td><td>ចូរកំណត់ បាទ ចាំ / ទេ</td><td>ប្រសិន << បាទ ចាំ >> ចូរលើកឧទាហរណ៍ និង រៀបរាប់ពី សកម្មភាពរបស់សិស្ស</td></tr>
<tr><td>គណិតវិទ្យា</td><td></td><td></td></tr>
<tr><td>ភាសាខ្មែរ</td><td></td><td></td></tr>
<tr><td>សិក្សាសង្គម</td><td></td><td></td></tr>
<tr><td>វិទ្យាសាស្ត្រអនុវត្ត</td><td></td><td></td></tr>
</table>

## ឯកសារទី៥: ការកំណត់សកម្មភាពនៃមុខវិជ្ជានីមួយៗ ដើម្បីលើកស្ទួយការគិតដោយច្នៃប្រឌិត

| “B” **ការកំណត់សកម្មភាព ឬ លំហាត់នៃមុខវិជ្ជាទាំង ៤ ដើម្បីពង្រីកការគិតដោយច្នៃប្រឌិត** | | |
|---|---|---|
| ***១. ការកំណត់លទ្ធផល :*** សិស្សត្រូវឆ្លើយសំណួរពីអ្វីដែលនឹងកើត ប្រសិនបើមានព្រឹត្តិការណ៍ប្លែកៗ កើតឡើង ។ សិស្សត្រូវនឹករកលទ្ធផលអោយបានច្រើនបំផុតដែលគេអាចនឹកឃើញក្រោយពីព្រឹត្តិការណ៍នោះកន្លងផុត ។ | | |
| តើបំណិននេះអាចពង្រឹងក្នុងមុខវិជ្ជានីមួយៗ បានដែរឬទេ ? | ចូរកំណត់ បាទ ចាំ ឬ ទេ | ប្រសិន << បាទ ចាំ >> ចូរលើកឧទាហរណ៍ និង រៀបរាប់ពីសកម្មភាពរបស់សិស្ស |
| គណិតវិទ្យា | | |
| ភាសាខ្មែរ | | |
| សិក្សាសង្គម | | |
| វិទ្យាសាស្ត្រអនុវត្ត | | |
| ***២. ការប្រើប្រាស់វត្ថុដោយរបៀបប្លែកៗ :*** ក្នុងផ្នែកនេះ សិស្សត្រូវពិចារណាលើវត្ថុធម្មតាមួយ ហើយព្យាយាមកំណត់ការប្រើប្រាស់វត្ថុនោះឱ្យបានច្រើនបំផុតដែលគេអាចនឹកបាន ។ ការប្រើប្រាស់វត្ថុដែលគេកំណត់នោះ មិនចាំបាច់តែសម្រាប់ធ្វើការងារទេ វាអាចសម្រាប់ជាល្បែងលេងក៏បានដែរ ។ | | |
| តើបំណិននេះអាចពង្រឹងក្នុងមុខវិជ្ជានីមួយៗ បានដែរឬទេ ? | ចូរកំណត់ បាទ ចាំ ឬ ទេ | ប្រសិន << បាទ ចាំ >> ចូរលើកឧទាហរណ៍ និង រៀបរាប់ពីសកម្មភាពរបស់សិស្ស |
| គណិតវិទ្យា | | |
| ភាសាខ្មែរ | | |

| | | |
|---|---|---|
| សិក្សាសង្គម | | |
| វិទ្យាសាស្ត្រអនុវត្ត | | |
| *៣. ការប្រើប្រាស់ពាក្យដោយស្ទាត់ :* សិស្សត្រូវរកពាក្យអោយបានច្រើន ដោយអោយមានន័យដូចពាក្យកំណត់ ។ | | |
| តើបំណិននេះអាចពង្រីងក្នុងមុខវិជ្ជានីមួយៗ បានដែរឬទេ ? | ចូរកំណត់ បាទ ចាំ ឬ ទេ | ប្រសិន << បាទ ចាំ >> ចូរលើកឧទាហរណ៍ និង រៀបរាប់ពីសកម្មភាពរបស់សិស្ស |
| គណិតវិទ្យា | | |
| ភាសាខ្មែរ | | |
| សិក្សាសង្គម | | |
| វិទ្យាសាស្ត្រអនុវត្ត | | |
| *៤. ការប្រើប្រាស់គំនិតដោយស្ទាត់ :* សិស្សត្រូវមើលរូបភាពដែលបានកំណត់ រួចរកពាក្យអោយបានច្រើនបំផុតដែលអាចរកបានដើម្បីពិពណ៌នារូបភាពនោះ ។ | | |
| តើបំណិននេះអាចពង្រីងក្នុងមុខវិជ្ជានីមួយៗ បានដែរឬទេ ? | ចូរកំណត់ បាទ ចាំ ឬ ទេ | ប្រសិន << បាទ ចាំ >>ចូរលើកឧទាហរណ៍ និង រៀបរាប់ពីសកម្មភាពរបស់សិស្ស |
| គណិតវិទ្យា | | |

| | | |
|---|---|---|
| ភាសាខ្មែរ | | |
| សិក្សាសង្គម | | |
| វិទ្យាសាស្ត្រអនុវត្ត | | |
| ***៥. ការបង្ហាញរូបារម្មណ៍ :*** សិស្សត្រូវមើលរូបភាពដែលគ្មានរូបរាងច្បាស់ ។ ក្រោយមកអ្នកសម្ភាសន៍នឹងសុំអោយគេគិតអ្វីៗ ដែលអាចស្រមៃឃើញពីរូបភាពនោះ ។ | | |
| តើបំណិននេះអាចពង្រឹងក្នុងមុខវិជ្ជានីមួយៗ បានដែរឬទេ ? | ចូរកំណត់ បាទ ចាំ ទេ | ប្រសិន << បាទ ចាំ >> ចូរលើកឧទាហរណ៍ និង រៀបរាប់ពីសកម្មភាពរបស់សិស្ស |
| គណិតវិទ្យា | | |
| ភាសាខ្មែរ | | |
| សិក្សាសង្គម | | |
| វិទ្យាសាស្ត្រអនុវត្ត | | |

| *៦. ការច្នៃរូបរាង* : សិស្សទទួលរូបភាពធរណីមាត្រងាយៗ ហើយច្នៃរូបភាពមួយចេញពីរូបរាងធរណីមាត្រនោះអោយបានរូបរាងច្រើនបំផុតដែលគេធ្វើបាន ។ | | |
|---|---|---|
| តើបំណិននេះអាចពង្រឹងក្នុងមុខវិជ្ជានីមួយៗ បានដែរឬទេ ? | ចូរកំណត់ បាទ ចាំ ទេ | ប្រសិន << បាទ ចាំ >> ចូរលើកឧទាហរណ៍ និង រៀបរាប់ពីសកម្មភាពរបស់សិស្ស |
| គណិតវិទ្យា | | |
| ភាសាខ្មែរ | | |
| សិក្សាសង្គម | | |
| វិទ្យាសាស្ត្រអនុវត្ត | | |

| *៧. បំណកស្រាយដោយប្រៀបធៀប* : សិស្សត្រូវមើលឃ្លាប្រៀបធៀបមិនទាន់គ្រប់លក្ខណៈដូចជា : " ក្តៅដូច . . . " ។ សិស្សត្រូវរកពាក្យច្រើនបំផុតដែលគេអាចរកបានដើម្បីបំពេញឃ្លាប្រៀបធៀបនោះ ។ ឧទាហរណ៍ : ក្តៅដូចភ្លើង ក្តៅដូចថ្ងៃ ក្តៅដូចព្រះអាទិត្យ . . . ។ | | |
|---|---|---|
| តើបំណិននេះអាចពង្រឹងក្នុងមុខវិជ្ជានីមួយៗ បានដែរឬទេ ? | ចូរកំណត់ បាទ ចាំ ឬ ទេ | ប្រសិន << បាទ ចាំ >> ចូរលើកឧទាហរណ៍ និង រៀបរាប់ពីសកម្មភាពរបស់សិស្ស |
| គណិតវិទ្យា | | |
| ភាសាខ្មែរ | | |
| សិក្សាសង្គម | | |

| | | |
|---|---|---|
| វិទ្យាសាស្ត្រអនុវត្ត | | |
| ***៨. ទំនាក់ទំនងរវាងពាក្យ :*** សិស្សត្រូវមើល ៣ ពាក្យ ដែលទាក់ទងគ្នានឹងរបៀបមួយ រួចគេត្រូវរកពាក្យទី ៤ ដែលទាក់ទងនឹងពាក្យទាំង ៣ នោះ ។ | | |
| តើបំណិននេះអាចពង្រឹងក្នុងមុខវិជ្ជានីមួយៗ បានដែរឬទេ ? | ចូរកំណត់ បាទ ចាំ ឬ ទេ | ប្រសិន << បាទ ចាំ >>ចូរលើកឧទាហរណ៍ និង រៀបរាប់ពីសកម្មភាពរបស់សិស្ស |
| គណិតវិទ្យា | | |
| ភាសាខ្មែរ | | |
| សិក្សាសង្គម | | |
| វិទ្យាសាស្ត្រអនុវត្ត | | |

## ឯកសារទី៦: ការកំណត់យុទ្ធវិធីបង្រៀន ដើម្បីពង្រឹងការគិតដោយវិភាគ និង ច្នៃប្រឌិត

“C” ចូរពិចារណាយុទ្ធវិធីបង្រៀនដែលបានបង្ហាញក្នុងតារាងនេះ ។ តើយុទ្ធវិធីណាខ្លះអាចប្រើប្រាស់បានសម្រាប់លើកកំពស់ការគិតដោយវិភាគ ? តើយុទ្ធវិធីណាខ្លះអាចប្រើប្រាស់បានសម្រាប់លើកកំពស់ការគិតដោយច្នៃប្រឌិត ? ប្រសិនបើយុទ្ធវិធីណាមួយត្រូវនឹងការគិតដោយវិភាគ ឬ ការគិតដោយច្នៃប្រឌិត ឬ ក៏ចូលទាំងពីរ សូមសរសេរពាក្យ ( បាទ ចាំប្ញទេ ) សមស្របក្នុងតារាងខាងក្រោមនេះ ។ ម្យ៉ាងទៀតចូរលើកឧទាហរណ៍នៃសកម្មភាព ឬ លំហាត់ជាក់ស្ដែងក្នុងកូឡោនខាងក្រោម ។ ប្រសិនបើយុទ្ធវិធីមិនត្រូវនឹងការគិតដោយវិភាគ និង ច្នៃប្រឌិតគ្រាន់តែសរសេរពាក្យ ( ទេ ) នោះគ្រប់គ្រាន់ហើយ ។

| យុទ្ធវិធី | តើត្រូវនឹងការពង្រឹងគិតដោយវិភាគដែរឬទេ ? << បាទ ចាំ >> | ប្រសិនបើត្រូវ សូមលើកឧទាហរណ៍នៃសកម្មភាពជាក់ស្ដែងមកបញ្ជាក់ | តើត្រូវនឹងការពង្រឹងគិតដោច្នៃប្រឌិតដែរឬទេ << បាទ ចាំ >> | ប្រសិនបើត្រូវ សូមលើកឧទាហរណ៍នៃសកម្មភាពជាក់ស្ដែងមកបញ្ជាក់ |
|---|---|---|---|---|
| ***១. ការសួរសំណួរ***<br>( គ្រូសួរសំណួរដល់សិស្សដែលសិស្សអាចឆ្លើយជាបុគ្គលដោយគ្មានការពិភាក្សាជាក្រុមតូច )<br>( សកម្មភាពក្រុមធំ ) | | | | |
| ***២. ល្បែងសិក្សា***<br>( គ្រូណែនាំសិស្សក្នុងការលេងល្បែងសិក្សា ឬ ក៏គ្រូរៀបចំបរិស្ថានបន្ទប់រៀនដើម្បីផ្ដល់ឱកាសអោយសិស្សប្រើប្រាស់ល្បែងសិក្សានៅពេលទំនេរ ) | | | | |

| | | | | |
|---|---|---|---|---|
| | | | | |
| *៣. ពិភាក្សាជាក្រុមតូច* ( គ្រូដាក់សំណួរឬបញ្ហាឱ្យសិស្សពិភាក្សាឬដោះស្រាយជាក្រុមតូច ដោយគ្មានសម្ភារឧបទេស ) | | | | |
| **យុទ្ធវិធី** | តើត្រូវនឹងការពង្រឹងការគិតដោយវិភាគដែរឬទេ ? << បាទ ចាំ >> | ប្រសិនបើត្រូវ សូមលើកឧទាហរណ៍នៃសកម្មភាពជាក់ស្តែងមកបញ្ជាក់ | តើត្រូវនឹងការពង្រឹងការគិតដោយច្នៃប្រឌិតដែរឬទេ ? << បាទ ចាំ >> | ប្រសិនបើត្រូវ សូមលើកឧទាហរណ៍នៃសកម្មភាពជាក់ស្តែងមកបញ្ជាក់ |
| *៤. សកម្មភាពជាក្រុមតូច* ( គ្រូចែកសម្ភារឧបទេសដល់សិស្សប្រើប្រាស់ជាក្រុមតូចតាមបែបសហការ ) | | | | |
| *៥. ល្បែងគ្រាប់/ល្បែង ត* ( ក្នុងមេរៀនមួយគ្រូកំណត់ពេលវេលាខ្លះឱ្យសិស្សចូលរួមលេងជាល្បែង ដើម្បីពង្រឹងការយល់ដឹងអំពីខ្លឹមសារមេរៀន ) | | | | |
| *៦. តួរតំនួរ និង ហត្ថកម្ម* ( ក្នុងមេរៀនមួយគ្រូកំណត់ពេលវេលាខ្លះឱ្យសិស្សចូលរួមក្នុងការតួរតំនួរ ឬ ធ្វើហត្ថកម្ម | | | | |

| | | | | |
|---|---|---|---|---|
| ដើម្បីពង្រឹងលើការយល់ដឹងខ្លឹមសារមេរៀន ឬ ក៏គ្រូអាចរៀបចំបរិស្ថានក្នុងបន្ទប់រៀន ( តុគូរគំនូរ ) ឱ្យសិស្សប្រើប្រាស់សម្ភារគូរគំនូរ និង ហត្ថកម្មក្នុងពេលទំនេរ ) | | | | |
| **យុទ្ធវិធី** | តើត្រូវនឹងការពង្រឹងការគិតដោយវិភាគដែរឬទេ ?<br><< បាទ ចាំ >> | ប្រសិនបើត្រូវសូមលើកឧទាហរណ៍នៃសកម្មភាពជាក់ស្តែងមកបញ្ជាក់ | តើត្រូវនឹងការពង្រឹងការគិតដោយច្នៃប្រឌិតដែរឬទេ<br><< បាទ ចាំ >> | ប្រសិនបើត្រូវ សូមលើកឧទាហរណ៍នៃសកម្មភាពជាក់ស្តែងមកបញ្ជាក់ |
| ***៧. ការស្រាវជ្រាវឬស្វ័យសិក្សាក្នុងម៉ោងសិក្សា :***<br>( គ្រូរៀបចំបរិស្ថានក្នុងបន្ទប់រៀន ដូចជាតុវិទ្យាសាស្ត្រអនុវត្ត តុបណ្ណាល័យ រូបភាពសិក្សាបិទលើជញ្ជាំង ដើម្បីឱ្យសិស្សធ្វើការស្រាវជ្រាវ និង ស្វ័យសិក្សា ក្នុងមេរៀនដែលកំពុងបង្រៀន ឬ ក្នុងពេលទំនេរ ) ។ ម៉្យាងទៀតសិស្សអាចធ្វើការស្រាវជ្រាវក្នុងបណ្ណាល័យ ក្នុងសាលារៀនប្រសិនបើមាន ។ | | | | |
| ***៨. លំហាត់នៅផ្ទះ***<br>( គ្រូដាក់លំហាត់ឱ្យសិស្សធ្វើនៅផ្ទះ ដើម្បីពង្រឹងការយល់ដឹងលើខ្លឹមសារដែលបានសិក្សា | | | | |

| | | | | |
|---|---|---|---|---|
| នៅសាលារៀន ) | | | | |
| *៩. ការស្រាវជ្រាវក្រៅម៉ោងសិក្សា* ( គ្រូឱ្យសិស្សជាបុគ្គល ឬ ក្រុមតូចធ្វើការស្រាវជ្រាវអំពីប្រធានបទដែលបានកំណត់ក្រៅម៉ោងសិក្សា ) ។ | | | | |

កម្មវិធីគាំទ្រសេវាអប់រំកុមារនៅតំបន់ដាច់ស្រយាល (អេស្កាប់)

EQUIP1
Educational Quality Improvement Program
Classrooms • Schools • Communities

## ឯកសារបណ្តុះបណ្តាលគ្រូថ្នាក់កុមារខេត្ត
## សម្រាប់បឋមសិក្សា

# សំណួរតាក់សូណូមី

## Taxonomy of Questions




ខេត្តកំពង់ចាម ប្រទេសកម្ពុជា
ខែ សីហា ឆ្នាំ ២០០៦
**ឯកសារដើមពីអង្គការខេប**

## ឯកសារទី១: គោលបំណង

### គោលបំណង

១. សិក្ខាកាម បកស្រាយកម្រិតសំណួរទាំង ៦ :

- ❖ កម្រិតចងចាំ
- ❖ កម្រិតយល់ដឹង
- ❖ កម្រិតអនុវត្ត
- ❖ កម្រិតវិភាគ
- ❖ កម្រិតសំយោគ
- ❖ កម្រិតវាយតម្លៃ ។

២. សិក្ខាកាមកំណត់បានពីលក្ខណៈសំខាន់ៗនៃកម្រិតសំណួរប្រភេទផ្សេងៗ គ្នា

៣. សិក្ខាកាមអាចប្រើប្រាស់សំណួរតាក់សូណូមីក្នុងកម្រិតតខ្ពស់ទាំង៣ក្នុងការបង្កើតសំណួរ ។

## ឯកសារទី២: លក្ខណៈនៃសំណួរកម្រិតចងចាំ

**<u>លក្ខណៈនៃសំណួរចងចាំ</u> :**

- សំណួរចងចាំ ស្ថិតក្នុងកម្រិតទាបជាងគេក្នុងសំណួរតាក់សូណូមី ។ ប៉ុន្តែនេះមិនមែនមានន័យថាសំណួរប្រភេទនេះឥតមានសារៈសំខាន់នោះទេ ។ ជាការពិតការចងចាំជាបំណិនមួយក្នុងការរៀនសូត្រដែលមានសារៈសំខាន់ណាស់
- សំណួរចងចាំទាមទារឱ្យសិស្សចងចាំពីហេតុការណ៍ ព្រឹត្តិការណ៍ និយមន័យ នឹកឃើញពីតម្លៃសីលធម៌ ឬតម្លៃសុជីវធម៌
- ពេលសិស្សឆ្លើយសំណួរចងចាំសិស្សបង្ហាញថាវាចងចាំពីអ្វីមួយបានប៉ុន្តែមិនចាំបាច់ឱ្យវាយល់អំពីអ្វីមួយនោះឡើយ ។

### សកម្មភាពសិស្សត្រូវធ្វើពេលគ្រូសួរសំណួរចងចាំ

សកម្មភាពរបស់សិស្ស :

- សិស្សចងចាំ
- សិស្សធ្វើបញ្ជី
- សិស្សរកឃើញ
- សិស្សនិយាយតាម
- សិស្សចង្អុលបង្ហាញ
- សិស្សប្រាប់ឈ្មោះ

## ឯកសារទី៣: លក្ខណៈនៃសំណួរកម្រិតយល់ដឹង

### លក្ខណៈនៃសំណួរកម្រិតយល់ដឹង

សំណួរកម្រិតយល់ដឹងតម្រូវឱ្យសិស្សផ្លាស់ប្តូរខ្លឹមសារពីទម្រង់មួយទៅទម្រង់មួយទៀត ។

ពាក្យ → ពាក្យ

រូប → ពាក្យ

លេខ → រូប

រូប → លេខ

ពាក្យ → រូប

**សកម្មភាពសិស្សត្រូវធ្វើពេលគ្រូសួរសំណួរកម្រិតយល់ដឹង**

សកម្មភាពរបស់សិស្ស :

- សិស្សគណនា
- សិស្សបកប្រែ បកស្រាយ បំឡែង
- សិស្សសរសេរអំពីគំនិតមនុស្សផ្សេងដោយប្រើពាក្យផ្ទាល់ខ្លួន
- សិស្សសង្ខេប
- សិស្សរាយការណ៍ ដោយគំនិតផ្ទាល់ខ្លួន
- សិស្សកំណត់និយមន័យ
- សិស្សផ្លាស់ប្តូរពាក្យសរសេរទៅជា . . . ។

## ឯកសារទី៤: លក្ខណៈនៃសំណួរកម្រិតអនុវត្ត

### លក្ខណៈនៃសំណួរកម្រិតអនុវត្ត

តម្រូវឱ្យសិស្សប្រើប្រាស់ បំណិន ឬ គោលការណ៍ ឬ វិធាន ឬ និយមន័យ ដែលគេបានរៀនរួចហើយ ដើម្បីដោះស្រាយបញ្ហាដែលរកមិនទាន់ឃើញ ។ បំណិន - វិធាន និង គោលការណ៍ ឬ និយមន័យ មួយចំនួនដែលអាចប្រើសម្រាប់ដោះស្រាយបញ្ហា ។

- ការវាស់រកចម្ងាយនៅលើផែនទី
- ការបូកប្រភាគដែលមានភាគបែងមិនដូចគ្នា
- ការប្រើក្បួនវេយ្យាករណ៍
- ការរកពាក្យនៅក្នុងវចនានុក្រម
- ការវាស់ផ្ទៃនៅក្នុងថ្នាក់រៀនមួយ
- ចំណាត់ថ្នាក់រុក្ខជាតិជាក្រុមទៅតាមលក្ខណៈរបស់វា
- ការកំណត់ នាម ឬ កិរិយាស័ព្ទ នៅក្នុងអត្ថបទ ។

**សកម្មភាពសិស្សត្រូវធ្វើពេលគ្រូសួរសំណួរកម្រិតអនុវត្ត**

សកម្មភាពរបស់សិស្ស :

- សិស្សដោះស្រាយ
- សិស្សធ្វើចំណាត់ថ្នាក់
- សិស្សវាស់
- សិស្សប្រើនិយមន័យ
- សិស្សបង្ហាញព័ត៌មានលើក្រាប
- សិស្សគណនា

## ឯកសារទី៥: លក្ខណៈនៃសំណួរកម្រិតវិភាគ

### លក្ខណៈនៃសំណួរកម្រិតវិភាគ

សំណួរវិភាគតម្រូវឱ្យមានសមត្ថភាពចេះត្រិះរិះ ២ យ៉ាង :

- បំបែកអ្វីមួយឱ្យទៅជាផ្នែកតូចៗ
- រកមើលទំនាក់ទំនងរវាងគំនិត ២ ឬ ច្រើនជាង ។

### សកម្មភាពសិស្សត្រូវធ្វើពេលគ្រូសួរសំណួរកម្រិតវិភាគ

សកម្មភាពរបស់សិស្ស:

- សិស្សសួរសំណួរ
- សិស្សធ្វើចំណាត់ថ្នាក់
- សិស្សប្រៀបធៀប
- សិស្សបំបែក
- សិស្សសង់ក្រាប
- សិស្សបង្កើតដ្យាក្រាម
- សិស្សជ្រើសរើស ( តាមលក្ខណៈវិនិច្ឆ័យ )

## ឯកសារទី៦: លក្ខណៈនៃសំណួរកម្រិតសំយោគ

### លក្ខណៈនៃសំណួរកម្រិតសំយោគ

សំណួរប្រភេទនេះតម្រូវឱ្យសិស្សប្រើសមត្ថភាពច្នៃប្រឌិត សំណួរច្នៃប្រឌិតផ្តល់ឱកាសឱ្យសិស្សបញ្ចេញយោបល់ ។ ដូច្នេះវាមានចម្លើយច្រើនសម្រាប់សំណួរតែមួយ ប៉ុន្តែក្នុងថ្នាក់រៀនមួយមានច្រើនក្រុមមានចម្លើយក្រុមខ្លះដូចគ្នា ។ ភាពខុសគ្នានៅក្នុងចម្លើយរបស់សិស្សគឺជាចំណុចខ្លាំងរបស់សំណួរ ។

សកម្មភាពសិស្សត្រូវធ្វើពេលគ្រូសួរសំណួរកម្រិតសំយោគ

សកម្មភាពរបស់សិស្ស

- សិស្សគិតស្រមៃ
- សិស្សច្នៃប្រឌិត
- សិស្សបង្កើត
- សិស្សបញ្ចេញគំនិតយោបល់ថ្មីៗ
- សិស្សគ្រោងផែនការ
- សិស្សផ្សំ
- សិស្សទស្សន៍ទាយ . . . ។

## ឯកសារទី៧: លក្ខណៈនៃសំណួរកម្រិតវាយតម្លៃ

### លក្ខណៈនៃសំណួរកម្រិតវាយតម្លៃ

មានកិច្ចការសំខាន់ ២ យ៉ាងដែលសំណួរវាយតម្លៃតម្រូវឱ្យសិស្សធ្វើ ។ កិច្ចការទី ១ សិស្សត្រូវបង្កើតលក្ខណៈវិនិច្ឆ័យដែលគេប្រើដើម្បីនឹងធ្វើការវិនិច្ឆ័យ ។ កិច្ចការទី ២ គឺត្រូវធ្វើការវិនិច្ឆ័យអំពីអ្វីមួយដោយយកលក្ខណៈវិនិច្ឆ័យទាំងអស់នេះមកប្រើប្រាស់ ។

ពេលសិស្សបង្កើតលក្ខណៈវិនិច្ឆ័យដើម្បីបញ្ចេញយោបល់ គេគួរតែដឹងផងដែរថា គំនិតយោបល់ទាំងអស់នេះមានលក្ខណៈជាអត្តនោម័តហើយគ្រាន់តែឆ្លុះបង្ហាញឱ្យឃើញពីមតិមួយប៉ុណ្ណោះ ។អ្នកផ្សេងទៀតអាចមានមតិផ្ទុយគ្នាស្រឡះទាំងលក្ខណៈវិនិច្ឆ័យក៏ដូច្នេះដែរដើម្បីវិនិច្ឆ័យ ។ ទោះជាយ៉ាងណាក៏ដោយកិច្ចការសំខាន់ក្នុងការឆ្លើយសំណួរវាយតម្លៃគឺសិស្សត្រូវយល់ច្បាស់អំពីស្តង់ដានៃលក្ខណៈវិនិច្ឆ័យហើយអាចអនុវត្តតាមស្តង់ដានោះយ៉ាងសមហេតុសមផលក្នុងការធ្វើការវាយតម្លៃ ។

### សកម្មភាពសិស្សត្រូវធ្វើពេលគ្រូសួរសំណួរកម្រិតវាយតម្លៃ

សកម្មភាពរបស់សិស្ស

- សិស្សវាយតម្លៃ " តើរឿងទន្សាយស៊ីចេកមានសារសំខាន់ឬទេ ? ហេតុអ្វី ? "
- សិស្សធ្វើការវិនិច្ឆ័យ
- សិស្សធ្វើការសំរេចចិត្ត
- សិស្សបញ្ចេញគំនិតយោបល់
- សិស្សកំណត់អាទិភាព
- សិស្សរៀបតាមលំដាប់លំដោយ
- សិស្សពិភាក្សាវែកញែក
- សិស្សលើកហេតុផលបញ្ជាក់ពីគំនិតរបស់គេ ។

**ឯកសារទី៨: អត្ថបទ: បឹងទន្លេសាប និង លំហាត់បង្កើតសំណួរ** ( សៀវភៅភាសាខ្មែរថ្នាក់ទី៦ទំព័រទី២៣៧)

## <u>អត្ថបទ</u> : បឹងទន្លេសាប

ប្រទេសកម្ពុជាសម្បូរប្រភពទឹកណាស់ ។ ប្រភពទឹកទាំងនោះ គឺទន្លេ ស្ទឹង ព្រែក និង អូរដែលហូរនាំទឹកចាក់ទៅសមុទ្រ និង បឹងបួ ។ បឹងដែលធំជាងគេនៅប្រទេសកម្ពុជាគឺ " បឹងទន្លេសាប " ។

កាលពីដើមបឹងនេះធំណាស់ ។ ឥឡូវនេះបឹងទន្លេសាបកាន់តែរួមតូចនិងកាន់តែរាក់ទៅដោយសារដីល្បាប់នៃទន្លេមេគង្គនិងស្ទឹងជាច្រើននៅជុំវិញបឹង ។ សព្វថ្ងៃបឹងទន្លេសាបនៅមានបណ្តោយប្រវែងជាង ១៣០គីឡូម៉ែត្រ ទទឹងប្រវែងប្រមាណ ៣០គីឡូម៉ែត្រ ទំហំផ្ទៃប្រហែលជាង ៣០០០គីឡូម៉ែត្រការេ និង ជម្រៅពី ០,៨០ ទៅ ២ ម៉ែត្រ ។ នៅរដូវវស្សាបឹងទន្លេសាបធំល្វឹងល្វើយ ហាក់បីដូចជាសមុទ្រមួយស្ថិតនៅកណ្តាលផ្ទៃប្រទេស ។

ផលយានទាំងឡាយអាចធ្វើដំណើរចុះឡើងភ្ជាប់រាជធានីភ្នំពេញទៅនឹងបណ្តាខេត្តដែលនៅជុំវិញបឹងនេះមានខេត្តកំពង់ឆ្នាំង ពោធិសាត់ បាត់ដំបង សៀមរាប និង កំពង់ធំ ។ តែនៅរដូវប្រាំង នាវាធំៗមិនអាចធ្វើដំណើរបានទេព្រោះទឹករាក់ពេក ។ បឹងទន្លេសាបគឺជាអាងធម្មជាតិមួយយ៉ាងធំសម្រាប់ទទួលផ្ទុកទឹកដែលហូរពីស្ទឹងទាំងឡាយនៅជុំវិញបឹង ។ បឹងទន្លេសាបគឺជាកំណប់មហាសាលរបស់ប្រជាជនកម្ពុជា ។ ក្រៅពីផ្តល់ទឹកនិងត្រីដ៏ច្រើនសន្ធឹកសន្ធាប់បឹងទន្លេសាបនៅជួយសម្រាលគ្រោះទឹកជំនន់បានមួយភាគធំទៀតផង ។

### លំហាត់បង្កើតសំណួរ

១. តើទន្លេសាបនិងទន្លេមេគង្គណាមួយដែលមានសារៈសំខាន់ជាងគេនៅប្រទេសកម្ពុជា ?

២. តើខេត្តណាខ្លះដែលនៅជាប់នឹងទន្លេសាប ?

៣. ចូរក្រឡេកមើលផែនទីប្រទេសកម្ពុជាដោយប្រើមាត្រដ្ឋានដើម្បីគណនាប្រវែងរបស់ទន្លេមេគង្គនៅប្រទេសកម្ពុជា

៤. នៅក្នុងប្រទេសកម្ពុជា តើបឹងអ្វីដែលធំជាងគេបំផុត ?

៥. តើមានភាពខុសប្លែកគ្នាអ្វីខ្លះរវាងទន្លេសាប និង ទន្លេមេគង្គ ?

៦. ចូរសរសេរដោយពណ៌នាសង្ខេបឱ្យបានបីល្បះអំពីទន្លេសាបដោយប្រើគំនិតផ្ទាល់ខ្លួន ។

៧. ចូរស្រមៃគិតថា គ្រួសាររបស់អ្នករស់នៅតាមដងទន្លេសាប ហើយពេលមួយនោះ ទន្លេរីងស្ងួតទឹកអស់ ។ តើវាជះឥទ្ធិពលអាក្រក់អ្វីខ្លះទៅលើជីវិតគ្រួសាររបស់អ្នក ?

៨. តើយើងត្រូវមានវិធានការអ្វីខ្លះដើម្បីការពារបរិស្ថានទន្លេសាបនិងទន្លេមេគង្គរបស់យើង ?

៩. តើមានលក្ខណៈប្រហាក់ប្រហែលគ្នាអ្វីខ្លះរវាងទន្លេសាបនិងទន្លេមេគង្គ ?

១០. តើការរស់នៅតាមដងទន្លេមានលក្ខណៈងាយស្រួលឬពិបាក ? សូមបញ្ជាក់ហេតុផល ។

**ឯកសារទី៩: អត្ថបទៈ កូនកតញ្ញូ** ( សៀវភៅភាសាខ្មែរថ្នាក់ទី៦ ទំព័រទី២៧)

**អត្ថបទៈ កូនកតញ្ញូ**

សុខាជាក្មេងស្រីម្នាក់ចេះស្រឡាញ់គោរពដឹងគុណឪពុកម្តាយ ។ នាងពុំដែលធ្វើអំពើខុសឆ្គងអ្វីដែលនាំឱ្យឪពុកម្តាយមិនសប្បាយចិត្តឡើយ ។

ពេលចេញទៅ និងពេលត្រឡប់មកពីសាលាវិញ សុខាបានជំរាបលានិងជំរាបសួរឪពុកម្តាយជានិច្ច ។ កាលបើនាងមានកិច្ចការខុសប្រក្រតី នាងតែងបានជំរាបប្រាប់ឪពុកម្តាយឱ្យបានដឹងជាមុន ដើម្បីកុំឱ្យគាត់មើលផ្លូវនិងមានការព្រួយបារម្ភចំពោះរូបនាង ។ ពេលទំនេរនាងឆ្លៀតជួយការងារក្នុងផ្ទះដូចជាជួយដាំស្ល រៀបចំផ្ទះ បោកសម្លៀកបំពាក់ខ្លួននិងឪពុកម្តាយផងដែរ ។ ពេលបរិភោគអាហារនាងបានរៀបចំម្ហូបចំណី និង ផ្លែឈើជូនឪពុកម្តាយនាងជានិច្ច ។

ដោយសារទង្វើដ៏ប្រពៃថ្លៃថ្លានេះទើបអ្នកស្រុក ញាតិមិត្តជិតឆ្ងាយកោតសរសើររាប់អាននាងគ្រប់ៗគ្នានិងចង់ឱ្យកូនខ្លួនល្អដូចនាងដែរ ។

សូមតែងសំណួរចំនួន៣ ជាកម្រិតវិភាគ កម្រិតសំយោគ និងកម្រិតវាយតម្លៃ

១.

២.

៣.

## ឯកសារទី១០: ការអនុវត្តតាក់សូណូមី

# ការអនុវត្តតាក់សូណូមី

| លំនាំក្នុងការគិត | កិរិយាស័ព្ទសមស្រប | ឈ្មោះសំណួរជាឧទាហរណ៍ | សកម្មភាព |
|---|---|---|---|
| ការចងចាំ | - ប្រាប់និយមន័យ<br>- ពិពណ៌នា<br>- គូរ<br>- បំពេញ<br>- រកឃើញ<br>- កំណត់ ( ប្រាប់បាន)<br>- ដាក់ស្លាក<br>- ធ្វើបញ្ជី<br>- ស្តាប់<br>- ប្រាប់ទីតាំង<br>- ផ្គូផ្គង<br>- ចងចាំ<br>- អង្កេត<br>- រំលឹកឡើងវិញ<br>- សូត្រ<br>- កត់ត្រា<br>- និយាយឡើងវិញ<br>- ជ្រើសរើស<br>- ថ្លែងការណ៍<br>- ប្រាប់ | - តើមានអ្វីដែលកើតឡើងក្រោយពី.?<br>- តើប៉ុន្មាន . . .  ?<br>- តើអ្នកណាជាអ្នកដែល . . .  ?<br>- ចូររៀបរាប់អំពីអ្វីដែលកើតឡើង . . . ។<br>- តើអ្នកណានិយាយជាមួយ . . ?<br>- តើអ្នកប្រាប់ខ្ញុំហេតុអ្វី . . .  ?<br>- ចូររកនិយមន័យនៃពាក្យ . . .<br>- តើ . . .  ជាអ្វី  ? | - ចូរធ្វើបញ្ជីព្រឹត្តិការណ៍សំខាន់ក្នុងរឿង  ។<br>- ចូរធ្វើព្រួញកាលបង្ហាញពីព្រឹត្តិការណ៍  ។<br>- ចូរធ្វើតារាងបង្ហាញអំពីការពិតផ្សេងៗ  ។<br>- ចូរធ្វើបញ្ជីអំពីព័តិមានផ្សេងៗដែលអ្នកអាចចងចាំបាន  ។<br>- ចូររាប់ឈ្មោះសត្វទាំងអស់ក្នុងរឿង  ។<br>- ចូរសូត្រកំណាព្យ . . . ។ |

| | | | |
|---|---|---|---|
| | - សរសេរ | | |
| <u>ការយល់ដឹង</u> | - ប្រៀបធៀប<br>- តស៊ូ<br>- ពិពណ៌នា<br>- ពិភាក្សា<br>- ញែក<br>- កត់ត្រាជាឯកសារ<br>- ប៉ាន់ស្មាន<br>- ពន្យល់<br>- បញ្ចេញ<br>- កំណត់លក្ខណៈទូទៅ<br>- កំណត់<br>- បកស្រាយ<br>- កំណត់ទីតាំង<br>- ពិពណ៌នាចំណុចសំខាន់<br>- ពន្យល់ឡើងវិញដោយប្រើភាសាផ្ទាល់ខ្លួន ។<br>- ទាយ<br>- ទទួលស្គាល់<br>- រាយការណ៍<br>- ថ្លែងការណ៍ដោយប្រើពាក្យជំនួសមានន័យដូចគ្នា ។<br>- ពិនិត្យឡើងវិញ<br>- និយាយប្រាប់ | - ចូរអ្នកសរសេរដោយប្រើពាក្យផ្ទាល់ខ្លួន . . . ?<br>- ចូរអ្នកសរសេរចំណុចសំខាន់ៗជាសង្ខេប . . . ?<br>- តើអ្នកមានគំនិតយ៉ាងដូចម្តេចអំពីអ្វីដែលកើតឡើងនៅពេលក្រោយ ...?<br>- តើអ្នកគិតថា អ្នកណា . . . ?<br>- តើគំនិតសំខាន់ជាអ្វី . . . ?<br>- តើអ្នកណាជាតួអង្គសំខាន់ . . ?<br>- តើអ្នកអាចញែករវាង . . . ?<br>- តើមានភាពខុសគ្នាយ៉ាងដូចម្តេចរវាង . . . ?<br>- តើអ្នកអាចលើកឧទាហរណ៍បង្ហាញអំពីគំនិតរបស់អ្នក . . . ?<br>- តើអ្នកអាចកំណត់និយមន័យសម្រាប់ . . . ? | - គូររូបភាពដើម្បីបង្ហាញព្រឹត្តិការណ៍មួយ ។<br>- បង្ហាញប្រធានបទក្នុងរឿងដោយគូររូបភាព ។<br>- រៀបរូបភាពតាមលំដាប់លំដោយនៃរឿង ។<br>- សរសេរ និង សម្តែងតួស្តីពីរឿង ។<br>- ចូរនិយាយរឿងឡើងវិញដោយប្រើពាក្យផ្ទាល់ខ្លួន ។<br>- ចូរគូស និង ផាត់ពណ៌រូបភាពដែលបង្ហាញអំពីព្រឹត្តិការណ៍មួយក្នុងរឿងដែលអ្នកចូលចិត្ត ។<br>- ចូរសរសេររបាយការណ៍សង្ខេបស្តីពីព្រឹត្តិការណ៍ ។<br>- រៀបចំផែនទីគំនិតដើម្បីបង្ហាញអំពីលំដាប់លំដោយនៃព្រឹត្តិការណ៍ ។<br>- ចូរចងក្រងរូបភាពជាសៀវភៅមួយ ។ |

| | | | |
|---|---|---|---|
| | - បកប្រែ | | |
| **ការអនុវត្ត** | - គណនា<br>- ផ្លាស់ប្តូរ<br>- ចំណាត់ថ្នាក់<br>- បញ្ចប់<br>- កសាង<br>- បង្ហាញ<br>- បង្ហាញតាមរយៈល្ខោន<br>- គូរ<br>- ប្រើប្រាស់<br>- ត្រួតពិនិត្យ<br>- បង្ហាញដោយគូរ<br>- រូបភាព<br>- បកស្រាយ<br>- ប្រើយ៉ាងប៉ិនប្រសប់<br>- ដំណើរការ<br>- រៀបចំតាមលំដាប់លំដោយ<br>- ស្រាយបំភ្លឺ<br>- ដោះស្រាយ<br>- សាកល្បង<br>- បកប្រែ<br>- សរសេរ | - តើអ្នកអាចស្គាល់ករណីមួយទៀតដែល . . . ?<br>- តើបញ្ហានេះអាចកើតឡើងនៅ . . ?<br>- តើអ្នកអាចធ្វើចំណាត់ថ្នាក់ដោយគិតពីលក្ខណៈដូចជា . . .?<br>- តើអ្នកផ្លាស់ប្តូរកត្តាណាខ្លះប្រសិនបើ . . . ?<br>- តើអ្នកអាចអនុវត្តវិធីនេះទៅនឹងបទពិសោធន៍របស់អ្នក . . .?<br>- តើអ្នកចង់សួរសំណួរអ្វីខ្លះទៅ . . . ?<br>- ដោយគិតអំពីព័ត៌មានដែលអ្នកបានទទួល តើអ្នកអាចរៀបចំសេចក្តីណែនាំស្តីអំពី . . . ?<br>- តើព័ត៌មាននេះមានផលប្រយោជន៍ឬទេ ប្រសិនបើ . . . ? | - បង្កើតជាគំរូដើម្បីបង្ហាញពីដំណើរការ ។<br>- សង់ដ្យាក្រាមដើម្បីបង្ហាញពីព្រឹត្តិការណ៍សំខាន់ ។<br>- ចងក្រងស្នាដៃនៃការស្រាវជ្រាវជាសៀវភៅមួយ ។<br>- ធ្វើរូបតំណាងដើម្បីបង្ហាញអំពីចំណុចសំខាន់ៗ ។<br>- ប្រមូលរូបថតនិងរូបភាពផ្សេងៗដើម្បីជួយពន្យល់ខ្លឹមសារមួយ ។<br>- បង្កើតល្បែងសិក្សា ។<br>- បង្កើតជាគំរូនៃវត្ថុមួយដោយធ្វើអំពីដីឥដ្ឋ ។<br>- រៀបចំតុក្កតាដែលមានសម្លៀកបំពាក់ប្រពៃណីជាតិ ។<br>- គូររូបភាពធំលើជញ្ជាំង ។<br>- រៀបចំសៀវភៅដែលមានសេចក្តីណែនាំអំពី . . . សម្រាប់អ្នកដទៃទៀតយកទៅប្រើប្រាស់ ។ |
| **ការវិភាគ** | - ផ្សព្វផ្សាយពាណិជ្ជកម្ម | - តើព្រឹត្តិការណ៍ណាខ្លះក្នុងរឿង | - ចូររៀបចំបញ្ជីសំណួរ |

| | | | |
|---|---|---|---|
| | - វិភាគ<br>- ពិចារណា<br>- គណនា<br>- ធ្វើចំណាត់ថ្នាក់<br>- ប្រៀបធៀប<br>- យល់អំពីភាសាខុសគ្នា<br>- ពិភាក្សា<br>- តស៊ូ<br>- ញែក<br>- កំណត់ធាតុខុសគ្នា<br>- ត្រួតពិនិត្យ<br>- សាកល្បង<br>- ពន្យល់<br>- កំណត់<br>- ស៊ើបអង្កេត<br>- រៀបចំផែនទី<br>- ធ្វើទំនាក់ទំនង<br>- បំបែកដោយឡែក<br>- ដោះស្រាយ<br>- ចែកជាផ្នែករង<br>- ស្ទង់ | មិនអាចកើតឡើងពិតប្រាកដ...?<br>- ប្រសិនបើ . . . កើតមានឡើង តើរឿងនេះអាចមានលទ្ធផលយ៉ាងដូចម្តេច ?<br>- តើរឿងប្រៀបធៀបទៅនឹង . . . យ៉ាងដូចម្តេច ?<br>- តើរឿងនេះមានប្រធានបទសំខាន់អ្វីខ្លះ . . . ?<br>- តើអ្នកអាចទាយលទ្ធផលនៃរឿងនេះបានយ៉ាងដូចម្តេច ?<br>- ហេតុអ្វី បានជាប្រែប្រួលបែបនេះ ?<br>- តើអ្នកប្រៀបធៀបនៃរឿងនេះទៅនឹង . . . យ៉ាងដូចម្តេច ?<br>- តើអ្នកអាចពន្យល់អ្វីដែលត្រូវកើតមានឡើងពេលដែល . . . ?<br>- តើ . . . ស្រដៀងនឹង . . . យ៉ាងដូចម្តេច ?<br>- តើ . . . មានបញ្ហាអ្វីខ្លះ ?<br>- តើអ្នកអាចកំណត់លក្ខណៈខុសគ្នារវាង . . . ?<br>- តើអ្នកអាចកំណត់មូលហេតុនៃ ... ?<br>- តើព្រឹត្តិការណ៍សំខាន់ក្នុងរឿងនៅកន្លែងណាខ្លះ ? | ដើម្បីប្រមូលព័ត៌មាន ។<br>- ចូររៀបចំការផ្សព្វផ្សាយពាណិជ្ជកម្មដើម្បីជួយលក់ផលិតផលថ្មី ។<br>- ចូរស៊ើបអង្កេតរកព័ត៌មានដើម្បីគាំទ្រទស្សនៈមួយ ។<br>- ចូររៀបចំផែនទីគំនិតដើម្បីជួយវិភាគជំហានីមួយៗ ។<br>- ចូរសង់ក្រាបដើម្បីបង្ហាញព័ត៌មានដែលត្រូវជ្រើសរើស ។<br>- រៀបចំល្បែងសិក្សាដោយបំបែកជាផ្នែកតូចៗរួចផ្គុំឡើងវិញ ។<br>- រៀបចំរចនាសម្ព័ន្ធក្រុមញាតិ ៧ សន្តាន ។<br>- ចូររៀបចំល្ខោនបង្ហាញពីខ្លឹមសារមួយដែលត្រូវបានសិក្សា ។<br>- ចូរសរសេរប្រវត្តិនៃមនុស្សម្នាក់ដែលត្រូវបានស្រាវជ្រាវ ។<br>- ចូររៀបចំរបាយការណ៍អំពីការស្រាវជ្រាវ ។<br>- កំណត់ជំហានទីមួយៗក្នុងការអនុវត្តសកម្មភាពមួយ |

| | | | |
|---|---|---|---|
| | | | - ចូរពិនិត្យគំនូរសិល្បៈឡើងវិញដោយប្រើលក្ខណៈវិនិច្ឆ័យផ្សេងៗ។ |
| **ការសំយោគ** | - ផ្សំគ្នា<br>- តែង<br>- កសាង<br>- បង្កើត<br>- គូរប្លង់<br>- ប្រឌិតឡើង<br>- កំណត់រូបមន្ត<br>- បង្កើតសម្មតិកម្ម<br>- ប្រើរូបារម្មណ៍<br>- កែលំអ<br>- បង្កើតឡើងខ្លួនឯង<br>- គ្រប់គ្រង<br>- រៀបចំ<br>- ធ្វើផែនការ<br>- ទាយ<br>- ត្រៀម<br>- ផលិត<br>- អះអាង<br>- ស្ថាន | - តើអ្នកអាចគូរប្លង់អំពី . . .ដើម្បី . ?<br>- តើអ្នកអាចតែងចម្រៀងអំពី . . . ?<br>- ចូរអ្នករកដំណោះស្រាយបញ្ហា . . .។<br>- ប្រសិនបើអ្នកមានធនធានគ្រប់បែបយ៉ាង តើអ្នកដោះស្រាយ . . . យ៉ាងដូចម្តេច ?<br>- តើអ្នកអាចរកដំណោះស្រាយក្រៅពីដំណោះស្រាយរបស់គេដើម្បី . . . ?<br>- ប្រសិនបើ . . .តើមានអ្វីកើតឡើង ?<br>- តើអ្នកអាចមានវិធីអ្វីខ្លះដើម្បីដោះស្រាយ . . . ?<br>- ចូរអ្នកនឹកគិតឱ្យបានច្រើនបំផុតអំពីការប្រើប្រាស់វត្ថុនេះ ។<br>- ចូរអ្នករៀបចំម្ហូបឆ្ងាញ់ដោយប្រើគ្រឿងផ្សំតាមវិធីថ្មី ។<br>- តើអ្នកអាចកសាងផែនការដើម្បី ? | - បង្កើតម៉ាស៊ីនដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់កិច្ចការមួយ ។<br>- ចូរគូរប្លង់អាគារដែលជាកន្លែងសិក្សាមួយ ។<br>- ចូរបង្កើតផលិតផលថ្មីមួយ រួចដាក់ឈ្មោះនិងរៀបចំផែនការផ្សព្វផ្សាយពាណិជ្ជកម្ម ។<br>- ចូររៀបរាប់អំពីអារម្មណ៍របស់អ្នកចំពោះ . . . ។<br>- ចូរសរសេររឿងល្ខោនស្តីអំពី . . . ។<br>- ចូរគូរក្របសៀវភៅ ។<br>- ចូរបង្កើតអក្សរសម្ងាត់ និង សរសេររឿងខ្លីដោយប្រើអក្សរសម្ងាត់នេះ ។ |
| **ការវាយតម្លៃ** | - ប៉ាន់តម្លៃ<br>- និយាយគាំទ្រ | - តើមានដំណោះស្រាយណាដែលល្អជាងដំណោះស្រាយនេះ ? | - ចូររៀបចំបញ្ជីលក្ខណៈវិនិច្ឆ័យដើម្បីវិនិច្ឆ័យកម្ម |

| | | | |
|---|---|---|---|
| | - និយាយប្រឆាំង<br>- ស្ទាបស្ទង់<br>- ជ្រើសរើស<br>- ប្រៀបធៀប<br>- សន្និដ្ឋាន<br>- ទិតៀនស្ថាបនា<br>- ពិភាក្សាតទល់<br>- ធ្វើការសំរេចចិត្ត<br>- កំណត់<br>- រើសអើង<br>- ធ្វើវិនិច្ឆ័យ<br>- ការពារគំនិត<br>- កំណត់ជាអាទិភាព<br>- លៃតម្លៃ<br>- ផ្តាំផ្ញើ<br>- សង្ខេប<br>- បញ្ជាក់ | - ចូរវិនិច្ឆ័យលើតម្លៃនៃ . . . ។<br>- ចូរអ្នកនិយាយគាំទ្រគំនិតរបស់អ្នក . . . ។<br>- តើអ្នកយល់ថានេះជាសកម្មភាពល្អឬ មិនល្អ ?<br>- ប្រសិនបើអ្នកជាអ្នកដោះស្រាយបញ្ហាវិញ តើអ្នកដោះស្រាយយ៉ាងដូចម្តេច ?<br>- តើអ្នកមានគំនិតកែប្រែណាខ្លះចំពោះសកម្មភាពនេះ ?<br>- តើអ្នកជឿថា . . . ?<br>- តើអ្នកជាមនុស្ស . . . ?<br>- តើអ្នកមានអារម្មណ៍យ៉ាងដូចម្តេច ប្រសិនបើ . . . ?<br>- តើអ្នកមានគំនិតយ៉ាងដូចម្តេចអំពីប្រសិទ្ធភាពនៃ . . . ?<br>- តើអ្នកមានគំនិតយ៉ាងដូចម្តេចអំពី..? | វិធីមួយ ។<br>- រៀបចំលក្ខណៈវិនិច្ឆ័យតាមអាទិភាព ។<br>- ចូរអ្នកជួយសម្របសម្រួលការពិភាក្សាតទល់រវាងក្រុមមនុស្ស ២ ក្រុម ស្តីអំពីខ្លឹមសារសំខាន់មួយ ។<br>- ចូរបង្កើតបទបញ្ជាផ្ទៃក្នុងដែលអ្នកយល់ថាមានសារៈសំខាន់សម្រាប់ ..។<br>- សរសេរលិខិតមួយដើម្បីបញ្ចេញគំនិតយោបល់របស់អ្នកអំពីអ្វីដែលត្រូវកែប្រែក្នុង . . . ។<br>- ចូរសរសេររបាយការណ៍ប្រចាំឆ្នាំ ។<br>- ចូរសម្តែងតួជាមេធាវីដែលត្រូវតែការពារកូនក្តី ។ |

កម្មវិធីគាំទ្រសេវាអប់រំកុមារនៅតំបន់ដាច់ស្រយាល(អេស្កាប់)

Educational Quality Improvement Program
Classrooms • Schools • Communities

## ឯកសារបណ្ដុះបណ្ដាលគ្រូថ្នាក់កុមារមេត្រី
## សម្រាប់បឋមសិក្សា

# គោលការណ៍ជាមូលដ្ឋានក្នុងការវាយតម្លៃសិស្ស

## Basic Guidelines in Conducting Student Assessment




ខេត្តកំពង់ចាម ប្រទេសកម្ពុជា
ខែ សីហា ឆ្នាំ ២០០៦

ឯកសារដើមពីអង្គការខេប

## ឯកសារទី១: ប្រភេទនៃការសម្រេចចិត្តលើការអប់រំ និង ប្រភេទខុសៗគ្នានៃការវាយតម្លៃ

,

**ប្រភេទនៃការសម្រេចចិត្តលើការអប់រំ**

- ការឱ្យឡើងថ្នាក់ឬការឱ្យត្រួតថ្នាក់
- ការជ្រើសរើសសិស្ស
- ការបញ្ជាក់ឱ្យវិញ្ញាបនប័ត្រ
- ការកែប្រែលើការបង្រៀន
- ការកែតម្រូវសិស្ស ។

**ប្រភេទនៃការវាយតម្លៃ**

- **ការវាយតម្លៃបែបធ្វើចំណាត់ថ្នាក់ពិន្ទុ (Norm-referenced )**

ការធ្វើតេស្តដែលបានកំណត់ដោយពិន្ទុហើយធ្វើការប្រៀបធៀបពិន្ទុសិស្សទៅនឹងសិស្សដទៃទៀតដែលបានធ្វើតេស្តដូចគ្នា

- **ការវាយតម្លៃបែបលក្ខណៈវិនិច្ឆ័យដាច់ខាត (Criterionreferenced)**

ការធ្វើតេស្តដោយដាក់ពិន្ទុ ហើយប្រៀបធៀបពិន្ទុទាំងនោះទៅនឹងស្តង់ដាដាច់ខាតមួយក្នុងការអនុវត្ត

- **ការវាយតម្លៃសរុប (Summative)**

ការធ្វើតេស្តដែលកើតឡើងនៅទីបញ្ចប់នៃវគ្គមួយឬឆមាសមួយក្នុងវត្ថុបំណងបូកសរុបកម្រិតលទ្ធផលសិក្សារបស់សិស្សក្នុងពេលដែលគេសម្រេចបាន

- **ការវាយតម្លៃជាដំណាក់ៗ (Formative)**

ការវាយតម្លៃ ដែលកើតមានឡើងមុន ឬ ក្នុងអំឡុងពេលបង្រៀនក្នុងគោលបំណងកែលំអវិធីបង្រៀន និង ការរៀនរបស់សិស្ស ។

- តេស្តវាយតម្លៃបែបធ្វើចំណាត់ថ្នាក់ពិន្ទុ មានន័យយ៉ាងសាមញ្ញថា "ការរៀបពិន្ទុសិស្សតាមលំដាប់លំដោយ" ។ រីឯការវាយតម្លៃបែបលក្ខណៈវិនិច្ឆ័យដាច់ខាត ពឹងផ្អែកទៅតាមលក្ខណៈវិនិច្ឆ័យមួយចំនួនដែលបាន កំណត់ជាមុន ។ <u>ឧទាហរណ៍</u> : ពិន្ទុ ៥ លើ ១០ តែងតែត្រូវបានចាតទុកជា " ស្តង់ដា " ក្នុងការឱ្យ ឡើងថ្នាក់ ។ ស្រដៀងគ្នានេះដែរ សូមបញ្ជាក់ថា ការវាយតម្លៃបូកសរុប គឺអ្វីដែលធ្វើនៅចុងបញ្ចប់ក្នុង អំឡុងពេលដ៏យូរ ឬ នៅទីបញ្ចប់នៃមេរៀនដ៏វែងមួយចំនួន ។ វាជាការបូកសរុប " ចុងបញ្ចប់ " ហើយត្រូវបានកត់ត្រាទុកជាឯកសារផ្លូវការ ។ ការវាយតម្លៃជាដំណាក់ គឺអ្វីៗដែលគ្រូធ្វើដើម្បីជួយ កែលំអការបង្រៀន ឬ ការរៀន របស់សិស្ស ។ ការវាយតម្លៃជាដំណាក់ មិនត្រូវបានកំណត់ទុកជា លទ្ធផលចុងក្រោយរបស់សិស្សទេ ។

- ការសម្រេចចិត្តនៃការអប់រំអាចប្រើប្រភេទនៃការវាយតម្លៃច្រើនជាងមួយៈ

<u>ឧទាហរណ៍</u> :

ការឱ្យឡើងថ្នាក់ ឬ ការឱ្យត្រួតថ្នាក់ ⟶ ការវាយតម្លៃបែបលក្ខណៈវិនិច្ឆ័យដាច់ខាត ការវាយតម្លៃសរុប ។

ការជ្រើសរើស ⟶ ការវាយតម្លៃបែបធ្វើចំណាត់ពិន្ទុ ការវាយតម្លៃសរុប ។

ការបញ្ជាក់សញ្ញាប័ត្រ ⟶ ការវាយតម្លៃបែបលក្ខណៈវិនិច្ឆ័យដាច់ខាត ការវាយតម្លៃសរុប ។

ការកែប្រែលើការបង្រៀន ⟶ ការវាយតម្លៃបែបលក្ខណៈវិនិច្ឆ័យដាច់ខាត ការវាយតម្លៃដំណាក់ៗ ។

ការកែតម្រូវសិស្ស ⟶ ការវាយតម្លៃបែបលក្ខណៈវិនិច្ឆ័យដាច់ខាត ការវាយតម្លៃដំណាក់ៗ ។

## ឯកសារទី២: លំហាត់ផ្គូរផ្គងរវាងប្រភេទនៃការសម្រេចចិត្តលើការអប់រំ និងប្រភេទនៃការវាយតម្លៃ

| ប្រភេទនៃការសម្រេចចិត្តលើការអប់រំ | ប្រភេទនៃការវាយតម្លៃ |
| --- | --- |
| -ការឱ្យឡើងថ្នាក់ឬការឱ្យត្រួតថ្នាក់ | **-ការវាយតម្លៃបែបធ្វើចំណាត់ថ្នាក់ពិន្ទុ (Norm-referenced)**<br>ការធ្វើតេស្តដែលបានកំណត់ដោយពិន្ទុ ហើយធ្វើការប្រៀបធៀបពិន្ទុសិស្សទៅនឹងសិស្សដទៃទៀតដែលបានធ្វើតេស្តដូចគ្នា |
| -ការជ្រើសរើសសិស្ស | **-ការវាយតម្លៃបែបលក្ខណៈវិនិច្ឆ័យដាច់ខាត (Criterion referencef)**<br>ការធ្វើតេស្តដោយដាក់ពិន្ទុ ហើយប្រៀបធៀបពិន្ទុទាំងនោះទៅនឹងស្តង់ដាដាច់ខាតមួយក្នុងការអនុវត្ត |
| -ការបញ្ជាក់ឱ្យវិញ្ញាបនប័ត្រ | **-ការវាយតម្លៃបូកសរុប (Summative)**<br>ការធ្វើតេស្តដែលកើតឡើង នៅទីបញ្ចប់នៃវគ្គមួយឬឆមាសក្នុងគោលបំណងបូកសរុបលទ្ធផលកម្រិតសិក្សារបស់សិស្ស ក្នុងពេលដែលគេសម្រេចបាន |
| -ការកែប្រែលើការបង្រៀន | **-ការវាយតម្លៃជាដំណាក់ៗ (Formative)**<br>ការវាយតម្លៃដែលកើតមានឡើងមុនឬក្នុងអំឡុងពេលបង្រៀនក្នុងគោលបំណងកែលំអវិធីបង្រៀន កែលំអការរៀនរបស់សិស្ស។ |
| -ការកែតម្រូវសិស្ស | |

## ឯកសារទី៣: ទំនាក់ទំនងរវាងការធ្វើការសម្រេចចិត្តលើការអប់រំ និង របៀបធ្វើការវាយតម្លៃ

**វត្ថុបំណងនៃការវាយតម្លៃ**




**ឧទាហរណ៍ :** ការវាយតម្លៃបូកសរុប ដើម្បីកំណត់ថា ត្រូវឱ្យឡើងថ្នាក់ឬឱ្យត្រួតថ្នាក់មានលក្ខណៈដូចតទៅ ÷

**១-ការវាយតម្លៃបូកសរុប (Summative Evaluation)**

- **ទំហំខ្លឹមសារ :** ទូលំទូលាយ (ខ្លឹមសារច្រើន)
- **ការជ្រើសរើសទម្រង់សំណួរ :** សំណួរឆ្លើយបានរហ័សមានន័យថា សំណួរដែលជួយយើងឱ្យវាយតម្លៃខ្លឹមសារច្រើនបំផុត ប៉ុន្តែអាចមានលំហាត់តែងសេចក្តីខ្លះផងដែរ
- **ភាពញឹកញាប់នៃការវាយតម្លៃ :** មិនញឹកញាប់ទេ នៅចុងបញ្ចប់នៃជំពូកឆមាស ឬ ឆ្នាំសិក្សា
- **របៀបប្រើទិន្នន័យ :** កត់ត្រាក្នុងបញ្ជីពិន្ទុដើម្បីទុកសំរាប់ធ្វើការបូកសរុបក្រោយបង្អស់
- **ភាពលំបាកនៃសំណួរ :** កំរិតមធ្យម
- **ប្រវែងតេស្ត :** វែង សំណួរច្រើន
- **បែបបទនៃការឱ្យពិន្ទុ :** ជាធម្មតាការវាយតម្លៃបូកសរុប ដើម្បីប្រៀបធៀបទៅនឹងលក្ខណៈវិនិច្ឆ័យដាច់ខាត ។

**២-ការវាយតម្លៃដំណាក់ ៗ (Formative Evaluation)**

- **ទំហំខ្លឹមសារ :** ចង្អៀត (សំណួរតិច)
- **ការជ្រើសរើសទម្រង់សំណួរ :** សំណួរ ដែល បញ្ចេញពីលំនាំដូចជាលំហាត់តែងសេចក្តី (**Essay**) ដើម្បីជួយឱ្យយើងដឹងនូវផ្នែកណាដែលសិស្សមិនទាន់យល់
- **ភាពញឹកញាប់នៃការវាយតម្លៃ :** ត្រូវតែធ្វើ ញឹកញាប់នៅមុន ក្នុងអំឡុង ឬ នៅទីបញ្ចប់នៃមេរៀន
- **របៀបប្រើទិន្នន័យ:** ដើម្បីកំណត់សិស្សដែលត្រូវកែតម្រូវ ។ ដើម្បីកំណត់ចំណុចមេរៀនដែលត្រូវរំលឹកឡើងវិញ ។ មិនត្រូវកត់ត្រាទុកសម្រាប់ការកំណត់លទ្ធផលចុងក្រោយបង្អស់នោះទេ

- **ភាពលំបាកនៃសំណួរ:** ជាធម្មតាពីងាយស្រួលទៅមធ្យម ។ សំណួរសង្កត់ធ្ងន់ទៅលើបំណិនជាមូលដ្ឋាន
- **ប្រវែងតេស្ត :**សំណួរតិចតួច
- **បែបបទនៃការឱ្យពិន្ទុ :** ការវាយតម្លៃដើម្បីប្រៀបធៀបទៅនឹងលក្ខណៈវិនិច្ឆ័យដាច់ខាត
  - អ្នកសម្របសម្រួលត្រូវបញ្ជាក់អំពីសារៈសំខាន់នៃវត្ថុបំណងឱ្យច្បាស់របស់គ្រូ ក្នុងការវាយតម្លៃមុននឹង ដំណើរការវាយតម្លៃជាក់ស្តែងលើសិស្សម្នាក់ៗ ។ ដូច្នេះសូមកុំធ្វើការវាយតម្លៃដែលមិនសមស្របទៅនឹងវត្ថុបំណង
  - សង្ខេបទំនាក់ទំនងរវាងការយល់ដឹងនូវវត្ថុបំណងរបស់គ្រូ ( មានន័យថា ការសម្រេចចិត្តនៃការអប់រំដែលត្រូវតែធ្វើ ) និងវិធីដំណើរការវាយតម្លៃជាក់ស្តែង ។ ប្រើតារាងដែលបានបង្ហាញនៅខាងក្រោមដើម្បីជួយពន្យល់លំដាប់លំដោយ នៃទំនាក់ទំនងរវាងការកំណត់វត្ថុបំណងរបស់គ្រូ ការបង្កើតនូវឧបករណ៍សម្រាប់វាស់ដូចជាតេស្តទម្រង់នៃការអង្កេត . . .។ ការបកស្រាយលទ្ធផលនឹងធ្វើការសម្រេចចិត្តចុងក្រោយបង្អស់
  - ចំពោះការបកស្រាយ សូមបញ្ជាក់ជូនសិក្ខាកាមថា ការប្រមូលទិន្នន័យដោយគ្មានការបកស្រាយមិនអាចជាការវាយតម្លៃបានទេ ។ ការបកស្រាយអំពីទិន្នន័យវាស់វែង (ឧទាហរណ៍ : ពិន្ទុ) តម្រូវឱ្យយើងបង្កើតរចនាសម្ព័ន្ធនៃការវាយតម្លៃ ដូចជាចំណាត់ថ្នាក់តាមពិន្ទុ ឬ ការដាក់លក្ខណៈវិនិច្ឆ័យដាច់ខាតមួយដែលអាចជួយយើងឱ្យកំណត់បានថាសិស្សទទួលជោគជ័យមិនទទួលជោគជ័យ ។

**<u>ឧទាហរណ៍</u> :** បើសិស្ស ១០ នាក់ ក្នុងម្នាក់ៗ បានពិន្ទុច្រើនជាង ៩០% លើតេស្ត ការបកស្រាយអំពីសមត្ថភាពសិស្សម្នាក់ៗ អាចមានភាពខុសគ្នាដោយផ្អែកទៅលើ : តើយើងប្រើប្រាស់គំរោងធ្វើការវាយតម្លៃបែបលក្ខណៈវិនិច្ឆ័យដាច់ខាតឬប្រើគំរោងវាយតម្លៃបែបធ្វើចំណាត់ថ្នាក់ពិន្ទុ ? ក្នុងគំរោងនៃការវាយតំលៃបែបលក្ខណៈវិនិច្ឆ័យដាច់ខាត សិស្សទាំងអស់ត្រូវបានវាយតម្លៃដោយវិជ្ជមាន រីឯក្នុងគំរោងនៃការវាយតម្លៃបែបចំណាត់ថ្នាក់ គឺត្រឹមតែសិស្សទាំងឡាយណាដែលមានចំណាត់ថ្នាក់លើគេប៉ុណ្ណោះដែលបានវាយតម្លៃថា វិជ្ជមាន ។ ដូច្នេះវាជាការសំខាន់ណាស់ ដែលអ្នកសម្របសម្រួលត្រូវធ្វើឱ្យសិក្ខាកាមយល់ថា ការមានរចនាសម្ព័ន្ធច្បាស់លាស់មានសារសំខាន់ណាស់ក្នុងការបកស្រាយទិន្នន័យវាស់វែងអំពីសមត្ថភាពរបស់សិស្ស ។

កំណត់វត្ថុបំណងនៃការវាយតម្លៃ
(ការសម្រេចចិត្តមួយចំនួនដែលយើងចង់បាន)

↓

បង្កើតនិងប្រើឧបករណ៍សម្រាប់វាស់ដែលសមស្របទៅនឹងវត្ថុបំណង

↓

បកស្រាយលទ្ធផលនៃការវាយតម្លៃ

↓

ធ្វើការសម្រេចចិត្តរបស់អ្នក

## ឯកសារទី៤: សុពលភាពតេស្ត (Validity)

- **លក្ខណៈតេស្តដែលល្អ**
  - សំណួរដែលងាយយល់
  - ត្រូវទាក់ទងទៅនឹងខ្លឹមសារដែលបានបង្រៀនក្នុងមេរៀននីមួយ ៗ
  - សំណួរមិនងាយពេក មិនពិបាកពេក
  - មិនវែងពេក មិនខ្លីពេក ។

- **តេស្ត** អាចមានលក្ខណៈសមស្របនិងមិនសមស្របទៅនឹងស្ថានភាពផ្សេងទៀត: ឧទាហរណ៍: ប្រសិនបើក្រសួងអប់រំត្រូវជ្រើសរើសសិស្ស ៥ នាក់ឱ្យទៅរៀននៅបរទេស ប៉ុន្តែត្រូវជ្រើសរើសក្នុងចំណោម បេក្ខជនជាង ១០០០ នាក់ ដែលបានដាក់ពាក្យសុំ ។ តើតេស្តនោះគួរមានសំណួរងាយស្រួល ឬលំបាក ? ( ចម្លើយ : វាគួរតែបញ្ចូលសំណួរលំបាកៗស្ទើរតែទាំងអស់ ។ ដូច្នេះគឺមានតែសិស្សពូកែបំផុតប៉ុណ្ណោះដែលអាចរកឃើញ) ។ បន្ទាប់មកយកឧទាហរណ៍មួយទៀតក្នុងស្ថានភាពមួយ ដែលក្នុងសាលាបឋមសិក្សាចង់កំណត់សិស្សានុសិស្សដែលអាចសម្រេចបញ្ញត្តិជាមូលដ្ឋាន ក្នុងការចេះអានចេះសរសេរ និង ចេះគិតលេខក្នុងវត្ថុបំណងដើម្បីឱ្យឡើងថ្នាក់ ។ តើសំណួរគួរ ជាសំណួរលំបាក ឬ ស្រួល? ចម្លើយ : កិច្ចការដែលបានបង្កើត ឬ ដែលបានគ្រោងនោះគួរតែបញ្ចូលសំណួរភាគ ច្រើនធុនមធ្យមមិនលំបាកពេក ដោយហេតុថា យើងចង់កំណត់អំពីចំណេះដឹងនៃបញ្ញត្តិជាមូលដ្ឋាន តែប៉ុណ្ណោះ ។ យើងគួរតែរំពឹងគិតថាសិស្សភាគច្រើនត្រូវជាប់

- ស្ថានភាពទាំងពីរដែលបានរៀបរាប់ខាងលើបង្ហាញថាវាមានការលំបាកក្នុង ការរកឱ្យឃើញគំរូសកល ឬ ទូទៅ (ស្តង់ដា )សម្រាប់តេស្តដែល “ ល្អ ” ។ ហេតុដូច្នេះហើយបានជាអ្នកប្រាជ្ញបានបង្កើតបញ្ញត្តិកម្មនេះហៅថា “ **សុពលភាព** ” (validity ) ដែលអាចឱ្យយើង វាយតម្លៃប្រសិទ្ធភាពនៃតេស្តរបស់យើង តាមរយៈសុពលភាពនេះឯង

> **សុពលភាពមានន័យថា ទំហំ និង កម្រិតនៃតេស្តមួយដែលត្រូវរៀបចំឡើងដើម្បីបំរើវត្ថុបំណងមួយ ។**

- ពន្យល់ថា សុពលភាពនាំឱ្យយើងរកឃើញសេចក្តីសំខាន់នៃការដឹងច្បាស់អំពីវត្ថុបំណងរបស់យើងក្នុងការវាយតម្លៃ ។ ជាថ្មីម្តងទៀត ការយល់ដឹងអំពីវត្ថុបំណងមានសារសំខាន់ក្នុងការបង្កើតតេស្តពីព្រោះវាផ្តល់ឱ្យមានស្តង់ដា ឬ លក្ខណៈវិនិច្ឆ័យនៃការកំណត់អំពីតេស្តមួយដែលល្អ ឬ មិនល្អ ។ តេស្តមួយអាចសមស្របទៅនឹងវត្ថុបំណងមួយ ប៉ុន្តែមិនសមស្របទៅនឹងវត្ថុបំណងមួយទៀត ដូចដែលបានឃើញខាងលើស្រាប់ហើយ ។

## ឯកសារទី៥: ការប្រើបញ្ញត្តិនៃសុពលភាពដើម្បីធ្វើផែនការតេស្តដែលមានប្រសិទ្ធភាព

នៅក្នុងការបំប៉ននេះ មានសុពលភាពពីរប្រភេទដែលលោកគ្រូ អ្នកគ្រូត្រូវដឹងគឺ : **សុពលភាពខ្លឹមសារ** និង **សុពលភាពបំណិន**

| | |
|---|---|
| **សុពលភាពខ្លឹមសារ សំដៅចំពោះកម្រិតនៃតេស្ត ដែលទាក់ទងទៅនឹងខ្លឹមសារ ដែលត្រូវវាយតម្លៃ ។** | **សុពលភាពបំណិន សំដៅចំពោះកម្រិតតេស្តដែល ទាក់ទងទៅនឹងបំណិន ដែលត្រូវវាយតម្លៃ ។** |

- បង្ហាញរបៀបផ្តល់គោលការណ៍ណែនាំ ក្នុងការវាយតម្លៃប្រសិទ្ធភាពនៃតេស្ត សុពលភាពខ្លឹមសារ និង សុពលភាពបំណិន ។

**<u>ករណីសិក្សា</u> : ដែលត្រូវបកស្រាយការអនុវត្តការតែងតេស្ត ដែលមិនមានសុពលភាព**

លោក ឈិន ជាគ្រូបង្រៀនថ្នាក់ទី ២ ។ តែលោកឈិនទើបតែបញ្ចប់ ៥ មេរៀនគណិតវិទ្យា ដូច្នេះលោកបានរៀបចំតេស្តប្រឡងឱ្យសិស្សធ្វើ ។ លោកឈិន បានបង្រៀនមេរៀននីមួយៗ ក្នុងរយៈពេលស្មើៗ គ្នា ។ មេរៀនភាគច្រើនសិស្សបានចងចាំរូបមន្តវិធីបូក ១៥ + ១២ ។ល ។ កាលណាលោកឈិនបានតែងតេស្តរបស់គាត់ គាត់ដាក់សំណួរ ២ ក្នុងមេរៀននីមួយៗ សំរាប់មេរៀន ៤ ដំបូង ហើយបានដាក់ ១២ សំណួរសំរាប់មេរៀនទី ៥ ។ សំណួរមួយចំនួនធំជាចំណោទ ដែលទាក់ទងជាមួយវិធីបូក វិធីដក ដល់សិស្សដែលបានរៀន ។ ពេលលោក ឈិន កែកិច្ចការនោះគ្មានសិស្សណាមួយបានប្រឡងជាប់ទេ ។

- ក្រោយពីអានករណីសិក្សានេះមក សួរសិក្ខាកាមនូវសំណួរខ្លះៗ ហេតុអ្វីបានជាសិស្សទាំងអស់ធ្លាក់តេស្តនេះ ។ ជាពិសេសសួរគាត់ថា តើទម្រង់ពិន្ទុតាមប្រធានបទនីមួយៗនៃតេស្តទាក់ទងទៅនឹងទម្រង់ពេលវេលានៃមេរៀននីមួយៗ ដែលបានបង្រៀនជាក់ស្តែងឬទេ ? ( **<u>ចម្លើយ</u> :** ទេ ) ពីព្រោះមេរៀននីមួយៗ ត្រូវបានបង្រៀនក្នុងរយៈពេលស្មើគ្នា ប៉ុន្តែមេរៀនចុងក្រោយមានចំនួនសំណួរច្រើនជាងគេ ។ សួរសិក្ខាកាមបន្តទៀតតើពួកគាត់គិតថាវាមានភាពយុត្តិធម៌ទេបើសិនជាយើងដាក់សំណួរ " កម្រិតអនុវត្ត " ឱ្យសិស្សធ្វើប៉ុន្តែយើងបានបង្រៀនគេត្រឹមតែសំណួរ "កម្រិតចងចាំ" ប៉ុណ្ណោះ ។ អ្វីដែលគេបានរៀន ហើយការអនុវត្តបែបនេះមិនត្រូវបានបង្រៀនជាក់ស្តែង
- ក្នុងរយៈពេលពិភាក្សាសំណួរនេះអ្នកសម្របសម្រួលត្រូវបង្ហាញថា តេស្តដែលបានរៀបរាប់ក្នុងករណីសិក្សានេះខ្វះសុពលភាពខ្លឹមសារ ក៏ដូចជាសុពលភាពបំណិន ។ សុពលភាពខ្លឹមសារ ព្រោះការវាយតម្លៃមិនឆ្លុះបញ្ចាំងនូវអ្វីដែលបានបង្រៀនជាក់ស្តែង ។ នេះគឺជាតេស្តមិនទាក់ទង ទៅនឹងខ្លឹមសារ

ដែលបានបង្រៀន ។ ប្រហាក់ប្រហែលគ្នានេះដែរ " កម្រិតអនុវត្តន៏ " ដែលជាផ្នែកបំណិនក៏នៅមិនទាន់ដែលបានបង្រៀនផងដែរ ។ លើចំណុចនេះហើយដែលគ្រូបានដាក់តេស្តឱ្យ សិស្សធ្វើ ។ សរុបសេចក្តីមកតេស្តដែលបានរៀបចំឡើងនេះមិនបំរើវត្ថុបំណងទេពីព្រោះវា មិនអាច វាស់ដោយត្រឹមត្រូវអ្វីដែលសិស្សបានរៀនជាក់ស្តែង

- មធ្យោបាយសំខាន់ដែលធ្វើឱ្យមានសុពលភាពខ្លឹមសារ និង សុពលភាពបំណិនក្នុងការបង្កើតតេស្ត គឺត្រូវប្រើតារាងមួយហៅថា តារាងផែនការតេស្ត (Table of Specifications ) ។ តារាងផែនការតេស្តនេះជាតារាងដែលជួយអ្នកសរសេរតេស្តឱ្យគិតពីខ្លឹមសារ និង បំណិនដែលបាន បង្រៀន ។ ចំនួននីមួយៗ ដែលបានបង្ហាញនៅក្នុងតារាងប្រាប់ពីចំនួនសំណួរក្នុងផ្នែកបំណិន និង ខ្លឹមសារនីមួយៗ

**ឧទាហរណ៍ : តារាងផែនការតេស្តសម្រាប់គណិតវិទ្យាថ្នាក់ទី ២ :**

- តើមានសំណួរប៉ុន្មាននៅក្នុងតេស្តនេះ ? ( ចម្លើយ : ២៥ )
- តើផ្នែកខ្លឹមសារណា ដែលទទួលការយកចិត្តទុកដាក់ខ្ពស់បំផុត ? (ចម្លើយ : ចំនួន ២0 ដល់ ១00 ; ១00 ដល់ ១000 ) ។
- តើផ្នែកខ្លឹមសារណាដែលទទួលការយកចិត្ត ទុកដាក់ទាបបំផុត ? (ចម្លើយ : ការរាប់លុយ )

| ខ្លឹមសារ \ បំណិន | ការចងចាំ | ការយល់ដឹង | ការអនុវត្ត | សរុប |
|---|---|---|---|---|
| លីត្រ | ២ | ២ | | ៤ |
| ការរាប់លុយ | | | ១ | ១ |
| ចំនួន ២0-១00 | ៣ | ២ | | ៥ |
| បូកចំនួនមានលេខ2ខ្ទង់ | | | ៥ | ៥ |
| ត្រីកោណនិងការេ | ២ | | | ២ |
| ម៉ែត , ដេស៊ីម៉ែត , សង់ទីម៉ែតនិងមីលីម៉ែត | ១ | ២ | | ៣ |
| ចំនួន ១00-១000 | ៣ | ២ | | ៥ |
| សរុប | ១១ | ៨ | ៦ | ២៥ |

- តើបំណិនណាដែលទទួលការយកចិត្ត ទុកដាក់ខ្ពស់បំផុត ? (ចម្លើយ : ការចងចាំ )
- តើបំណិនណា ដែលទទូការយកចិត្តទុកដាក់ទាបបំផុត ? (ចម្លើយ : ការអនុវត្ត )
- បើតេស្តនេះមានសុពលភាព តើវាបានប្រាប់អ្វីដល់អ្នកអំពីរបៀបបង្រៀនខ្លឹមសារនីមួយៗ ? (ចម្លើយ : គ្រូចាត់ទុកមេរៀនខ្លះ សំខាន់ជាងមេរៀនដទៃ ។ មេរៀនទាំងនេះបានសន្មត់ថាត្រូវបង្រៀនរយៈពេលវែងជាងមេរៀនដទៃ ។ បានសង្កត់ធ្ងន់ក្នុងការដាក់សំណួរចងចាំច្រើនជាងសំណួរអនុវត្ត ) ។

## ឯកសារទី៦: ការប្រើទម្រង់សំណួរខុសៗ គ្នាក្នុងការបង្កើតតេស្ត

- នៅក្នុងផ្នែកនេះអ្នកសម្របសម្រួលត្រូវព្យាយាមអធិប្បាយពន្យល់សិក្ខាកាមនូវទម្រង់សំណួរខុសៗគ្នាដែលសមស្របទៅនឹងវត្ថុបំណងនៃការវាយតម្លៃផ្សេងៗគ្នា ។ ទម្រង់នីមួយៗមានគុណសម្បត្តិ និង គុណវិបត្តិដែលត្រូវតែយល់ឱ្យបានច្បាស់ ។ ពន្យល់សិក្ខាកាមថា សំណួរជាមូលដ្ឋាន ២ ប្រភេទដែលត្រូវបានប្រើច្រើនជាងគេបំផុតក្នុងការរៀបចំតេស្ត ។ សំណួរទាំង ២ ប្រភេទនេះ គឺ " **សំណួរមិនលំអៀង** " និង " **សំណួរលំអៀង** "

ប្រភេទនៃសំណួរ

| មិនលំអៀង | លំអៀង |
|---|---|
| សំណួរដែលនាំពីផលក្នុងនោះការដាក់ពិន្ទុមិនប្រែប្រួលរវាងអ្នកកែ ។ | សំណួរណែនាំពីលំនាំក្នុងនោះការដាក់ពិន្ទុអាចប្រែប្រួលរវាងអ្នកកែ ។ |

- ដាក់តារាងបង្ហាញនិយមន័យនៃប្រភេទនីមួយៗនៅលើក្តារខៀនហើយពន្យល់ភាពខុសគ្នា ។ កត់ចំណាំថា សំណួរមិនលំអៀងអាច ឆ្លើយបានយ៉ាងរហ័សមានចម្លើយត្រឹមត្រូវតែមួយគត់ ហើយសង្កត់ធ្ងន់លើផលចុងក្រោយបង្អស់ក្នុងការសិក្សា ( មានន័យថា សិស្សអាច ឆ្លើយនឹងសំណួរបាន ឬ មិនបាន ) សំណួរបែបនេះមិនបញ្ជាក់ពីអំពីការយល់ដឹងរបស់សិស្សលើផ្នែកនីមួយៗនៃលំនាំ ( ឧទាហរណ៍ : របៀបបូកលេខ២ តួ )ដែលសិស្សម្នាក់មិនអាចដឹងនោះទេ ។ ជាទូទៅសំណួរមិនលំអៀងមានការលំបាកបំផុតក្នុងការសរសេរ ប៉ុន្តែងាយស្រួលក្នុងការកែ ។ ឧទាហរណ៍រួមនៃសំណួរមិនលំអៀង គឺមានសំណួរជ្រើសរើសសំណួរចំលើយខ្លី និង សំណួរផ្គូផ្គង ។ ចំណែកឯសំណួរលំអៀងតែងតែស៊ីពេលវែងក្នុងការឆ្លើយ មានចំលើយច្រើនដែលកំណែអាចប្រែប្រួលទៅតាមការបកស្រាយរបស់អ្នកកែ ។ ហើយសង្កត់ធ្ងន់លើលំនាំនៃការសិក្សា ។ សំណួរលំអៀងមានការងាយស្រួលក្នុងការតែង ប៉ុន្តែមានការលំបាកណាស់ក្នុងការកែ ។ ទោះបីថា សំណួរតែងសេចក្តីជាឧទាហរណ៍ ដែលគេស្គាល់ជាងគេនៃសំណួរលំអៀងក៏អាចមានទម្រង់ផ្សេងៗជាច្រើនផងដែរ ។
- <u>ឧទាហរណ៍</u> : សំណួរបង្ហាញខាងក្រោមទាំងពីរសួរព័ត៌មានដូចគ្នា ។ ចម្លើយខុសរបស់សិស្សដែលបានបង្ហាញទោះយ៉ាងណាក៏ដោយផ្តល់ឱ្យអ្នកកែនូវព័ត៌មានខុសគ្នាអំពីការសិក្សារបស់សិស្ស ។ សំណួរជ្រើសរើសគ្រាន់ តែបង្ហាញថាសិស្សមិនដឹងពីរបៀបបូកលេខ ។ សំណួរនៅផ្នែកខាងស្តាំបង្ហាញ

៥៥ + ៣៥ = ?

ក. ៧៥
ខ. ៨០
គ. ៨១
ឃ. ៩០

៥៥
\+ ៣៥
____
៨១០

ថា សិស្សនៅមិនទាន់យល់របៀបផ្តុំឡើងវិញ ( ត្រាទុក ) នៅ ពេលធ្វើលេខបូក ។ នេះវាបង្ហាញនូវ កំហុសក្នុង " លំនាំ " នៃការបូកលេខ ។ ព័ត៌មាននេះមានប្រយោជន៏ចំពោះគ្រូ ក្នុងការដឹងថា ត្រូវរំលឹកខ្លឹមសារ ឬ ជួយសិស្សជាបុគ្គល ។ ដូច្នេះវាមានប្រយោជន៏ណាស់សម្រាប់ប្រភេទ វាយតម្លៃជាដំណាក់ៗ ។ល ។

- វត្ថុបំណងរបស់ខ្លួនក្នុងដំណើរការតេស្តមួយមានឥទ្ធិពលយ៉ាងខ្លាំងលើទម្រង់នៃសំណួរដែលយើងប្រើ ក្នុងការរៀបចំតេស្ត ។ដូចដែលបានកំណត់ពីមុនសំណួរមិនលំអៀងមានទំនោរសមស្របទៅនឹងប្រភេទ នៃការវាយតម្លៃបូកសរុប ។ ឯសំណួរលំអៀងសមស្របសម្រាប់ការវាយតម្លៃជាដំណាក់ៗ ។ ទោះបី ការណែនាំនេះមិនមែនជាការដាច់ខាត( មានន័យថា សំណួរតែងសេចក្តីនៅពេលខ្លះអាចត្រូវបានប្រើ ក្នុងការវាយតម្លៃបូកសរុបហើយសំណួរមិនលំអៀងសម្រាប់ប្រើក្នុងការវាយតម្លៃជាដំណាក់ៗ ) វាពិតជាជួយក្នុងការផ្តល់គោលការណ៏ណែនាំទូទៅមួយក្នុងការជ្រើសរើសទម្រង់សំណួរ ។

កម្មវិធីគាំទ្រសេវាអប់រំកុមារនៅតំបន់ដាច់ស្រយាល(អេស្កាប់)

EQUIP1
Educational Quality Improvement Program
Classrooms • Schools • Communities

## ឯកសារបណ្តុះបណ្តាលគ្រូថ្នាក់កុមារមេត្រី
## សម្រាប់បឋមសិក្សា

# ការរៀបចំកម្រងស្នាដៃសិស្សថ្នាក់កុមារមេត្រី



# Student Portfolios





ខេត្តកំពង់ចាម ប្រទេសកម្ពុជា
ខែ សីហា ឆ្នាំ ២០០៦
**ឯកសារដើមពីអង្គការខេប**

## ឯកសារទី១: ការរៀបចំកម្រងស្នាដៃសិស្ស

### ១. សេចក្តីផ្តើម :

### *១.១ អ្វីទៅដែលហៅថាកម្រងស្នាដៃសិស្ស ?*

- កម្រងស្នាដៃសិស្ស គឺជាការប្រមូលស្នាដៃរបស់សិស្ស ដើម្បីបង្ហាញភស្តុតាងជាឯកសារអំពីលទ្ធផលនៃការសិក្សារបស់សិស្ស ។ ស្នាដៃផ្សេងៗ របស់សិស្សម្នាក់ៗ ត្រូវប្រមូលទុកក្នុងសឺមីដោយមានបិទឈ្មោះសិស្ស ឬ ក៏អាចប្រមូលស្នាដៃសិស្សជាក្រុម ៗ ដោយមានសឺមីប្រចាំក្រុមដែលបង្ហាញពីលទ្ធផលនៃការសិក្សាបែបសហការ ។ ការប្រើប្រាស់កម្រងស្នាដៃសិស្សមិនមែនជាសកម្មភាពដែលអាចញែកបានពីសកម្មភាពផ្សេង ៗ ទៀតក្នុងបន្ទប់រៀនបានឡើយ ។ កម្រងស្នាដៃសិស្សនេះជាឧបករណ៍មួយដែលជួយអោយគ្រូសំរេចបាននូវគោលបំណងរួមនៃកម្មវិធីសិក្សាដោយឆ្លុះបញ្ចាំងលើការលូតលាស់ក្នុងបំណិនផ្សេង ៗ និង សមត្ថភាពយល់ដឹងរបស់សិស្សម្នាក់ ៗ ។

### *១.២ ភាពខុសគ្នាក្នុងការរៀបចំកម្រងស្នាដៃសិស្ស*

- គ្រូម្នាក់ ៗ អាចប្រើប្រាស់ ឬ គ្រប់គ្រងកម្រងស្នាដៃសិស្សដោយគំនិតច្នៃប្រឌិតដោយឡែក ៗ ពីគ្នា ។ វិធីដែលប្រើប្រាស់កម្រងស្នាដៃសិស្សត្រូវពឹងផ្អែកលក្ខណៈចាំបាច់ខ្លះ ៗ ដូចខាងក្រោម ÷
    - គោលបំណងជាអាទិភាពរបស់គ្រូ
    - កម្រិតថ្នាក់របស់សិស្ស
    - ចំនួនសិស្សក្នុងថ្នាក់
    - បទពិសោធន៍ដែលគ្រូមានកន្លងមក ស្តីពីការប្រើប្រាស់កម្រងស្នាដៃសិស្ស
    - បទពិសោធន៍ដែលសិស្សធ្លាប់មាន ស្តីពីការប្រើប្រាស់កម្រងស្នាដៃសិស្ស
    - សម្ភារខ្លះ ៗ ដូចជា ÷ សឺមី , ទម្រង់លំហាត់ , ទម្រង់លំហាត់គិតដោយច្នៃប្រឌិត , ទម្រង់លំហាត់គិតដោយវិភាគ , គូល័រទៀន , ក្រដាសរ៉ាម . . . ។ល ។
    - កន្លែងក្នុងបន្ទប់រៀន ដើម្បីទុកដាក់ថែរក្សាកម្រងស្នាដៃសិស្សដែលជាកន្លែងងាយស្រួលសម្រាប់សិស្សយកទៅប្រើប្រាស់
    - បន្ទប់រៀនមួយពេល ឬ ពីរពេល ។

- វិធីផ្សេង ៗ ក្នុងការរៀបចំកម្រងស្នាដៃសិស្ស ៖

ក/ ការរៀបចំកម្រងស្នាដៃដោយឡែកសម្រាប់មុខវិជ្ជានីមួយ ៗ ក្នុងសិស្សម្នាក់ ៗ

ខ/ ការរៀបចំកម្រងស្នាដៃមួយទទួលស្នាដៃសិស្សគ្រប់មុខវិជ្ជាទាំងអស់ក្នុងសិស្សម្នាក់ ៗ

គ/ ការរៀបចំកម្រងស្នាដៃដោយឡែកសម្រាប់មុខវិជ្ជានីមួយ ៗ ក្នុងក្រុមសិស្ស

ឃ/ ការរៀបចំកម្រងស្នាដៃសិស្ស ក្នុងសិស្សម្នាក់ ៗ សម្រប់មុខវិជ្ជាមួយចំនួន

ង/ ការរៀបចំកម្រងស្នាដៃសិស្ស របស់ក្រុមសិស្សក្នុងមុខវិជ្ជាដោយឡែក ។

## ២. ជំហាននៃការអភិវឌ្ឍកម្រងស្នាដៃសិស្សនៅកម្ពុជា ៖

- ការប្រើប្រាស់កម្រងស្នាដៃសិស្ស ជាវិធីសាស្ត្រថ្មីសម្រាប់អ្នកអប់រំនៅកម្ពុជា ។ គ្រូដែលមិនទាន់មានបទពិសោធន៍ និង ការយល់ដឹងច្បាស់លាស់ មិនអាចប្រើវិធីសាស្ត្រនេះយ៉ាងពេញលេញអស់លទ្ធភាពភ្លាម ៗ បាននោះទេ ។ គ្រូក្នុងកម្រងដែលកំពុងអនុវត្តន៍ *បញ្ជីសេវាកម្មកម្រិតមធ្យម* នឹងទទួលការបំប៉នអំពីល្បិចប្រើប្រាស់ និង បញ្ញត្តិមូលដ្ឋាន ។ បទពិសោធន៍នេះនឹងជួយអោយយើងរៀបចំវិធីប្រើប្រាស់កម្រងស្នាដៃសិស្សដែលសមស្របតាមបន្ទប់រៀនក្នុងសាលារៀននៅកម្ពុជា ។ ពេលដែលគ្រូយល់កាន់តែច្បាស់គេអាចជ្រើសរើសសកម្មភាពមួយផ្សេងទៀតអំពីការប្រើប្រាស់កម្រងស្នាដៃសិស្សលើ *បញ្ជីសេវាកម្មកម្រិតខ្ពស់* ។

 ដូច្នេះឯកសារនេះ ផ្តល់ជាគំនិតយោបល់មួយចំនួនជួយអោយគ្រូចាប់ផ្តើមប្រើសីមីស្នាដៃសិស្សជាមួយសិស្សរបស់គេ ។ គ្រូអាចកែសម្រួលវិធី និង ល្បិចក្នុងឯកសារនេះតាមការយល់ឃើញរបស់គាត់ទាក់ទងនឹងស្ថានភាពជាក់ស្តែងនៅក្នុងបន្ទប់រៀននីមួយ ៗ ។

## ៣. បញ្ហាកន្លងមកក្នុងការប្រើប្រាស់កម្រងស្នាដៃសិស្ស ៖

- ក្នុងឆ្នាំសិក្សា ២០០១-២០០២ គ្រូដែលចូលរួមក្នុង *កម្មវិធីសាលាកុមារមេត្រី* បានសាកល្បងប្រើប្រាស់កម្រងស្នាដៃសិស្សជាច្រើននាក់ ។ ក៏ប៉ុន្តែការសាកល្បងនេះបានបញ្ជាក់អំពីបញ្ហាមួយចំនួនទាក់ទងនិងការប្រើប្រាស់កម្រងស្នាដៃសិស្ស ។ ឯកសារនេះព្យាយាមដោះស្រាយបញ្ហាដែលមានកន្លងមក ។

ក/ គ្មានគោលបំណងច្បាស់លាស់ក្នុងការប្រមូលស្នាដៃសិស្ស

ខ/ គ្រូមួយចំនួនយល់ច្រឡំថាគេត្រូវតែប្រើកម្រងស្នាដៃសិស្សជំនួសវិធីវាយតម្លៃផ្លូវការ ។ ( ការប្រើប្រាស់កម្រងស្នាដៃសិស្ស អាចជួយដល់ប្រពន្ធ័វាយតម្លៃបែបបូកសរុប ( Summative ) ក៏ប៉ុន្តែមិនអាចជំនួសប្រពន្ធ័វាយតម្លៃនេះទាំងស្រុងបានទេ )

គ/ មានបញ្ហាខ្លះទៀត ទាក់ទងនឹងការគ្រប់គ្រងកម្រងស្នាដៃសិស្សដែលបង្ហាញក្នុងសំណួរខាងក្រោមនេះ ÷

- តើគួរតែប្រើសឺមីមួយសម្រាប់សិស្សម្នាក់ ឬ សឺមីមួយសម្រាប់មុខវិជ្ជាមួយក្នុងសិស្សម្នាក់ ៗ ?
- តើស្នាដៃដែលបានប្រមូលគួរតែមានលក្ខណៈយ៉ាងដូចម្តេចខ្លះ ?
- តើគួរតែប្រមូលស្នាដៃល្អ ឬ ស្នាដៃមិនល្អរបស់សិស្ស ?
- តើគួរតែប្រមូលស្នាដៃអោយបានញឹកញាប់ដល់កម្រិតណា ?
- តើអ្នកណាជាអ្នកធ្វើការសំរេចចិត្តអំពីអ្វីដែលត្រូវតែដាក់ក្នុងសឺមីរបស់សិស្សម្នាក់ ឬ របស់ក្រុម ?
- ក្រោយពីបានប្រមូលស្នាដៃហើយ តើគ្រូ ឬ សិស្សត្រូវធ្វើដូចម្តេច ?
- នៅចុងបញ្ចប់ឆ្នាំសិក្សា តើគ្រូនិងសិស្ស ត្រូវធ្វើយ៉ាងដូចម្តេចជាមួយកម្រងស្នាដៃសិស្សដែលបានរៀបចំ ?

- ផ្នែកខាងក្រោមក្នុងឯកសារនេះព្យាយាមឆ្លើយតបទៅនឹងបញ្ហាដែលបានលើកឡើងខាងលើរួចហើយ ។ ឯកសារនេះរៀបរាប់អំពីលំហាត់ជាក់ស្តែងមួយចំនួន ដែលគ្រូអាចសាកល្បងជាមួយសិស្ស ។ ការអនុវត្តលំហាត់ទាំងនេះអាចជួយអោយគ្រូយល់អំពីទំនាក់ទំនងរវាងខ្លឹមសារក្នុងកម្មវិធីសិក្សាដែលគេត្រូវតែបង្រៀនទៅនឹងការប្រើប្រាស់កម្រងស្នាដៃសិស្ស ។

## ៤. មូលហេតុដែលអ្នកអប់រំប្រើប្រាស់កម្រងស្នាដៃសិស្ស

- មានមូលហេតុសំខាន់ចំនួន ៤ ដែលធ្វើអោយអ្នកអប់រំចាប់អារម្មណ៍ការប្រើប្រាស់កម្រងស្នាដៃសិស្ស ÷
  - ការបង្កើនការងាររបស់គ្រូកាន់តែប្រសើរឡើង
  - ការបង្កើនការសិក្សារបស់សិស្សកាន់តែប្រសើរឡើង
  - ការបង្កើនការចូលរួមពីមាតាបិតាសិស្ស និង សហគមន៍កាន់តែប្រសើរឡើងក្នុងវិស័យអប់រំ
  - ការបង្កើនប្រសិទ្ធភាពវាយតម្លៃលទ្ធផលនៃការសិក្សារបស់សិស្សកាន់តែប្រសើរឡើង ។

## ឯកសារទី២: លក្ខណៈនៃកម្រងស្នាដៃសិស្ស

- តារាងខាងក្រោមនេះបញ្ជាក់អំពីមូលហេតុទាំង ៤ ដោយពិព័ណនាអំពីលក្ខណៈជាក់ស្តែងមួយចំនួន ÷

| តួនាទី | លក្ខណៈ |
| --- | --- |
| • ការធ្វើអោយការងាររបស់គ្រូកាន់តែប្រសើរឡើង | - ជាខ្លឹមសារជាក់ស្តែងសម្រាប់បំផុសការពិភាក្សារវាងគ្រូស្តីអំពីសេចក្តីត្រូវការនិងសមត្ថភាពរបស់សិស្សម្នាក់ៗ ពេលដែលសិស្សឡើងថ្នាក់<br>- ខ្លឹមសារជាក់ស្តែងសម្រាប់បំផុសការពិភាក្សារវាងគ្រូបន្ទុកថ្នាក់ និង គ្រូបំប៉នសិស្សបន្ថែមស្តីពីសេចក្តីត្រូវការរបស់សិស្សម្នាក់ ៗ<br>- ខ្លឹមសារជាក់ស្តែងសម្រាប់អោយគ្រូពិចារណាលើប្រសិទ្ធភាពនៃការបង្រៀន<br>- ជួយដល់ក្រុមបច្ចេកទេសអោយមានការយល់ដឹងកាន់តែច្បាស់ អំពីសកម្មភាពបង្រៀនប្រចាំថ្ងៃ<br>- ខ្លឹមសារជាក់ស្តែងជួយវាយតម្លៃភាពកុមារមេត្រីនៃថ្នាក់រៀន ។ |
| • ការបង្កើនការសិក្សារបស់សិស្សកាន់តែប្រសើរឡើង | - សិស្សទទួលខុសត្រូវកាន់តែខ្ពស់ឡើងសម្រាប់ការរៀនសូត្ររបស់ខ្លួន<br>- សិស្សពេញចិត្តនឹងលទ្ធផលនៃការរៀនសូត្ររបស់ខ្លួន កាន់តែច្រើនឡើង<br>- សិស្សចូលរួមក្នុងសកម្មភាពរៀនសូត្រកាន់តែច្រើន<br>- ផ្តល់ឱកាសអោយសិស្សចូលរួមស្វ័យវាយតម្លៃ<br>- ជាខ្លឹមសារសម្រាប់បំផុសការពិភាក្សា រវាងសិស្សនិងសិស្សអំពីខ្លឹមសារនៃមេរៀន ។ |
| • ការបង្កើនការចូលរួមរបស់មាតាបិតាសិស្ស និង សហគមន៍កាន់តែប្រសើរឡើងក្នុងវិស័យអប់រំ | - ជាខ្លឹមសារ សម្រាប់បំផុសការពិភាក្សា រវាងគ្រូ និង មាតាបិតាសិស្ស<br>- ស្នាដៃសិស្សនេះអាចយកទៅបិទលើក្តារខៀនជូនពតិមាន ដែលស្ថិតនៅកន្លែងសាធារណៈរបស់សហគមន៍<br>- ជាខ្លឹមសារ ជាក់ស្តែងសម្រាប់ការពិភាក្សារវាងសិស្ស និង មាតាបិតារបស់សិស្សម្នាក់ ៗ<br>- ជួយអោយមាតាបិតាយល់កាន់តែច្បាស់នូវសកម្មភាពបង្រៀន និង រៀនប្រចាំថ្ងៃពេលគាត់មកទស្សនកិច្ច ។ |
| • ការបង្កើនប្រសិទ្ធភាពវាយតម្លៃលទ្ធផលនៃការសិក្សារបស់សិស្សកាន់តែប្រសើរឡើង | - ជាខ្លឹមសារបំផុសលើការពិភាក្សារវាងគ្រូ និង សិស្សម្នាក់ ៗ<br>- ជាភស្តុតាងបង្ហាញអំពីសេចក្តីត្រូវការជាក់ស្តែងនៃសិស្សម្នាក់ ៗ ដល់ថ្នាក់បំប៉នសិស្សបន្ថែម<br>- ជួយអោយគ្រូកំណត់គោលបំណងកាន់តែច្បាស់សម្រាប់មេរៀនថ្មីនៅពេលខាងមុខ<br>- ជួយអោយគ្រូរៀបចំខ្លឹមសារសម្រាប់មេរៀនថ្មីនៅពេលខាងមុខ<br>- ជួយបំភ្លឺ បញ្ហាសម្រាប់ការវាយតម្លៃដំណាក់ ៗ ( Formative )<br>- ពង្រឹងទំនាក់ទំនងរវាងការវាយតម្លៃបែបបូកសរុប ( Summative )និង ការវាយតម្លៃដំណាក់ៗ ( Formative ) ដោយផ្តល់ខ្លឹមសារសម្រាប់ប្រៀបធៀបពិន្ទុតេស្តជាមួយលទ្ធផលការងារប្រចាំថ្ងៃរបស់សិស្ស។ |

## ឯកសារទី៣: យុទ្ធវិធីនៃការប្រើប្រាស់សឺមីស្នាដៃសិស្ស

### ១. យុទ្ធវិធីនៃការប្រើប្រាស់សឺមីស្នាដៃសិស្ស

- ក្នុងការរៀបចំកម្រងស្នាដៃសិស្ស គួរតែរៀបជារបៀបដែលមានការឆ្លុះបញ្ចាំងលើការអភិវឌ្ឍ បំណិន និង ការយល់ដឹងកាន់តែច្បាស់លើកិច្ចការរបស់សិស្សជាមួយនឹងគំនិតយោបល់របស់គេ ។ ក៏ប៉ុន្តែប្រភេទ បំណិន និង សមត្ថភាពដែលសិស្សអាចមានលក្ខណៈខុស ៗ គ្នា តាមកម្រិតថ្នាក់ ដូច្នេះត្រូវតែមានវិធីខុសគ្នាក្នុងការអនុវត្តយុទ្ធវិធី
- យើងអាចពិចារណាអំពីវិធីរៀបចំកម្រងស្នាដៃសិស្សសម្រាប់ថ្នាក់នីមួយ ៗ ដោយសង្កត់ធ្ងន់ទៅលើកត្តា ៤ យ៉ាង ÷
  - តើអ្នកណាជាអ្នកជ្រើសរើសស្នាដៃសិស្សបញ្ចូលក្នុងសឺមី ( គ្រូ ឬ សិស្ស ) ?
  - ប្រភេទស្នាដៃសម្រាប់បញ្ចូលក្នុងសឺមី
  - ការរៀបចំសេចក្តីព្រាង និង ពិចារណាឡើងវិញលើសេចក្តីព្រាង
  - ការពិចារណាលើស្នាដៃសិស្សក្នុងសឺមី ។
- <u>ចំណាំ</u> : គ្រូមិនគួរដាក់ពិន្ទុលើស្នាដៃសិស្សក្នុងសឺមីនោះទេ ពីព្រោះ ÷

  - ខ្វះពេលវេលា
  - អាចប៉ះពាល់អារម្មណ៍របស់សិស្ស
  - បញ្ហាគំនិតលំអៀងរបស់អ្នកកែ
  - មិនមែនជាការវាយតម្លៃសរុប . . . ។

#### *១.១ យុទ្ធវិធីរៀបចំកម្រងស្នាដៃសិស្សថ្នាក់ទី ១*

*១.១.១ <u>តើអ្នកណាជាអ្នកជ្រើសរើសស្នាដៃសិស្សបញ្ចូលសឺមី ?</u>*

- ដោយសារសិស្សអាយុតិចពេក គ្រូគួរតែទទួលខុសត្រូវក្នុងការប្រមូល និង បញ្ចូលស្នាដៃក្នុងសឺមី ។ ម្យ៉ាងទៀតគ្រូគួរតែសរសេរកាលបរិច្ឆេទ ។ ប្រសិនបើសិស្សមិនទាន់ចេះសរសេរឈ្មោះ គ្រូគួរតែសរសេរអោយសិស្ស ។

*១.១.២ <u>ប្រភេទស្នាដៃ :</u>*

- ការសរសេរព្យញ្ជនៈ និង ស្រះ
- ការសរសេរព្យញ្ជនៈ និង ស្រះ ដោយមានគូររូបភាព
- ការសរសេរពាក្យ និង គូររូបភាពតាមពាក្យ
- ការធ្វើលំហាត់ស្គាល់ពាក្យ
- ការចម្លងឈ្មោះ និង គូររូបភាពតាមខ្លឹមសារឈ្មោះនោះ
- ការបំពេញពាក្យតាមចន្លោះឃ្លា ឬ ឈ្មោះ ( ដារា . . . . . ផ្ការ )
- ការសរសេរឈ្មោះដោយគំនិតច្នៃប្រឌិត និង គូររូបភាព ។

- យើងសូមជូនជាយោបល់ថា គ្រូគួរតែកំណត់ពេលវេលាជាក់ស្តែងនៅចុងបញ្ចប់រៀងរាល់សប្តាហ៍សម្រាប់ការប្រើប្រាស់កម្រងស្នាដៃសិស្ស ។ សិស្សធ្វើការងារតាមខ្លឹមសារដែលគ្រូបានបង្រៀនក្នុងសប្តាហ៍នោះ ( ដូចឧទាហរណ៍ខាងលើ ) ដើម្បីជ្រើសរើសបញ្ចូលក្នុងសឺមី ។ ក្នុងសប្តាហ៍សិស្សអាចហាត់សរសេរ និង ហាត់គូរលើក្តារឆ្នួន ឬ អាចប្រើសម្ភារផ្សេងទៀត (ដូចប្រអប់ដីខ្សាច់ ) ដែលគ្រូយល់ថាសមស្រប ។ នៅចុងបញ្ចប់សប្តាហ៍ គ្រូចែកជូនក្រដាសមួយសន្លឹកដល់សិស្សម្នាក់ៗ ។ សិស្សគូរ ឬ សរសេរ លើក្រដាសនេះដោយប្រើសមត្ថភាពដែលគេមានស្រាប់ ។ បន្ទាប់មកគ្រូសរសេរឈ្មោះសិស្ស និង កាលបរិច្ឆេទ ហើយនិង យកក្រដាសនោះបញ្ចូលក្នុងសឺមី ។ ស្នាដៃនេះជាការឆ្លុះបញ្ចាំងលទ្ធផលនៃការសិក្សារបស់សិស្សម្នាក់ ៗ ក្នុងសប្តាហ៍នោះ ។

*១.១.៣ <u>ការរៀបចំសេចក្តីព្រាងគំនិត</u>*

- យុទ្ធវិធីនេះ ចង់បញ្ជាក់ *<u>អំពីការរីកចំរើនជាទូទៅ</u>* ក្នុងឆ្នាំសិក្សាដោយអោយសិស្សធ្វើលំហាត់មួយនៅចុងបញ្ចប់នៃខែនីមួយ ៗ ។ លំហាត់នេះផ្តល់ឱកាសអោយសិស្សបង្ហាញនិងប្រើប្រាស់បំណិនថ្មី ៗ ដែលគេបានរៀនក្នុងខែនេះ
- នៅចុងបញ្ចប់ខែនីមួយ ៗ សិស្សម្នាក់ ៗ ត្រូវបានទទួលក្រដាសមួយសន្លឹក គ្រូអោយសិស្សធ្វើលំហាត់ដែលមានឈ្មោះថា " ខ្ញុំ " ។ សិស្សអាចគូររូបភាពដោយបង្ហាញខ្លួនគេ ឬ មិត្តគេ ឬ ផ្ទះគេ . . .។ ល ។ និង សរសេរពាក្យតាមរូបភាព ឬ ឈ្មោះដែលសមស្របតាមជីវិតរស់នៅរបស់គេ ។ លំហាត់នេះត្រូវធ្វើឡើងវិញជារៀងរាល់ខែ ក៏ប៉ុន្តែគួរតែមានការកែលំអ និង ការរីកចំរើនតាមសមត្ថភាព និង បំណិនថ្មីរបស់សិស្ស ។ ប្រសិនបើគ្រូសង្កេតឃើញថា មានសិស្សមួយចំនួនមិនសូវរីកចំរើនទេ គ្រូគួរតែព្យាយាមជួយសិស្សទាំងនោះភ្លាម
- នៅចុងបញ្ចប់ខែទី ១ ប្រហែលសិស្សគ្រាន់តែចេះគូររូបភាពបង្ហាញខ្លួនគេ និង ប្រហែលរូបភាពនេះពិបាកយល់ ។ គ្រូមិនគួរ

ព្រួយបារម្ភទេ នៅពេលឃើញថា សិស្សខ្លួនចាប់ផ្តើមគូររូបភាពមិនទាន់សមស្របដំបូងនេះ ។ នៅពេលដែលសិស្សធ្វើលំហាត់នេះឡើងវិញពេលខែក្រោយ ៗ ទៀតនោះ សិស្សអាចមានការអភិវឌ្ឍឡើងវិញលើបញ្ហាគូររូបភាព និង អាចចាប់ផ្តើមសរសេរពាក្យ ដូចជា ឈ្មោះរបស់គេ ឬ វត្ថុផ្សេង ៗ ក្នុងបរិស្ថានរបស់គេ ដូចជា " ផ្ទះ " " សាលារៀន " " ជីដូនជីតា " " ប៉ា " " ម៉ាក់ "... ។ ល ។ នៅខែជិតចុងបញ្ចប់ឆ្នាំសិក្សាសិស្សអាចសរសេរឈ្មោះ ឬ ឃ្លា ពេញលេញមួយ

- គ្រូគួរតែទទួលស្គាល់ថា លំហាត់នេះ ជាលំហាត់ច្នៃប្រឌិត ដែលអោយសិស្សផ្សារភ្ជាប់គំនិតយោបល់របស់គេជាមួយបំណិនដែលគេបានរៀននៅសាលា ។ ដូច្នេះចម្លើយរបស់សិស្សម្នាក់ៗមានលក្ខណៈខុសគ្នា សិស្សគួរតែមានសេរីភាពក្នុងការសរសេរ

- ទោះបីជាយ៉ាងណាក៏ដោយ គ្រូមានតួនាទីមួយសំខាន់ជាអ្នកសំរបសំរួល ដើម្បីជួយសិស្សប្រើប្រាស់សក្តានុភាពរបស់គេយ៉ាងពេញលេញ ។ គ្រូមានការយល់ដឹងអំពីសមត្ថភាពរបស់សិស្សម្នាក់ ៗ និង បំណិនដែលគេបានរៀនរួចមកហើយ ។ ដូច្នេះពេលដែលសិស្សកំពុងធ្វើលំហាត់នេះ គ្រូគួរតែដើរជុំវិញបន្ទប់ និង ជំរុញអោយសិស្សធ្វើតាមសមត្ថភាពពេញលេញរបស់គេដោយបំផុសសំណួរ ដើម្បីអោយសិស្សបញ្ចេញគំនិត ។ ជាការសំខាន់មួយប្រសិនបើគ្រូអាចបំផុសសំណួរ និង សរសើរអ្វី ៗ ដែលសិស្សកំពុងព្យាយាមធ្វើ ។ គ្រូអាចបំផុសសំណួរ និង បញ្ចេញគំនិតយោបល់សម្រាប់សិស្សផ្សេង ៗ ដោយសារសិស្សម្នាក់ ៗ មានសមត្ថភាពខុស ៗ គ្នា ។ពេលដែលគ្រូដើរជុំវិញបន្ទប់ គ្រូមិនត្រូវបញ្ជាសិស្សនូវអ្វីដែលសិស្សត្រូវសរសេរ ឬ គូររូបភាពឡើយ ។ ក៏ប៉ុន្តែគ្រូជាអ្នកបញ្ចេញគំនិតបែបសន្ទនាជួយអោយសិស្សនឹកឃើញខ្លួនឯង ។
  <u>ឧទាហរណ៍</u> : គ្រូមិនគួរនិយាយ

  " *ឥលូវលោកគ្រូសូមអោយប្អូន ៗ សរសេរពាក្យ ផ្ទះ លើរូបភាពរបស់អ្នក* " ។ ក៏ប៉ុន្តែគ្រូអាចប្រើពាក្យបែបសន្ទនា ចចារ " *ល្អណាស់នេះជាផ្ទះស្អាត ដែលប្អូនបានគូរ... តើប្អូនបានស្គាល់ព្យញ្ជនៈអ្វីដែលផ្តើមពាក្យផ្ទះ...............*

  *ល្អណាស់ ព្យញ្ជនៈ " ផ " ឥឡូវសូមប្អូនសរសេរពាក្យ ផ្ទះ អោយបានពេញលេញ... ប្រហែលអ្នកនៅជុំវិញខ្លួនប្អូនជួយបន្ថែមទៀត... ប្អូន ៗ ទាំងអស់ក្នុងក្រុមនេះអាចជួយគ្នាទៅវិញទៅមកក្នុងការសរសេរពាក្យ ដែលទាក់ទងនឹងរូបភាពរបស់ប្អូន ។ ប្អូនកុំព្រួយអ្វីប្រសិនបើប្អូនពិបាកសរសេរពាក្យនេះ តែគួរប្អូនខំប្រឹងធ្វើអោយបានល្អ* "

- វាជាការសំខាន់ដែលគ្រូចេះតែងសំណួរ និង បញ្ចេញគំនិតដែលសមស្របទៅនឹងកម្រិតសមត្ថភាពរបស់សិស្សម្នាក់ ៗ ។ <u>ឧទាហរណ៍</u> : ប្រសិនបើសិស្សម្នាក់មានការលំបាកក្នុងការសរសេរព្យញ្ជនៈ មិនគួរអោយសិស្សនេះព្យាយាមសរសេរឈ្មោះពេញលេញ ។ ក៏ប៉ុន្តែគ្រូអាចអោយសិស្សនេះសរសេរព្យញ្ជនៈតាមវត្ថុផ្សេង ៗ ក្នុងរូបភាព ឬ គ្រាន់តែគូរវត្ថុ ឬ មនុស្សថែមទៀតក្នុងរូបភាព ។ ក្នុងករណីផ្សេង ប្រសិនបើ សិស្សផ្សេង ៗ ទៀតងាយស្រួលក្នុងការសរសេរពាក្យ និង មានបំណិនការអានល្អ គ្រូគួរតែជំរុញអោយសិស្សប្រភេទនេះព្យាយាមសាកល្បងសរសេរឈ្មោះវែង ៗ ដែលគេអាចធ្វើបាន

- ខាងក្រោមនេះ ជាឧទាហរណ៍មួយចំនួននៃ <u>*ពាក្យផ្តើម*</u> ដែលគ្រូអាចប្រើក្នុងលំហាត់នេះ ÷

*" ល្អណាស់ ! រូបភាពនេះប្អូនគូរដូចរូបប្អូន ឥឡូវសូមនិយាយប្រាប់លោកគ្រូ តើអ្នកណារស់នៅជាមួយប្អូនក្នុងផ្ទះនេះ ? តើប្អូនអាចគូររូបមនុស្សម្នាក់ទៀតដែលនៅផ្ទះជាមួយប្អូនបានដែរឬទេ ? "*

*" អូ ! នេះជារូបភាពល្អណាស់ តើប្អូនអាចព្យាយាមសរសេរឈ្មោះប្អូននៅខាងក្រោមរូបភាពនេះបានទេ ? "*

*" តើផ្ទះនេះជាផ្ទះរបស់ប្អូនឬ ? ប្អូនគូរបានល្អហើយ តើប្អូនអាចសរសេរពាក្យផ្ទះបានដែរឬទេ ? ប្រហែលមិត្តប្អូនក្នុងក្រុមជួយ កុំព្រួយ បើប្អូនសរសេរខុស " ។*

*" រូបភាពនេះបង្ហាញអំពីប្អូនកំពុងអង្គុយនៅក្នុងបន្ទប់រៀនមែន ទេ ? តើរូបនេះជានរណាដែលអង្គុយជិតប្អូន ? ។ តើនេះជា សុខា មែនទេ ? តើប្អូនអាចសាកល្បងសរសេរឈ្មោះប្អូន និង ឈ្មោះ សុខា លំមើល ? ប្រហែល សុខា អាចជួយប្អូនក្នុងការសរសេរឈ្មោះរបស់គេ " ។*

- នៅជិតចុងបញ្ចប់នៃឆ្នាំសិក្សា គ្រូអាចប្រើពាក្យផ្តើមដែលជំរុញអោយសិស្សសាកល្បងនូវការបញ្ចេញលទ្ធផលស្នាដៃដែលមានកម្រិតខ្ពស់ជាងដើមឆ្នាំសិក្សា ប្រសិនបើគ្រូយល់ថា សិស្សអាចធ្វើបាន ។ <u>ឧទាហរណ៍</u> :

*" អូ ! ខ្ញុំមើលឃើញថា ក្នុងរូបភាពនេះប្អូនកំពុងធ្វើដំណើរទៅសាលារៀន តើប្អូនអាចព្យាយាមសាកល្បងសរសេរ "**ខ្ញុំកំពុងទៅសាលារៀន**" នៅខាងក្រោមរូបភាព " បានទេ ?*

*" តើប្អូនអាចសាកល្បងគូររូបភាពបង្ហាញអំពីអ្វី ៗ ដែលប្អូនបានធ្វើនៅសាលាក្នុងសប្តាហ៍នេះ ? ជ្រើសរើសពាក្យក្នុងប្រអប់ធនាគារពាក្យ ដើម្បីងាយស្រួលសម្រាប់ប្អូនសរសេរល្បះនោះ" ។*

### *១.១.៤ <u>ការពិចារណាលើស្នាដៃសិស្សក្នុងសីមី</u>*

- លំហាត់មួយ ដែលមានសារសំខាន់ក្នុងការប្រើប្រាស់កម្រងស្នាដៃសិស្ស គឺការជួយ ផ្តល់ឱកាស អោយសិស្សពិចារណា និងរំលឹកឡើងវិញអំពីអ្វី ៗ ដែលគេបានធ្វើ ។ សម្រាប់ថ្នាក់ទី ១ ល្បិចមួយដែលងាយធ្វើក្នុងការជួយដល់សិស្សអោយគេចេះពិចារណា គឺការផ្តល់ឱកាសអោយសិស្សម្នាក់ ៗ និយាយអំពីការងាររបស់គេ ។ គ្រូអាចប្រើវិធីផ្សេង ៗ ដើម្បីបំផុសការនិយាយរបស់សិស្ស ។ វិធីនេះ អាចជួយពង្រឹងភាសាខ្មែរលើបំណិននិយាយ ( នេះជាកត្តាគន្លឹះមួយនៃការសិក្សាភាសាខ្មែរថ្នាក់ទី ១ ) ។

ក) គ្រូដើរជុំវិញបន្ទប់ និង ចាប់ផ្តើមចរចាជាមួយសិស្សអំពីការងាររបស់គេ ។ <u>ឧទាហរណ៍</u> :

*" តើនេះជាអ្នកណាក្នុងរូបភាពរបស់ប្អូន ? "*

*" តើបងស្រីរបស់ប្អូនមានអាយុប៉ុន្មាន ? "*

*" តើតាប្អូនរស់នៅភូមិណា ? "*

*" តើមានមនុស្សប៉ុន្មាននាក់រស់នៅជាមួយប្អូននៅផ្ទះ ? "*

*" តើមិត្តណាខ្លះនៅក្រុមនេះរស់នៅជិតផ្ទះប្អូន ? "*

ខ) ជួយអោយសិស្សនឹកឃើញកំហុសរបស់គេ ជាជាងកែលំអកំហុសត្រង់ ៗ ទៅគេ ។ ឧទាហរណ៏ :

*" ល្អណាស់ សុខា ! លោកគ្រូបានឃើញថា ប្អូនបានព្យាយាមសរសេរពាក្យ ( ផ្ទះ ) វាជិតត្រូវហើយ ឥឡូវសូមប្អូនប្រកបពាក្យ ( ផ្ទះ ) អោយគ្រូស្តាប់ . . . ល្អណាស់ ។ ឥឡូវគ្រូចង់ដឹងថា តើមានប្អូនណាខ្លះទៀតខិតខំប្រឹងប្រែងការងារដូច សុខា ? "*

គ) សិស្សចាប់ដៃគូ និយាយអំពីរូបភាពរបស់គេទៅវិញទៅមករយៈពេល ២ ទៅ ៣ នាទី ។ គ្រូអាចចាប់ផ្តើមសកម្មភាពនេះដូចតទៅ ÷

*" ល្អណាស់ ! យើងឃើញថា ប្អូនបានបញ្ចប់ការគូររបស់ប្អូនអស់ហើយ សូមប្អូនចាប់ដៃគូ រួចបង្ហាញរូបភាព និង និយាយប្រាប់គេអំពីអ្វីដែលប្អូនបានគូរ និង សរសេរ "*

ឃ) សិស្ស ២ ទៅ ៣ នាក់ ស្ម័គ្រចិត្តនិយាយអំពីការងារស្នាដៃរបស់គេអោយសិស្សទាំងអស់ក្នុងថ្នាក់ស្តាប់ ។

- ជាការសំខាន់ផងដែរថាសិស្សអាចដឹងថា ខ្លួនគេកំពុងតែមានការរីកចំរើនលើបានច្រើនជាងមុន ។ ពេលដែលគ្រូដើរជុំវិញបន្ទប់ គ្រូគួរតែចង្អុលបង្ហាញចំណុចខ្លាំងហើយថ្មី ៗ ដែលសិស្សធ្វើក្នុងលំហាត់នេះ ដែលកន្លងមកគេមិនអាចធ្វើបាន ។

  *" ប្អូនសង្កេតឃើញថា គំនូររបស់ប្អូនបានល្អជាងខែមុន "*

  *" ខែនេះប្អូនចេះសរសេរឈ្មោះខ្លួនដោយគ្មានគ្រូជួយ "*

  *" តើប្អូនដឹងទេ ខែនេះប្អូនអាចសរសេរបានពាក្យច្រើន " ។*

  ជួនកាលគ្រូជួបការលំបាកក្នុងថ្នាក់ដែលមានសិស្សច្រើន ដើម្បីសរសើរសិស្សម្នាក់ ៗ ។ ទោះបីជាយ៉ាងណាក៏ដោយពាក្យសរសើររបស់គ្រូមានតម្លៃខ្ពស់សម្រាប់សិស្ស ។ ដូច្នេះគ្រូគួរតែចងចាំថា ពេលបង្រៀនកន្លង មកក្នុងសប្តាហ៏ គាត់ធ្លាប់បានលើកសរសើរសិស្សបានច្រើនដែរឬទេ ? ។

- សិស្សនៅថ្នាក់ទី ១ មានការលំបាកក្នុងការប្រៀបធៀបស្នាដៃរបស់គេ ។ ដូច្នេះយើងមិនគួរអោយសិស្សឆ្លើយសំណួរដែល

សួររបៀបប្រៀបធៀប ដូចជា ÷

*" តើប្អូនឃើញមានការរីកចំរើនអ្វីខ្លះពីស្នាដៃមួយនេះទៅស្នាដៃខែមុន " ?* ក៏ប៉ុន្តែលោកគ្រូអាចសួរសំណួរជាទូទៅ អោយសិស្សស្ម័គ្រចិត្តឆ្លើយ

*" តើប្អូនមួយណាអាចប្រាប់គ្រូអំពីការងារថ្មីដែលប្អូនបានធ្វើសម្រាប់ពេលឥឡូវនេះ "*

- ការប្រើប្រាស់កម្រងស្នាដៃសិស្សអាចមានផលប្រយោជន៍ក្នុងការជួយកែលំអស្នាដៃដែលមិនទាន់ល្អ ។ ក៏ប៉ុន្តែគ្រូត្រូវតែប្រុងប្រយ័ត្នក្នុងការនិយាយអំពីការងារមិនល្អនាំអោយសិស្សបាក់ទឹកចិត្ត

- គ្រូមិនគួរអោយសិស្សឆ្លើយសំណួរ " *ប្អូនប្រាប់លោកគ្រូបានទេអំពីអ្វីដែលប្អូនធ្វើមិនបានល្អ ?* " ។ ក៏ប៉ុន្តែគ្រូអាចអោយសិស្សបញ្ចេញគំនិតយោបល់ដោយសួរថា ÷

*" ពេលដែលប្អូន ៗ គូរ និង សរសេរ រូបភាពនៅពេលក្រោយ តើប្អូន ៗ ចង់បន្ថែមគំនិតថ្មី ៗ អ្វីខ្លះទៀតលើរូបភាពរបស់ប្អូន ? សូមប្អូន ៗ ទាំងអស់គ្នាបិទភ្នែកគិតស្រមៃដល់រូបភាពសម្រាប់ពេលក្រោយ " ។*

- ម្យ៉ាងទៀត គ្រូត្រូវចេះរៀបចំបញ្ជីខ្លី ៗ នៃកំហុសជាទូទៅដែលលោកគ្រូបានសង្កេតឃើញក្នុងស្នាដៃរបស់សិស្ស ។ គ្រូអាចលើកកំហុសនេះជាមួយសិស្សទាំងអស់គ្នា ធ្វើដូចនេះបានន័យថា គ្រូបំភ្លឺកំហុសជាជាងបំភ្លឺអ្នកធ្វើកំហុសផ្ទាល់តែម្តង ។ <u>ឧទាហរណ៍</u> : ប្រសិនបើលោកគ្រូបានឃើញថា សិស្សច្រើននាក់បានសរសេរពាក្យ " ផ្ទះ " ខុស គ្រូអាចបំភ្លឺកំហុសនេះនៅលើក្តារខៀនរយៈពេល ១ ទៅ ២ នាទី

*" ឥឡូវលោកគ្រូចង់អោយប្អូន ៗ ទាំងអស់ចងចាំពេលដែលយើងសរសេរពាក្យ ផ្ទះ កុំភ្លេចដាក់ជើង ( ្ ) ។ ឥឡូវតើប្អូនណាខ្លះហ៊ានសាកល្បងសរសេរពាក្យ ផ្ទះ លើក្តារខៀន ។ "*

## *១.២ យុទ្ធវិធីរៀបចំសឺមីស្នាដៃសិស្សថ្នាក់ទី ២*

### *<u>១.២.១ តើអ្នកណាជាអ្នកជ្រើសរើសស្នាដៃសិស្សចូលសឺមី ?</u>*

- ដោយសារសិស្សអាយុតិចពេក គ្រូគួរតែទទួលខុសត្រូវក្នុងការប្រមូល និង បញ្ចូលស្នាដៃសិស្សក្នុងសឺមី ។ ម្យ៉ាងទៀតគ្រូគួរតែសរសេរកាលបរិច្ឆេទ ។ គ្រូគួរតែត្រួតពិនិត្យមើលថាសិស្សទាំងអស់បានសរសេរឈ្មោះរបស់ខ្លួនលើស្នាដៃហើយឬនៅ ? ។

*១.២.២ ប្រភេទស្នាដៃ :*

- ការបំពេញពាក្យតាមចន្លោះឃ្លា ឬ ល្បះ
- ការសរសេរល្បះដោយគំនិតច្នៃប្រឌិត និង គូររូបភាព
- ឆ្លើយសំណួរអំពីអត្ថន័យរបស់ខ្លឹមសារអត្ថបទក្នុងសៀវភៅសិក្សា
- សរសេរការពិពណ៌នាអំពីពតិមានប្រចាំថ្ងៃ និង គូររូបភាព
- សរសេរការពិពណ៌នាអំពីពតិមានប្រចាំថ្ងៃ ដោយប្រើទម្រង់បំពេញល្បះដូចខាងលើ ហើយអោយសិស្សសាកល្បងថែមល្បះ មួយ ឬ ពីរ ល្បះទៀត ដោយប្រើគំនិតច្នៃប្រឌិតរបស់គេ
- សរសេរការពិពណ៌នាពតិមានប្រចាំថ្ងៃ ដោយខ្លួនឯង ( គ្មានជំនួយពីគ្រូ ) និង គូររូបភាព ។

| ពតិមានប្រចាំថ្ងៃ |
|---|
| ថ្ងៃនេះជាថ្ងៃ . . . ។ |
| ថ្ងៃនេះ . . . ណាស់ ។ |
| ម្សិលមិញខ្ញុំបានទៅ . . . ។ |
| ម្តាយខ្ញុំបានទិញ . . . ។ |

- យើងសូមជូនជាយោបល់ គ្រូគួរតែកំណត់ពេលវេលាជាក់ស្តែងក្នុងចុងបញ្ចប់រៀងរាល់សប្តាហ៍សម្រាប់ការប្រើប្រាស់កម្រងស្នាដៃសិស្ស ។ សិស្សធ្វើការងារតាមខ្លឹមសារដែលគ្រូបានបង្រៀនក្នុងសប្តាហ៍នីមួយៗ ( ដូចឧទាហរណ៍ខាងលើ ) ដើម្បីជ្រើសរើសបញ្ចូលក្នុងសឺមី ។ ក្នុងសប្តាហ៍សិស្សអាចហាត់សរសេរ និង ហាត់គូរលើក្តារឆ្នួន ឬ អាចប្រើសម្ភារផ្សេងទៀតដែលគ្រូយល់ថាសមស្រប ។ នៅចុងបញ្ចប់សប្តាហ៍ គ្រូចែកជូនក្រដាសមួយសន្លឹកដល់សិស្សម្នាក់ៗ ។សិស្សគូរ ឬ សរសេរលើក្រដាសនេះដោយប្រើសមត្ថភាពដែលគេមានស្រាប់ ។ បន្ទាប់មកគ្រូត្រួតពិនិត្យ តើសិស្សបានសរសេរឈ្មោះ និងកាលបរិច្ឆេទ ហើយនិងយកក្រដាសនោះបញ្ចូលក្នុងសឺមី ។ ស្នាដៃនេះជាការឆ្លុះបញ្ចាំងលទ្ធផលនៃការសិក្សារបស់សិស្សម្នាក់ ៗ ក្នុងសប្តាហ៍នោះ ។

*១.២.៣ ការរៀបចំសេចក្តីព្រាងគំនិត*

- សម្រាប់ផ្នែកនេះ គ្រូអាចប្រើវិធី ដូចដែលបានរៀបរាប់ខាងលើសម្រាប់ថ្នាក់ទី ១ ដោយអោយសិស្សធ្វើលំហាត់មួយនៅចុងបញ្ចប់ខែនីមួយ ៗ ដោយប្រើពាក្យ " ខ្ញុំ " ឬ ឈ្មោះ ។ ក៏ប៉ុន្តែសម្រាប់ថ្នាក់ទី ២ គ្រូគួរតែសង្កត់ធ្ងន់ទៅលើសំណេរច្រើនជាងគំនូរ ។ ជាការសំខាន់ផងដែរ ថាគ្រូត្រូវចាប់អារម្មណ៍លើគំនិតសរសេររបស់សិស្ស ។ គ្រូមិនគួរសង្កត់ធ្ងន់លើការសរសេរ ឬ ប្រកបពាក្យត្រឹមត្រូវបានច្រើនពេកនោះទេ ។ សិស្សមានសេរីភាពជួយគ្នាទៅវិញទៅមកជាមួយបញ្ហាប្រកប ។ ម្យ៉ាងទៀតគ្រូគួរតែរៀបចំបរិស្ថានក្នុងបន្ទប់រៀន ដោយមានបញ្ជីវាក្យស័ព្ទបិទលើជញ្ជាំង ដែលសមស្របតាមភាសារបស់សិស្សថ្នាក់ទី ២ ។ ឧទាហរណ៍ : គួរតែមានបញ្ជីពាក្យកន្លែងផ្សេង ៗ ក្នុងមូលដ្ឋាន បញ្ជីពាក្យទាក់ទងនិងគ្រួសារ , បញ្ជីពាក្យទាក់ទងនឹងម្ហូបអាហារ , បញ្ជីពាក្យទាក់ទងនឹងមុខរបរ , បញ្ជីពាក្យទាក់ទងនឹងធាតុអាកាស បញ្ជីពាក្យទាក់ទងនឹងពណ៌ និង បញ្ជីគុណនាមងាយ ៗ ។

<u>ចំណាំ</u> : ការប្រកបពាក្យត្រឹមត្រូវមិនមែនជាគោលបំណងនៃសកម្មភាពនេះ ។ គ្រូចង់ជំរុញការច្នៃប្រឌិតរបស់សិស្ស ។ ដូច្នេះ ទោះបីសិស្សសរសេរពាក្យតាមប្រកបមិនត្រឹមត្រូវក៏ដោយ គ្រូមិនគួរធ្វើអោយសិស្សភ័យខ្លាច ឬ ត្រូវមានការបារម្ភឡើយ ។ អ្វីដែលសំខាន់ គឺថាសិស្សមានឱកាសបញ្ចេញគំនិតយោបល់របស់គេ ។ យើងទទួលស្គាល់ថា ការប្រកបពាក្យត្រឹមត្រូវ គឺជារឿងសំខាន់មែន ក៏ប៉ុន្តែគ្រូមានឱកាសសង្កត់ធ្ងន់ទៅលើបញ្ហាប្រកបពាក្យនៅមេរៀនផ្សេង ៗ ទៀត ។ ជាការពិត ពេលដែលគ្រូអោយសិស្សសរសេរដោយសេរី គ្រូអាចមានការយល់ដឹងកាន់តែច្បាស់អំពីបញ្ហាប្រកបដែលសិស្សជួបប្រទះ ហើយគាត់អាចរៀបចំមេរៀនជាក់ស្តែងមួយ ដើម្បីដោះស្រាយបញ្ហានោះ ។ អោយសិស្សធ្វើខុស ដោយគ្មានភ័យខ្លាច គឺជាកត្តាសំខាន់មួយក្នុងវិធីវាយតម្លៃជាដំណាក់ៗ ។

### *១.២.៤ <u>ការពិចារណាស្នាដៃសិស្សក្នុងសឺមី</u>*

- គ្រូថ្នាក់ទី ២ អាចប្រើវិធីស្រដៀង និង គ្រូថ្នាក់ទី ១ ដូចបានរៀបរាប់ខាងលើ ។

## *១.៣ យុទ្ធវិធីរៀបចំកម្រងស្នាដៃសិស្សថ្នាក់ទី ៥ និង ថ្នាក់ទី ៦*

### *១.៣.១ <u>តើអ្នកណាជាអ្នកជ្រើសរើសស្នាដៃសិស្សចូលសឺមី ?</u>*

- នៅថ្នាក់ទី ៥ និង ថ្នាក់ទី ៦ សិស្សមានបំណិនទាក់ទងនឹងការសរសេរព្យញ្ជនៈ ពាក្យ និង ប្រកប រួចមកហើយ ព្រមទាំងគេចេះសរសេរ ល្បះ ឬ ឃ្លា ងាយ ៗ ។ ដូច្នេះយើងសង្ឃឹមថា ស្នាដៃរបស់សិស្សម្នាក់ ៗ អាចមានលក្ខណៈខុស ៗ គ្នា ។ គ្រូគួរតែជំរុញអោយមានភាពខុសគ្នានេះ កុំអោយសិស្សចម្លងគំនិតយោបល់ពីគ្នា ឬ ពីគ្រូ ។ ម្យ៉ាងទៀត សិស្សនេះចាប់ផ្តើមមានបំណិនចេះវិនិច្ឆ័យ និង វាយតម្លៃដោយមានសុពលភាពច្រើនជាងសិស្សថ្នាក់ទី ១ និង ថ្នាក់ទី ២ ។ ពេលដែលសិស្សជ្រើសរើសស្នាដៃបញ្ចូលក្នុងសឺមី សិស្សកំពុងអភិវឌ្ឍន៍បំណិនវាយតម្លៃរបស់ខ្លួន ។ ពេលដែលសិស្សឆ្លុះបញ្ចាំងលើការរីកចំរើនរបស់គេ វាគឺជាការសំខាន់ថា សិស្សចេះពិចារណាលើការងារដែលគេពេញចិត្ត និង មិនពេញចិត្ត ។

### *១.៣.២ <u>ប្រភេទស្នាដៃសម្រាប់បញ្ចូលក្នុងសឺមី</u>*

- ខ្លឹមសារក្នុងសឺមីរបស់សិស្សថ្នាក់ទី ៥ និង ថ្នាក់ទី ៦ គួរតែឆ្លុះបញ្ចាំងភាពខុសគ្នាក្នុងការច្នៃប្រឌិត និង ការបញ្ចេញគំនិតយោបល់របស់សិស្ស ។ ខ្លឹមសារសមស្របអាចមានដូចតទៅ ÷
    - ការសរសេរកំណត់ហេតុប្រចាំថ្ងៃ
    - ការសរសេរអំពីការទស្សន៍ទាយរឿង ( លំហាត់ជូនខាងក្រោម )
    - ការវិភាគកិច្ចការ និង រៀបចំជំហានក្នុងការអនុវត្តន៍កិច្ចការនេះ ( ឧ . ការដាំបាយ )

- ការគូរគំនូរ
- ការសរសេរសំបុត្រ
- ការឆ្លើយសំណួរស្ដីអំពីការអានសៀវភៅសិក្សា ។

- សិស្សនៅថ្នាក់ទី ៥ និង ថ្នាក់ទី ៦ អាចបំពេញទម្រង់បែបបទ ស្ដីអំពីប្រវត្តិផ្ទាល់ខ្លួនរបស់គេនៅដើមឆ្នាំសិក្សា ។ អាចថែរក្សាទុកទម្រង់នេះក្នុងកម្រងស្នាដៃ ។ យើងផ្ដល់គំរូនៃទម្រង់បែបបទនេះភ្ជាប់ខាងក្រោយឯកសារនេះ ។ គ្រូអាចថតចម្លងទម្រង់នេះសម្រាប់សិស្សរបស់គេ ។ គ្រូអាចកែសម្រួលទម្រង់នេះតាមការយល់ឃើញរបស់គាត់

- ក្នុងការដាក់បញ្ហាអោយសិស្សធ្វើនៅថ្នាក់ទី ៥ និង ថ្នាក់ទី ៦ គ្រូគួរតែបញ្ចូលគំនិតច្នៃប្រឌិតជាជាងគំនិត *ចងចាំ* ។ ពេលដែលគ្រូចង់ដឹងអំពីប្រសិទ្ធភាពនៃកិច្ចការដែលគាត់អោយសិស្សធ្វើ គ្រូអាចវាយតម្លៃស្នាដៃក្នុងសឺមី យោងតាមតាក់សូណូមី ។ នេះជួយអោយគ្រូដឹងថា កិច្ចការដែលគាត់ដាក់អោយសិស្សធ្វើតម្រូវអោយសិស្សនោះ ប្រើបំណិនគិតកម្រិតខ្ពស់ ឬ កម្រិតទាប ។ ជាពិសេសគ្រូគួរតែដាក់បញ្ហាអោយសិស្សធ្វើនៅថ្នាក់ទី ៥ និង ទី ៦ ដោយតម្រូវអោយសិស្សគិតកម្រិតខ្ពស់ ដូចជា ៖
  - គិតដោយវិភាគ ( <u>ឧទាហរណ៍</u> : សិស្សត្រួតពិនិត្យអត្ថបទមួយឡើងវិញ គេអាចញែកបានពីអ្វីដែលជាការពិត និង អ្វីដែលជាគំនិត )
  - គិតដោយច្នៃប្រឌិត ( <u>ឧទាហរណ៍</u> : សិស្សស្ដាប់សេចក្ដីផ្ដើមនៃរឿងមួយ ហើយនឹងប្រើបំណិនច្នៃប្រឌិតរបស់ខ្លួនដើម្បីទស្សន៍ទាយ និង បង្កើតសេចក្ដីបញ្ចប់សមស្របនៃរឿងនេះ )
  - គិតដោយវាយតម្លៃ ( <u>ឧទាហរណ៍</u> : សិស្សបញ្ចេញគំនិតយោបល់អំពីបញ្ហាមួយ ហើយនឹងអាចលើកហេតុផលស្ដីអំពីគំនិតរបស់គេ ដើម្បីបញ្ជាក់អំណះអំណាងសមហេតុសមផល ) ។

ដូចនេះការទុកស្នាដៃក្នុងសឺមី គួរតែឆ្លុះបញ្ចាំងពីគំនិតរបស់សិស្ស ។ មិនគួរបញ្ចូលលំហាត់ដូចជា ការសរសេរអក្សរស្អាត . . . ។ ម្យ៉ាងទៀត គ្រូមិនគួរវាយតម្លៃស្នាដៃដោយគិតអំពីការសរសេរអក្សរល្អ ក៏ប៉ុន្តែត្រូវគិតពីការឆ្លុះបញ្ចាំងលើការរីកចំរើនរបស់សិស្ស ក្នុងការប្រើប្រាស់ភាសាដែលមានលក្ខណៈគិតដោយវិភាគ និង គិតដោយច្នៃប្រឌិត ។

<u>**ចំណាំ**</u> : គ្រូមិនគួរយល់ច្រឡំថា បញ្ហាសរសេរស្អាត ប្រកបត្រឹមត្រូវ និង ប្រើប្រាស់វេយ្យាករណ៍ មិនមែនជាបញ្ហាមិនសំខាន់នោះទេ ។ បញ្ហាដូចនេះវាពិតជាសំខាន់មែន ប៉ុន្តែគ្រូអាចដោះស្រាយបញ្ហានេះដោយមិនចាំបាច់ប្រើប្រាស់កម្រងស្នាដៃសិស្សទេ ។ គ្រូអាចចំណាយពេលវេលាដោយឡែកលើបញ្ហានេះ ក៏ប៉ុន្តែពេលដែលគ្រូចង់វាស់ការរីកចំរើនភាសាខ្មែរក្នុងកម្រងស្នាដៃ គ្រូគួរតែសង្កត់ធ្ងន់ទៅលើកត្តាដូចខាងក្រោម ៖

- ភាពច្បាស់លាស់ និង ភាពសមហេតុសមផលក្នុងការសរសេរគំនិតយោបល់
- លក្ខណៈច្នៃប្រឌិតក្នុងការសរសេរ
- សិស្សហ៊ានបញ្ចេញគំនិតយោបល់របស់ខ្លួន
- សិស្សចេះបញ្ជាក់គំនិតយោបល់របស់គេដោយលើកហេតុផល និង ឧទាហរណ៍ ជាក់ស្តែង ។

- នៅចុងបញ្ចប់សប្តាហ៍ទីមួយ ៗ សិស្សគួរតែជ្រើសរើសស្នាដៃ ពីរ ប្រភេទ របស់គេ ។ ស្នាដៃ មួយ ជាស្នាដៃដែលគេពេញចិត្ត ហើយស្នាដៃមួយទៀតជាស្នាដៃដែលគេមិនពេញចិត្ត ។

*១.៣.៣ <u>ការរៀបចំសេចក្តីព្រាងគំនិត និង ពិចារណាឡើងវិញលើសេចក្តីព្រាង :</u>*

- នៅចុងបញ្ចប់នៃខែនីមួយ ៗ គ្រូគួរតែអោយសិស្សសរសេរអំពីប្រធានបទមួយ ។ បើសិស្សមិនទាន់មានទម្លាប់សរសេរដោយច្នៃប្រឌិត គ្រូអាចជួយបំផុសគំនិតយោបល់ដល់សិស្ស ដោយធ្វើលំហាត់ទាក់ទងទៅនឹងការទស្សន៍ទាយ ។ គ្រូអាចជ្រើសរើសចំណងជើងមួយ ហើយនឹងរៀបចំសេចក្តីផ្តើមនៃរឿងនេះ ដូចខាងក្រោមនេះ ÷

*<u>គ្រោះថ្នាក់ចរាចរ</u> :*

*" ភ្លៀងធ្លាក់យ៉ាងខ្លាំង ។ តាចាស់ម្នាក់គាត់ប្រញាប់ទៅផ្ទះរបស់គាត់វិញ ។ គាត់ត្រូវជូនយាយរបស់គាត់ ដែលឈឺធ្ងន់ធ្ងរទៅមន្ទីរពេទ្យ . . . " ។*

  - គ្រូអាចចាប់ផ្តើមមេរៀននេះ ដោយបំផុសគំនិតយោបល់របស់សិស្សទាក់ទងនឹងពាក្យថា " *គ្រោះថ្នាក់ចរាចរ* " ។ គួរតែកត់ត្រាគំនិតយោបល់របស់សិស្សលើក្តារខៀន ( ទោះបីជាគ្រូយល់តាមគំនិតនេះ ឬ មិនយល់ ) ។ ក្រៅពីនេះ គ្រូអានសេចក្តីផ្តើមដូចខាងលើ ហើយនឹងសុំអោយសិស្សព្យាយាមទស្សន៍ទាយអំពីអ្វី ៗ ដែលអាចកើតមានឡើង ។ សិស្សអាចសរសេរសេចក្តីផ្តើមរបស់គ្រូ ក៏ប៉ុន្តែត្រូវបន្តរឿងនេះរហូតដល់ចប់ ដោយច្នៃប្រឌិត ។

- ជាដំបូង គ្រូអាចសាកល្បងលំហាត់ដូចនេះ ដោយអោយសិស្សធ្វើការជាក្រុម ។ នៅលើកក្រោយៗ សិស្សអាចធ្វើការងារជាដៃគូ ។ ពេលដែលសិស្សមានទម្លាប់ក្នុងការសរសេរច្នៃប្រឌិតហើយ គ្រូអាចអោយគេសរសេរជាបុគ្គល ។ គ្រូគួរតែដាក់លំហាត់បែបនេះអោយសិស្សធ្វើរៀងរាល់ខែ ។ ពេលដែលសិស្សកំពុងធ្វើលំហាត់នេះ គ្រូគួរតែដើរជុំវិញបន្ទប់រៀន ដើម្បីជួយអោយសិស្សកែលំអការងាររបស់គេ ។ ក៏ប៉ុន្តែ គ្រូមិនគួរបញ្ចេញគំនិតយោបល់ទាក់ទងនឹងការសរសេរអក្សរស្អាត

ឬ ប្រកបពាក្យមិនត្រឹមត្រូវនោះឡើយ ក៏ប៉ុន្តែគួរតែសង្កត់ធ្ងន់ទៅលើភាពច្បាស់លាស់ និង លក្ខណៈច្នៃប្រឌិតរបស់សិស្ស ។ គ្រូគួរតែជំរុញអោយសិស្សវិភាគអំពីអ្វីដែលគេបានសរសេរ តាមរយៈការជួយអោយសិស្សរំលឹកឡើងវិញពីកិរិយាស័ព្ទ គុណនាម និង គុណកិរិយា ដែលគេបានប្រើប្រាស់ ។ ដូចនេះគ្រូនៅថ្នាក់ទី ៥ និង ថ្នាក់ទី ៦ អាចប្រើពាក្យដូចជា ÷

*" សុខា ! លោកគ្រូសុំមើលពីអ្វីដែលប្អូនបានសរសេរ <u>ព្រឹកមិញគាត់បានមកផ្សារ</u> , ល្អណាស់ ! ឥឡូវនេះ តើ សុខា បានពិចារណាទេថា តាគាត់ជិះអ្វីមកផ្សារ ? តើគាត់ជិះកង់ ? តើគាត់ដួលតាក់ស៊ី ? តើគាត់ត្រូវដើរ ? (សុខា ឆ្លើយ : **គាត់បានដើរ** ) ប្អូនចង់និយាយថា គាត់បានដើរ ! ឥឡូវប្អូនត្រូវគិតថា គាត់ជាមនុស្សចាស់ បិទភ្នែក និង ស្រមៃមើលលើការធ្វើដំណើររបស់តា តើគាត់ដើរយ៉ាងដូចម្តេច ? លឿន . . . យឺត . . . ។ "*

*" ល្អណាស់ ! ដារ៉ា គ្រូសុំមើលការសរសេររបស់ប្អូនបន្តិច " ។ លោកគ្រូឃើញថា សេចក្តីផ្តើមរបស់ប្អូនល្អណាស់ <u>ស្រីម្នាក់ និង កូនពីរនាក់ បានដើរតាមផ្លូវគ្រឡិចគ្រឡុកមកផ្សារ ។ ភ្លៀងធ្លាក់ខ្លាំងណាស់ . . . ។</u> ឥឡូវនេះ ដារ៉ា តើប្អូនធ្លាប់បានដើរពេលដែលមានភ្លៀងធ្លាក់ខ្លាំងដែរឬទេ ? នៅពេលនោះ តើប្អូនមានអារម្មណ៍យ៉ាងដូចម្តេច ? ពិបាកមើលផ្លូវដែរឬទេ ? ប្អូនចូលជ្រកតាមផ្ទះគេដែរឬទេ ? ក្រោយពីរាំងភ្លៀងមកផ្លូវវាយ៉ាងដូចម្តេច ? ប្រហែល ដារ៉ា អាចឆ្លងគំនិតយោបល់របស់មិត្តក្នុងក្រុម ។ "*

### *១.៣.៤ <u>ការពិចារណាលើស្នាដៃសិស្សក្នុងសីមី</u>*

- គ្រូគួរតែអោយសិស្សថ្នាក់ទី ៥ និង ថ្នាក់ទី ៦ ជ្រើសរើសកិច្ចការដែលគេបានធ្វើក្នុងរយៈពេល ១ សប្តាហ៍ សម្រាប់បញ្ចូលក្នុងសីមី ។ គេគួរតែជ្រើសរើសអ្វីមួយដែលគេពេញចិត្ត ហើយនិងអ្វីមួយដែលគេមិនសូវពេញចិត្ត ។ គ្រូអាចប្រើវិធីដូចវិធីសម្រាប់ថ្នាក់ទី ១ និង ថ្នាក់ទី ២ ដែលត្រូវបានរៀបរាប់ខាងលើដើម្បីជំរុញអោយសិស្សពិចារណាលើស្នាដៃរបស់គេ ។ សិស្សគួរតែមានឱកាស ១ សប្តាហ៍ម្តងនិយាយអំពីការងាររបស់គេរយៈពេល ២ ឬ ៣ នាទី ជាមួយក្រុមគេឬថ្នាក់ទាំងមូល ។ សិស្សផ្សេងទៀតគួរតែមានឱកាសសួរសំណួរអំពីកិច្ចការនេះ ។ ធ្វើដូចនេះ ធ្វើអោយសិស្សដែលបង្ហាញស្នាដៃពិចារណាពីស្នាដៃរបស់ខ្លួន ។ ម្យ៉ាងទៀតពេលដែលសិស្សផ្សេងទៀតសួរសំណួរ សិស្សនេះប្រហែលជាពិចារណាលើស្នាដៃរបស់គេដែលបានធ្វើ

- វិធីពិចារណាលើស្នាដៃក្នុងថ្នាក់ទី ៥ និង ថ្នាក់ទី ៦ អាចមានរចនាសម្ព័ន្ធដែលមានលក្ខណៈច្បាស់ជាងថ្នាក់ទី ១ និង ទី ២ ។ ជាប្រចាំខែលទ្ធផលនៃការពិចារណាអាចកត់ត្រាលើទម្រង់បែបបទ ។ ទម្រង់បែបបទនេះអាចបញ្ចូលក្នុងកម្រងស្នាដៃផងដែរ ខាងក្រោមនេះមានទម្រង់បែបបទគំរូមួយ

**<u>ទម្រង់ពិចារណាប្រចាំខែ</u>**

ឈ្មោះសិស្ស : ................................................ ថ្នាក់ទី : ............................................

កាលបរិច្ឆេទ : ................................................ ឈ្មោះមិត្តខ្ញុំ : ..................................

១. ចូររៀបរាប់អំពីអ្វីមួយដែលប្អូនបានធ្វើ ឬ បានរៀននៅសាលាក្នុងខែកន្លងមកដែលប្អូនចាប់អារម្មណ៍ខ្លាំង ?

........................................................................................................................................

........................................................................................................................................

២. ចូរជ្រើសរើសស្នាដៃមួយដែលប្អូនពេញចិត្តចេញពីសឺមីរបស់ប្អូន ចូររៀបរាប់អំពីអ្វីដែលប្អូនបានជ្រើសរើសមកនេះ ?

........................................................................................................................................

........................................................................................................................................

៣. ចូរប្អូនពន្យល់ហេតុអ្វីបានជាប្អូនពេញចិត្តស្នាដៃនេះ ?

........................................................................................................................................

........................................................................................................................................

៤. ចូរជ្រើសរើសស្នាដៃមួយដែលប្អូនមិនពេញចិត្តចេញពីសឺមីរបស់ប្អូន។ ចូររៀបរាប់ពីអ្វីដែលប្អូនបានជ្រើសរើសមកនេះ?

........................................................................................................................................

........................................................................................................................................

៥. ចូរប្អូនពន្យល់ហេតុអ្វីបានជាប្អូនមិនពេញចិត្តស្នាដៃនេះ ?

........................................................................................................................................

........................................................................................................................................

៦. ចូរប្អូនមើលស្នាដៃក្នុងសឺមីមិត្តភក្តិរបស់ប្អូន ។ ចូរសួរសំណួរទៅមិត្តភក្តិរបស់ប្អូនពីអ្វីដែលគេបានគូរ ឬ សរសេរ ? សរសេរសំណួរដែលប្អូនបានសួរដាក់ខាងក្រោមនេះ ។

........................................................................................................................................

........................................................................................................................................

៧. សរសេរចម្លើយរបស់មិត្តភក្តិប្អូន

........................................................................................................................................

........................................................................................................................................

៨. សុំអោយមិត្តភក្តិរបស់ប្អូនអានចម្លើយក្នុងទម្រង់បែបបទនេះ ។ តើមិត្តភក្តិរបស់ប្អូនអាចជួយកែកំហុសខ្លះ ១ មួយចំនួនបានឬទេ ? អោយមិត្តរបស់ប្អូនចុះហត្ថលេខាក្នុងប្រអប់ខាងក្រោមនេះ ។

## ឯកសារទី៤: ការស្វែងយល់បន្ថែមលើការប្រើប្រាស់កម្រងស្នាដៃសិស្ស

### ១. ទំនាក់ទំនងរវាងការប្រើប្រាស់កម្រងស្នាដៃសិស្សនិងការវាយតម្លៃបែបបូកសរុប ( **Summative** )

- ការប្រើប្រាស់កម្រងស្នាដៃសិស្ស គឺជាវិធីមួយដើម្បីពង្រឹងប្រសិទ្ធភាព នៃការវាយតម្លៃបែបបូកសរុប ។ គ្រូមិនគួរច្រឡំ ថា ការប្រើប្រាស់កម្រងស្នាដៃសិស្ស ជាវិធីជំនួស វិធីវាយតម្លៃបែបបូកសរុបនោះទេ

- កម្រងស្នាដៃសិស្ស ជាឯកសារដែលបង្ហាញអំពីលទ្ធផលនិងការរីកចំរើនក្នុងការរៀនសូត្ររបស់សិស្សយ៉ាងទៀងទាត់ ។ ដូច្នេះ គ្រូអាចប្រៀបធៀបលទ្ធផលនៃការវាយតម្លៃបែបបូកសរុប (ដែលជាពិន្ទុនៃតេស្តដែលធ្វើក្នុងពេលតែមួយ) ទៅនឹងលទ្ធផល ដែលបានទទួលជារៀងរហូតមក ( ស្នាដៃសិស្សក្នុងសឺមី ) ធ្វើដូចនេះអាចបញ្ជាក់និងបំភ្លឺបញ្ហាដែលទាក់ទងនឹងភាពសមស្រប និងសុពលភាពនៃតេស្តក្នុងការវាយតម្លៃបូកសរុប

- កម្រងស្នាដៃសិស្សផ្តល់លទ្ធផលនៃការរៀនសូត្រជាប្រចាំ និង ជាឯកសារដែលអាចជួយគ្រូអោយយល់និងពន្យល់លទ្ធផលនៃ ការវាយតម្លៃបែបបូកសរុប ។ ដូចនេះកម្រងស្នាដៃសិស្សអាចប្រើជាខ្លឹមសារសម្រាប់ការពិភាក្សារវាងគ្រូនិងឪពុកម្តាយពេល ដែលគ្រូចង់ពន្យល់អំពីពិន្ទុទាបរបស់សិស្សក្នុងលទ្ធផលតេស្ត ។ ឪពុកម្តាយអាចមានការពិបាកយល់អំពីពិន្ទុតេស្តហើយនិង ពិបាកយល់ទៀតអំពីបញ្ហាដែលកូនរបស់គេជួបប្រទះដោយសារពិន្ទុតេស្តនេះមានលក្ខណៈអរូបី ។ ក៏ប៉ុន្តែស្នាដៃសិស្សក្នុងសឺមី គឺជាលទ្ធផលជាក់ស្តែងដែលគ្រូអាចបង្ហាញដើម្បីបំភ្លឺបញ្ហារបស់កូនគាត់នោះ ។

### ២. ការប្រើប្រាស់កម្រងស្នាដៃសិស្សបន្តទៅថ្នាក់លើ

- គ្រូប្រចាំថ្នាក់ ហើយនិងសិស្ស គួរតែពិភាក្សាជាមួយគ្នាអំពីអ្វីដែលគេចង់ធ្វើជាមួយកម្រងស្នាដៃនៅចុងបញ្ចប់ឆ្នាំសិក្សា ។ ទោះបីជាយ៉ាងណាក៏ដោយ ប្រសិនជាគ្មានគំនិតយោបល់ល្អ ៗ ទេ យើងជូនជាយោបល់ថា សិស្សគួរតែយកសឺមីស្នាដៃ របស់ខ្លួនទៅផ្ទះថែរក្សាទុក លុះដល់ដើមឆ្នាំសិក្សាថ្មីយកមកថ្នាក់រៀនវិញ

- ក៏ប៉ុន្តែប្រហែលជា គ្រូ និង សិស្ស អាចសាកល្បងគំនិតដូចតទៅ ។ សិស្សទាំងអស់ជ្រើសរើសស្នាដៃរបស់គេមួយចំនួនតូច ដែលគេពេញចិត្ត ហើយប្រមូលស្នាដៃទាំងអស់នេះបញ្ចូលទៅក្នុងក្រឡុចធំ ( សម្រាប់មួយថ្នាក់មួយក្រឡុ ។ គ្រូ និង សិស្ស គួរតែប្រើគំនិតច្នៃប្រឌិតរបស់ខ្លួន ដើម្បីរៀបចំការបង្ហាញស្នាដៃនេះអោយបានស្អាត ។ គួរតែរៀបចំក្របសម្រាប់ក្រឡុដោយ គួររូបភាព និង ដាក់ចំណងជើង ដូចជា " ***កិច្ចការរបស់យើងនៅថ្នាក់ទី . . . ឆ្នាំសិក្សា . . .*** " ក្នុងឆ្នាំសិក្សាថ្មីបន្ទាប់អាច ដាក់ក្រឡុនេះនៅជ្រុងបណ្ណាល័យក្នុងថ្នាក់ ។ បើធ្វើដូចនេះរៀងរាល់ឆ្នាំសិស្សណាដែលចាប់ផ្តើមប្រើកម្រងស្នាដៃសិស្សចាប់

ពីថ្នាក់ទី ១ នឹងមានក្រូណូស្នាដៃសិស្សចំនួន ៥ ពេលដែលគេរៀននៅថ្នាក់ទី ៦ ។ ពេលដែលសិស្សនេះឆ្លងភូមិសិក្សាអាចថែរក្សាក្រូណូទាំងអស់របស់គេក្នុងបណ្ណាល័យសាលារៀន

- នៅពេលដែលសិស្សឡើងថ្នាក់នៅដើមឆ្នាំសិក្សា គ្រូចាស់ និង គ្រូថ្មីរបស់គេ គួរតែប្រជុំជាមួយគ្នា ។ គ្រូចាស់អាចប្រើប្រាស់កម្រងស្នាដៃសិស្សម្នាក់ ៗ ឬ ក្រូណូធំស្នាដៃសិស្ស ដើម្បីបង្ហាញអំពីសកម្មភាពដែលសិស្សបាន អនុវត្តឆ្នាំកន្លងមក ។ ម្យ៉ាងទៀត គ្រូចាស់អាចបញ្ជាក់អំពីសេចក្តីត្រូវការរបស់សិស្សដែលរៀនយឺតជាងគេ ។ ធ្វើដូចនេះអាចជួយគ្រូថ្មីរៀបចំកិច្ចតែងការបង្រៀន ឬ *លំនាំគោលគំនិត* ដែលឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់សិស្ស ។ គណៈកម្មការកម្រង និង ប្រធានក្រុមបច្ចេកទេសគួរតែកំណត់កាលបរិច្ឆេទពិសេសសម្រាប់កិច្ចប្រជុំនេះដើម្បីអោយការងារប្រកបដោយប្រសិទ្ធភាព

- គ្រូទាំងអស់អាចពិនិត្យមើលសកម្មភាពដែលបង្ហាញក្នុងសឺមីស្នាដៃសិស្ស ដែលជាប្រភពប្រមូលគំនិតយោបល់ និង បទពិសោធន៍ផ្សេង១ សម្រាប់ការបង្រៀនរបស់គេ ។ ប្រភពពត៌មាននេះអាចមានផលប្រយោជន៍ពិសេសសម្រាប់គ្រូទើបតែចេញថ្មីពីសាលាគរុកោសល្យ ឬ សម្រាប់គ្រូ ដែលមិនបានបង្រៀនកម្រិតថ្នាក់នេះកាលពីឆ្នាំមុន ។

### ៣. ទំនាក់ទំនងរវាងកម្រងស្នាដៃសិស្ស និង សកម្មភាពផ្សេង ៗ ក្នុងបញ្ជីសេវាកម្មសាលាកុមារមេត្រី

- *ថ្នាក់សាកល្បងសាលាកុមារមេត្រី :*

  ការប្រើប្រាស់កម្រងស្នាដៃសិស្ស គឺជាសកម្មភាពចម្បងក្នុងថ្នាក់មេត្រី ។

- *ការសិក្សាបែបសហការ :*

  សឺមីស្នាដៃសិស្សអាចប្រើប្រាស់ជាខ្លឹមសារសម្រាប់បំផុសការពិភាក្សារវាងសិស្សនិងសិស្សអំពីសកម្មភាពសិក្សា ។ ម្យ៉ាងទៀតសិស្សអាចជួយគ្នាទៅវិញទៅមក និង ជួយកែលំអការងាររបស់ខ្លួន ។

- *ថ្នាក់បំប៉នសិស្សបន្ថែម :*

  ការប្រើប្រាស់កម្រងស្នាដៃសិស្សអាចមានទំនាក់ទំនង ២ យ៉ាង ជាមួយថ្នាក់បំប៉នសិស្សបន្ថែម ។ វាអាចជួយអោយគ្រូស្គាល់សិស្សណាខ្លះដែលត្រូវការជំនួយបំប៉នបន្ថែម មុននឹងកំណត់សិស្សដោយពឹងផ្អែកទៅលើពិន្ទុតេស្តវាយតម្លៃបែបបូកសរុប ។ ម្យ៉ាងទៀតគ្រូប្រចាំថ្នាក់អាចប្រើកម្រងស្នាដៃសិស្ស ដើម្បីបង្ហាញចំណុចខ្សោយរបស់សិស្ស ។ ធ្វើដូចនេះអាចជួយអោយគ្រូថ្នាក់បំប៉នបន្ថែមរៀបចំមេរៀនដោយសង្កត់ធ្ងន់កាន់តែច្បាស់លើសេចក្តីត្រូវការរបស់សិស្ស

- *ការសង្កេតថ្នាក់របស់ប្រធានក្រុមបច្ចេកទេស :*

  ពេលដែលប្រធានក្រុមបច្ចេកទេសសង្កេតការបង្រៀនរបស់គ្រូ ប្រធានក្រុមបច្ចេកទេសអាចផ្តល់ពត៌មានត្រឡប់អំពី

មេរៀនដែលគាត់បានសង្កេត ។ ក៏ប៉ុន្តែប្រសិនជាមានសីមីស្នាដៃសិស្សក្នុងថ្នាក់ប្រធានក្រុមមានឱកាសផ្តល់ពត៌មានត្រឡប់ដល់គ្រូអំពីសកម្មភាពប្រចាំថ្ងៃដែលគាត់មិនបានសង្កេត

- <u>ទស្សនកិច្ចរបស់មាតាបិតាសិស្សនៅសាលារៀន</u> :

នៅចុងបញ្ចប់ឆមាស ឬ ដំណាច់ឆ្នាំសិក្សា គ្រូអាចរៀបចំកម្រងស្នាដៃសិស្សបង្ហាញដល់មាតាបិតាសិស្ស ។ សម្រាប់សកម្មភាពនេះសិស្សគួរតែរៀបចំក្របស្អាតសម្រាប់សីមីរបស់គេ

- <u>ការខ្សៀនជូនពតិមានក្នុងសហគមន៍</u> :

ដើម្បីជួយអោយសហគមន៍យល់អំពីសកម្មភាពប្រចាំថ្នាក់ គ្រូអាចបិទស្នាដៃរបស់សិស្សបង្ហាញជាបណ្តោះអាសន្នលើក្តារខ្សៀនជូនពតិមានរបស់សហគមន៍ ។

-ជាខ្លឹមសារជាក់ស្តែងសំរាប់បំផុសការពិភាក្សារវាងគ្រូ ស្តីអំពីសេចក្តីត្រូវការ និងសមត្ថភាពរបស់សិស្សម្នាក់ៗពេលដែលសិស្សឡើងថ្នាក់។

- ខ្លឹមសារជាក់ស្តែងសំរាប់បំផុសការពិភាក្សារវាងគ្រូបន្ទុកថ្នាក់ និង គ្រូបំប៉នសិស្សបន្ថែមស្តីពីសេចក្តីត្រូវការរបស់សិស្សម្នាក់ៗ ។

- ខ្លឹមសារជាក់ស្តែងសំរាប់អោយ គ្រូពិចារណាលើប្រសិទ្ធ-ភាពនៃការបង្រៀន ។

- ជំនួយជួយដល់ក្រុមបច្ចេកទេស ឱ្យមានការយល់ដឹងកាន់តែច្បាស់អំពីសកម្មភាពបង្រៀនប្រចាំថ្ងៃ ។

- ខ្លឹមសារជាក់ស្តែងជួយ វាយតំលៃភាពកុមារមេត្រីនៃថ្នាក់រៀន ។

- សិស្សទទួលខុសត្រូវកាន់តែច្រើនឡើង សំរាប់ការរៀនសូត្ររបស់ខ្លួន ។

- សិស្សពេញចិត្តនឹងលទ្ធផល នៃការរៀនសូត្ររបស់ខ្លួនកាន់តែច្រើនឡើង ។

- សិស្សចូលរួមក្នុងសកម្មភាពរៀនសូត្រកាន់តែច្រើន ។

- ផ្តល់ឱកាសអោយសិស្សចូលរួមស្វ័យវាយតំលៃ ។

- ជាខ្លឹមសារសំរាប់បំផុសការពិភាក្សារវាងសិស្សនិងសិស្ស អំពីខ្លឹមសារនៃមេរៀន ។

- ជាខ្លឹមសារ សំរាប់បំផុសការពិភាក្សារវាងគ្រូនិងមាតាបិតាសិស្ស ។

- ជាប្រភព ស្នាដៃសិស្សដែលអាចយកទៅបិទលើក្ដារខៀន ជូនពតិមាន ដែលស្ថិតនៅកន្លែងសាធារណៈរបស់សហ-គមន៍ ។

- ជាខ្លឹមសារ ជាក់ស្ដែងសំរាប់ការពិភាក្សារវាងសិស្ស និង មាតាបិតារបស់សិស្សម្នាក់ ៗ ។

- ជួយអោយមាតាបិតាយល់កាន់តែច្បាស់ នូវសកម្មភាព បង្រៀន និង រៀនប្រចាំថ្ងៃពេលគាត់មកទស្សនកិច្ច ។

- ជាខ្លឹមសារបំផុស លើការពិភាក្សារវាងគ្រូ និង សិស្ស ម្នាក់ ៗ ។

- ជាភស្តុតាងបង្ហាញអំពីសេចក្តីត្រូវការជាក់ស្តែងនៃសិស្សម្នាក់ៗ ដល់ថ្នាក់បំប៉នសិស្សបន្ថែម ។

- ជួយអោយគ្រូកំណត់គោលបំណង កាន់តែច្បាស់សំរាប់មេរៀនថ្មីនៅពេលខាងមុខ ។

- ជួយអោយគ្រូរៀបចំខ្លឹមសារសំរាប់មេរៀនថ្មី នៅពេលខាងមុខ ។

- ជួយបំភ្លឺ បញ្ហាសំរាប់ការវាយតំលៃដំណាក់ៗ
（ Formative ）។

- ពង្រឹងទំនាក់ទំនង រវាងការវាយតំលៃបែបបូកសរុប (Summative) និងការវាយតំលៃដំណាក់ៗ (Formative) ដោយផ្តល់ខ្លឹមសារសំរាប់ប្រៀបធៀប ពិន្ទុតេស្តជាមួយលទ្ធផលការងារប្រចាំថ្ងៃរបស់សិស្ស ។